
ត្រីវិស័យ
និពន្ធដោយ: ញឹបវ៉ាន់ សុខឈាល់
រចនារូបដោយ: បូ ចំរើន

មាតិកា

១ ត្រីវិស័យ ……………………………………………………………………..…… ៥
២ វង្វេង ……………………………………………………………………..…… ៣១
៣ វិថីទៅកាន់សេចក្ដីសង្ឃឹម ………………………………………….……………. ៥៥
៤ សេចក្ដីសង្គ្រោះ ………………………………………………………………….. ៧៨
៥ លិខិតអញ្ជើញ …………………………………………………………………… ៨៩
៦ ការសម្រេចចិត្តដ៏សំខាន់បំផុត ……………………………………………………….. ៩៣

## អារម្ភកថា

នៅក្នុងលោកសន្និវាសនេះ ការសម្រេចចិត្តគឺជាគ្រឹះដ៏សំខាន់បំផុតមួយសម្រាប់បុគ្គលគ្រប់ៗរូប។ ដោយឡែក ការសម្រេចចិត្តខ្លះគ្រាន់តែជារឿងសាមញ្ញ ធម្មតា តែប៉ុណ្ណោះ ខណះពេលដែលមានការសម្រេចចិត្តមួយចំនួនទៀត ជះឥទ្ធិពលដល់ជីវិត និងអនាគតរបស់យើងយ៉ាងធ្ងន់ធ្ងរ។ តួយ៉ាង ដូចជាការសម្រេចចិត្តទាក់ទងទៅនឹងជីវិតខាងព្រលឹងវិញ្ញាណជាដើម៕

ចាប់តាំងពីមួយជំនាន់ទៅមួយជំនាន់ទៀត មនុស្សមានទស្សនះជាច្រើនផ្សេងៗគ្នាជុំវិញជីវិតខាងព្រលឹងវិញ្ញាណ ជាពិសេសគឺជីវិតនៅស្ថានបរមលោក។ តើមនុស្សនឹងទៅណាបន្ទាប់ពីពួកគេស្លាប់? តើគួរធ្វើយ៉ាងណាដើម្បីបានទៅដល់កន្លែងមួយដែលមនុស្សគ្រប់ៗគ្នាប៉ងប្រាថ្នា បន្ទាប់ពីពួកគេបានលាចាកពីផែនដីនេះ?

គោលបំណងនៃសៀវភៅមួយក្បាលដែលបងប្អូនកំពុងតែកាន់ក្នុងដៃនេះ គឺដើម្បីបកស្រាយចម្ងល់សង្ស័យទាំងអស់ខាងលើនេះ។ ស្របពេលជាមួយគ្នានេះផងដែរ បុព្វហេតុនៃការចងក្រងសៀវភៅមួយក្បាលនេះឡើង គឺដើម្បីទុកសម្រាប់ជាចន្លុះក្នុងការបំភ្លឺ ក៏ដូចជាចង្អុលបង្ហាញផ្លូវ អោយបងប្អូនបានឃើញជាក់ច្បាស់នូវត្រើវិស័យដ៏ពិតប្រាកដតែមួយគត់ ដែលនឹងដឹកនាំបងប្អូនទៅកាន់នគរស្ថានសួគ៌ដែលជាទីប៉ងប្រាថ្នារបស់បុគ្គលគ្រប់ៗរូប៕

ជាចុងបញ្ចប់ ក្នុងនាមជាអ្នកនិពន្ធ ខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះនឹងក្លាយជាគ្រាប់ពេជ្រដ៏មានតម្លៃមហាសាលមួយគ្រាប់នៅក្នុងដៃបងប្អូន។ ជាពិសេស ខ្ញុំសូមអធិស្ឋាន សូមអោយព្រះអម្ចាស់ដែលជាម្ចាស់ស្ថានសួគ៌បើកទ្វារចិត្តបងប្អូន ដើម្បីអោយបងប្អូនបានឃើញ និងបានស្គាល់ទ្រង់ ប្រយោជន៍អោយបងប្អូនបានចូលទៅរស់នៅក្នុងនគរស្ថានសួគ៌អស់កល្បជានិច្ចជាមួយទ្រង់៕

# ត្រីវិស័យ

## ១ ត្រីវិស័យ

បុព្វបុរសខ្មែរបានបន្សល់ទុកសុភាសិតដ៏មានតម្លៃមួយថា "ចាប់ច្រវ៉ាសម្លឹងត្រើយ" ដើម្បីអប់រំកូនចៅជំនាន់ក្រោយអោយចេះរៀបចំ និងស្គាល់គោលដៅនៃជីវិតរបស់ខ្លួនអោយបានច្បាស់លាស់ ទើបអាចសម្រេចជោគជ័យ ឬឈានដល់ត្រើយដ៏ពិតប្រាកដនៃជីវិតបាន។ ការស្គាល់គោលដៅនៃជីវិត កំណត់របៀបដែលយើងត្រូវរស់នៅដើម្បីសម្រេចគោលដៅនោះ ជៀសវាងការចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា។ ក្នុងន័យដូចគ្នានេះដែរ ជីវិតដែលគ្មានគោលដៅប្រៀបបានដូចជាចកដែលអណ្តែតតែលតោលតែឯងនៅលើផ្ទៃទឹកដ៏ធំធេង យូរៗទៅនឹងត្រូវស្រពោនក្រៀមស្វិតក្រោមកំដៅព្រះសូរិយាជាអសារបង់ជាក់ជាមិនខាន។ ជីវិតត្រូវតែមានគោលដៅច្បាស់លាស់!

ដោយឡែក "ត្រីវិស័យ គឺជាប្រដាប់មួយប្រភេទ រង្វង់មុខស្រដៀងនឹងនាឡិកា មានទ្រនិចវិលចង្អុលទៅទិសខាងជើងជានិច្ច សម្រាប់អ្នកដំណើរប្រើមើលកុំអោយវង្វេងច្រលំទិស។ ត្រីវិស័យជាវត្ថុចាំបាច់សម្រាប់អ្នកធ្វើដំណើរតាមសមុទ្រ ឬតាមតំបន់ដែលខ្លួនមិនធ្លាប់ស្គាល់" [1] ។ ក្នុងគោលបំណងឆ្ពោះទៅដល់គោលដៅដោយជោគជ័យ ជៀសវាងការវង្វេងច្រលំជាអសារបង់នោះ ត្រីវិស័យគឺមានសារៈសំខាន់ និងចាំបាច់ជាទីបំផុត។ ប្រសិនបើគ្មានត្រីវិស័យ អ្នកដំណើរនឹងវង្វេងតែលតោល ចំណាយពេលវេលាឥតប្រយោជន៍ ហើយគេប្រហែលមិនអាចឈានទៅដល់គោលដៅដ៏ពិតប្រាកដបានឡើយ។ តើអ្វីជាត្រីវិស័យនៃជីវិតរបស់អ្នក? តើអ្វីដែលជួយចង្អុលបង្ហាញផ្លូវអ្នកទៅកាន់គោលដៅដ៏ពិតប្រាកដនៃជីវិតរបស់អ្នក?

ជាបឋម តើអ្វីដែលជាគោលដៅនៃជីវិតរបស់អ្នក? តើអ្វីដែលជាគោលដៅនៃជីវិតរបស់គ្រួសារអ្នក? តើអ្វីដែលជាគោលដៅនៃជីវិតកូនៗរបស់អ្នក? លើសពីនេះទៅទៀត សំនួរដែលសំខាន់បំផុតនោះគឺ តើអ្វីដែលជាគោលដៅនៃជីវិតរបស់មនុស្សជាតិផងទាំងពួង? ជាការពិតណាស់ ប្រសិនបើយើងសួរសំនួរទាំងនេះទៅកាន់មនុស្សដប់នាក់ផ្សេងៗគ្នា នោះយើងប្រហែលជានឹងទទួលបានចម្លើយ១០ផ្សេងៗគ្នាផងដែរ ព្រោះមនុស្សទាំងអស់គ្នាសុទ្ធតែបានសម្រេច និងកំណត់គោលដៅនៃជីវិតរបស់គេរៀងៗខ្លួន។ បុគ្គលខ្លះបានកំណត់គោលដៅនៃជីវិតរបស់ខ្លួន តាមគោលបំណងដែលខ្លួនស្រមើលស្រម៉ៃចង់បាន ខណៈពេលដែលបុគ្គលមួយចំនួនទៀតបានដាក់គោលដៅនៃជីវិតរបស់ខ្លួនឯងតាមលំអានរបស់បុគ្គលជោគជ័យផ្សេងៗទៀត តាមគ្រួសារ និងតាមសង្គមជាក់ស្តែង លនិងល។ ចាប់តាំងពីមួយជំនាន់ទៅមួយជំនាន់ទៀត មនុស្សជាតិខិតខំកំណត់គោលដៅនៃជីវិតតាមទម្លាប់របស់ខ្លួន ដោយពេលខ្លះមិនបានទាំងគិតទាល់តែសោះថា "តើអ្វីដែលជាគោលដៅដ៏ចម្បងពិតប្រាកដ និងសំខាន់បំផុតសម្រាប់ជីវិត"? តើជា ទ្រព្យសម្បត្តិ? កិត្តិយស? អំណាច? សុខភាព? សុភមង្គល? គ្រួសារ? ចំណេះដឹង? រូបសម្បត្តិ? ចរិយាសម្បត្តិ? លនិងល។ ទាំងនេះគឺជាអ្វីដែលលោកិយអោយតម្លៃ ហើយមនុស្សបានខិតខំបំពេញជីវិតរបស់ខ្លួនជាមួយនឹងរបស់ទាំងអស់នោះ ដោយគិតថាជីវិតរបស់គេនឹងបានពេញលេញ ជោគជ័យ មានតម្លៃ និងមានអត្ថន័យ ខណៈពេលដែលពួកគេមានអ្វីៗគ្រប់យ៉ាង។

---

[1] វចនានុក្រមខ្មែរ ភាគ១និងភាគ២

បន្តិចម្តងៗ របស់ទាំងអស់នោះបានក្លាយទៅជាគោលដៅនៃជីវិតរបស់មនុស្ស ហើយមនុស្សស៊ូទ្រាំខំធ្វើសព្វគ្រប់បែបយ៉ាងដើម្បីយោងចាប់យករបស់ទាំងអស់នោះមកបំពេញគេ ដោយភ្លេចខ្លួនឯងថា គេកំពុងតែរស់នៅក្នុងនាមជាទាសករនៃរបស់ទាំងអស់នោះ៕

ម៉េចវិញ ប្រសិនបើវត្តមានរបស់មនុស្សជាតិទាំងឡាយនៅលើផែនដី បានភ្ជាប់មកជាស្រេចនូវគោលដៅនៃជីវិតដ៏ជាក់លាក់ពិតប្រាកដតែមួយគត់ដែលព្រះជាម្ចាស់ ដែលបានបង្កើតសព្វសារពើទាំងអស់បានប្រោសប្រទានដល់ពួកគេរឹង តួនាទីតែមួយគត់របស់មនុស្ស គឺសម្រាប់សម្រេចតាមគោលដៅរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់ពួកគេ ព្រោះនោះគឺជាគោលដៅតែមួយគត់ដែលនឹងបំពេញជីវិតមនុស្សអោយបានពេញជាបរិបូរណ៍។ ការនេះគឺបានសេចក្តីថា តួនាទីរបស់មនុស្សមិនមែនដើម្បីបង្កើតគោលដៅថ្មីៗសម្រាប់ខ្លួនឯងនោះទេ ផ្ទុយទៅវិញ គឺរស់នៅដោយស្មោះត្រង់ដើម្បីបំពេញតាមគោលដៅដែលព្រះជាម្ចាស់បានកំណត់អោយ។ មនុស្សបានភ្លក់រសជាតិសេចក្តីសុខសាន្តដ៏ពិតប្រាកដ និងពេញបរិបូរណ៍ ដរាបណាពួកគេបានរស់នៅស្របតាមគោលដៅតែមួយគត់ដែលព្រះជាម្ចាស់បានកំណត់ទុកអោយ មិនមែនរស់នៅតាមគោលដៅដែលពួកគេបានបង្កើតឡើងសម្រាប់ជីវិតផ្ទាល់ខ្លួននោះឡើយ។ ក្នុងន័យដូចគ្នានេះដែរ ការតស៊ូព្យាយាមខិតខំទ្រាំទ្រសម្រេចគោលដៅរបស់មនុស្សគឺគ្មានប្រយោជន៍ទាល់តែសោះ ប្រសិនបើគោលដៅទាំងនោះមិនស្របតាមគោលដៅដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់ពួកគេតាំងពីដើមដំបូងមកម្ល៉េះ។ មកដល់ត្រឹមនេះចំណោទបញ្ហាគឺថា តើអ្វីដែលជាគោលដៅដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់មនុស្សគ្រប់ៗរូប?

នេះគឺជាសំនួរដ៏សំខាន់បំផុតមួយ ដ្បិតអីពេលខ្លះ “លោកអ្នកអាចឈានទៅដល់គ្រប់ទាំងគោលដៅផ្ទាល់ខ្លួនរបស់លោកអ្នកបាន ដែលបានប្រែក្លាយទៅជាជ័យជំនះដ៏លេចធ្លោរ ដោយសារខ្នាតរបស់លោកិយនេះមែន ប៉ុន្តែនៅតែរកមិនឃើញគោលបំណងរបស់ព្រះជាម្ចាស់ដែលបានបង្កើតលោកអ្នកមក

ដដែល

” [2] ។ មនុស្សបានសម្រេចជោគជ័យគ្រប់បែបយ៉ាងទាំងអស់ក្នុងជីវិតរបស់ខ្លួន លើកលែងតែការដ៏សំខាន់បំផុតតែមួយគត់ដែលព្រះជាម្ចាស់បានទាមទារពីពួកគេ។ ការនេះគឺឥតប្រយោជន៍ទទេ! ព្រោះពួកគេមិនបានរស់នៅតាមគោលដៅដ៏សំខាន់បំផុត ហើយពិតប្រាកដតែមួយគត់របស់ខ្លួន ពោលគឺពួកគេរស់នៅដោយមិនចំគោលដៅនៃជីវិត។ ជាលទ្ធផលមនុស្សកំពុងតែវង្វេង តែលតោល គ្មានទិសដៅច្បាស់លាស់ ក្នុងលោកិយដ៏ធំល្វឹងល្វើយ ត្បិតពួកគេមិនស្គាល់គោលដៅដ៏សំខាន់តែមួយគត់ដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់គេ។ មនុស្សកំពុងតែចំណាយជីវិតដ៏មានតម្លៃដោយឥតប្រយោជន៍។ ការនេះគួរអោយសោកស្តាយខ្លាំងណាស់!

ត្រឡប់ទៅសំណួរខាងលើវិញ តើអ្វីដែលជាគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់មនុស្ស? មនុស្សត្រូវការអ្នកបង្ហាញផ្លូវ។ មនុស្សត្រូវការត្រីវិស័យដើម្បីចង្អុលបង្ហាញផ្លូវដ៏ពិតប្រាកដ ព្រោះមនុស្សកំពុងតែវង្វេង៕

ដូចគ្នានេះដែរ សំនួរដ៏សំខាន់មួយទៀតគឺ តើនរណាអាចប្រាប់មនុស្សអំពីគោលដៅនៃជីវិតដ៏ពិតប្រាកដរបស់គេបាន? តើនរណាដែលបានរស់នៅយូរល្មម មានប្រាជ្ញាជ្រៅជ្រះល្មម មិនចេះកុហក ស្គាល់គោលដៅនៃជីវិតដ៏ពិតប្រាកដ

[2] ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោយលោក រីក វ៉ារិន ទំព័រ២១

របស់មនុស្ស លទ្ធិផល ហើយអាចបញ្ជាក់បង្ហាញប្រាប់គេអំពីអាថ៌កំបាំងដ៏ជ្រាលជ្រៅមួយនេះ? មនុស្សត្រូវការបុគ្គលអង្គនោះដើម្បីជាពន្លឺបំភ្លឺផ្លូវ ប្រយោជន៍កុំអោយពួកគេវង្វេងជាអសារបង់តទៅមុខទៀត៕

## ក ព្រះបន្ទូល

> "ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង" ។

ឧបមាថា មានប៉ូលីសស៊ើបអង្កេតមួយក្រុមកំពុងតែស្រាវជ្រាវរកមើលដើមចមនៃបញ្ហាដើម្បីឈានទៅរកដំណោះស្រាយដ៏ត្រឹមត្រូវបំផុតមួយ។ ប្រាកដណាស់ ប៉ូលីសនឹងចុះទៅដល់កន្លែងកើតហេតុ ដើម្បីសាកសួរសាក្សីដែលមានវត្តមាននៅទីនោះ ខណះពេលដែលហេតុការកំពុងតែកើតឡើង។ ប៉ូលីសនឹងមិនសួរនាំរកតម្រុយពីអ្នកដ៏ទៃដែលមិនដឹង ឬមិនបានឃើញហេតុការណ៍នោះជាក់លាក់ឡើយ ព្រោះការនេះនឹងមិនជួយដល់ការស៊ើបអង្កេតរកខុសត្រូវរបស់គាត់ទេ។ ដូចគ្នានេះដែរ ដើម្បីយល់ច្បាស់អំពីគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់មនុស្ស គប្បីគួរយើងចាប់ផ្តើមពីព្រះជាម្ចាស់ដែលបានបង្កើតសព្វសារពើទាំងអស់ រួមបញ្ចូលទាំងមនុស្សលោកផងដែរ ព្រោះតាំងពីដើមដំបូងមកម្ល៉េះ ព្រះជាម្ចាស់មិនត្រឹមតែបង្កើតមនុស្សនោះទេ លើសពីនេះទៅទៀត ព្រះអង្គបានប្រោសប្រទានអោយមនុស្សមានគោលដៅដ៏ជាក់លាក់បំផុតមួយសម្រាប់ជីវិតរបស់គេ។ ក្នុងនាមជាព្រះអាទិករ ព្រះជាម្ចាស់ជ្រាបអំពីមនុស្ស និងគោលដៅនៃជីវិតដ៏ពិតប្រាកដរបស់មនុស្សបានច្បាស់លាស់ជាងនរណាៗទាំងអស់។ ដូចគ្នានេះដែរ "មានតែក្នុងព្រះអម្ចាស់ប៉ុននោះ ដែលយើងអាចរកឃើញដើមកំណើត អត្តសញ្ញាណ អត្ថន័យ សារះសំខាន់ និងជោគវាសនារបស់យើង" [3]។ ដូច្នេះ "ប្រសិនបើលោកអ្នកចង់ដឹងថា ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់អ្នកនៅលើផែនដីនេះ លោកអ្នកត្រូវចាប់ផ្តើមជាមួយព្រះជាម្ចាស់ជាមុនសិន។ លោកអ្នកបានកើតមកដោយសារគោលបំណងរបស់ព្រះអង្គ និងសម្រាប់គោលបំណងរបស់ព្រះអង្គ"[4]៕

ដោយឡែក គ្រោះថ្នាក់ដ៏ធំបំផុតមួយរបស់មនុស្សជាតិខណះពេលដែលពួកគេកំពុងតែព្យាយាមស្វះស្វែងរកគោលដៅសម្រាប់ជីវិតរបស់ខ្លួន គឺការសម្លឹងមើលទៅលោកិយ ហើយសាកសួរលោកិយ ដោយមិនយល់សោះថាលោកិយកំពុងតែលិចលង់ ខូចបង់ សៅហ្មង បាត់បង់ និងវង្វេងចេញពីគោលដៅដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ដូចយើងទាំងអស់គ្នាដែរ។ ចំណែកឯផលដែលហុចអោយ គឺមនុស្សកាន់តែវង្វេងទៅៗ។ នេះគឺជារូបភាពដែលមនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់។ ពួកគេនឹងវង្វេងទាំងអស់គ្នា!

---

[3] ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោយលោក រីក វ៉ារិន ទំព័រ២០

[4] ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោយលោក រីក វ៉ារិន ទំព័រ១៩

តើមនុស្សអាចទទួចសួរ ជីកកកាយស្វែងរកចម្លើយដ៏អាថ៌កំបាំងមួយនេះពីព្រះជាម្ចាស់ដោយរបៀបណា បើមនុស្សមិនទាំងស្គាល់ទ្រង់ផង? នេះគឺជាគោលបំណងនៃសៀវភៅមួយក្បាលនេះ គឺដើម្បីជួយលោកអ្នកអោយរកឃើញត្រីវិស័យដ៏ពិតប្រាកដ ហើយត្រឹមត្រូវតែមួយគត់ ដែលអាចនឹងចង្អុលបង្ហាញផ្លូវអោយអ្នកទៅកាន់ព្រះជាម្ចាស់ ក៏ដូចជាជួយចង្អុលផ្លូវលោកអ្នកអោយមើលឃើញអំពីគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់លោកអ្នកផងដែរ៕

គ្មានអ្វីទាំងអស់ លើកលែងតែ.....៖ តើលោកអ្នកដឹងដែរឬទេថា កាលពីដើមដំបូងបង្អស់គឺគ្មានអ្វីទាំងអស់ លើកលែងតែព្រះជាម្ចាស់ ព្រះវិញ្ញាណ និងព្រះបន្ទូល។ គ្មានភពផែនដី គ្មានភពផ្សេងៗទាំងអស់ គ្មានធម្មជាតិ គ្មានកាល គ្មានពេលវេលា គ្មានយប់ គ្មានថ្ងៃ គ្មានព្រះអាទិត្យ គ្មានផ្កាយ គ្មានព្រះចន្ទ គ្មានទេវតា គ្មានមេឃ គ្មានដី គ្មានគ្រប់ជីវិតទាំងអស់ដែលកំរើកនៅលើផ្ទៃមេឃ លើដី និងក្នុងទឹក លនិងល ពោលគឺគ្មានអ្វីទាំងអស់ លើកលែងតែព្រះ។ ព្រះគម្ពីរបរិសុទ្ធដែលជាគោលជំនឿរបស់គ្រិស្តបរិស័ទ បានបើកសម្តែងថា “កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី។ ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជម្រៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក” (លោកុប្បត្តិ១៖១-២)។ ទាក់ទងទៅនឹងការបង្កើតនេះទៀតសោត ព្រះគម្ពីរបរិសុទ្ធក៏បានបង្ហុលបង្ហាញផងដែរថា ព្រះជាម្ចាស់មានព្រះបន្ទូល ហើយក៏កើតមានដូច្នោះមែន។ គ្រប់សព្វសារពើទាំងអស់ មានដើមដំណើតចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយឡែក បណ្តាអ្នកដឹកនាំក្រុមជំនុំគ្រិស្តបរិស័ទនៅជំនាន់ដើមក៏បានបញ្ជាក់គាំទ្រគោលជំនឿមួយនេះផងដែរថា “កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយនឹងព្រះតាំងអំពីដើមមក គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ” (យ៉ូហាន១៖១-៣)។ “ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ សុទ្ធតែកើតមកដោយសារទ្រង់ ហើយសម្រាប់ទ្រង់ទាំងអស់ផង ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរដោយសារទ្រង់” (កូឡុស១៖១៦-១៧)។ ព្រះបន្ទូលដែលមានព្រះវត្តមានគង់នៅជាមួយនឹងព្រះជាម្ចាស់ចាប់តាំងពីមុនដើមកំណើតនៃលោកិយមកម្ល៉េះ មិនត្រឹមតែជាសាក្សីនៃការបង្កើតនោះទេ លើសពីនេះទៅទៀត ព្រះបន្ទូលគឺជាព្រះដែលបានបង្កើតសព្វសារពើទាំអស់ ហើយសព្វសារពើទាំងអស់មានស្ថេរភាពដោយសារតែព្រះបន្ទូល។ បើដូច្នោះ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាប្រទីបបំភ្លឺផ្លូវអោយមនុស្សមើលឃើញអំពីគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់ពួកគេ៕

មួយវិញទៀត ព្រះគម្ពីរបរិសុទ្ធបានអះអាងយ៉ាងប្រទៀតថា “គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលអោយតែង ......” (២ធីម៉ូថេ៣៖១៦-១៧)។ គ្រប់ទាំងសេចក្តីទាំងអស់នៅក្នុងព្រះគម្ពីរបរិសុទ្ធដែលគ្រិស្តបរិស័ទកំពុងតែប្រើប្រាស់ មិនមែនជាគំនិតរបស់មនុស្សនោះទេ ផ្ទុយទៅវិញ គឺជាព្រះបន្ទូលដ៏ពិតរបស់ព្រះជាម្ចាស់។ ដោយផ្អែកលើអំនះអំណាងទាំងនេះ យើងនឹងសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងអស់គ្នា ដើម្បីជាពន្លឺបំភ្លឺផ្លូវ និងជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញអោយឃើញអំពីគោលដៅនៃជីវិតដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់មនុស្សជាតិទាំងឡាយដែលជាស្នាព្រះហស្តដ៏ល្អអស្ចារ្យរបស់ទ្រង់តែមួយអង្គគត់៕

## ខ នគរស្ថានសួគ៌

ជាបឋម មុននឹងក្រលេកទៅរកមើលគោលដៅនៃជីវិត ខ្ញុំសូមបង្វែរទិសដៅលោកអ្នកទាំងអស់គ្នាអោយឈាងទៅមើល "នគរស្ថានសួគ៌" តាមចក្ខុវិស័យរបស់ព្រះគម្ពីរបរិសុទ្ធជាមុនសិន ត្បិតនគរស្ថានសួគ៌មានទំនាក់ទំនងដោយមិនអាចកាត់ផ្តាច់បានពីការបង្កើតមនុស្ស។ លើសពីនេះទៅទៀត យើងអាចនិយាយបានថា មនុស្សត្រូវបានបង្កើតមកសម្រាប់អោយសោយសុខនៅក្នុងនគរស្ថានសួគ៌ជាមួយនឹងព្រះជាម្ចាស់ដែលជាម្ចាស់ស្ថានសួគ៌អស់កល្បជានិច្ច។ ដោយឡែក នៅក្នុងសង្គមខ្មែរ មនុស្សស្ទើតែគ្រប់ស្រទាប់វណ្ណៈ គ្រប់សម័យកាល និងគ្រប់វ័យទាំងអស់ យល់អំពីអត្ថន័យរបស់ពាក្យ "ស្ថានសួគ៌"។ បើទោះបីជាការយល់ដឹងរបស់ជនជាតិខ្មែរ និងជនជាតិដ៏ទៃផ្សេងៗទៀតអំពីស្ថានសួគ៌នៅមានកំរិតនៅឡើយយ៉ាងណាក្តី ក៏ស្ថានសួគ៌គឺជាទីប៉ងប្រាថ្នារបស់បុគ្គលគ្រប់ៗរូប ដែលផ្ទុយស្រលះពីស្ថាននរកដែលគ្មាននរណាម្នាក់ចង់នឹកនាទៅដល់សោះឡើយ។ វាសំខាន់ដល់ម្ល៉េះ បានជានគរស្ថានសួគ៌គឺជាប្រធានបទដ៏ធំចម្បងបំផុតមួយនៅក្នុងសេចក្តីបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត ក៏ដូចជានៅក្នុងព្រះគម្ពីរបរិសុទ្ធទាំងមូលផងដែរ។ ស្តេចដាវីឌ គឺជាស្តេចដ៏ជោគជ័យបំផុតមួយអង្គនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ក្នុងអំឡុងពេលប្រហែលជាជាង១ ០០០ឆ្នាំមុនគ.ស។ ខណះពេលដែលក្សត្រអង្គនេះ មានព្រះជន្មនៅលើផែនដី ព្រះអង្គសឹងតែមានគ្រប់អ្វីៗទាំងអស់ដែលជាទីប៉ងប្រាថ្នារបស់មនុស្សលោក។ បើទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសំណេរមួយរបស់ស្តេចដាវីឌ ព្រះអង្គបានលើកឡើងថា "១ថ្ងៃនៅក្នុងព្រះលាននៃទ្រង់ (ព្រះជាម្ចាស់) នោះវិសេសជាង១ពាន់ថ្ងៃណាទៀត ទូលបង្គំសូមធ្វើជាអ្នកឆ្មាំទ្វារនៅក្នុងដំណាក់របស់ព្រះនៃទូលបង្គំប្រសើរជាងនៅក្នុងលំនៅនៃសេចក្តីអាក្រក់"(ទំនុកតម្កើង៨៤៖១០)។ អត្ថន័យនៃសំណេររបស់ស្តេចដាវីឌ គឺនគរស្ថានសួគ៌ដែលជាព្រះរាជដំណាក់របស់ព្រះជាម្ចាស់ ល្អបណ្តាច់លើសអ្វីៗទាំងអស់។ ពាក្យពេជន៍មិនអាចពិពណ៌នាអំពីនគរស្ថានសួគ៌បានឡើយ រីឯគំនិត និងការស្រមើលស្រម៉ៃក៏មិនអាចនឹកដល់នគរស្ថានសួគ៌បានដែរ ដ្បិតអីនគរស្ថានសួគ៌ល្អវិសេសដល់ម្ល៉េះ ទើបបានជាសូម្បីតែស្តេចដ៏ជោគជ័យដូចជាស្តេចដាវីឌជាដើម ស៊ូសូមធ្វើជាអ្នកឆ្មាំទ្វារក៏បានដែរ អោយតែបាននៅក្នុងព្រះដំណាក់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ នគរស្ថានសួគ៌ គួរតែជាទីប៉ងប្រាថ្នារបស់មនុស្សគ្រប់ៗរូបមែន៕

## ៦១ ការសម្រាកដ៏ពេញបរិបូរណ៍

> “រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ហើយ ក៏គ្មានសមុទ្រទៀតឡើយ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ តាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្តី ខ្ញុំមានលឺសម្លេងមួយយ៉ាងខ្លាំង ចេញពីស្ថានសួគ៌មកថា មើលរោងឧបោសថរបស់ព្រះបាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ត្បិតសេចក្តីមុនទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ” (វិវរណៈ២១៖១-៤)។

ថ្វីត្បិតតែគ្មាននរណាម្នាក់អាចស្រម៉ៃដល់អំពីភាពអស្ចារ្យរបស់នគរស្ថានសួគ៌ក៏ពិតមែន ក៏ប៉ុន្តែផ្ទាំងទស្សនីយភាពខាងលើ គឺជារូបភាពដ៏ប្រពៃឧត្តមបំផុតមួយផ្នែករបស់នគរស្ថានសួគ៍ដែលព្រះជាម្ចាស់សព្វព្រះរាជ្យហឫទ័យបើកសម្តែងអោយលោកយ៉ូហានបានឃើញ។ តាមរយៈនិមិត្តរបស់លោកយ៉ូហានខាងលើ យើងក៏បានយល់ដល់ជ្រុងមួយនៃនគរស្ថានសួគ៌ផងដែរ។ រូបភាពខាងលើ គឺជាព្រឹត្តិការណ៍នាពេលអនាគត ហើយបើផ្អែកលើព្រះគម្ពីរបរិសុទ្ធ យើងជឿជាក់ថារូបភាពនេះនឹងបានសម្រេចឡើងជាក់ជាប្រាកដមែន។ កង់ប្រវត្តិសាស្ត្ររបស់មនុស្សជាតិកំពុងតែវិលរំកិលខិតជិតទៅរកព្រឹត្តិការណ៍ដ៏ជាឧឡារិកមួយនេះ ដ្បិតវាគឺជាគម្រោងផែនការណ៍ដែលព្រះជាម្ចាស់បានរៀបចំទុកតាំងពីដើមដំបូងមកម៉្លេះ ខណៈពេលដែលទ្រង់បានចាក់គ្រឹះបង្កើតផ្ទៃមេឃ និងផែនដី។ ព្រះជាម្ចាស់ស្មោះត្រង់ចំពោះការងាររបស់ទ្រង់ ព្រះអង្គនឹងបញ្ចប់ការងារដែលទ្រង់បានចាប់ផ្តើម ដូច្នោះគម្រោងផែនការណ៍ និងនិមិត្តរបស់ព្រះជាម្ចាស់អំពីនគរស្ថានសួគ៌នឹងបានសម្រេចជាក់ជាមិនខាននាពេលអនាគត៕

ដោយយល់ដល់និមិត្តរបស់លោកយ៉ូហានខាងលើ បណ្តាជនដែលកំពុងតែវង្វេងទិសដៅ តែលតោល គ្មានកោះត្រើយក្នុងសមុទ្រលោកិយដ៏ធំល្វឹងល្វើយ ប្រៀបបានដូចជាហ្វូងចៀមដែលកំពុងតែវង្វេងបាត់ម្ចាស់ ឬកូនចកកណ្តាលទន្លេដ៏ធំល្វឹងល្វើយ សមណាស់តែទទួលបានការលួងលោមកំសាន្តចិត្ត ដ្បិតអីនឹងមានពេលមួយមកដល់ នៅនគរស្ថានសួគ៍ គេនឹងមិនវង្វេង កំព្រា រងារ ហើយឯកាតែឯកឯងទៀតទេ។ មនុស្សនឹងបាននៅជួបជុំជាមួយនឹងព្រះជាម្ចាស់នៅក្នុងទីកន្លែងរបស់ព្រះអង្គផ្ទាល់ ហាក់បីដូចជាហ្វូងចៀមដែលនៅក្នុងការមើលថែទាំពីអ្នកគង្វាលដ៏ស្មោះត្រង់របស់ពួកគេយ៉ាងដូច្នោះដែរ។ នៅក្នុងនគរស្ថានសួគ៌ ព្រះជាម្ចាស់នឹងជូតទឹកភ្នែកពួកគេចេញដោយផ្ទាល់ព្រះហស្តទាំងទ្វេររបស់ទ្រង់ផ្ទាល់ ហើយនេះគឺជារូបភាពនៃការកំសាន្តចិត្ត ការមើលថែបំប៉ន សេចក្តីស្រលាញ់ថ្នាក់ថ្នម ការយកចិត្តទុកដាក់លនិងល រីឯសេចក្តីស្លាប់ សេចក្តីសោកសង្រេង សេចក្តីយំទួញ ទុក្ខលំបាក នឹងលែងមានវត្តមាននៅក្នុងចំណោមពួកគេទៀតហើយ ព្រោះពួកគេកំពុងតែស្ថិតនៅក្នុងព្រះវត្តមានដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។ នេះគឺជាគោលដៅដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់មនុស្សរបស់ទ្រង់ គឺអោយពួកគេបានសំរាកក្នុងសេចក្តីសុខសាន្តដ៏ពិតប្រាកដ ក្នុង

ទីកន្លែងរបស់ទ្រង់ ជាមួយនឹងទ្រង់ផ្ទាល់ដែលជាព្រះតែមួយអង្គគត់របស់ពួកគេ។ មនុស្សត្រូវបានបង្កើតមកដើម្បីអោយគេបានសម្រាកដោយសុខសាន្តក្នុងព្រះវត្តមានរបស់ព្រះដ៏ធំឧត្តុងឧត្តម។ លោកហ្វន រ៉ូបឺតបានលើកឡើងថា "ផ្នែកមួយនៃគោលបំណងរបស់ថ្ងៃឈប់សំរាកដែលអ៊ីស្រាអែលត្រូវកាន់តាម (និក្ខមនំ២០៖៨-១១) គឺដើម្បីរំលឹកអោយគេដឹងថា នោះឯងជាជីវិតដែលព្រះបានមានបំណងប្រទានអោយមនុស្ស ជាជាងការដែលគ្រាន់តែខ្វល់ខ្វាយចំពោះពិភពលោកបច្ចុប្បន្ននេះ
"[5] ៕

ដូចគ្នានេះដែរ បើផ្អែកលើភស្តុតាងនៃការបង្កើតក្នុងពីរជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិ ព្រះជាម្ចាស់បានចំណាយពេល៦ថ្ងៃដោយយកចិត្តទុកដាក់ជាទីបំផុតដើម្បីបង្កើតសព្វសារពើទាំងអស់ ដោយរាប់បញ្ចូលទាំងមនុស្សជាតិផងដែរ។ ដោយឡែក នៅថ្ងៃទី៧ ព្រះគម្ពីរបរិសុទ្ធបានគូសវាសបញ្ជាក់យ៉ាងច្បាស់ថា "ដូច្នេះផ្ទៃមេឃ និងផែនដីក៏បានរួចជាស្រេច ព្រមទាំងរបស់សព្វសារពើផង លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើនោះបានហើយជាស្រេច ទ្រង់ក៏បានឈប់ផ្អាកសម្រាកនៅថ្ងៃទី៧នោះពីគ្រប់ទាំងការដែលទ្រង់ធ្វើ ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សម្រាកពីគ្រប់ទាំងការដែលទ្រង់បានបង្កើតបានធ្វើ" (លោកុប្បត្តិ២៖១-៣)។ ចំនុចកំពូលនៃការបង្កើតប្រាំមួយថ្ងៃដំបូង គឺសម្រាប់ការសម្រាកនៅថ្ងៃទីប្រាំពីរ។ ដូចគ្នាទៅនឹងគំនិតរបស់លោកហ្វន រ៉ូបឺតខាងលើដែរ ខ្ញុំគិតថា គោលដៅនៃជីវិតដែលព្រះជាម្ចាស់បានបង្កើតមកគឺដើម្បីអោយមនុស្សបានសម្រាកដោយសុខសាន្ត ស្កប់ស្កល់ អស់កល្បជានិច្ចជាមួយនឹងព្រះអង្គក្នុងព្រះវត្តមានផ្ទាល់របស់ទ្រង់។ ក្រៅពីនៅក្នុងទីកន្លែងរបស់ព្រះជាម្ចាស់ និងក្នុង/ជាមួយព្រះជាម្ចាស់ មនុស្សមិនអាចស្គាល់រស់ជាតិនៃការសម្រាកដោយសុខសាន្តដ៏ពិតប្រាកដបានឡើយ។

គួរកត់សំគាល់ផងដែរថា ការឈប់សម្រាកដ៏ពិតប្រាកដគឺចាប់ផ្តើមចេញពីព្រះជាម្ចាស់។ បើផ្អែកលើបទគម្ពីរខាងលើ "...... លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើនោះបានហើយជាស្រេច ទ្រង់ក៏បានឈប់ផ្អាកសម្រាកនៅថ្ងៃទី៧នោះពីគ្រប់ទាំងការដែលទ្រង់ធ្វើ ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សម្រាកពីគ្រប់ទាំងការដែលទ្រង់បានបង្កើតបានធ្វើ"។ ព្រះជាម្ចាស់សម្រាក! ហើយព្រះអង្គផ្ទាល់បានញែកទុកថ្ងៃសម្រាកដ៏បរិសុទ្ធនោះ ព្រមទាំងប្រទានព្រះពរដល់ថ្ងៃនោះផងដែរ។ បន្ទាប់មក ព្រះជាម្ចាស់បានអញ្ជើញមនុស្សដែលទ្រង់ទើបនឹងបង្កើតអោយចូលរួមសម្រាកជាមួយទ្រង់ នៅក្នុងទីកន្លែងរបស់ទ្រង់ផ្ទាល់។ គោលដៅចុងក្រោយនៃការបង្កើតមនុស្ស គឺការសម្រាកក្នុងទ្រង់៕

នៅថ្ងៃសម្រាកដ៏បរិសុទ្ធនោះ ទាំងព្រះជាម្ចាស់ និងស្នាព្រះហស្តរបស់ទ្រង់សព្វព្រះហឫទ័យ និងពេញចិត្តយ៉ាងខ្លាំងពន់ពេក ព្រោះនេះគឺជាគោលដៅនៃការបង្កើត ហើយមនុស្សបានរស់នៅចំគោលដៅនៃជីវិតរបស់ពួកគេ។ ស្របពេលជាមួយគ្នានេះផងដែរ នៅថ្ងៃសម្រាកសិរីល្អរបស់ព្រះជាម្ចាស់ត្រូវបានលើកសរសើរតម្កើងពីសំណាក់គ្រប់ជីវិតទាំងអស់ ជាពិសេសមនុស្សជាតិ ដែលការនេះប្រៀបបានដូចជាដង្វាយដ៏ឈ្ងុយឈ្ងប់នៅលើអាសនារបស់ទ្រង់ រីឯមនុស្ស

[5] វិសាលភាពនៃព្រះជាម្ចាស់ និពន្ធដោយលោក ហ្វន រ៉ូបឺត ទំព័រ៣៧

វិញកំពុងតែរស់នៅក្នុងព្រះពរ សេចក្ដីសុខសាន្ត ភាពស្កប់ស្កល់ អំណរ ការសម្រាកដ៏ពិតប្រាកដតាមរយៈការរស់នៅដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់៕

## ១២ ចម្រៀងនៃការសរសើរតម្កើង

លោកសាវ័កយ៉ូហានដដែល ក៏បានមានប្រសាសន៍ដោយផ្ទាល់បន្ថែមទៀតផងដែរទាក់ទាក់ទងទៅទិដ្ឋភាពនៃនគរស្ថានសួគ៌ថា "ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្គ និងកូនចៀម ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃ គេបន្លឺសម្លេងថា សេចក្ដីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នាដែលគង់លើបល្ល័ង្គ ហើយស្រេចនឹងកូនចៀមផង រួចអស់ទាំងទេវតាដែលឈរនៅជុំវិញបល្ល័ង្គ ព្រមទាំងពួកចាស់ទុំ និងតួមានជីវិតទាំង៤ ក៏ទំលាក់ខ្លួនក្រាបចុះនៅចំពោះបល្ល័ង្គ ថ្វាយបង្គំដល់ព្រះ ទាំងទូលថា អាម៉ែន សូមថ្វាយព្រះពរ សិរីល្អ ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម ព្រះចេស្តា និងឥទ្ធិឫទ្ធិ ដល់ព្រះនៃយើងរាល់គ្នា នៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន" (វិវរណៈ៧:៩-១២)។ ដោយឡែក អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងក៏បានសរសេរបំផុសឡើងស្រដៀងគ្នាផងដែរថា "ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះនៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់នៅចន្លោះអាកាស ជាទីសម្តែងព្រះចេស្តាទ្រង់ ចូរសរសើរដល់ទ្រង់ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់អោយសមនឹងសណ្ឋានដ៏ធំប្រសើររបស់ទ្រង់ ចូរសរសើរទ្រង់ដោយសូរត្រែ ចូរសរសើរទ្រង់ដោយដេញពិណ និងចាប៉ី ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនិងខ្លុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងអោយលឺរងំ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងលឺសូររំពង គួរអោយជីវិតទាំងឡាយដែលមានដង្ហើមបានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ" (ទំនុកតម្កើង១៥០)។ និមិត្តរបស់លោកសាវ័កយ៉ូហានអំពីតថភាពនាពេលអនាគត ក៏ដូចជារូបភាពដែលបានដិតដាប់លើឃ្លោងឃ្លានៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ បានឆ្លុះបញ្ចាំងអំពីប្រធានបទដ៏សំខាន់បំផុតមួយគឺ "ចម្រៀងនៃការសរសើរតម្កើង" ព្រោះការសរសើរតម្កើងព្រះជាម្ចាស់គឺជាយុទ្ធកានៃជីវិត។ ជីវិតមានន័យ ជោគជ័យ រស់ចំគោលដៅ ដរាបណាបានដើរតាមការចង្អុលបង្ហាញរបស់ត្រីវិស័យដ៏ពិតប្រាកដមួយនេះ គឺរស់នៅដើម្បីថ្វាយបង្គំព្រះដ៏ពិតតែមួយអង្គគត់។ វត្តមានរបស់មនុស្សដើម្បីអោយព្រះកិត្តិនាម និងសិរីល្អរបស់ព្រះជាម្ចាស់ត្រូវបានថ្វាយបង្គំ ហើយសរសើរតម្កើងនៅគ្រប់ផ្នែកទាំងអស់នៃផែនដី តាមរយៈជីវិតរបស់ពួកគេ។ តើមានប្រយោជន៍អ្វី ប្រសិនបើមនុស្សបានលោកិយទាំងមូលជាមរតក តែវង្វេងចេញពីត្រីវិស័ដ៏ពិតប្រាកដនៃជីវិត ដោយស៊ូទ្រាំខំរស់នៅដើម្បីអ្វីៗសព្វសារពើទាំងអស់ តែមិនមែនដើម្បីព្រះជាម្ចាស់ ដែលជាគោលដៅដ៏សំខាន់តែមួយគត់សម្រាប់ជីវិតរបស់ពួកគេ៕

> គ្រប់សព្វសារពើទាំងអស់សុទ្ធតែកើតមកដោយសារទ្រង់ ហើយសម្រាប់ទ្រង់ទាំងអស់។

តាមរយៈការសង្ខេបយ៉ាងខ្លីខាងលើ តើអ្វីជាគោលដៅនៃជីវិតរបស់មនុស្ស? ព្រះកិត្តិនាមរបស់ព្រះជាម្ចាស់ និងសិរីល្អរបស់ទ្រង់ គឺជាគោលដៅនៃការរស់នៅរបស់មនុស្ស។ មនុស្សត្រូវបានបង្កើតមកដើម្បីទ្រង់ ហើយតាមរយៈការនេះតែមួយគត់ ដែលមនុស្សស្គាល់រស់ជាតិនៃសេចក្ដីសុខសាន្តដ៏ពិតប្រាកដ ព្រោះនេះគឺជាគោលដៅនៃជីវិត។ មនុស្សគ្មានសិទ្ធរស់ដើម្បីកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួនសោះឡើយ ព្រោះគ្រប់ទាំងអស់គឺជាកម្មសិទ្ធរបស់ព្រះជាម្ចាស់តែមួយអង្គគត់ ហើយព្រះអង្គតែមួយអង្គគត់ដែលសមនឹងទទួលយកគ្រប់ទាំងឧត្ដមភាព គ្រប់រូបភាពទាំងអស់។ ការនេះគឺបានសេចក្ដីថា ប្រសិនបើជោគជ័យរបស់មនុស្សមិនមែនជាការសរសើរតម្កើងដល់សិរីល្អរបស់ព្រះជាម្ចាស់ នោះគេកំពុងតែដើរបញ្ច្រាស់គោលដៅដ៏ពិតប្រាកដនៃជីវិតហើយ៕

ព្រះជាម្ចាស់តែមួយអង្គគត់ដែលជាម្ចាស់នៃសព្វសារពើទាំងអស់ ហើយជាម្ចាស់នៃការសរសើរតម្កើងពីសំណាក់មនុស្សគ្រប់ជាតិទាំងឡាយ! ព្រះជាម្ចាស់តែមួយអង្គគត់ដែលសមនឹងទទួលយកការសរសើរតម្កើងពីគ្រប់ទាំងស្នាព្រះហស្ដទាំងអស់របស់ទ្រង់។ ចូរអោយមនុស្សជាតិទាំងឡាយ បានក្រាបថ្វាយបង្គំ និងសរសើរតម្កើង ព្រះកិត្តិនាមដ៏ខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់អោយសំណុំនឹងសណ្ឋានដ៏ខ្ពង់ខ្ពស់ឧត្ដុងឧត្ដមរបស់ទ្រង់៕

## គ ម្ចាស់ស្ថានសួគ៌

មកដល់ត្រឹមនេះ យើងបានមើលឃើញ និងយល់ខ្លះៗអំពីទិដ្ឋភាពនៃនគរស្ថានសួគ៌ ដែលជាទីប៉ងប្រាថ្នារបស់បុគ្គលគ្រប់ៗរូប។  លើសពីនេះទៅទៀត ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏បានចង្អុលបង្ហាញផងដែរ អំពីត្រីវិស័យនៃជីវិតរបស់មនុស្ស ឬគោលដៅនៃជីវិត។ មួយវិញទៀត ព្រះជាម្ចាស់គឺជាម្ចាស់ស្ថានសួគ៌ ហើយនិមិត្តរបស់ព្រះអង្គក្នុងការបង្កើត គឺដើម្បីអោយមនុស្សបានចូលទៅសម្រាកសោយសុខក្នុងនគរដ៏ឧត្ដុងឧត្ដមរបស់ទ្រង់ ជាមួយទ្រង់។ ដោយឡែក មានពំនោលមួយបានលើកឡើងថា “ផឹកទឹកអោយនឹកប្រភព ជ្រកម្លប់អោយនឹកអ្នកដាំ” ក្នុងគោលបំណងជួយរំលឹកដាស់តឿនអោយមានការនឹករលឹក និងដឹងគុណដល់បុគ្គលដែលជាម្ចាស់។ ម្យ៉ាងទៀត ការស្គាល់ម្ចាស់ និងមានទំនាក់ទំនងល្អជាមួយនឹងម្ចាស់គឺជាស្ពាននាំឈានទៅរកផលប្រយោជន៍ទាំងអស់នោះ។ ដូចគ្នានេះដែរ បើមនុស្សចង់ចូលទៅក្នុងនគរដ៏វិសេសវិសាលរបស់ព្រះជាម្ចាស់ គប្បីគេគួរបានស្គាល់ និងមានទំនាក់ទំនងជាមួយទ្រង់ជាមុនសិន? តើព្រះជាម្ចាស់ដែលជាម្ចាស់ស្ថានសួគ៌ដ៏ឧត្ដុងឧត្ដម ជាម្ចាស់នៃឧត្ដមភាពគ្រប់ទាំងអស់ មានលក្ខណៈសម្បត្តិបែបណាដែរ? សំនួរដែលសំខាន់មួយទៀតនោះគឺ តើមនុស្សត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីទទួលបានអភ័យឯកសិទ្ធចូលទៅសម្រាកក្នុងនគរស្ថានសួគ៌? គោលបំណងនៃសៀវភៅមួយក្បាលនេះ គឺដើម្បីជាត្រីវិស័យចង្អុលបង្ហាញផ្លូវលោកអ្នកអោយរកឃើញផ្លូវចូលទៅក្នុងនគរស្ថានសួគ៌របស់ព្រះជាម្ចាស់៕

### គ១ ព្រះដ៏ជាព្រះ

ព្រះគម្ពីរបរិសុទ្ធបានអះអាងយ៉ាងច្បាស់ថា សព្វសារពើទាំងអស់គឺជាស្នាព្រះហស្ដរបស់ព្រះជាម្ចាស់ (ទំនុកតម្កើង២៤៖១-២)។ ព្រះជាម្ចាស់បានបង្កើតគ្រប់ទាំងអស់ គ្រប់គ្រងលើគ្រប់ទាំងអស់ ជាម្ចាស់លើគ្រប់ទាំងអស់ ហើយគ្រប់ទាំងអស់គឺសម្រាប់ព្រះជាម្ចាស់តែមួយអង្គគត់។ ព្រះជាម្ចាស់ដែលបានពិពណ៍នានៅក្នុងព្រះគម្ពីរបរិសុទ្ធដូចខាងលើ គឺជា

ព្រះតែមួយអង្គគត់ដែលពួកគ្រិស្តបរិស័ទកំពុងតែថ្វាយបង្គំ ទ្រង់ធំឧត្តម ទ្រង់ជាព្រះលើសអស់ទាំងព្រះ ទ្រង់ជាព្រះមហាក្សត្រលើសអស់ទាំងមហាក្សត្រ ព្រះអង្គគ្រប់គ្រងលើគ្រប់ជាតិសាសន៍ទាំងអស់ដែលមានវត្តមាននៅលើផែនដីរបស់ទ្រង់ ហើយព្រះអង្គគឺជាព្រះតែមួយអង្គគត់របស់គ្រប់ជាតិសាសន៍ទាំងអស់ដែលទ្រង់បានបង្កើតមក។ ព្រះបន្ទូលរបស់ទ្រង់បានធ្វើជាទីបន្ទាល់ដោយផ្ទាល់ថា "... ភាពដ៏ធំ និងព្រះចេស្តា សិរីល្អ ជ័យជំនះ និងតេជានុភាពនោះសុទ្ធតែជារបស់ផងទ្រង់ ត្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ និងនៅផែនដីជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យនេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានតម្កើងឡើងជាប្រធានលើទាំងអស់" (១របាក្សត្រ២៩៖១១)។ "ត្បិតព្រះយេហូវ៉ាទ្រង់ខ្ពស់បំផុត ទ្រង់គួរស្ញែងខ្លាច ទ្រង់ជាមហាក្សត្រយ៉ាងធំលើផែនដីទាំងមូល" (ទំនុកតម្កើង៤៧៖២)។ "ព្រះយេហូវ៉ាទ្រង់បានតាំងបល្ល័ង្កទ្រង់នៅលើស្ថានសួគ៌ ហើយរាជ្យទ្រង់ក៏គ្រប់គ្រងលើទាំងអស់" (ទំនុកតម្កើង១០៣៖១៩)។ ព្រះអង្គពេញដោយអំណាចព្រះចេស្តាលើសទាំងអស់ "........ ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្តាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា ទ្រង់ធ្វើអ្វីដូច្នោះបានឡើយ" (ដានីញ៉ែល៤៖៣៥)។ លនិងល។ ខ្ញុំជឿថា គ្មានពាក្យពេចន៍ណាដែលអាចរៀបរាប់អោយចំអស់អំពីជម្រៅ និងទំហំនៃឧត្តមភាពដ៏ធំឧត្តុងឧត្តមរបស់ព្រះដែលគ្រិស្តបរិស័ទកំពុងតែថ្វាយបង្គំបានឡើយ ព្រោះគឺព្រះអង្គហើយដែលធំឧត្តម ល្អហួសពីការពណ៌នា។ ព្រះជាម្ចាស់តែមួយអង្គគត់ដែលល្អបំផុត ដូចដែលលោកនេហេមាបានលើកឡើងថា គឺទ្រង់តែមួយដែលជាព្រះឯកអង្គ (នេហេមា៩៖៦)។ ព្រះជាម្ចាស់បានបញ្ជាក់ម្តងហើយម្តងទៀតដល់ស្នាព្រះហស្តទាំងឡាយរបស់ទ្រង់ថា "អញនេះជាយេហូវ៉ា គ្មានព្រះណាដទៃឡើយ ក្រៅពីអញឥតមានព្រះឯណាទៀតសោះ......." (អេសាយ៤៥៖៥)។ ព្រះជាម្ចាស់ដ៏ជាព្រះលើសអស់ទាំងព្រះ មិនមែនជាព្រះមួយអង្គនៅក្នុងចំណោមព្រះដ៏ទៃផ្សេងៗទៀតជាច្រើននោះទេ ផ្ទុយទៅវិញ ព្រះគម្ពីរបរិសុទ្ធបានគូសវាសបញ្ជាក់យ៉ាងច្បាស់ថា ព្រះដ៏ពិតគឺមានតែមួយអង្គគត់ គឺទ្រង់នេះហើយ។ ព្រះជាម្ចាស់គឺជាព្រះដ៏ពិតតែមួយអង្គគត់ ជាព្រះអាទិករដែលពោរពេញទៅដោយអំណាច ព្រះចេស្តា និងសិរីល្អ ហើយព្រះអង្គផ្ទាល់តែមួយអង្គគត់ដែលជាម្ចាស់ស្ថានសួគ៌៕

### គ២ ម្ចាស់នៃសិរីល្អ

ក្នុងនាមជាម្ចាស់នៃសព្វសារពើទាំងអស់ ព្រះជាម្ចាស់តែមួយអង្គគត់ដែលសមនឹងទទួលបានការលើកសរសើរតម្កើងពីគ្រប់របស់សព្វសារពើទាំងអស់។ ព្រះជាម្ចាស់បានមានព្រះបន្ទូលដោយផ្ទាល់ទាក់ទងទៅនឹងសិរីល្អដែលជាកម្មសិទ្ធតែមួយគត់របស់ទ្រង់ថា "អញជាយេហូវ៉ា នេះហើយជាឈ្មោះរបស់អញ អញមិនព្រមប្រគល់សិរីល្អរបស់អញដល់អ្នកណាទៀតឡើយ ឬអោយសេចក្តីសរសើររបស់អញដល់រូបឆ្លាក់ឡើយ"(អេសាយ៤២៖៨)។ ព្រះជាម្ចាស់មិនអនុញ្ញាត ហើយក៏មិនសព្វព្រះហឫទ័យអោយមនុស្សដែលជាស្នាព្រះហស្ត និងជាកម្មសិទ្ធរបស់ទ្រង់ រស់នៅដើម្បីជាសិរីល្អដល់អ្វីៗផ្សេងៗទៀតឡើយ ក្រៅពីសម្រាប់

> "ឱព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា ត្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង"។

តែជាសិរីល្អរបស់ទ្រង់តែមួយអង្គគត់។ គ្រប់ទាំងដង្ហើមចេញចូលដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ គឺដើម្បីជាការសរសើរតម្កើងដល់សិរីល្អតែមួយគត់របស់ទ្រង់។ ជីវិតរបស់មនុស្ស គឺសម្រាប់ជាសិរីល្អដល់ព្រះដែលបានបង្កើតគេមក។ ការនេះគឺបានសេចក្ដីថា ការរស់នៅដោយមិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់ គឺជាការរស់នៅដែលខុសគោលដៅជីវិត ហើយជាការប៉ះបោរប្រឆាំងជាមួយនឹងនិមិត្តរបស់ព្រះដ៏លើសអស់ទាំងព្រះ។ បើដូច្នោះ វរហើយ! អស់អ្នកដែលបដិសេធន៍មិនព្រមថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ដែលជាម្ចាស់នៃសិរីល្អ។ វរហើយ! អស់អ្នកដែលលួចយកសិរីល្អដែលជាកម្មសិទ្ធរបស់ព្រះដ៏ធំឧត្តម។ វរហើយ! អស់អ្នកដែលរស់នៅដើម្បីខ្លួនឯង មិនមែនដើម្បីព្រះជាម្ចាស់៕

### គ៣ ព្រះដ៏សព្វញ្ញូញាណ

អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងបានលើកឡើងថា “ត្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំក្នុងផ្ទៃម្តាយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ត្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ កាលទូលបង្គំកើតមាននៅទីកំបាំង ហើយបានសូន្យធ្វើបែបចំឡែកៗនៅទីទាបនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំក្នុងកាលដែលមិនទាន់មានរូបរាយនៅឡើយ ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់ គឺអស់ទាំងថ្ងៃអាយុដែលបានតម្រូវអោយទូលបង្គំរស់នៅក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយនោះនៅឡើយ” (ទំនុកតម្កើង១៣៩៖១៣-១៦)។ តាមរយៈបទគម្ពីរនេះ អ្នកនិពន្ធមិនត្រឹមតែទទួលស្គាល់ព្រះជាម្ចាស់ថាជាអ្នកសូនបង្កើតមនុស្សនោះឡើយ លើសពីនេះទៅទៀត គឺគាត់បានកោតសរសើរស្ញប់ស្ញែងយ៉ាងអស្ចារ្យចំពោះស្នាព្រះហស្តដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ក្នុងការសូនបង្កើតមនុស្សដោយយកព្រះទ័យទុកដាក់ជាទីបំផុត។ បើគ្មានព្រះជាម្ចាស់ នោះក៏គ្មានវត្តមានរបស់មនុស្សដែរ។ ជីវិត និងគោលដៅនៃជីវិតរបស់មនុស្សចាប់ផ្តើមចេញពីព្រះជាម្ចាស់ដែលជាអ្នកសូនបង្កើតគេដោយផ្ទាល់៕

មួយវិញទៀត ព្រះជាម្ចាស់មិនត្រឹមតែបង្កើតមនុស្សនោះទេ ព្រះអង្គថែមទាំងស្គាល់មនុស្សម្នាក់ៗយ៉ាងច្បាស់លាស់ និងជាក់លាក់ជាទីបំផុត។ គ្មាននរណាម្នាក់អាចស្គាល់អ្នកបានគ្រប់ជ្រុងជ្រោយដូចជាព្រះជាម្ចាស់នោះទេ សូម្បីតែអ្នកខ្លួនឯងផ្ទាល់។ គ្មានអាថ៌កំបាំងណាមួយដែលលាក់កប់នៅក្នុងជម្រៅចិត្តរបស់មនុស្ស ដែលអាចលាក់ពីព្រះជាម្ចាស់បានឡើយ។ ព្រះជាម្ចាស់ជ្រាបសព្វទាំងអស់។ ព្រះជាម្ចាស់បានបង្កើតមនុស្ស ហើយព្រះអង្គបានកំណត់រយៈពេលនៃជីវិតរបស់ពួកគេនៅលើផែនដីរួចជាស្រេច ដោយគ្មាននរណាអាចប្រកែកកែប្រែឡើយសោះឡើយ។ លោកលូកាបានបញ្ជាក់បន្ថែមលើហ្នឹងទៀតថា សូម្បីតែសក់ក្បាលរបស់អ្នកក៏ព្រះអង្គជ្រាបគ្រប់ចំនួនដែរ (លូកា១២៖៧)។ “ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះ និងការដែលទូលបង្គំក្រោកឡើងផង ទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយដែរ ទ្រង់ពិនិត្យពិចារណាផ្លូវច្រក និងទីដេករបស់ទូលបង្គំ ក៏ស្គាល់អស់ទាំងផ្លូវប្រព្រឹត្តិរបស់ទូលបង្គំដែរ ដ្បិតឱព្រះយេហូវ៉ាអើយ ពាក្យសំដីមិនទាន់មាននៅអណ្តាតទូលបង្គំនៅឡើយ នោះទ្រង់ក៏ជ្រាបគ្រប់ជំពូកហើយ...... ដូច្នោះទាំងសេចក្តីងងឹតនោះឯងមិនលាក់ពីទ្រង់ឡើយ ទោះទាំងយប់ក៏ភ្លឺដូចជាពេលថ្ងៃដែរ ឯសេចក្តីងងឹត និងពន្លឺភ្លឺនោះស្មើគ្នានៅចំពោះទ្រង់” (ទំនុកតម្កើង១៣៩៖២-៤; ១២)។ គ្មានព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងចំពោះមនុស្ស បើទោះបីជានៅអតីតកាល

បច្ចុប្បន្នកាល និងអនាគតកាលក្តី ដែលព្រះជាម្ចាស់មិនបានជ្រាបនោះទេ។ ដូចគ្នានេះដែរ គ្មានចិត្តគំនិត សកម្មភាព និងពាក្យសំដីណាមួយដែលអាចលាក់កំបាំងពីព្រះជាម្ចាស់បានជាដាច់ខាត ស្របគ្នាទៅនឹងទំនុករបស់អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរដែលបានលើកឡើងថា "គ្មានអ្វីកើតមកដែលទ្រង់ទតមើលមិនឃើញនោះឡើយ គឺគ្រប់ទាំងអស់នៅជាអាក្រាតហើយចំហនៅចំពោះព្រះនេត្រនៃព្រះ...."(ហេព្រើ៤៖១៣)។ ព្រះអាទិករដ៏ធំឧត្តុងឧត្តម ដែលជាម្ចាស់ស្ថានសួគ៌គឺជាព្រះដ៏សព្វញ្ញូញាណ៕

## គ៤ ព្រះដ៏បរិសុទ្ធ

តើយើងគួរប្រៀបប្រដូចភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ទៅនឹងអ្វីបាន បើយើងទាំងអស់គ្នាកំពុងតែលិចលង់នៅក្នុងផែនដីដែលប្រលាក់ជោគជាំទៅដោយអំពើបាប ភាពសៅហ្មង គ្មានសោះភាពបរិសុទ្ធដ៏ពិតប្រាកដនោះ ពោលគឺយើងមិនដែលមានបទពិសោធន៍ជាមួយនឹងកំរិតនៃដ៏ភាពបរិសុទ្ធដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ឡើយ។ ដូចគ្នាទៅនឹងបុគ្គលិកលក្ខណៈជាច្រើនផ្សេងៗទៀតរបស់ព្រះជាម្ចាស់ដែរ មនុស្សមិនអាចស្វែងយល់បានគ្រប់ជ្រុងជ្រោយអំពីភាពដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ឡើយ។ បើប្រៀបធៀបគំនិតរបស់មនុស្សអំពីភាពបរិសុទ្ធ ទៅនឹងភាពបរិសុទ្ធដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ ប្រៀបបានដូចជាតំណក់ទឹកសន្សើម ជាមួយនឹងចំនុះទឹកនៅក្នុងផ្ទៃមហាសាគរដ៏ធំល្វឹងល្វើយ។ បើទោះបីជាយ៉ាងណាក៏ដោយ បើផ្អែកលើព្រះគម្ពីរបរិសុទ្ធ ព្រះអាទិករដែលជាម្ចាស់នៃសព្វសារពើទាំងអស់ ដែលព្រះអង្គកំពុងតែគង់លើព្រះរាជ្យបល្ល័ង្គដ៏អស្ចារ្យរបស់ទ្រង់ត្រូវបានពណ៌នាថា ".... បរិសុទ្ធ បរិសុទ្ធ គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ ផែនដីទាំងមូលពេញដោយសិរីល្អនៃទ្រង់" (អេសាយ៦៖៣)។ "គ្មានព្រះណាបរិសុទ្ធដូចព្រះយេហូវ៉ាឡើយ ដ្បិតក្រៅពីទ្រង់គ្មានព្រះឯណាទៀតសោះ...... " (សាំយូអែលទី១ ២៖២)។ "ចូរលើកតម្កើងព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំ ហើយថ្វាយបង្គំនៅត្រង់ភ្នំបរិសុទ្ធរបស់ទ្រង់ចុះ ត្បិតព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំទ្រង់បរិសុទ្ធ"(ទំនុកតម្កើង៩៩៖៩)។ ព្រះជាម្ចាស់បរិសុទ្ធដល់ម្ល៉េះ រហូតដល់សព្វសារពើទាំងអស់ដែលនៅក្នុងព្រះវត្តមានរបស់ទ្រង់នឹងត្រូវវិនាសជាក់ជាមិនខាន ប្រសិនបើមិនបានញែកចេញអោយបានបរិសុទ្ធជាមុន។ ស្របពេលជាមួយគ្នានេះផងដែរ អំពើបាប ភាពសៅហ្មងលនិងល មិនអាចឈរនៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធបានជាដាច់ខាត។ លើសពីនេះទៅទៀត មនុស្សបាបមិនអាចចូលទៅជិតព្រះជាម្ចាស់បានឡើង ត្បិតទ្រង់បរិសុទ្ធដល់ម្ល៉េះ៕

តើលោកអ្នកដឹងដែរឬទេថា ខណៈពេលដែលព្រះជាម្ចាស់បានលេចមកឯលោកម៉ូសេ ទ្រង់បានបង្គាប់ដល់គាត់ថា "កុំអោយមកជិតនេះឡើង ចូរដោះស្បែកជើងចេញ ត្បិតកន្លែងដែលឈរនោះជាដីបរិសុទ្ធ"(និក្ខមនំ៣៖៥)។ ដីនោះត្រូវបានញែកចេញជាបរិសុទ្ធ ព្រោះព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធគង់នៅទីនោះ ឯលោកម៉ូសេដែលជាមនុស្សបាប មិនបរិសុទ្ធមិនអាចចូលទៅជិតទ្រង់បានជាដាច់ខាត។ រូបភាពនេះបានលេចឡើងសារជាថ្មីម្តងទៀត ខណៈពេលដែលព្រះជាម្ចាស់បានយាងចុះមកលើកំពូលភ្នំស៊ីណាយអោយពួកអ៊ីស្រាអែលបានឃើញ។ ពេលនោះ ព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេថា ".......ចូរប្រយ័ត្នកុំអោយឡើងទៅលើភ្នំឡើយ កុំអោយទាំងជាន់ដល់ជើងភ្នំផង ត្បិតអ្នកណាដែលជាន់ដល់ភ្នំ នោះនឹងត្រូវស្លាប់ជាមិនខាន" (និក្ខមនំ១៩៖១២)។ ពួកអ៊ីស្រាអែល ក៏ដូចជាមនុស្សបាបទាំងពួងផងដែរ គ្មាននរណាម្នាក់អាចឈរនៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធបានឡើយ ឬក៏គេនឹងត្រូវស្លាប់ជាក់ជាមិនខាន។

ពេលនោះ ប្រជារាស្ត្រអ៊ីស្រាអែលភ័យខ្លាចញាប់ញ័ររន្ធត់ មិនហ៊ានចូលទៅជិតទីដែលព្រះជាម្ចាស់មានព្រះវត្តមាននោះឡើយ ព្រោះទីនោះជាទីបរិសុទ្ធ ឯពួកគេជាមនុស្សបាបមិនបរិសុទ្ធ (និក្ខមនំ២០ះ១៨-១៩)៕

អំពើបាបមិនត្រូវបានអនុញ្ញាតអោយចូលទៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធជាដាច់ខាត លើសពីនេះទៅទៀត គឺព្រះជាម្ចាស់ស្អប់អំពើបាប ហើយព្រះអង្គមិនមើលរម្លងអំពើបាបណាមួយសោះឡើយ។ ព្រះដ៏បរិសុទ្ធវិនិច្ឆ័យអំពើបាបដែលមិនបរិសុទ្ធ ដូចដែលព្រះបន្ទូលផ្ទាល់របស់ទ្រង់បានលើកឡើងយ៉ាងប្រទៀតថា “ត្បិតទ្រង់មិនមែនជាព្រះដែលសព្វព្រះហឫទ័យនឹងសេចក្តីល្មើសទេ ឯសេចក្តីអាក្រក់នឹងនៅជាមួយទ្រង់មិនបាន ពួកឆ្មើងឆ្មៃនឹងឈរនៅចំពោះព្រះនេត្រទ្រង់មិនបានទេ ទ្រង់ក៏ស្អប់បណ្តាអ្នកដែលប្រព្រឹត្តិអំពើទុច្ចរិត ទ្រង់នឹងបំផ្លាញពួកអ្នកដែលដែលពោលពាក្យភូតភរ ព្រះយេហូវ៉ាទ្រង់ខ្ពើមឆ្អើមចំពោះមនុស្សដែលតែងតែកំចាយឈាម ហើយបោកប្រាសគេ”(ទំនុកតម្កើង៥ះ៤-៦)។ ដោយឡែក លោកហោរ៉ាហាបាគូកក៏បាននិយាយដូចគ្នាដែរថា “ទ្រង់មានព្រះនេត្របរិសុទ្ធក្រៃលែង និងទតមើលការអាក្រក់មិនបាន ក៏ពិនិត្យមើលការទុច្ចរិតមិនបានដែរ..... ” (ហាបាគូក១ះ១៣)៕ អំពើបាបដ៏តូចបំផុតមួយនៅក្នុងចិត្ត គំនិតរបស់មនុស្ស ដែលគ្មាននរណាម្នាក់មើលឃើញសោះ តែព្រះជាម្ចាស់ទ្រង់ជ្រាប ហើយព្រះអង្គនឹងមិនមើលរម្លងវាជាដាច់ខាត ពោលគឺព្រះជាម្ចាស់នឹងវិនិច្ឆ័យអំពើបាបដ៏តូចតាចមួយនោះ ព្រោះវាធំ ហើយអាក្រក់ដល់ម្ល៉េះនៅចំពោះព្រះនេត្ររបស់ទ្រង់៕

ព្រះជាម្ចាស់បរិសុទ្ធ រីឯអំពើបាបមិនត្រូវបានអនុញ្ញាតសោះឡើយនៅក្នុងព្រះវត្តមានរបស់ទ្រង់។ ព្រះអង្គស្អប់អំពើបាប ហើយព្រះអង្គស្អប់មនុស្សបាប។ នេះមិនមែនជាដំណឹងល្អសម្រាប់មនុស្សទាំងអស់គ្នាដែលជាមនុស្សបាបនោះទេ។ ចប់ហើយមនុស្សបាប!

ដោយព្រោះព្រះជាម្ចាស់គឺជាព្រះដ៏សុចរិត បរិសុទ្ធ ព្រះអង្គទាមទារអោយអស់អ្នកដែលនៅក្នុងព្រះវត្តមានរបស់ទ្រង់ត្រូវតែសុចរិត ហើយបរិសុទ្ធជាដាច់ខាត។ ព្រះជាម្ចាស់មានព្រះបន្ទូលដោយផ្ទាល់ថា “..... ត្រូវអោយឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញនេះដែលជាព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា អញបរិសុទ្ធ” (លេវីវិន័យ១៩ះ២)។ ចំណែកឯ អ្នកដឹកនាំក្រុមជំនុំគ្រិស្តបរិស័ទជំនាន់ដំបូងក៏បានរំលឹកផងដែរថា “ចូរអោយអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ ត្បិតមានសេចក្តីចែងទុកមកថា ចូរអោយឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ” (ពេត្រុសទី១ ១ះ១៥-១៦)។ នេះជាច្បាប់ ជាស្តង់ដា ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌របស់ព្រះជាម្ចាស់ដ៏បរិសុទ្ធ គឺអ្នកត្រូវតែបរិសុទ្ធ! គ្មានបាបសោះឡើយ! ល្អឥតខ្ចោះមួយរយភាគរយ៕

## គ៥ វរហើយមនុស្សបាប!

"ឱព្រះយេហូវ៉ាអើយ តើអ្នកណានឹងនៅក្នុងរោងឧបោសថរបស់ទ្រង់បាន តើអ្នកណានឹងនៅលើភ្នំបរិសុទ្ធនៃទ្រង់បាន"(ទំនុកតម្កើង១៥៖១)។

"តើអ្នកណានឹងឡើងទៅឯភ្នំនៃព្រះយេហូវ៉ា តើអ្នកណានឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន គឺជាអ្នកដែលមានដៃស្អាត និងចិត្តបរិសុទ្ធ......." (ទំនុកតម្កើង២៤៖៣-៤)។

ខណៈពេលដែលព្រះដ៏បរិសុទ្ធបានបើកសម្តែងអង្គទ្រង់មកឯលោកហោរ៉ាអេសាយ លោកអេសាយបានតក់ស្លុត ហើយភ័យរន្ធត់ញាប់ញ័រយ៉ាងខ្លាំងពន់ពេក ដោយបានឧទានឡើងថា "វរហើយខ្ញុំ ខ្ញុំត្រូវវិនាសជាពិត ត្បិតខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត ហើយខ្ញុំនៅកណ្តាលបណ្តាមនុស្សដែលមានបបូរមាត់មិនស្អាតដែរ ពីព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ" (អេសាយ៦៖៥)។ ក្នុងនាមជាហោរ៉ា លោកអេសាយស្គាល់ច្បាស់ថា ខ្លួនឯងជាអ្នកណា ហើយលើសពីនេះទៅទៀត លោកយល់អំពីលក្ខណះដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់។ ក្នុងសភាពជាមនុស្សបាប លោកអេសាយដឹងថា គាត់មិនអាចឈរនៅចំពោះព្រះដ៏បរិសុទ្ធបានជាដាច់ខាត។ ដូចគ្នានេះដែរ ស្ថានភាពរបស់មនុស្សគ្រប់ជាតិសាសន៍ទាំងឡាយ ក៏មិនខុសអ្វីអំពីលោកហោរ៉ាអេសាយផងដែរ ព្រោះគ្រប់ៗគ្នាសុទ្ធតែស្ថិតនៅក្រោមកំរិតនៃបន្ទាត់បាប។ ដូចចម្ងល់របស់អ្នកនិពន្ធកណ្ឌទំនុកតម្កើងខាងលើ តើនរណាដែលល្អល្មម សុចរិតល្មម បរិសុទ្ធល្មម សមនឹងឈរនៅចំពោះព្រះដ៏បរិសុទ្ធ? ចម្លើយគឺគ្មានទេ បើគេត្រូវពឹងលើខ្លួនឯង។ បើដូច្នោះ សំនួរដ៏សំខាន់មួយគឺ តើត្រូវធ្វើដូចម្តេចដើម្បីអោយមនុស្សអាចឈរនៅចំពោះព្រះដ៏បរិសុទ្ធបាន ដោយមិនចាំបាច់ត្រូវវិនាស?

ស្ថានសួគ៍គឺមានពិត! បើទោះបីជានៅទីនោះ នឹងមិនមានវត្តមានរបស់មនុស្សម្នាគ្រប់ៗគ្នាក៏ពិតមែន តែនឹងមានមនុស្សមកពីគ្រប់ជាតិសាសន៍ទាំងអស់សម្រាកដោយស្កប់ស្កល់នៅក្នុងសេចក្តីសុខសាន្តដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ ហើយនៅទីនោះទៀតសោត សិរីល្អតែមួយគត់របស់ព្រះជាម្ចាស់នឹងត្រូវបានលើកសរសើរតម្កើងនៅក្នុងចំណោមមនុស្សម្នាគ្រប់ជាតិសាសន៍ទាំងអស់នោះ។ ឈប់សិន! ឈប់សិន! ព្រោះបើយើងសំឡឹងមើលច្បាប់សម្រាប់ចូលទៅជ្រកកោននៅក្នុងនគរស្ថានសួគ៌ និងតថភាពរបស់មនុស្សជាតិ នោះគ្មាននរណាម្នាក់ដែលល្អល្មម សុចរិតល្មម បរិសុទ្ធល្មម និងគ្រប់គ្រាន់ល្មមអាចចូលទៅសម្រាកនៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធ ខ្ពង់ខ្ពស់ និងឧត្តុងឧត្តមបានជាដាច់ខាត ត្បិតព្រះគម្ពីរបរិសុទ្ធបានគូសវាសបញ្ជាក់យ៉ាងប្រទាំ្យតថា "ពិតប្រាកដជាគ្មានមនុស្សសុចរិតណានៅផែនដី ដែលប្រព្រឹត្តិសុទ្ធតែល្អឥតធ្វើបាបឡើយនោះទេ"(សាស្តា៧៖២០)។ មនុស្សទាំងអស់សុទ្ធតែជាប់មានបាប ហើយមនុស្សបាបគ្មានសង្ឃឹមសោះឡើយ! វរហើយមនុស្សបាប!

ទស្សនះខាងលើពិតប្រាកដជាត្រឹមត្រូវ ដែលគ្មានអ្វីដែលអាចប្រកែកបាននោះឡើយ ក៏ប៉ុន្តែ ម៉េចវិញ! ប្រសិនបើមានផ្លូវដ៏ពិតប្រាកដមួយដែលអាចដឹកនាំមនុស្សអោយចូលទៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់បានដោយជោគជ័យ ដែលព្រះអង្គផ្ទាល់ជាអ្នករៀបចំសម្រាប់ពួកគេតាំងពីដើមដំបូងមកម្ល៉េះ ព្រោះទ្រង់ជ្រាបច្បាស់ណាស់ថាមនុស្សបាបមិនអាចល្អគ្រប់គ្រាន់ដើម្បីចូលទៅកាន់នគរស្ថានសួគ៌បានដោយឯកឯងនោះទេ។ គំនិតដូចគ្នានេះដែរ ម៉េចវិញ ប្រសិនបើតាំងតែពីដើមដំបូងមកម្ល៉េះ ព្រះជាម្ចាស់បានប្រោសប្រទានត្រីវិស័យដ៏ពិតប្រាកដតែមួយគត់ដែលនឹង

ចង្អុលបង្ហាញផ្លូវមនុស្សជាតិអោយបានទៅដល់ឯទ្រង់ដោយជោគជ័យ ត្បិតទ្រង់ស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ ផ្ទុយទៅវិញ មនុស្សជាតិបែរជាវង្វេង ហើយសម្រេចចិត្តបដិសេធន៍ ព្រមទាំងបោះបង់ចោលត្រីវិស័យដ៏វិសេសអស្ចារ្យ មួយនោះទៅវិញ។ ជាងនេះទៀតសោត មនុស្សជាតិបានជ្រើសរើសយកផ្លូវដើរដោយខ្លួនឯងតាមរយៈត្រីវិស័យ មួយផ្សេងទៀតដែលបានចង្អុលបង្ហាញថា ប្រសិនបើគេធ្វើល្អល្មមគ្រប់គ្រាន់នោះ ព្រះជាម្ចាស់នឹងអនុញ្ញាតអោយគេ ចូលទៅសម្រាកនៅក្នុងនគរស្ថានសួគ៍របស់ទ្រង់ ហើយនេះមិនមែនជាត្រីវិស័យដែលព្រះជាម្ចាស់បានប្រោសប្រទាន មកដល់មនុស្សជាតិសោះឡើយ។ មនុស្សជាតិកំពុងតែដើរតាមត្រីវិស័យដែលមិនត្រឹមត្រូវ៕

មុននឹងបន្តដំណើរទៅមុខទៀត ដើម្បីស្វែងរកត្រីវិស័យដ៏ពិតប្រាកដដែលព្រះដ៏ជាព្រះបានប្រោសប្រទាន មកដល់មនុស្សដែលជាស្នាព្រះហស្តដ៏វិសេសរបស់ទ្រង់ ប្រយោជន៍អោយមគេបានចូលទៅក្នុងព្រះដំណាក់របស់ទ្រង់ ដោយជោគជ័យនោះ ក្នុងនាមជាអ្នកនិពន្ធ ខ្ញុំសូមអធិស្ឋានដល់ព្រះអាទិករដ៏ខ្ពង់ខ្ពស់ឧត្តុងឧត្តមហួសពីការពណ៌នា សូម ព្រះអង្គគង់ជាពន្លឺបំភ្លឺផ្លូវចិត្តរបស់បងប្អូនអោយបានមើលឃើញផ្លូវដ៏ពិតប្រាកដតែមួយគត់ ដែលអាចដឹកនាំបងប្អូនអោយ ចូលទៅសម្រាកនៅក្នុងព្រះវត្តមានរបស់ទ្រង់បានដោយជោគជ័យ ប្រយោជន៍អោយសិរីល្អតែមួយគត់របស់ព្រះអង្គត្រូវ បានលើកសរសើរតម្កើង ស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់តាំងតែពីដើមដំបូងមកម្ល៉េះ៕

## ឃ អតីតកាល

ជីវិតនៅក្នុងសួនច្បារអេដែន គឺជារូបភាពឆ្លុះអំពីជីវិតនៅក្នុងនគរស្ថានសួគ៌។ ដោយឡែក បន្ទាប់ពីព្រឹត្តិការណ៍ នៅក្នុងជំពូកទី៣ នៃព្រះគម្ពីរលោកុប្បត្តិ ជីវិតរបស់មនុស្សត្រូវបានផ្លាស់ប្រែទាំងស្រុងរហូតដល់សព្វថ្ងៃ។ ជំនួសអោយ ការសោយសុខក្នុងព្រះពរ និងព្រះគុណរបស់ព្រះជាម្ចាស់ មនុស្សត្រូវរស់នៅក្នុងបណ្តាសា ក្រោមព្រះពិរោធន៍របស់ទ្រង់ វិញ៕

ដូចជាការឧបមាកាលពីដើមដំបូងមកដែរ ដើម្បីយល់អំពីស្ថានការណ៍អោយបានច្បាស់លាស់ និងស៊ីជម្រៅ ប៉ូលីស ស៊ើបអង្កេតគប្បីត្រូវតែចុះទៅដល់កន្លែងកើតហេតុ ហើយសាកសួរសាក្សីដែលមានវត្តមាននៅទីនោះ។ ដូចជាករណី ខាងលើនេះដែរ វាសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា ក្នុងការចុះទៅដល់កន្លែងកើតហេតុ ខណៈពេលដែលរបត់នៃ ជីវិតរបស់មនុស្សជាតិត្រូវបានផ្លាស់ប្តូរទាំងស្រុង ដើម្បីស្វែងរកមើលអំពីបុព្វហេតុនៃការផ្លាស់ប្រែនោះ ហើយម្យ៉ាងទៀត ដោយព្រោះនៅទីនោះឯង ខណៈពេលនោះឯង ដែលព្រះជាម្ចាស់បានផ្តល់ត្រីវិស័យតែមួយគត់សម្រាប់បង្ហាញផ្លូវមនុស្ស អោយវិញត្រឡប់ទៅឯទ្រង់វិញ។ ដូច្នេះ ជាបន្ទាប់មកទៀត យើងទាំងអស់គ្នានឹងវិលត្រឡប់ទៅកាន់អតីតកាលរាប់ពាន់ ជំនាន់រហូតដល់សម័យមនុស្សដំបូងតែពីរនាក់គត់ដែលព្រះជាម្ចាស់បានបង្កើតដោយផ្ទាល់ គឺអាដាំ និងអេវ៉ា៕

ព្រះអាទិករ៖ ព្រះគម្ពីរបរិសុទ្ធបានចាប់ផ្តើមដំបូងដោយបើកសម្តែងអោយឃើញយ៉ាងប្រទាំ្យតថា កាលពីដើម ដំបូងបង្អស់គឺគ្មានអ្វីៗទាំងអស់ លើកលែងតែព្រះជាម្ចាស់ (លោកុប្បត្តិ១៖១-២)។ ព្រះជាម្ចាស់តែមួយអង្គគត់ដែលមាន ព្រះជន្មគង់នៅអស់កល្បជានិច្ច (ទំនុកតម្កើង៩០៖២)។ ខុសគ្នាអំពីស្នាព្រះហស្តផ្សេងទៀត ព្រះជាម្ចាស់គ្មានដើមកំណើត នោះទេ ផ្ទុយទៅវិញ ព្រះអង្គគឺជាដើមកំណើត និងជាប្រភពនៃអ្វីៗសព្វសារពើទាំងអស់។ ព្រះជាម្ចាស់គឺជាព្រះដ៏ពិតតែ មួយអង្គគត់ដែលល្អឥតខ្ចោះ ដូចគ្នានេះដែរ គ្រប់សព្វសារពើទាំងអស់ដែលទ្រង់បានបង្កើតមកគឺសុទ្ធតែល្អឥតខ្ចោះ។

> ត្រីវិស័យជីវិត៖ ជីវិតគឺសម្រាប់ជាសិរីល្អដល់ព្រះជាម្ចាស់

បន្ទាប់ពីបានបង្កើតសព្វសារពើទាំងអស់ដោយល្អឥតខ្ចោះអស់ហើយ ព្រះជាម្ចាស់មានព្រះបន្ទូលថា “ចូរយើងធ្វើមនុស្សអោយដូចជារូបយើង អោយមានភាពដូចយើង ហើយអោយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង ទ្រង់ក៏បង្កើតមនុស្សអោយដូចរូបអង្គទ្រង់ គឺបានបង្កើតគេអោយចំនឹងរូបអង្គទ្រង់នេះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូលថា ចូរបង្កើតកូនអោយចម្រើនជាច្រើនឡើង អោយមានពាសពេញលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតទាំងឡាយដែលកំរើកនៅផែនដីផង”(លោកុប្បត្តិ១៖២៦-២៨)។ ព្រះជាម្ចាស់បានបង្កើតមនុស្សតាមគម្រោងរបស់ទ្រង់ ហើយព្រះអង្គមានផែនការណ៍សម្រាប់ពួកគេ។ លោក រីក វ៉ររិន បាននិយាយថា“ក្មេងៗជាច្រើនអាចកើតមកដោយឪពុកម្តាយមិនបានគ្រោងទុក
ប៉ុន្តែពួកគេសុទ្ធតែបានគ្រោងទុកមកពីព្រះជាម្ចាស់”[6] ។ វត្តមានរបស់មនុស្សទាំងអស់នៅលើផែនដីមិនមែនជាការចៃដន្យ ឬដោយធម្មជាតិនោះទេ ផ្ទុយទៅវិញ វាគឺជាគម្រោងផែនការណ៍ដ៏អស្ចារ្យបំផុតរបស់ព្រះជាម្ចាស់៕

មួយវិញទៀត ដោយផ្អែកលើព្រះបន្ទូលខាងលើ យើងឃើញថា មនុស្សជាតិត្រូវបានញែកដាច់ដោយឡែក ហើយខ្ពង់ខ្ពស់លើសអស់ទាំងស្នាព្រះហស្តផ្សេងៗទៀត ដែលព្រះជាម្ចាស់បានបង្កើតពីមុនមក។ មនុស្សត្រូវបានបង្កើតមកក្នុងនាមជាអ្នកគ្រប់គ្រង និងត្រួតត្រាលើធម្មជាតិទាំងឡាយដោយសេចក្តីស្រលាញ់ ជាមួយនឹងព្រះជាម្ចាស់ មិនមែនដើម្បីអោយគេកោតខ្លបខ្លាចធម្មជាតិ ហើយគោរពថ្វាយបង្គំធម្មជាតិនោះទេ៕

**និមិត្តនៃការបង្កើត៖** ហេតុអ្វីបានជាព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ខ្លាំងដល់ម្ល៉េះសម្រាប់មនុស្សជាតិ? តើវត្តមានរបស់មនុស្សនៅលើផែនដីគឺដើម្បីអ្វី? លោកហោរ៉ាអេសាយបានឆ្លើយដោយជំនឿជឿជាក់ថា មនុស្សជាតិត្រូវបានបង្កើតមកសម្រាប់ជាសិរីល្អរបស់ព្រះជាម្ចាស់ (អេសាយ៤៣៖៦-៧) ហើយនេះគឺជាគោលដៅនៃជីវិតរបស់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ គឺការរស់នៅដើម្បីជាសិរីល្អតែមួយគត់របស់ព្រះជាម្ចាស់ ដែលជាអ្នកបង្កើតពួកគេ ជាអ្នកមានគុណ និងជាម្ចាស់របស់ពួកគេ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឃើញព្រះកិត្តិនាម និងសិរីល្អតែមួយគត់របស់ទ្រង់ត្រូវបានថ្វាយបង្គំ និងលើកសរសើរតម្កើងនៅគ្រប់ផ្នែកទាំងអស់នៃផែនដី តាមរយៈមនុស្សដែលព្រះអង្គបានបង្កើតមកដោយផ្ទាល់ (ហាបាគូក២៖១៤)។ បើទោះបីជាយ៉ាងណាក៏ដោយ ព្រះជាម្ចាស់មិនមែនបង្កើតមនុស្ស ដើម្បីអោយពួកគេគ្រាន់តែបំរើ និងថ្វាយបង្គំទ្រង់ដោយបង្ខិតបង្ខំក្នុងនាមជាទាសករគ្មានតម្លៃតែប៉ុននោះទេ ដ្បិតដើមឈើដឹងខុសត្រូវនៅកណ្តាលសួនច្បារអេដែន គឺជាភស្តុតាងយ៉ាងប្រទ្យ៉តថា មនុស្សមានជម្រើសក្នុងការថ្វាយបង្គំព្រះដ៏ពិតរបស់ពួកគេ។ ផ្ទុយទៅវិញ មនុស្សត្រូវបានបង្កើតមកដើម្បីថ្វាយបង្គំព្រះអាទិកររបស់ពួកគេ ព្រោះការរស់នៅដោយថ្វាយបង្គំព្រះជាម្ចាស់គឺជាផ្លូវតែមួយគត់ដែលដឹកនាំមនុស្សទៅកាន់ការសម្រាក និងសេរីភាពដ៏ពិតប្រាកដ(ម៉ាថាយ១១៖២៨-៣០ ទំនុកតម្កើង៤៖៨ ២៣៖១-២ ៦២៖១-២ )។ យើងអាចនិយាយបានម្យ៉ាងទៀតថា តាមរយៈការថ្វាយបង្គំព្រះជាម្ចាស់ មនុស្ស

---

[6] ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោយលោក រីក វ៉ររិន ទំព័រ២៨

នឹងស្គាល់រស់ជាតិនៃសេចក្តីសុខសាន្តដ៏ពិតប្រាកដ ព្រោះការថ្វាយបង្គំព្រះជាម្ចាស់គឺជាកូនសោរតែមួយគត់ដែលនឹងនាំគេអោយចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ដែលជាប្រភពនៃព្រះពរសព្វបែបយ៉ាងទាំងអស់។ ការរស់នៅដោយថ្វាយបង្គំព្រះជាម្ចាស់ គឺជាការរស់នៅដោយចំគោលដៅនៃជីវិត។ ផ្ទុយទៅវិញ ដរាបណាមនុស្សមិនបានរស់នៅដើម្បីថ្វាយបង្គំ ព្រមទាំងសរសើរតម្កើងសិរីល្អរបស់ព្រះជាម្ចាស់ នោះគេកំពុងតែរស់នៅក្រៅរង្វង់នៃព្រះពររបស់ព្រះជាម្ចាស់ ហើយជីវិតរបស់គេនឹងវង្វេងតែលតោល គ្មានលំនឹង គ្មានភាពស្កប់ស្កល់ គ្មានសេចក្តីសុខសាន្តដ៏ពិតប្រាកដដូចដែលព្រះជាម្ចាស់បានគ្រោងទុកសម្រាប់គេនោះទេ។ ព្រះគម្ពីរបរិសុទ្ធបានចង្អុលឡើងក្នុងរូបភាពផ្សេងៗគ្នាថា ជីវិតដែលចាក់ឫសជាប់នឹងព្រះជាម្ចាស់ ជីវិតដែលមានការថ្វាយបង្គំព្រះជាម្ចាស់ជាគ្រឹះ ប្រៀបបានដូចជាដើមឈើដែលដុះនៅតាមមាត់ទឹកយ៉ាងដូច្នោះដែរ គឺវានឹងរីកចម្រើនលូតលាស់ ខៀវខ្ចី បង្កើតផលផ្លែផ្កា ពោលគឺជាជីវិតដ៏រស់រវើកដែលជាទីប៉ងប្រាថ្នារបស់បុគ្គលគ្រប់ៗរូប៕

ចុះបើយ៉ាងដូច្នោះក្តី ការនេះមិនមែនបានសេចក្តីថា ព្រះជាម្ចាស់ត្រូវការមនុស្សដើម្បីថ្វាយបង្គំ និងលើកតម្កើងសិរីល្អរបស់ទ្រង់ ប្រយោជន៍អោយព្រះកិត្តិនាម និងឧត្តមភាពរបស់ទ្រង់បានកាន់តែឧត្តុងឧត្តមខ្ពង់ខ្ពស់ឡើងនោះទេ ព្រោះព្រះជាម្ចាស់មិនអាស្រ័យលើមនុស្សឡើយ។ សិរីល្អរបស់ព្រះជាម្ចាស់នៅតែខ្ពង់ខ្ពស់ឧត្តុងឧត្តមជាដរាប បើទោះបីជាមនុស្សមិនបានលើកតម្កើងទ្រង់ ឬថ្វាយសិរីល្អដល់ទ្រង់យ៉ាងណាក្តី។ លើសពីនេះទៅទៀត ស្នាព្រះហស្តដ៏ទៃផ្សេងៗទៀតនឹងលើកតម្កើង ហើយថ្វាយសិរីល្អដល់ព្រះជាម្ចាស់ បើទោះបីជាមនុស្សបរាជ័យក្នុងការសម្រេចនិមិត្តនេះ ព្រោះការថ្វាយបង្គំគឺជាគោលដៅនៃវត្តមានរបស់ស្នាព្រះហស្តសព្វសារពើទាំងអស់ (ទំនុកតម្កើង១៩៖១ លូកា១៩៖៤០)៕

ស្របពេលជាមួយគ្នានេះផងដែរ លោកគ្រូពេទ្យលូកាក៏បានសរសេរបញ្ជាក់អោយបានរឹតតែច្បាស់លាស់ថែមទៀតដែរថា “ដ្បិតព្រះដែលបង្កើតលោកិយ និងរបស់សព្វសារពើ ព្រះអង្គនោះជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី ទ្រង់មិនគង់នៅក្នុងវិហារដែលដៃមនុស្សបានធ្វើនោះទេ ក៏មិនបាច់មានដៃមនុស្សបំរើទ្រង់ ដូចជាទ្រង់ត្រូវការអ្វីនោះផងដែរ ដ្បិតគឺទ្រង់ដែលផ្គត់ផ្គង់ដោយព្រះអង្គទ្រង់អោយគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក” (កិច្ចការ១៧៖២៤-២៥)។ ព្រះវត្តមានរបស់ព្រះអាទិករដ៏ធំឧត្តមមិនមែនស្ថិតនៅក្រោមការផ្គត់ផ្គង់របស់មនុស្ស ធម្មជាតិ ឬទេវតាណាមួយឡើយ ផ្ទុយទៅវិញ គ្រប់សព្វសារពើទាំងអស់ត្រូវបានបង្កើតមកអោយស្ថិតក្រោមការផ្គត់ផ្គង់ ការការពារ និងការគ្រប់គ្រងរបស់ទ្រង់ដែលជាព្រះដ៏លើសអស់ទាំងព្រះ។ វត្តមានរបស់ព្រះជាម្ចាស់ឯករាជ្យចេញពីសព្វសារពើទាំងអស់ តែសព្វសារពើទាំងអស់មិនអាចដាច់ចេញដោយគ្មានព្រះដែលជាប្រភពនៃជីវិតបានឡើយ។ ការនេះគឺបានសេចក្តីថា មនុស្សត្រូវបានបង្កើតមកដើម្បីពឹងផ្អែកលើព្រះ ទុកចិត្តលើព្រះ ហើយដើរតាមព្រះ។ បើដូច្នោះ តើមនុស្សមានអ្វីដើម្បីថ្វាយដល់ព្រះជាម្ចាស់? ចិត្តស្តាប់បង្គាប់ ចុះចូល ទុកចិត្ត ជំនឿ ការថ្វាយបង្គំ លនិងល ព្រោះទាំងនេះគឺជានិមិត្តនៃការបង្កើតរបស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិ៕

មួយវិញទៀត នៅពេលដែលខ្ញុំអានរឿងអំពីការបង្កើតជាលើដំបូង គំនិតមួយដែលលេចមកក្នុងខួរក្បាលខ្ញុំភ្លាមគឺព្រះជាម្ចាស់គួរតែធុញទ្រាន់ក្នុងការគង់នៅតែអង្គឯងដោយគ្មានអ្វីសោះ ហេតុដូច្នោះហើយបានជាព្រះអង្គសម្រេចព្រះទ័យបង្កើតសព្វសារពើទាំងអស់ រួមបញ្ចូលទាំងមនុស្សផងដែរ ព្រោះព្រះជាម្ចាស់ត្រូវការទំនាក់ទំនង។ ពិតជាមានមនុស្សជាច្រើនផ្សេងៗទៀត គិតដូចខ្ញុំដូច្នោះដែរ។ បើទោះបីជាយ៉ាងណាក៏ដោយ គប្បីយើងត្រូវដឹងផងដែរថា មុនពេលដែល

ព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើទាំងអស់ ព្រះអង្គមានទំនាក់ទំនងដ៏ល្អឥតខ្ចោះនៅក្នុងចំណោមព្រះត្រៃឯក ហើយលើសពីនេះទៅទៀត ព្រះអង្គស្កប់ស្កល់យ៉ាងពន់ពេកក្នុងទំនាក់ទំនងដ៏អស្ចារ្យមួយនោះ ដោយមិនប៉ងប្រាថ្នាទំនាក់ទំនងណាផ្សេងទៀតដើម្បីបំពេញទ្រង់ឡើយ ពោលគឺព្រះជាម្ចាស់មិនត្រូវការទំនាក់ទំនងជាមួយមនុស្សដើម្បីធ្វើអោយទ្រង់កាន់តែស្កប់ស្កល់ថែមទៀតនោះឡើយ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានបង្កើតមនុស្ស ហើយនាំយកគេចូលទៅក្នុងគ្រួសារនៃព្រះត្រៃឯក ប្រយោជន៍អោយមនុស្សបានភ្លក់រសជាតិនូវទំនាក់ទំនងដ៏ល្អឥតខ្ចោះនេះ និងមានពិសោធន៍ជាមួយនឹងការល្អៗដ៏គ្រប់លក្ខណ៍ទាំងអស់ដូចទ្រង់ដែរ៕

ព្រះជាម្ចាស់មិនបានបង្កើតមនុស្សមកដើម្បីបំពេញទ្រង់នោះទេ ផ្ទុយទៅវិញដើម្បីអោយមនុស្សបានពេញហូរហៀងដោយការល្អទាំងអស់ដែលមកពីទ្រង់៕

មកុដនៃសិរីល្អ៖ មនុស្សត្រូវបានបង្កើតមកចេញពីសេចក្ដីស្រលាញ់ដ៏គ្រប់លក្ខណ៍របស់ព្រះជាម្ចាស់។ ផ្ទុយពីស្នាព្រះហស្តដ៏ទៃផ្សេងៗទៀត ព្រះជាម្ចាស់បានបង្កើតមនុស្សអោយចំនឹងរូបអង្គទ្រង់ មានភាពដូចទ្រង់ ហើយជាតំណាងរបស់ទ្រង់ដែលខ្ពង់ខ្ពស់បំផុត។ ក្នុងនាមជាតំណាងរបស់ព្រះជាម្ចាស់ មនុស្សមានអភ័យឯកសិទ្ធិគ្រប់គ្រងលើសព្វសារពើទាំងអស់ ដែលព្រះអង្គបានបង្កើតមកដើម្បីជាសិរីល្អរបស់ទ្រង់ផ្ទាល់ ហើយលើសពីនេះទៅទៀត ព្រះដ៏ជាព្រះបានអនុញ្ញាតអោយសិរីល្អដ៏ឧត្តុងឧត្តមតែមួយគត់របស់ទ្រង់ចែងចាំងនៅក្នុងចំណោមមនុស្ស និងតាមរយៈមនុស្សទៀតផង។ ព្រះជាម្ចាស់បានបំពាក់មុដកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុងឧត្តមបំផុតដល់មនុស្ស។ “តាមរយៈព្រះបង្គាប់បញ្ជាអោយមនុស្សគ្រប់គ្រងលើសព្វសារពើទាំងអស់ ព្រះជាម្ចាស់បានញែកមនុស្សដាច់ចេញដោយឡែកពីស្នាព្រះហស្ដផ្សេងៗទៀត ហើយប្រទានងារជាស្ដេចដល់ពួកគេ គឺអំណាចគ្រប់គ្រងលើផែនដីទាំងមូល” [7]។ ព្រះជាម្ចាស់បានញែកមនុស្សដាច់ដោយឡែកពីស្នាព្រះហស្តសព្វសារពើទាំងអស់សម្រាប់សិរីល្អរបស់ទ្រង់។ ដូចគ្នាទៅនឹងសំនួរកាលពីដើមដំបូងផងដែរ អ្នកនិពន្ធកណ្ឌ៍ទំនុកតម្កើងបានសរសេរដោយការអស្ចារ្យក្នុងចិត្តថា “តើមនុស្សជាអ្វីដែលទ្រង់នឹករលឹកដល់គេ ហើយកូនមនុស្សផងដែលទ្រង់ប្រោសដូច្នោះ ដ្បិតទ្រង់បានធ្វើអោយគេទាបជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ និងកេរ្តិ៍ឈ្មោះអោយទុកជាមកុដ ទ្រង់បានតាំងគេអោយត្រួតលើអស់ទាំងការនៃព្រះហស្តទ្រង់ ក៏បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់អោយនៅក្រោមជើងគេ”(ទំនុកតម្កើង៨៖៤-៦ សូមមើល ហេព្រើរ២៖៧)។ មនុស្សជាតិគឺជាមកុដនៃសិរីល្អដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះដ៏ជាព្រះ៕

បើទោះបីជាយ៉ាងណាក៏ដោយ តោងយើងចងចាំផងដែរថា មនុស្សជាតិត្រូវបានបង្កើតមកអោយមានលក្ខណៈដូចជាព្រះ ដែលជាព្រះវរបិតារបស់ពួកគេ ប្រយោជន៍អោយពួកគេអាចបើកសម្ដែងលក្ខណៈដ៏អស្ចារ្យរបស់ព្រះជាម្ចាស់តាមរយៈការគ្រប់គ្រង ការការពារ និងការថែរក្សាសព្វសារពើទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកដោយសេចក្តីស្រលាញ់ដូចដែលព្រះជាម្ចាស់បានគ្រប់គ្រងដែរ (លោកុប្បត្តិ២៖១៥)។ តាមរយៈមនុស្សជាតិ លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ ក៏ដូចជាសិរីល្អតែមួយគត់របស់ទ្រង់នឹងត្រូវបានបើកសម្ដែងដល់ និងលើគ្រប់ផ្នែកទាំងអស់នៃផែនដី ដែលព្រះអង្គផ្ទាល់បានបង្កើតមកដើម្បីសិរីល្អរបស់ទ្រង់៕

---

[7] From Eden to the New Jerusalem By T. Desmond Alexander, p76

ស្របពេលជាមួយគ្នានេះដែរ ព្រះជាម្ចាស់បានបង្កើតមនុស្សគ្រប់ពូជសាសន៍ទាំងអស់ ប្រយោជន៍អោយគេបានរួមរស់ និងទទួលយកនូវការល្អឥតខ្ចោះសព្វបែបយ៉ាងទាំងអស់ដែលទ្រង់ផ្ទាល់មានពិសោធន៍ ដូចជា ឧត្តមភាព អំណរ អំណាច ភាពសុខសាន្ត ភាពស្កប់ស្កល់ ភាពពេញលេញ សេចក្តីស្រលាញ់ ទំនាក់ទំនងដ៏ល្អឥតខ្ចោះនៅក្នុងចំណោមព្រះត្រៃឯក លនិងល។ លោក រីក វ៉ារិន បាននិយាយថា "ព្រះគម្ពីរទាំងមូល គឺជារឿងមួយរបស់ព្រះជាម្ចាស់ដែលទ្រង់បានបង្កើតជាគ្រួសារមួយដែលនឹងស្រលាញ់ព្រះអង្គ ថ្វាយកិត្តិយសដល់ព្រះអង្គ និងសោយរាជ្យជាមួយព្រះអង្គអស់កល្បជានិច្ច

"[8] ។ ការនេះគឺបានសេចក្តីថា បើមនុស្សជាតិស្មោះត្រង់ក្នុងការថ្វាយសិរីល្អដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ដល់ទ្រង់ នោះមនុស្សនឹងបានសោយរាជ្យដោយអស់កល្បជានិច្ចជាមួយនឹងព្រះដ៏ខ្ពង់ខ្ពស់ នៅក្នុងនគរស្ថានសួគ៌របស់ទ្រង់ ហើយគ្រប់អ្វីៗទាំងអស់ដែលព្រះអង្គមានគឺជាមរតករបស់ពួកគេ។ នេះគឺជាផែនការណ៍របស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិ តាំងតែពីមុនពេលដែលព្រះអង្គចាប់ផ្តើមបង្កើតលោកិយ៍មកម្ល៉េះ គឺដើម្បីអោយពួកគេបានគ្រប់គ្រងមរកតដ៏បរិបូរណ៍ ហើយអស្ចារ្យនេះ ជាមួយទ្រង់ផ្ទាល់ (អេភេសូ១៖៤)។ ភាពខុសគ្នារវាងការបង្កើតមនុស្ស និងសព្វសារពើផ្សេងៗទៀតគឺ ព្រះជាម្ចាស់បានបង្កើតសព្វសារពើទាំងអស់ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្ស ហើយព្រះជាម្ចាស់បានបង្កើតមនុស្សដើម្បីជាតំណាងរបស់ទ្រង់ គ្រងមរតកជាមួយទ្រង់ ដោយចាប់ផ្តើមពីការគ្រប់គ្រងលើសព្វសារពើទាំងអស់ក្នុងនាមជាតំណាងតែមួយគត់របស់ទ្រង់។ បើទោះបីជាយ៉ាងណាក៏ដោយ គ្រប់ស្នាព្រះហស្តទាំងអស់ រួមបញ្ចូលទាំងមនុស្សផងដែរ ត្រូវបានបង្កើតមកដើម្បីសិរីល្អតែមួយគត់របស់ព្រះជាម្ចាស់ដែលជាម្ចាស់លើទាំងអស់៕

មិនខុសអ្វីអំពីបណ្តាស្នាព្រះហស្តដទៃផ្សេងៗទៀតនោះទេ មនុស្សជាតិមិនសាកសមនឹងទទួលយកនូវមកុដកិត្តិយសដ៏ខ្ពង់ខ្ពស់មួយនេះសោះឡើយ តែនេះគឺជាព្រះគុណរបស់ព្រះជាម្ចាស់។ មនុស្សជាតិត្រូវបានបង្កើតមក ដើម្បីសោយសុខដោយអស់កល្បជានិច្ចលើព្រះគុណដ៏ជ្រាលជ្រៅតែមួយគត់របស់ព្រះជាម្ចាស់៕

### ឃ១ រូបភាពនៃនគរស្ថានសួគ៌

> "ទេវតាក៏បង្ហាញ អោយខ្ញុំឃើញទន្លេទឹកនៃជីវិតថ្លាដូចកែវចរណៃដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម ឯនៅកណ្តាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេទាំងសងខាងនោះមានដើមជីវិត ដែលបង្កើតផ្លែ១២ដង គឺ១ខែម្តងៗ ហើយស្លឹកឈើនោះក៏សម្រាប់នឹងមើលអស់ទាំងសាសន៍អោយជាគ្រានោះនឹងគ្មានសេចក្តីបណ្តាសាទៀតឡើយ ហើយបល្ល័ង្កនៃព្រះនិងកូនចៀមក៏នឹងនៅក្នុងក្រុងនោះ ឯពួកបាវនៃទ្រង់គេនឹងបំរើទ្រង់ គេនឹងឃើញព្រះភក្ត្រទ្រង់ ហើយព្រះនាមទ្រង់នៅលើថ្ងាសគេ ក៏នឹងឥតមានយប់ទៀតឡើយ ហើយគេមិនត្រូវការនឹងចង្កៀងណា ឬព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបំភ្លឺគេ ហើយគេនឹងសោយរាជ្យនៅអស់កល្បជានិច្ចរៀងរាបទៅ" (វិវរណៈ២២៖១-៥)។

---

[8] ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោយលោក រីក វ៉ារិន ទំព័រ១៤៣

នេះគឺជាជ្រុងមួយនៃរូបភាពនៅនគរស្ថានសួគ៌ដែលព្រះជាម្ចាស់បានបើកសម្ដែងដល់លោកយ៉ូហានថា មនុស្សនឹងបានសោយរាជ្យនៅអស់កល្បជានិច្ចរៀងរាបតទៅ ជាមួយនឹងព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់។ ព្រះជាម្ចាស់ និងមនុស្សនឹងបានរួមរស់នៅជាមួយគ្នាដោយសុខសាន្ត គ្មានបណ្ដាសាណាឡើយនៅក្នុងព្រះដំណាក់របស់ទ្រង់ផ្ទាល់ គឺនគរស្ថានសួគ៌ ។ ព្រះគម្ពីរបរិសុទ្ធបានបញ្ចប់ទៅ ដោយបន្សល់ទុកនូវរូបភាពដែលបង្កប់ទៅដោយអត្ថន័យដ៏អស្ចារ្យមួយនេះ ដែលប្រវត្តិសាស្ត្ររបស់មនុស្សជាតិកំពុងតែរត់សំដៅតម្រង់ទៅរក គឺនគរស្ថានសួគ៌។ ដូចដែលខ្ញុំធ្លាប់បានបញ្ជាក់ប្រាប់ពីខាងលើមកម្ល៉េះ រូបភាពមួយនេះនឹងបានសម្រេចឡើងជាពិតប្រាកដមែន ព្រោះនេះគឺជាគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ ចាប់តាំងពីខណៈពេលដែលព្រះអង្គចាប់ផ្ដើមចាក់គ្រឹះបង្កើតភពផែនដីមកម្ល៉េះ។ មនុស្សនឹងបានរួមរស់ប្រកបដោយសេចក្ដីសុខសាន្តជាមួយនឹងព្រះអាទិកររបស់ពួកគេ៕

បើទោះបីជាយ៉ាងណាក៏ដោយ តើបងប្អូនដឹងដែរឬទេថា ព្រះគម្ពីរបរិសុទ្ធមិនត្រឹមតែបានបញ្ចប់ដោយបង្ហាញអោយមនុស្សជាតិឃើញអំពីរូបភាពនៃនគរស្ថានសួគ៌ដែលជាទីប៉ងប្រាថ្នារបស់បុគ្គលគ្រប់ៗរូបនោះទេ ស្របពេលជាមួយគ្នានេះផងដែរ ព្រះគម្ពីរបរិសុទ្ធក៏បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ប្រវត្តិសាស្ត្ររបស់មនុស្សជាតិបានចាប់ផ្ដើមជាមួយនឹងរូបភាពនៃនគរស្ថានសួគ៌។ មនុស្សធ្លាប់បានរស់នៅក្នុងរូបភាពនៃនគរស្ថានសួគ៌ជាមួយនឹងព្រះជាម្ចាស់។ ដោយឡែក បើផ្អែកលើតថភាពរបស់មនុស្សជាតិសព្វថ្ងៃវិញ មនុស្សមិនមែនកំពុងតែរស់នៅក្នុងរូបភាពនៃនគរស្ថានសួគ៌សោះ។ ការនេះបានសេចក្ដីថា យើងបានមើលរម្លងកំណាត់ប្រវត្តិសាស្ត្ររបស់មនុស្សជាតិត្រង់កន្លែងណាមួយជាក់ជាមិនខាន ពោលគឺកន្លែងដែលជីវិតរបស់មនុស្សត្រូវបានផ្លាស់ប្រែពីការរស់នៅក្នុងរូបភាពដូចនគរស្ថានសួគ៌ មកជីវិតដែលពោរពេញទៅដោយទុក្ខលំបាកដូចបច្ចុប្បន្នកាលនេះ។ តើរបត់នៃប្រវត្តិសាស្ត្រនោះស្ថិតនៅត្រង់ណា? តើអ្វីជាបុព្វហេតុនៃការផ្លាស់ប្រែនោះ? តើមនុស្សជាតិមានសង្ឃឹមអាចនឹងឈានចូលទៅរស់នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បានសារជាថ្មីឬទេ? គោលបំណងជាបន្តបន្ទាប់មកទៀតនៃសៀវភៅមួយក្បាលនេះ គឺដើម្បីបកស្រាយនូវចម្ងល់ខាងលើ និងជាពិសេសគឺដើម្បីបង្ហាញជូននូវគ្រឹះវិស័យដ៏ពិតប្រាកដតែមួយគត់ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ដើម្បីដឹកនាំផ្លូវគេអោយចូលទៅក្នុងព្រះដំណាក់របស់ទ្រង់វិញ៕

សួនច្បារអេដែន៖ ដើម្បីជាជំនួយជួយអោយយើងទាំងអស់គ្នាយល់ អំពីរូបភាពមួយនេះអោយបានកាន់តែច្បាស់លាស់ថែមទៀតនោះ ចូរយើងធ្វើដំណើរត្រឡប់ចូលទៅកាន់សួនច្បារអេដែនដែលជាទីលំនៅរបស់មនុស្សដំបូងទាំងអស់គ្នា។ ជាបឋម គួររំលឹកផងដែរថា បើផ្អែកលើព្រះគម្ពីរបរិសុទ្ធ គ្រប់យ៉ាងទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតគឺល្អ ហើយ "ល្អ" តាមស្តង់ដាររបស់ទ្រង់ផ្ទាល់ដែលជាព្រះដ៏បរិសុទ្ធ។ ព្រះជាម្ចាស់បានទតមកមើលគ្រប់សព្វសារពើទាំងអស់ ហើយព្រះអង្គផ្ទាល់បានទទួលស្គាល់ស្តង់ដាររបស់វាថាល្អប្រពៃណាស់ និងជាទីពេញព្រះហឫទ័យទ្រង់ណាស់។ ការរីកចម្រើនលូតលាស់ ការប្រាស្រ័យទាក់ទងគ្នា ការរស់នៅ ចិត្ត គំនិត លនិងល របស់មនុស្ស និងសព្វសារពើទាំងអស់បានដើរនៅក្នុងគន្លងរបស់ព្រះជាម្ចាស់ ដើម្បជាសិរីល្អដល់ទ្រង់ ស្របតាមគម្រោងផែនការណ៍នៃការបង្កើត។ ចំណែកឯរូបភាពនៃការបាក់បែក ប្រះស្រាំ វិនាស ព្រាត់ប្រាស់ ការឈឺចាប់ ភាពអាត្មានិយម ទុក្ខសោកសៅ ការច្រណែនឈ្នានីស សំអប់ លនិងល គឺគ្មានវត្តមានសោះឡើយនៅខណៈពេលនោះ។ សព្វសត្វទាំងអស់បានរស់នៅក្នុងភាពសុខសាន្តដ៏ពិតប្រាកដ ព្រមទាំងបានរីកចម្រើននៅក្នុងព្រះពររបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ត្បិតទ្រង់បានប្រទាន

ព្រះពរដល់គ្រប់ទាំងអស់(លោកុប្បត្តិ១៖២២; ១៖២៨)។ មួយវិញទៀត មនុស្សដំបូងបានរស់នៅដោយស្តាប់បង្គាប់ ទុកចិត្ត ចុះចូល និងពឹងផ្អែកលើព្រះជាម្ចាស់តែមួយអង្គគត់ដែលជាបង្អែកដ៏រឹងមាំបំផុតរបស់ពួកគេ ចំណែកឯព្រះជាម្ចាស់វិញ ទ្រង់ស្មោះត្រង់ក្នុងការមើលថែរក្សា ការពារ និងផ្គត់ផ្គង់ពួកគេដោយ "...... ធ្វើអោយដីដុះគ្រប់អស់ទាំងដើមឈើដែលគួរពិចរពិលរមើលមើល ហើយសម្រាប់ជាអាហារផង" (លោកុប្បត្តិ២៖៩ សូមមើល លោកុប្បត្តិ១៖២៩-៣០)។ នៅចុងបញ្ចប់នៃពីរជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិ ព្រះជាម្ចាស់បានប្រទានព្រះពរដ៏អស្ចារ្យមួយទៀតដល់មនុស្ស គឺព្រះអង្គប្រទានជំនួយដល់មនុស្សដំបូងដែលត្រូវនឹងគេ ប្រយោជន៍អោយពួកគេមានអំណរ និងរីកចម្រើនទាំងអស់គ្នានៅក្នុងទ្រង់ (លោកុប្បត្តិ២៖១៨-២៣)។ ជីវិតនៅក្នុងសួនច្បារអេដែន បានឆ្លុះបញ្ចាំងយ៉ាងប្រទាំងអំពីជីវិតនៅក្នុងនគរស្ថានសួគ៌ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់មនុស្សដែលព្រះអង្គបានសូនបង្កើតមកដោយផ្ទាល់៕

ដូចគ្នានេះដែរ នៅខណៈពេលដែលមនុស្សដំបូងបានសម្រាក ព្រមទាំងសោយសុខនៅក្នុងព្រះគុណ និងព្រះពររបស់ព្រះជាម្ចាស់ នៅក្នុងទីកន្លែងរបស់ព្រះអង្គនោះ (សួនច្បារអេនដែន) ពួកគេគតមានសេចក្តីអៀនខ្មាសសោះឡើយ បើទោះបីជាពួកគេនៅអាក្រាត (លោកុប្បត្តិ២៖២៥) ព្រោះគ្រប់យ៉ាងទាំងអស់គឺសុទ្ធតែល្អ ទាំងទស្សនៈវិស័យ ចិត្ត និងគំនិតរបស់ពួកគេ។ មនុស្សដំបូងគឺល្អឥតខ្ចោះ បានរស់នៅក្នុងទីកន្លែងដែលល្អឥតខ្ចោះ ហើយបានសោយសុខក្នុងព្រះពរដ៏ល្អឥតខ្ចោះ។ មនុស្សដំបូងមិនត្រឹមតែបានរស់នៅក្នុងទីកន្លែងរបស់ព្រះជាម្ចាស់តែប៉ុននោះទេ ជាងនេះទៅទៀត នៅក្នុងសួនច្បារអេដែន មនុស្សដំបូងបានរស់នៅក្នុងព្រះវត្តមានផ្ទាល់របស់ព្រះជាម្ចាស់ ហើយនៅទីនោះផងដែរ ព្រះអាទិករ និងមនុស្សបានប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ នៅក្នុងទំនាក់ទំនងដ៏ល្អឥតខ្ចោះ គ្មានការភ័យខ្លាច ឬភាពអាម៉ាសសោះឡើយ (លោកុប្បត្តិ៣៖៨)។ នៅក្នុងសួនច្បារអេដែន ទាំងទ្វេរភាគីពេញចិត្ត ព្រមទាំងមានអំណរយ៉ាងខ្លាំងក្នុងការប្រាស្រ័យទាក់ទងទៅវិញទៅមកដោយសេចក្តីស្រលាញ់ ការគោរព ផ្តល់កិត្តិយស លនិងល។ នៅក្នុងសួនច្បារអេដែន និមិត្តរបស់ព្រះជាម្ចាស់ត្រូវបានបំពេញ ហើយមនុស្សបានរស់នៅចំគោលដៅនៃជីវិតរបស់ពួកគេ៕

បន្ទាប់ពីព្រះជាម្ចាស់បានបង្កើតមនុស្សអោយដូចនឹងរូបអង្គទ្រង់ "ទ្រង់ប្រទានពរដល់គេ ហើយមានព្រះបន្ទូលថា ចូរបង្កើតកូនអោយចម្រើនជាច្រើនឡើង អោយមានពាសពេញលើផែនដីចុះ ត្រូវបង្ក្រាបលើផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតទាំងឡាយដែលកំរើកលើផែនដីផង" (លោកុប្បត្តិ១៖២៨)។ ព្រះពរនេះមានទំនាក់ទំនងដ៏ចាំបាច់បំផុតជាមួយនឹងនិមិត្តរបស់ព្រះជាម្ចាស់ក្នុងការបង្កើត ត្បិតកាលណាមនុស្សរបស់ព្រះជាម្ចាស់បានចេញទៅរស់នៅពាសពេញផែនដីនោះ សិរីល្អរបស់ព្រះជាម្ចាស់នឹងត្រូវបានសរសើរតម្កើងនៅគ្រប់ផ្នែកទាំងអស់នៃផែនដីទាំងមូលតាមរយៈមនុស្សទាំងនោះ។ "ទំហំនៃសួនច្បារអេដែននឹងកាន់តែរីកចម្រើនធំឡើងៗគ្របដណ្តប់ផ្ទៃផែនដីទាំងមូល ខណៈពេលដែលមនុស្សបានបង្កើតកូនអោយចម្រើនជាច្រើនឡើងៗពាសពេញលើផែនដី ហើយយូរៗទៅផែនដីទាំងមូលនឹងក្លាយទៅជាសួនច្បារដ៏បរិសុទ្ធ ឬទីក្រុងដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់"[9]។ រូបភាពនេះស្របទៅតាមទំនាយរបស់លោកហោរ៉ាហាបាគូកដែលបានលើកឡើងថា ផែនដីទាំងមូលនឹងពេញទៅដោយសិរីល្អរបស់ព្រះជាម្ចាស់ ដូចជាទឹកក៏នៅពេញសមុទ្រដែរ (ហាបាគូក២៖១៤)។ ព្រះពរដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សដំបូង គឺដើម្បីសិរីល្អតែមួយគត់របស់ទ្រង់៕

[9] From Eden to the New Jerusalem By T. Desmond Alexander, p23

នៅក្នុងសួនច្បារអេនដែនដដែល ព្រះជាម្ចាស់បានត្រាស់បង្គាប់អោយមនុស្សដំបូង “ធ្វើការ ហើយថែរក្សា” សួនច្បារ ឬព្រះដំណាក់របស់ព្រះជាម្ចាស់ (លោកុប្បត្តិ២៖១៥)។ តួនាទីរបស់មនុស្សដំបូងនៅក្នុងសួនច្បារអេដែន ដូចគ្នាទៅនឹងតួនាទីដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកកុលសម្ព័ន្ធលេវីអោយមើលថែរក្សារោងឧបោសថដែលជាព្រះដំណាក់របស់ទ្រង់ (ជនគណនា៣៖៧-៨ ៨៖២៦ ១៨៖៥-៦)។ មនុស្សដំបូង ក៏ដូចជាពួកលេវីផងដែរ មានតួនាទីដើម្បីមើលថែរក្សាព្រះដំណាក់របស់ព្រះជាម្ចាស់អោយបានស្ថិតស្ថេរជាបរិសុទ្ធ កុំអោយទៅជាខូចសៅហ្មងដោយសារបាប ឬអំពើរស្មូងផ្សេងៗ។ នៅក្នុងសួនច្បារអេដែន ក៏ដូចជានៅក្នុងរោងឧបោសថផងដែរ ដង្វាយដ៏ឈ្ងុយឈ្ងប់នៅលើអាសនាដែលជាទីគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ គឺការថ្វាយបង្គំ និងការលើកសរសើរតម្កើងសិរីល្អរបស់ទ្រង់។ មនុស្សដំបូង និងពួកកុលសម្ព័ន្ធលេវី ត្រូវតែធ្វើការ ថែរក្សា ហើយចាំយាមជានិច្ច ប្រយោជន៏អោយក្លិនដ៏ឈ្ងុយឈ្ងប់នៃការសរសើរតម្កើងព្រះជាម្ចាស់ដំណើរការជានិច្ច នៅក្នុងព្រះដំណាក់របស់ទ្រង់៕

នៅក្នុងសួនច្បារអេដែន រូបភាពនៃនគរស្ថានសួគ៌ត្រូវបានបើកសម្តែងដល់យើងទាំងអស់គ្នា។ ប្រវត្តិសាស្រ្តរបស់មនុស្សជាតិបានចាប់ផ្តើមនៅក្នុងរូបភាពនៃនគរស្ថានសួគ៌ តាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់។ នៅក្នុងសួនច្បារអេដែន ព្រះជាម្ចាស់គឺជាព្រះតែមួយអង្គគត់នៅក្នុងចិត្តមនុស្ស ហើយមនុស្សគឺជាមកុដនៃសិរីល្អតែមួយគត់របស់ព្រះជាម្ចាស់ ដែលជាទីសព្វព្រះហឫទ័យរបស់ទ្រង់ណាស់។ មួយវិញទៀត មនុស្សត្រូវបានបំពេញអោយបានពេញជាបរិបូរណ៍តាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ នៅក្នុងអំឡុងពេលដែលពួកគេកំពុងតែរស់នៅក្នុងសួនច្បារអេដែន ពោលគឺពេលដែលពួកគេរស់នៅដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់តែមួយអង្គគត់។ នៅក្នុងសួនច្បារអេដែន មនុស្សស្គាល់គោលដៅនៃជីវិតរបស់ខ្លួន ព្រមទាំងបានរស់នៅតាមគោលដៅមួយនោះដោយជោគជ័យ៕

## ឃ២ ចិត្តមនុស្ស

មនុស្សត្រូវបានបង្កើតមកក្នុងគោលដៅមួយ គឺដើម្បីអោយពួកគេស្រលាញ់ព្រះអម្ចាស់ដែលជាព្រះដ៏ពិតតែមួយអង្គគត់របស់ពួកគេអោយបានអស់អំពីចិត្ត អស់អំពីគំនិត ហើយអស់អំពីព្រលឹងនៃគេ (ម៉ាថាយ២២៖៣៧-៣៧ ម៉ាកុស១២៖៣០)។ នេះគឺជាការទាមទាររបស់ព្រះជាម្ចាស់ពីសំណាក់មនុស្សជាតិគ្រប់ៗរូបដែលជាស្នាព្រះហស្តរបស់ទ្រង់ផ្ទាល់ ហើយស្តង់ដានេះមិនបានផ្លាស់ប្រែឡើយ។ ព្រះជាម្ចាស់ទាមទារយកសិទ្ធិរបស់ទ្រង់ជាម្ចាស់ និងជាព្រះមហាក្សត្រ គ្រប់គ្រងលើបល្ល័ង្កចិត្តរបស់មនុស្សតែមួយអង្គគត់ ហើយការនេះអាចសម្រេចទៅបាន ដរាបណាមនុស្សបានចុះចូល និងស្តាប់បង្គាប់ព្រះជាម្ចាស់មួយរយភាគរយនៅគ្រប់កាលទេសៈទាំងអស់។ លោក ហ្វន រ៉ូបឺត បាននិយាយថា “កាតព្វកិច្ចរបស់យើង គឺត្រូវចុះចូលចំពោះព្រះអង្គដែលជាស្តេចរបស់យើង ហើយត្រូវថ្វាយសិរីរុងរឿងដែលជារបស់ព្រះអង្គទៅដល់ទ្រង់វិញ (សូមអានវិវរណៈ៤៖១១)” [10]។ ព្រះជាម្ចាស់ទាមទារគ្រប់គ្រងលើចិត្ត គំនិត និងជីវិតរបស់មនុស្សមួយរយភាគរយ៕

ព្រះជាម្ចាស់ទាមទារគ្រប់គ្រងលើចិត្ត គំនិត និងជីវិតរបស់មនុស្សមួយរយភាគរយ។

10 វិសាលភាពនៃព្រះជាម្ចាស់ និពន្ធដោយលោក ហ្វន រ៉ូបឺត ទំព័រ៣២

ការចុះចូល និងការស្តាប់បង្គាប់ដ៏ពេញលេញ ដោយអស់ពីចិត្ត មានតម្លៃ លុះត្រាតែមានសេរីភាពនៃការសម្រេចចិត្តពេញលេញដែរ ឬក៏យើងអាចនិយាយម្យ៉ាងទៀតថា ប្រសិនបើមនុស្សគ្មានជម្រើសនោះទេ ការចុះចូល និងការស្តាប់បង្គាប់ក៏គ្មានតម្លៃដែរ។ សេរីភាពនៃការសម្រេចចិត្ត គឺជាកិត្តិយស និងសបញ្ជាក់អំពីសេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅបំផុតមួយទៀត ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្ស។ ព្រះជាម្ចាស់ស្រលាញ់មនុស្សខ្លាំងដល់ម្ល៉េះ បានជាព្រះអង្គប្រោសប្រទានជម្រើសដល់មនុស្ស ប្រយោជន៍អោយសេចក្តីស្រលាញ់ដែលទាំងទ្វេរភាគីមានគឺជាសេចក្តីស្រលាញ់ដ៏ពិតប្រាកដផុសចេញពីក្រអៅដួងចិត្ត មិនមែនជាការបង្ខិតបង្ខំនោះទេ។ តាមគំនិតរបស់ខ្ញុំ "ដើមដឹងខុសត្រូវ" ដែលព្រះជាម្ចាស់បានដាក់នៅកណ្តាលសួនច្បារអេដែន គឺជាសេចក្តីរំលឹកមនុស្សដំបូងជារៀងរាល់ថ្ងៃថា ពួកគេមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្ត ពោលគឺមនុស្សអាចជ្រើសរើសបន្តរស់នៅដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់ ឬជ្រើសរើសបដិសេធន៍ព្រះជាម្ចាស់ដោយរស់នៅដើម្បីចិត្តខ្លួនឯងវិញ បើទោះបីជាការនេះមិនមែនជាគោលដៅនៃជីវិតរបស់ពួកគេយ៉ាងណាក្តី។ ថ្វីត្បិតតែ មនុស្សមានសិទ្ធិជ្រើសរើសយកផ្លូវដែលខ្លួនត្រូវដើរ ក៏ប៉ុន្តែពួកគេគ្មានសិទ្ធិជ្រើសរើសយកលទ្ធផលរបស់វានោះទេ ពោលគឺមនុស្សត្រូវតែរស់នៅជាមួយនឹងលទ្ធផលនៃការសម្រេចចិត្តរបស់ខ្លួន ដោយជៀសមិនផុត។ ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់អំពីលទ្ធផលនៃការបដិសេធន៍ទ្រង់ថា "តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវអោយឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន"(លោកុប្បត្តិ២:១៧)។ អនាគតរបស់មនុស្សដំបូង គឺអាស្រ័យលើការសម្រេចចិត្តរបស់ពួកគេរៀងរាល់ថ្ងៃ៕

ចិត្តមនុស្សសមណាស់តែបានពោរពេញទៅដោយអំណរ ព្រមទាំងអរព្រះគុណដល់ព្រះអាទិករដែលបានប្រោសប្រទានកិត្តិយស សេចក្តីស្រលាញ់ និងសព្វសារពើទាំងអស់ដល់ពួកគេ ផ្ទុយទៅវិញមនុស្សបានឆ្លើយតបដោយអាត្មានិយមបំផុតចំពោះព្រះជាម្ចាស់។ ព្រះបន្ទូលបានបើកសម្តែងយ៉ាងប្រទាំ្យតអំពីការដែលមនុស្សបានបែរខ្នងដាក់ព្រះជាម្ចាស់ថា "កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មមគួរនឹងចង់បាន ដើម្បីអោយបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកអោយដល់ប្តីដែរ គាត់ក៏បរិភោគតាម"(លោកុប្បត្តិ៣:៦)។ មនុស្សដំបូងបានបដិសេធន៍មិនព្រមទទួលស្គាល់ព្រះជាម្ចាស់ជាស្តេចលើបល្ល័ង្កចិត្តរបស់ពួកគេទៀតទេ តែបែរជាត្រឡប់ទៅចុះចូល ស្តាប់បង្គាប់ ព្រមទាំងធ្វើតាមចិត្តខ្លួនឯងទៅវិញ ដ្បិតចិត្តមនុស្សលោភលន់ មិនស្កប់ស្កល់នឹងព្រះពរទាំងឡាយដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេ ហើយលើសពីនេះទៅទៀត គឺមនុស្សចង់បានដូចជាព្រះដ៏ធំឧត្តុងឧត្តម។ ចិត្តមនុស្សចង់អោយកេរ្តិ៍ឈ្មោះរបស់ខ្លួនផ្ទាល់ត្រូវបានលើកសរសើរតម្កើងដូចជាព្រះកិត្តិនាមដ៏ខ្ពង់ខ្ពស់របស់ព្រះដ៏ជាព្រះដែរ។ មនុស្សបានដើរប្រាស់គោលដៅនៃជីវិតដែលព្រះជាម្ចាស់បានកំណត់ទុកអោយ ដោយការរស់នៅដើម្បីជាសិរីល្អដល់ខ្លួនឯង ជាជាងរស់នៅដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់ ហើយការនេះបានជំរុញអោយមនុស្សប្រឆាំងនឹងគោលដៅដ៏ថ្លៃថ្លាតែមួយគត់របស់ព្រះជាម្ចាស់ក្នុងការបង្កើត។ មនុស្សដំបូងបានបរាជ័យក្នុងការចុះចូល និងស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយពួកគេមិនបានស្រលាញ់ព្រះអម្ចាស់ដែលជាព្រះដ៏ពិតតែមួយគត់របស់ពួកគេអោយអស់អំពីចិត្ត អស់អំពីគំនិត ហើយអស់អំពីព្រលឹងនៃពួកគេ ដូចការដែលពួកគេស្រលាញ់ខ្លួនឯងនោះឡើយ។ នេះជាអំពើបាប។ ការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ សបញ្ជាក់យ៉ាងច្បាស់ថា មនុស្សជាអ្នកគ្រប់គ្រងលើបល្ល័ង្កចិត្តរបស់ខ្លួនឯងផ្ទាល់ មិនមែនព្រះជាម្ចាស់ទេ។ មនុស្សសម្រេចចិត្ត ដើរតាមចិត្តអាត្មានិយមរបស់ខ្លួនឯង ជំនួសអោយការដើរតាមត្រីវិស័យដែល

ព្រះជាម្ចាស់បានរៀបចំទុកសម្រាប់ជីវិតរបស់គេ។ ឯផលដែលហុចអោយ មនុស្សមិនបានរស់នៅតាមគោលដៅនៃជីវិតឡើយ។ មនុស្សកំពុងតែវង្វេងនៅក្រៅសួនច្បារអេដែន៕

ឃ៣ បណ្តាសា

ព្រះគម្ពីរបរិសុទ្ធបានបញ្ជាក់យ៉ាងប្រទាំងតថា "....... ត្រូវបណ្តាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្តីដែលកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ ដើម្បីនឹងប្រព្រឹត្តិតាម" (កាឡាទី៣៖១០)។ មនុស្សដំបូងបានបដិសេធន៍មិនធ្វើតាមព្រះជាម្ចាស់ ហើយបណ្តាសាគឺជាលទ្ធផលនៃការសម្រេចចិត្តរបស់ពួកគេ។ ជំពូកទី៣នៃព្រះគម្ពីរលោកុប្បត្តិ គឺជាទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតបំផុតមួយរបស់មនុស្សជាតិ ដ្បិតអីនៅទីនោះ ព្រះជាម្ចាស់បានដាក់បណ្តាសាលើគ្រប់ស្នាព្រះហស្តដ៏ល្អឥតខ្ចោះទាំងអស់ដែលព្រះអង្គបានបង្កើតមកដោយផ្ទាល់ ដោយព្រោះតែការមិនស្តាប់បង្គាប់របស់មនុស្សដំបូង។ "ដោយសារបាបរបស់មនុស្ស ពិភពដ៏ឥតខ្ចោះរបស់ព្រះក៏ត្រឡប់ជាខូចអស់ ទាំងខាងសាច់ឈាម និងវិញ្ញាណ" [11]។ អំពើបាបបានបង្ខូចគ្រប់ទាំងអស់។ ក្នុងនាមជាព្រះអាទិករដែលស្រលាញ់ស្នាព្រះហស្តរបស់ទ្រង់ខ្លាំងដល់ម្ល៉េះ គួរតែពិបាកបំផុតសម្រាប់ទ្រង់ក្នុងការដាក់បណ្តាសាបំផ្លាញគ្រប់ទាំងអស់។ បើទោះបីជាយ៉ាងណាក៏ដោយ "ទ្រង់ក៏មានព្រះបន្ទូលទៅស្ត្រីវិញថា អញនឹងចម្រើនអោយឯងមានសេចក្តីព្រួយលំបាកជាច្រើនឡើង ក្នុងវេលាដែលឯងមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯប្តី ហើយប្តីនឹងត្រួតត្រាលើឯង រួចទ្រង់ក៏មានព្រះបន្ទូលទៅអ័ដាមថា ដោយព្រោះឯងបានស្តាប់តាមប្រពន្ធឯង ហើយស៊ីផ្លែឈើនោះដែលអញបានហាមមិនអោយស៊ីឡើយ នោះដីត្រូវបណ្តាសាដោយព្រោះឯង  ឯងត្រូវរកស៊ីពីដីដោយនឿយហត់អស់មួយជីវិត ដីនឹងដុះជាបន្លា ហើយអញ្ចាញអោយឯង ឯងត្រូវស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបឯងត្រឡប់ទៅជាដីវិញ ពីព្រោះអញបានយកឯងពីដីមក ត្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ"(លោកុប្បត្តិ៣៖១៦-១៩)។ ដោយសារតែអំពើបាប ព្រះពរគ្រប់បែបយ៉ាងទាំងអស់ត្រូវបានជំនួសដោយបណ្តាសា។ ការសម្រេចចិត្តរបស់មនុស្សដំបូងប្រៀបបានដូចជាការចោលសាច់ស្រវាំចាប់យកឆ្អឹងវិញ ដោយការបែរខ្នងដាក់ព្រះជាម្ចាស់ដែលជាប្រភពនៃព្រះពរ ហើយដើរតម្រង់ឆ្ពោះទៅរកបណ្តាសារជាជំនួស។ មនុស្សបានសម្រេចចិត្តរស់នៅផ្ទុយស្រលះពីគោលដៅនៃជីវិតដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់ពួកគេ ហើយជាលទ្ធផលមនុស្សក៏មិនអាចសោយសុខនៅក្នុងព្រះពរ និងសេចក្តីសុខសាន្តដ៏ពិតប្រាកដដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់ពួកគេដែរ។ ផលផ្លែនៃការសម្រេចចិត្តរបស់មនុស្ស គឺសេចក្តីស្រលាញ់ជំនួសដោយការផិតក្បត់ ភាពស្មោះត្រង់ជំនួសដោយកលក្បិច ភាពសុខសាន្តជំនួសដោយទឹកភ្នែក ការជួបជុំជំនួសដោយភាពនិរាសព្រាត់ប្រាស់ ជីវិតជំនួសដោយសេចក្តីស្លាប់ ព្រះពរជំនួសដោយបណ្តាសា និងជាចុងក្រោយ "ល្អ" ជាទីគាប់ព្រះឫទ័យរបស់ព្រះជាម្ចាស់ត្រូវបានជំនួសដោយ "អាក្រក់ គួរអោយស្អប់ខ្ពើម" នៅចំពោះទ្រង់វិញ លនិងល ។ ស្របពេលជាមួយគ្នានេះផងដែរ "ពួកគេលែងរស់នៅថ្វាយព្រះជាម្ចាស់ ហើយក៏លែងរស់នៅដើម្បីគ្នានឹងគ្នាទៀតដែរ ប៉ុន្តែពួកគេគ្រាន់តែរស់នៅដើម្បីខ្លួនឯងតែប៉ុននោះ។ ពួកគេម្នាក់ៗបានក្លាយជាព្រះរបស់ពួកគេ ពេលនោះពួកគេមានតែការទាស់ទែង

---

[11] វិសាលភាពនៃព្រះជាម្ចាស់ និពន្ធដោយលោក ហ្វន រ៉ូប៊ីត ទំព័រ៣១

និងសម្អប់ ឬអាចនិយាយម្យ៉ាងទៀតថា មានតែបាបជំនួសអោយក្តីសុខសាន្ត ភាពសុខដុម ក្តីស្រលាញ់ និងឯកភាពនោះ" [12]។ ការដើរប្រាស់ចាកពីត្រីវិស័យនៃជីវិត ក៏ដូចជាការរស់នៅដោយខុសពីគោលដៅនៃជីវិតផងដែរ បណ្តាលអោយមនុស្សដែលធ្លាប់តែជាមកុដនៃសិរីល្អរបស់ព្រះជាម្ចាស់ ត្រឡប់ទៅជាទទេរក្នុងផែនដីដ៏ធំល្វឹងល្វើយ ហើយគ្មានទិសដៅច្បាស់លាស់ ប្រៀបបានដូចជាកូនចៀមដែលវង្វេងតែលតោលក្នុងចំណោមហ្វូងចចកដ៏សែនគ្រោះថ្នាក់ ព្រោះគ្មានអ្នកគង្វាលដើម្បីមើលថែរក្សា ការពារ និងដឹកនាំផ្លូវពួកគេដោយសេចក្តីស្រលាញ់ដូចមុន។ ការសម្រេចចិត្តដ៏ល្ងង់ខ្លៅបំផុតរបស់មនុស្ស បានឆក់យកការល្អ និងព្រះពរគ្រប់យ៉ាងទាំងអស់ចេញពីពួកគេ ដោយរួមបញ្ចូលទាំងគោលដៅនៃជីវិតផងដែរ។ នៅក្រៅសួនច្បារអេដែន មនុស្សបានបាត់បង់គោលដៅនៃជីវិតរបស់ខ្លួន៕

មួយវិញទៀត គប្បីយើងត្រូវដឹងផងដែរថា អំពើបាបមិនត្រឹមតែបង្ខូចទំនាក់ទំនងរវាងព្រះ និងមនុស្សនោះទេ លើសពីនេះទៅទៀត អំពើបាបបានបង្ខូចគ្រប់ទំនាក់ទំនងទាំងអស់។ ដោយព្រោះអំពើបាប មនុស្សដែលព្រះជាម្ចាស់ស្រលាញ់ដល់ម្ល៉េះ បានចាប់ផ្តើមភ័យខ្លាច ហើយរត់ពួនពីទ្រង់ដែលជាម្ចាស់ ដែលធ្លាប់តែផ្តល់ជំរកដ៏សែនកក់ក្តៅបំផុតដល់ពួកគេ ត្បិតទំនាក់ទំនងដ៏ល្អឥតខ្ចោះដែលមនុស្សធ្លាប់មានជាមួយនឹងព្រះជាម្ចាស់ត្រូវបានបង្ខូចហើយ (លោកុប្បត្តិ៣៖១០)។ អំពើបាបបានរាំងមនុស្សមិនអោយចូលទៅប្រកប និងសោយសុខក្នុងព្រះពរបស់ព្រះជាម្ចាស់(អេសាយ៥៩៖២)។ ស្របពេលជាមួយគ្នានេះផងដែរ ដោយព្រោះអំពើបាប ប្តី-ប្រពន្ធដែលចាប់ផ្តើមដោយសេចក្តីស្រលាញ់ដ៏បរិសុទ្ធល្អឥតខ្ចោះ បែរជាប្រួលប្រែ អាត្មានិយម គិតរកតែសេចក្តីសុខ និងផលប្រយោជន៍ផ្ទាល់ខ្លួន (លោកុប្បត្តិ៣៖១២) បងប្អូនសាច់ឈាមតែមួយបែរជាច្រណែនគ្នា ស្អប់គ្នា ហើយហែកហួរគ្នាស៊ី (លោកុប្បត្តិ៤) កូនមិនគប្បីចំពោះឪពុកម្តាយ (លោកុប្បត្តិ៩៖២២) រីឯឪពុកម្តាយដាក់បណ្តាសាកូន (លោកុប្បត្តិ៩៖២៤-២៥) ជាហូរហែរហូតដល់ភ្លើងសង្គ្រាមឆាបឆេះស្ទើតែគ្រប់សម័យកាលទាំងអស់រវាងជាតិសាសន៍មួយ និងជាតិសាសន៍មួយទៀត ព្រោះអំពើបាបគឺជាគ្រឹះនៃទំនាក់ទំនង។ លើសពីនេះទៅទៀត មនុស្សដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សដំបូងដើម្បីជួយស្អាងគ្នាឡើងនៅក្នុងទ្រង់ និងជួយនាំសិរីល្អរបស់ទ្រង់ទៅកាន់គ្រប់ផ្នែកទាំងអស់នៃផែនដីទាំងមូល បែរជាបបួលគ្នា ហើយរួមគំនិតគ្នា ទាស់ប្រឆាំងជាមួយនឹងទ្រង់ដោយផ្ទាល់ទៅវិញ (លោកុប្បត្តិ៣៖៦ ១១៖១-៦)។ ដោយព្រោះអំពើបាប ទំនាក់ទំនងរបស់មនុស្សលែងជាការលើកសរសើរតម្កើងសិរីល្អរបស់ព្រះជាម្ចាស់ទៀតហើយ តែជាការបង្អាប់បន្ថោកដល់ព្រះកិត្តិនាមទ្រង់ទៅវិញ (អេសេគាល៣៦៖២០)៕

ដូចដែលព្រះជាម្ចាស់បានព្រមានមនុស្សដំបូងទុកជាមុនរួចមកហើយថា ការដើរចេញពីព្រះជាម្ចាស់ ស្មើនឹងការដើរតម្រង់ទៅរកសេចក្តីស្លាប់ សេចក្តីវិនាស (លោកុប្បត្តិ២៖១៧)។ ដោយព្រោះតែការសម្រេចចិត្តរបស់មនុស្សដំបូង ពួកគេមិនត្រឹមតែបាត់បង់អភ័យឯកសិទ្ធិក្នុងការរស់នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់នោះទេ ជាងនេះទៅទៀត គឺមនុស្សត្រូវតែស្លាប់ទាំងខាងសាច់ឈាម និងខាងព្រលឹងវិញ្ញាណ (លោកុប្បត្តិ៣៖២២-២៤)។ រូបកាយរបស់មនុស្សនឹងត្រូវស្លាប់ ហើយក្លាយទៅជាធូលីដី រីឯព្រលឹងវិញ្ញាណរបស់ពួកគេវិញនឹងត្រូវជាប់ឃុំឃាំងនៅក្នុងបឹងភ្លើងដែលឆេះអស់កល្បជានិច្ច ដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់អស់អ្នកដែលបដិសេធន៍ទ្រង់ រួមជាមួយនឹងអារក្ស ព្រមទាំងពួកទេវតា

[12] ផ្លូវទៅកាន់ភ្នំកាល់វ៉ារី និពន្ធដោយលោក រ៉យ ហេសៀន ទំព័រ៦២

របស់វាផងដែរ (ម៉ាថាយ២៥៖៤១)។ នៅទីនោះ គ្មានទេព្រះពរ សេចក្ដីសុខសាន្ត អំណរ លនិងល តែពេញដោយទុក្ខវេទនា អស់កល្បជានិច្ច។ ស្របពេលជាមួយគ្នានេះផងដែរ លទ្ធផលនៃការសម្រេចចិត្តរបស់មនុស្សដំបូង គឺការរស់នៅក្រៅសួនច្បារអេដែន ព្រាត់ប្រាស់ចេញពីព្រះជាម្ចាស់ដែលជាប្រភពនៃព្រះពរ រស់នៅយ៉ាងវេទនាទាំងផ្លូវចិត្ត ផ្លូវអារម្មណ៍ និងផ្លូវកាយ ដែលពួកគេមិនធ្លាប់បានជួបប្រទះសោះឡើយពីមុនមក។ លើសពីនេះទៅទៀត ដោយព្រោះអំពើបាប មនុស្សដំបូងលែងជាមនុស្សរបស់ព្រះជាម្ចាស់ទៀតហើយ ចំណែកឯព្រះជាម្ចាស់វិញក៏មិនព្រមធ្វើជាព្រះរបស់ពួកគេទៀតដែរ (ហូសេ១៖៩)។ មនុស្សត្រូវតែរស់នៅជាមួយនឹងលទ្ធផលមួយនេះ ដោយគ្មានសិទ្ធិបដិសេធន៍មិនទទួលយកឡើយ៕

ជាចុងបញ្ចប់ មនុស្សដំបូងបានសម្រេចចិត្តដោះដូរសិរីល្អដ៏កាត់ថ្លៃពុំបានរបស់ព្រះជាម្ចាស់ ទៅយករបស់ដែលតែងតែពុករលួយដែលជាទីគាប់ភ្នែករបស់ពួកគេទៅវិញ។ ទាក់ទងទៅនឹងការនេះផងដែរ លោកហោរ៉ាយេរេមា បានពាំនាំយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកបញ្ជាក់ថា “ .... តែរាស្ត្ររបស់អញបានដូរព្រះដ៏ជាសិរីល្អរបស់ខ្លួន អោយបានតែរបស់ដែលឥតមានប្រយោជន៍វិញ...... បានទាំងបោះបង់ចោលអញដែលជាក្បាលទឹករស់ ហើយបានដាប់ធ្វើអាងវិញ ជាអាងប្រះបែកទាំងទុកទឹកមិនបានផង” (យេរេមា២៖១១-១៣)។ ឆ្លើយតបទៅនឹងការសម្រេចចិត្តមួយនេះ លោក ចេ. ឌី. ក្រោលី បានសរសេរថា “នេះគឺជាការសម្រេចចិត្តដ៏ល្ងង់ខ្លៅបំផុត នៅក្នុងប្រវិត្តិសាស្ត្រនៃពិភពលោក” [13]។ ជាជាងរស់នៅដើម្បីព្រះជាម្ចាស់ដែលជាត្រីវិស័យនៃជីវិតដ៏ពិតប្រាកដ មនុស្សបានសម្រេចចិត្តរស់នៅដោយអាត្មានិយមដើម្បីខ្លួនឯងទៅវិញ ពោលគឺមនុស្សកំពុងតែវង្វេងចេញពីត្រីវិស័យនៃជីវិត។ មនុស្សមិនបានរស់នៅចំគោលដៅនៃជីវិតឡើយ៕

---

[13] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. ក្រោលី ទំព័រ៣៩

## ២ វង្វេង

មនុស្សគ្រប់ជាតិសាសន៍ទាំងអស់បានកើតមកជាហូរហែរពីសម័យកាលមួយទៅសម័យកាលមួយទៀត ដោយចាប់ផ្តើមពីមនុស្សដំបូងគឺអាដាំ។ បើទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការធ្លាក់ចុះនៃអំពើបាប មនុស្សទាំងឡាយមិនបានចាប់ផ្តើមពីក្រដាស ស ល្អតតខ្មោះដូចអាដាំធ្លាប់មាននោះទេ ពោលគឺមនុស្សគ្រប់ជាតិសាសន៍ទាំងអស់សុទ្ធតែកើតមកក្នុងអំពើបាប ដោយជាប់មានបាបជាមរតក។ អំពើបាបរបស់អាដាំដែលជាតំណាងរបស់មនុស្សជាតិទាំងឡាយនៅចំពោះព្រះជាម្ចាស់ត្រូវបានរាប់ថាជាអំពើបាបរបស់យើងទាំងអស់គ្នាផង។ ម្ចាលមនុស្សទាំងឡាយជាប់មានបាប ហើយមិនបរិសុទ្ធនៅចំពោះព្រះដ៏បរិសុទ្ធ ចាប់តាំងពីពេលដែលពួកគេសម្រាលចេញពីផ្ទៃម្តាយមកម៉្លេះ។ យើងអាចនិយាយម្យ៉ាងទៀតថា មនុស្សបានកើតមកដោយដាច់ចេញពីព្រះដែលជាប្រភពនៃព្រះពរ និងជាជីវិត។ គ្រាប់ពូជនៃអំពើបាបបានដាក់ដាំដុះនៅក្នុងចិត្តរបស់មនុស្សចាប់តាំងពីពេលនៅក្នុងផ្ទៃម្តាយមកម៉្លេះ ហើយផលផ្លែដ៏គ្រោះថ្នាក់របស់វាបានរីកចម្រើនដោយមិនអាចគ្រប់គ្រងបាន ប្រៀបបានដូចជាដើមបញ្ញើរក្អែកដែលត្រូវតែកាប់កាត់ចោល ឬវានឹងបំផ្លាញដើមឈើដ៏ធំមួយជាក់ជាមិនខាន៕

ខ្ញុំចាំបានថា កាលពីប៉ុន្មានឆ្នាំមុន គ្រូពេទ្យបានណែនាំអោយខ្ញុំប្រុងប្រយត្ន័ចំពោះការលេងបាល់ទាត់ ព្រោះជង្គង់របស់ខ្ញុំធ្លាប់ជួបគ្រោះថ្នាក់ ហើយតលូវវាខូច និងខ្សោយមិនអាចទ្រាំទ្រលេងបានដូចមុនទេ។ គាត់ក៏បានបន្ថែមទៀតថា យល់ល្អគួរតែឈប់លេងបាល់ទាត់ ហើយហែលទឹកជំនួសវិញដើម្បីសុខភាព។ បើទោះបីជាយ៉ាងណាក៏ដោយ ពេលនោះខ្ញុំអាចដើរបាន ហើយរត់បានលឿនទៀតផង ដូច្នោះខ្ញុំនៅតែបន្តលេងបាល់ទាត់ដូចមនុស្សអាយុ២០ឆ្នាំដដែល ដោយគ្មានការប្រុងប្រយត្ន័សោះឡើយ។ អ្នកប្រហែលជាអាចស្មានដឹងថានឹងមានអ្វីកើតឡើង? នៅល្ងាយមួយ ពេលកំពុងតែចាប់ផ្តើមលេងបាល់បានប្រហែលជាប្រាំនាទី ខ្ញុំរត់បណ្តើរបាល់តែម្នាក់ឯង ខ្ញុំក៏ដួល! ហើយជង្គង់ស្តាំរបស់ខ្ញុំឈឺចាប់យ៉ាងខ្លាំងលើសពីការទ្រាំ ដែលខ្ញុំមិនដែលជួបប្រទះសោះពីមុនមក។ បន្ទាប់ពីនោះមក ខ្ញុំត្រូវនៅមួយកន្លែង ឬប្រើឈើច្រត់ដោយការឈឺចាប់ ពិបាក ព្រមទាំងត្រូវតែធ្វើការវះកាត់ជង្គង់ទៀតផង។ ហេតុអ្វីបានជាខ្ញុំនៅតែមានះលេងបាល់ទាត់ ទាំងដឹងថាជង្គង់របស់ខ្ញុំកំពុងតែខ្សោយ ហើយសូម្បីតែគ្រូពេទ្យក៏បានព្រមានខ្ញុំទុកជាមុនដែរ? ព្រោះខ្ញុំអត់យល់សោះថា តើស្ថានភាពជង្គង់របស់ខ្ញុំពិតជាធ្ងន់ធ្ងរកំរិតណា? ជាជាងរករបៀបថែរក្សា ការពារជង្គង់របស់ខ្ញុំ ខ្ញុំបែរជាបំផ្លាញវាទៅវិញ ព្រោះខ្ញុំគិតខុសថាវាគ្មានបញ្ហាធ្ងន់ធ្ងរឡើយ។ បញ្ហារបស់ខ្ញុំ បណ្តាលមកពីខ្ញុំមើលស្រាលនូវបញ្ហាដ៏ធ្ងន់ធ្ងររបស់ជង្គង់ខ្ញុំ។ មនុស្សនៅតែបន្តធ្វើរឿងមិនត្រឹមត្រូវ ខុសឆ្គង និងមិនល្អដដែល ប្រសិនបើគេមិនយល់ និងមិនជឿអំពីលទ្ធផលដ៏ធ្ងន់ធ្ងររបស់វា បើទោះបីជាមានគេរំលឹកដាស់តឿនយ៉ាងណាក៏ដោយ ដូចជា ការពិសាបារី ស្រា ការបោះបង់ចោលការសិក្សា ការប្រើថ្នាំញៀន លនិងល ជាដើម រហូតដល់ពេលមួយដែលគេនឹងស្តាយក្រោយ។ ក្នុងន័យដូចគ្នានេះផងដែរ មនុស្សនឹងនៅតែព្រងើយកន្តើយដដែលចំពោះអំពើបាបរបស់ខ្លួន ប្រសិនបើគេមិនយល់សោះថា តើស្ថានភាពនៃអំពើបាបរបស់គេធ្ងន់ធ្ងរកំរិតណា? បញ្ហារបស់មនុស្ស បណ្តាលមកពីគេមើលស្រាលនូវបញ្ហាដ៏ធ្ងន់ធ្ងររបស់អំពើបាប។ មនុស្សខិតខំស្វះស្វែងរកព្រះជាម្ចាស់ ដរាបណាគេជឿជាក់ថា ទ្រង់ជាសេចក្តីសង្ឃឹមតែមួយគត់សម្រាប់ដំណោះស្រាយអំពើបាបរបស់គេ៕

ពេលខ្លះ មនុស្សបានរស់នៅដោយត្រេកត្រអាលក្នុងអំពើបាបទាំងមិនដឹងសោះថា នោះគឺជាអំពើបាប។ ម្យ៉ាងទៀត រវាងជាតិសាសន៍មួយ ទៅជាតិសាសន៍មួយទៀត អំពើបាបមានទម្ងន់ និងមានរូបភាពខុសៗគ្នា។ ពេលខ្លះ អំពើបាបនៅក្នុងវប្បធម៌ខ្មែរ មិនមែនជាអំពើបាបនៅក្នុងវប្បធម៌ដ៏ទៃផ្សេងទៀតឡើយ។ ដូចគ្នានេះដែរ ពេលខ្លះអំពើបាបមួយ មានទម្ងន់ទោសខុសគ្នារវាងវប្បធម៌ខ្មែរ និងវប្បធម៌ដទៃផ្សេងទៀត។ ដូច្នោះ ជាការចាំបាច់ណាស់សម្រាប់មនុស្សទាំងឡាយក្នុងការស្គាល់អំពើបាប និងទម្ងន់ទោសរបស់វាតាមទស្សនះរបស់ព្រះដ៏បរិសុទ្ធ ព្រោះព្រះជាម្ចាស់នឹងកាត់ទោសបាបតាមស្តង់ដាររបស់ទ្រង់ផ្ទាល់ មិនមែនតាមស្តង់ដាររបស់ជនជាតិណាមួយឡើយ៕

## ក អំពើបាប

ធម្មជាតិគ្រប់ទីកន្លែងទាំងអស់នៃផែនដីទាំងមូលបានដិតដានជាប់ទៅដោយសិរីល្អ និងឧត្តមភាពដ៏ឧត្តុងឧត្តមបំផុតរបស់ព្រះជាម្ចាស់ (ទំនុកតម្កើង១៩)។ បើដូច្នោះ វាគឺជាការដ៏ល្ងង់ខ្លៅបំផុតមួយដែលគិតថា លើលោកនេះគ្មានព្រះដែលជាម្ចាស់ និងជាអ្នកបង្កើតសព្វសារពើទាំងអស់ (ទំនុកតម្កើង១៤៖១)។ ភស្តុតាងនៃព្រះវត្តមានរបស់ព្រះដ៏អស្ចារ្យត្រូវបានបើកសម្តែងយ៉ាងប្រទៀតតាមរយៈធម្មជាតិទាំងឡាយដែលជាស្នាព្រះហស្តរបស់ទ្រង់តែមួយអង្គគត់ ដូចដែលលោកសាវ័កប៉ុលបានលើកឡើងថា “... ការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសម្តែងមកក្នុងពួកគេហើយ ដោយព្រោះទ្រង់សម្តែងការនោះអោយគេឃើញជាក់ ដ្បិតអ្វីៗរបស់ទ្រង់ដែលរកមើលមិនឃើញតាំងពីកំណើតលោកិយ៍មក ទោះទាំងព្រះចេស្តាដ៏នៅអស់កល្បជានិច្ច និងនិស្ស័យជាព្រះរបស់ទ្រង់នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើតមក ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានតម្កើងទ្រង់ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេដែលឥតយោបល់ក៏បានត្រឡប់ជាងងឹតទៅ គេអួតខ្លួនថាមានប្រាជ្ញាបានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ គឺគេបំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច អោយទៅជារូបមើលទៅដូចជាមនុស្សដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើង៤ និងសត្វលូនវារដែរ” (រ៉ូម១៖១៩-២៣)។ មនុស្សបានទាញយកផលប្រយោជន៍(ព្រះពរ)គ្រប់បែបយ៉ាងទាំងអស់ចេញពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ក៏ប៉ុន្តែមនុស្សមិនបានថ្វាយបង្គំ និងលើកសរសើរតម្កើងសិរីល្អរបស់ព្រះជាម្ចាស់អោយបានសាកសមនឹងព្រះកិត្តិនាមដ៏ខ្ពង់ខ្ពស់របស់ទ្រង់ឡើយ ផ្ទុយទៅវិញ មនុស្សបានយកសិរីល្អដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ថ្វាយដល់វិញ្ញាណអាក្រក់ដែលជាសត្រូវរបស់ទ្រង់។ ក្នុងពេលជាមួយគ្នានេះផងដែរ មនុស្សបានវង្វេងទៅថ្វាយបង្គំស្នាព្រះហស្តសព្វសារពើទាំងអស់ ដោយបដិសេធន៍ព្រះអាទិករដែលបានបង្កើតសព្វសារពើទាំងអស់នោះ។ មនុស្សមិនបានចាត់ទុកព្រះជាម្ចាស់ ជាយុទ្ធការនៃជីវិត ឬជាស្តេចសោយរាជ្យក្នុងបល្ល័ង្កចិត្តរបស់គេឡើង ផ្ទុយទៅវិញ ភាពអាត្មានិយមបានជំរុញអោយមនុស្សលើកតម្កើងខ្លួនឯងអោយអង្គុយលើបល្ល័ង្កចិត្តរបស់ខ្លួន។ ឯផលដែលហុចអោយ មនុស្សបានរស់នៅដើម្បីខ្លួនឯង ជាជាងដើម្បីព្រះជាម្ចាស់ដែលជាម្ចាស់ និងជាអ្នកមានគុណរបស់ពួកគេ។ មនុស្សដែលបានបង្កើតមកដើម្បីសិរីល្អរបស់ព្រះជាម្ចាស់ បែរជាលួចយកសិរីល្អដ៏អស្ចារ្យ

> ជីវិតដែលផ្ទុយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺជាអំពើបាប។

កាត់ថ្លៃពុំបាននេះសម្រាប់ខ្លួនឯងទៅវិញ។ ដូចគ្នានេះដែរ ព្រះជាម្ចាស់បានបង្កើតមនុស្សមកអោយដូចជារូបអង្គទ្រង់ដើម្បីទ្រង់ ផ្ទុយទៅវិញ មនុស្សបែរជាបង្កើតព្រះអោយដូចជារូបគេផ្ទាល់ និងដើម្បីគេទៅវិញ។ មនុស្សបានប្រព្រឹត្តិផ្ទុយពីនិមិត្តនៃការបង្កើតរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ថា ការបដិសេធន៍ព្រះជាម្ចាស់គឺជាអំពើបាប។ ការមិនព្រមថ្វាយបង្គំ និងថ្វាយសិរីល្អដល់ព្រះជាម្ចាស់គឺជាអំពើបាប។ ការថ្វាយបង្គំអ្វីផ្សេងក្រៅពីព្រះជាម្ចាស់គឺជាអំពើបាប។ ជីវិតដែលផ្ទុយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺជាអំពើបាប៕

ឧត្តមភាពៈ កេរ្តិ៍ឈ្មោះ កិត្តិយស អំណាច ភាពថ្កុំថ្កើង លនិងល ប្រៀបបានដូចជាផ្លែឈើដ៏ជាទីគាប់ភ្នែករបស់មនុស្សជាតិទាំងពួង ចាប់តាំងតែពីដើមដំបូងមកម្ល៉េះ។ ដោយឡែក ការលើកតម្កើងខ្លួនឯង ដោយបដិសេធន៍ឧត្តមភាពរបស់ព្រះជាម្ចាស់ គឺជាគ្រឹះនៃអំពើបាប។ ជាក់ស្តែង ចូរយើងក្រឡេកមកមើលស្នាព្រះហស្តដ៏វិសេសវិសាលបំផុតមួយរបស់ព្រះជាម្ចាស់ ដែលក្រោយមកបានត្រឡប់ប្រែក្លាយទៅជាសត្រូវដ៏ធំបំផុតមួយចំពោះនគរព្រះវិញ។ លោកហោរ៉ាអេសេគាលបាននិយាយថា អារក្សសាតាំងគឺជាចេរូប៊ីនដែលព្រះជាម្ចាស់បានចាក់ប្រេងជ្រើសតាំងឡើងអោយបានខ្ពង់ខ្ពស់ និងធំជាងបណ្តាទេវតាផ្សេងៗទាំងអស់នៅចំពោះព្រះជាម្ចាស់ (អេសេគាល២៨៖១១-១៥)។ ដោយឡែក ព្រះគម្ពីរបរិសុទ្ធក៏បានចង្អុលបង្ហាញយ៉ាងច្បាស់ផងដែរថា ចេរូប៊ីនអង្គនោះគឺជាទេវតាដែលពោរពេញទៅដោយសេចក្តីអំនួត ភាពអាត្មានិយម សេចក្តីលោភលន់ លនិងល។ ទេវតាដែលព្រះជាម្ចាស់បានលើកតម្កើងអង្គនោះ បែរជាមានចិត្តចង់លើកតម្កើងខ្លួនឯងអោយបានខ្ពង់ខ្ពស់ដូចជាព្រះដ៏ខ្ពង់ខ្ពស់បំផុតទៅវិញ (អេសាយ១៤៖១៣)។ ទេវតាអង្គនោះមិនបានដឹងគុណចំពោះព្រះពរ និងព្រះគុណដ៏ជ្រាលជ្រៅដែលព្រះជាម្ចាស់បានប្រោសប្រទានដល់រូបគេនោះទេ ផ្ទុយទៅវិញ គេបែរជាវង្វេងរាប់ខ្លួនស្មើជាមួយនឹងព្រះដ៏ធំឧត្តម ហើយប្រដែងយកឧត្តមភាពរបស់ទ្រង់ទៅវិញ ដោយគេមិនសមនឹងទទួលបានអ្វីសោះឡើយ។ ដូចគ្នានេះដែរ មនុស្សដំបូងដែលព្រះជាម្ចាស់បានបង្កើតមកអោយដូចជារូបអង្គទ្រង់ ថែមទាំងបំពាក់មកុដកិត្តិយសដ៏ថ្លាថ្លៃដល់ពួកគេអោយបានខ្ពង់ខ្ពស់លើសអស់ទាំងស្នាព្រះហស្តដ៏ទៃផ្សេងៗទៀត បែរជាវង្វេង ដោយបដិសេធន៍ឧត្តភាពរបស់ព្រះជាម្ចាស់ ព្រោះចិត្តចង់បានដូចជាព្រះ (លោកុប្បត្តិ៣៖៦)។ ពួកគេមិនចង់រស់នៅដើម្បីព្រះជាម្ចាស់ទៀតទេ ហើយពួកគេចង់រស់នៅដើម្បីឧត្តមភាពរបស់ខ្លួនឯងវិញ។ មនុស្សដំបូងចង់ឃើញកេរ្តិ៍ឈ្មោះរបស់ខ្លួនត្រូវបានទទួលស្គាល់ និងលើកសរសើរតម្កើង ដោយបដិសេធន៍មិនព្រមលើកតម្កើងព្រះកិត្តិនាមរបស់ព្រះជាម្ចាស់ឡើង។ អាដាំនិងប្រពន្ធរបស់គាត់បានផ្តាច់ខ្លួនចេញពីព្រះជាម្ចាស់ ដើម្បីកសាងឧត្តមភាពសម្រាប់ខ្លួនឯង ដោយចាប់ផ្តើមពីការបដិសេធន៍មិនព្រមស្តាប់បង្គាប់ព្រះជាម្ចាស់។ ការលើកតម្កើងខ្លួនឯងដោយបដិសេធន៍ព្រះជាម្ចាស់ ក៏ដូចជាការមិនព្រមទទួលស្គាល់ឧត្តមភាពរបស់ព្រះជាម្ចាស់ផងដែរ គឺជាអំពើបាប៕

ស្តេចនៃបល្លង្ក៍ចិត្តៈ ក្នុងនាមជាអ្នកអាន យើងទទួលស្គាល់ថា ការសម្រេចចិត្តរបស់ទេវតាចេរ៉ូប៊ីន និងមនុស្សដំបូងខាងលើគឺជាការសម្រេចចិត្តដោយអាត្មានិយម រមិលគុណ និងឆោតល្ងង់បំផុតមួយ។ ថ្វីបើយ៉ាងដូច្នោះក្តី គប្បីយើងត្រូវដឹងផងដែរថា នេះគឺជាលំអាននៃការសម្រេចចិត្តរបស់មនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ ពោលគឺមនុស្សចង់អង្គុយលើបល្លង្ក៍ចិត្តរបស់ខ្លួនឯង ដោយបដិសេធន៍មិនព្រមទទួលស្គាល់ព្រះជាម្ចាស់ឡើយ។ មនុស្សទំនោរទៅរកការដើរតាមចិត្តខ្លួនឯង ជាជាងដើរតាមមាគ៌ារបស់ព្រះជាម្ចាស់។ ក្នុងន័យដូចគ្នានេះផងដែរ ដើម្បីឧត្តមភាពរបស់ខ្លួនឯង មនុស្សមិនខ្វល់ខ្វាយអំពីអ្វីទាំងអស់ សូម្បីតែសិរីល្អរបស់ព្រះជាម្ចាស់។ តួយ៉ាង ប្រវត្តិសាស្រ្តបានចារថ្កោលទោស

យ៉ាងធ្ងន់ធ្ងរចំពោះការរស់នៅរបស់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ថា “នៅគ្រានោះឯង គ្មានស្តេចនៅស្រុកអ៊ីស្រាអែលទេ គឺមនុស្សទាំងឡាយតែងតែប្រព្រឹត្តិការអ្វី តាមដែលគេយល់ឃើញថាត្រឹមត្រូវគ្រប់គ្នា”(ចៅហ្វាយ២១៖២៥)។ ក្នុងនាមជាស្តេចនៃបល្ល័ង្កចិត្តរបស់ខ្លួន មនុស្សបានបដិសេធន៍ចោលព្រះជាម្ចាស់ ក៏ដូចជាស្តង់ដាដែលព្រះអង្គបានកំណត់អោយដែរ ហើយថែមទាំងវង្វេងចេញពីគោលដៅនៃជីវិតរបស់ខ្លួនគេ ជាលទ្ធផលមនុស្សតែងតែប្រព្រឹត្តិការអ្វីតាមដែលគេយល់ឃើញថាត្រឹមត្រូវគ្រប់ៗគ្នា បើទោះបីជាការទាំងនោះជាអំពើបាបនៅចំពោះព្រះជាម្ចាស់។ សេចក្តីពិតលែងជាស្តង់ដានៃជីវិតរបស់មនុស្សទៀតហើយ ផ្ទុយទៅវិញ មនុស្សបានបង្កើតស្តង់ដា ឬច្បាប់សម្រាប់រស់នៅដោយខ្លួនឯង តាមចិត្តខ្លួនឯង ទាំងស្តង់ដាទាំងនោះគួរអោយស្អប់ខ្ពើមនៅចំពោះព្រះជាម្ចាស់។ ដោយសារអំពើបាប មនុស្សបានយកសចាជាខ្មៅបោះបង់ចោលសេចក្តីពិត ហើយស្រវ៉ាអោបយកការកុហកមកទុកក្នុងជីវិតរបស់ខ្លួនទៅវិញ (រ៉ូម១៖២៥)។ ដោយសារការនេះ សេចក្តីពិតគ្រប់បែបយ៉ាងទាំងអស់អំពីជីវិត អំពីគោលដៅនៃជីវិត និងអំពីព្រះជាម្ចាស់ លនិងល បានបាត់បង់ទាំងស្រុងពីមនុស្សជាតិ ប្រៀបបានដូចជាស្រកាត្រីដែលរាំងកែវភ្នែកពួកគេមិនអោយមើលឃើញព្រះជាម្ចាស់ ក៏ដូចជាគោលដៅនៃជីវិតដ៏ពិតប្រាកដរបស់ពួកគេផងដែរ។ រីឯលទ្ធផលដែលហុចអោយ គឺមនុស្សកំពុងតែវង្វេងនៅក្នុងមហាសមុទ្របាប។ មនុស្សជាស្តេចនៃបល្ល័ង្កចិត្តរបស់ខ្លួនឯង ជាលទ្ធផលព្រះជាម្ចាស់បានបោះបង់គេចោលទៅក្នុងសេចក្តីវិនាស ស្របតាមការដឹកនាំរបស់ចិត្តបាបរបស់ពួកគេ (រ៉ូម១៖២៦)។ មនុស្សជាតិដែលព្រះជាម្ចាស់បានបង្កើតមកដោយល្អឥតខ្ចោះ បានត្រឡប់ជាអាក្រក់បំផុត (លោកុប្បត្តិ៦៖៥ យេរេមា១៧៖៩ អេភេសូ៤៖១៨-១៩)៕

បាបអរូបៈ ចំនុចអវិជ្ជមានជាច្រើនត្រូវបានរាប់ថាជាអំពើបាប ដូចជាភាពលោភលន់ ការកាប់សម្លាប់ ការមិនគោរពឪពុកម្តាយ ការមិនគោរពចាស់ជរា ការមិនអោយតម្លៃជនពិការ ការច្រណែនឈ្នានីស ការជេរប្រទេចផ្តាសា ការគេងបន្លំ ការកុហកបោកប្រាស់ ភាពអសីលធម៌ លនិងល រីឯទម្ងន់ទោសរបស់វាទៀតសោតគឺខុសៗគ្នា។ មួយវិញទៀត ភាគច្រើនមនុស្សនិយាយផ្តោតទៅលើអំពើបាបខាងក្រៅដែលខ្លួនមើលឃើញ ជាជាងអំពើបាបដ៏ធំងងឹតនៅក្នុងចិត្តដែលមើលមិនឃើញជម្រៅឡើយ។ ដោយឡែក មនុស្សមើលតែសំបកខាងក្រៅ តែព្រះជាម្ចាស់វិញទតចំជម្រៅចិត្ត (សាំយូអែលទី១ ១៦៖៧)។ កាលពីពេលដែលព្រះយេស៊ូវគ្រិស្តមានព្រះវត្តមាននៅលើផែនដី ព្រះអង្គមានព្រះបន្ទូលដោយប្រទ្បំតថា “អ្នករាល់គ្នាបានលឺសេចក្តីដែលសម្តែងដល់មនុស្សពីបុរាណថា កុំអោយសម្លាប់មនុស្សអោយសោះ បើអ្នកណាសម្លាប់មនុស្សនោះក្រែងត្រូវជាប់ជំនុំជំរះហើយ តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នោះវិញថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន នោះក្រែងត្រូវជាប់ជំនុំជំរះដែរ ហើយអ្នកណាដែលស្តីអោយបងប្អូនថា អាចោលម្សៀត នោះក្រែងពួកក្រុមជំនុំធ្វើទោស តែចំណែកអ្នកណាដែលថា អាឆ្កួត នោះក្រែងធ្លាក់ទៅក្នុងភ្លើងនរក.......... អ្នករាល់គ្នាបានលឺសេចក្តីដែលសម្តែងពីដើមមកថា កុំអោយផិតអោយសោះ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលគ្រាន់តែក្រឡេកឃើញស្ត្រី ហើយមានតម្រេកសំរើបចង់បាន នោះឈ្មោះថាបានប្រព្រឹត្តិសេចក្តីកំផិតនឹងនាងនោះនៅក្នុងចិត្តខ្លួនហើយ” (ម៉ាថាយ៥៖២១-២៨)។ ពាក្យថាបាបនៅក្នុងស្តង់ដារបស់ព្រះជាម្ចាស់មិនត្រឹមតែជាសកម្មភាពដែលបានសម្តែងមកខាងក្រៅតែប៉ុននោះទេ ជាងហ្នឹងទៅទៀត ព្រះយេស៊ូវគ្រិស្តបានសង្កត់យ៉ាងធ្ងន់ទៅលើចិត្តបាបដែលមនុស្សគ្មានអំណាចនឹងកែប្រែដោយខ្លួនឯងសោះឡើយ។ ដូចដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានលើកឡើងថា “.... ចិត្តនៃមនុស្សជាតិក៏ពេញដោយសេចក្តីអាក្រក់ ហើយក៏មានសេចក្តីចំកួតក្នុងចិត្ត អស់ពេលដែលរស់នៅ ក្រោយនោះក៏ទៅឯពួកមនុស្ស

ស្លាប់ ”(សាស្ដា៩៖៣)។ ដំណោះស្រាយនៃអំពើបាបរបស់មនុស្សមិនមែនត្រឹមតែជាការគ្រប់គ្រងសកម្មភាពបាបខាងក្រៅតែប៉ុននោះទេ ជាងនេះទៅទៀត គឺដំណោះស្រាយចំពោះចិត្តបាបដែលជាឫសគល់ដ៏ពិតប្រាកដ ពោលគឺមនុស្សត្រូវការចិត្តថ្មីដែលល្អ បរិសុទ្ធ គ្មានបាបសោះ ត្បិតសកម្មភាពបាបទាំងឡាយហូរចេញពីចិត្តបាបដែលមនុស្សជាច្រើនបានមើលរម្លង។ ព្រះយេស៊ូគ្រិស្តធ្លាប់មានព្រះបន្ទូលដោយផ្ទាល់ថា “តែឯសេចក្ដីដែលចេញពីមាត់មក នោះមកអំពីចិត្តវិញ គឺសេចក្ដីទាំងនោះហើយដែលធ្វើអោយមនុស្សស្មោគរោគ ត្បិតគឺពីក្នុងចិត្តនោះឯងដែលចេញអស់ទាំងគំនិតអាក្រក់ គឺការកាប់សម្លាប់គេ ផិតក្បត់ សហាយស្មន់ លួចប្លន់ ធ្វើបន្ទាល់ក្លែងក្លាយ ហើយនិងជេរប្រមាថ សេចក្ដីទាំងនោះទើបធ្វើអោយមនុស្សស្មោគរោគមែន.... ”(ម៉ាថាយ១៥៖១៨-២០)។ មនុស្សអាចគ្រប់គ្រងសកម្មភាពបាបខាងក្រៅបាន តែគេមិនអាចគ្រប់គ្រងចិត្តបាបខាងក្នុងរបស់គេបានឡើយ៕

មនុស្សអាចមានឱកាសម្ដងហើយម្ដងទៀត ដើម្បីកែប្រែភាពអវិជ្ជមានដែលសម្ដែងចេញមកខាងក្រៅអោយបានល្អប្រសើរជាងមុន ក៏ប៉ុន្តែ បើទោះបីជាមនុស្សមានឱកាសចាប់ផ្ដើមជាថ្មីយ៉ាងណាក្ដី ក៏គេជៀសមិនផុតពីការធ្វើបាបដែរដរាបណាគេមានចិត្តថ្មីដែលល្អបរិសុទ្ធ។ គួយ៉ាង បន្ទាប់ពីព្រះជាម្ចាស់សម្រេចព្រះហឫទ័យដាក់ទោសមនុស្សលោកដោយសារទឹកជំនន់ធំ (លោកុប្បត្តិ៦) ហាក់បីដូចជាគ្រួសារនិងកូនចៅរបស់លោកណូអេបានចាប់ផ្ដើមសារជាថ្មី ក៏ប៉ុន្តែបើយើងពិនិត្យអោយបានដាក់លាក់ទៅ ពួកគេនៅតែមានចិត្តបាបដដែល ហើយរស់នៅក្នុងផែនដីដែលខូចបង់ដដែល។ ជាលទ្ធផល ពេលវេលាកាន់តែកន្លងទៅមុខ ឯចិត្តរបស់មនុស្សក៏កាន់តែអាក្រក់ទៅៗផងដែរ។ រីឯ ប៉មបាបិល គឺជាភស្តុតាងយ៉ាងប្រទ្យំតអំពីចិត្តបាបរបស់ពួកគេ ពោលគឺមនុស្សតែងតែចិញ្ចឹមចិត្តប៉ងប្រាថ្នាចង់បានដូចជាព្រះជាម្ចាស់ ព្រមទាំងលួចយកព្រះសិរីល្អ និងព្រះកិត្តិនាមដែលជាកម្មសិទ្ធតែមួយគត់របស់ព្រះអង្គ (លោកុប្បត្តិ១១)។ បញ្ហារបស់មនុស្សមិនមែនបណ្ដាលមកពីការអូសទាញពីខាងក្រៅនោះទេ ផ្ទុយទៅវិញគឺដោយសារតែចិត្តដែលពោរពេញដោយអំពើបាបរបស់ខ្លួនឯងផ្ទាល់៕

**ដំណឹងល្អ៖** ទេវតាចេរ៉ូប៊ីន ក៏ដូចជាមនុស្សដំបូងដែរ បានកាត់ផ្ដាច់ចេញពីនឹមរបស់ព្រះជាម្ចាស់ មកជ្រកក្រោមនឹមរបស់អំពើបាបវិញ ដោយអនុញ្ញាតអោយអំពើបាបគ្រប់គ្រងលើបល្ល័ង្កចិត្តរបស់ពួកគេជំនួសព្រះជាម្ចាស់។ ចិត្តដ៏ល្អឥតខ្ចោះដែលព្រះជាម្ចាស់បានបង្កើត បានត្រឡប់ជាពោរពេញ និងជិនដាមជាប់ទៅដោយអំពើបាប ដែលហុចផលផ្លែជាសកម្មភាពបាបគ្រប់រូបភាពទាំងអស់។ មនុស្សបានរួចផុតពីអន្លង់បាប លុះត្រាណាគេបានសម្លាប់ចិត្តបាបចោល ហើយទទួលយកចិត្តថ្មីដែលល្អបរិសុទ្ធ។ មនុស្សត្រូវការចិត្តថ្មីដែលល្អបរិសុទ្ធ ហើយគ្មានបាបសោះ។ នេះគឺជាលក្ខខណ្ឌដែលមនុស្សជាតិគ្រប់ៗរូប និងគ្រប់សម័យកាលទាំងអស់មិនអាចបំពេញបានដោយខ្លួនឯងសោះឡើយ ក៏ប៉ុន្តែដំណឹងល្អគឺ នេះគឺជាអ្វីដែលព្រះជាម្ចាស់បានសន្យាថានឹងបំពេញ ហើយប្រោសប្រទានអោយមនុស្សគ្រប់ៗរូបតាមរយៈសេចក្ដីជំនឿរបស់គេផ្ទាល់ ដូចដែលលោកហោរ៉ាអេសេគាលបានផ្ដល់ជាពន្លឺនៃសេចក្ដីសង្ឃឹមមកថា “នោះអញនឹងប្រោសទឹកស្អាតទៅលើឯងរាល់គ្នា ដូច្នោះឯងនឹងបានស្អាត អញនឹងជំរះឯងរាល់គ្នាអោយស្អាត ពីគ្រប់ទាំងសេចក្ដីស្មោគរោគ ហើយពីអស់ទាំងរូបព្រះរបស់ឯងផង អញនឹងអោយឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់ឯងចេញ រួចនឹងអោយមានចិត្តជាសាច់វិញ អញនឹងដាក់វិញ្ញាណអញនៅក្នុងឯងរាល់គ្នា ហើយបណ្ដាលអោយឯងដើរតាមក្រឹត្យក្រម ហើយរក្សាបញ្ញត្តិច្បាប់របស់អញ ព្រមទាំងប្រព្រឹត្តិតាមផង”(អេសេគាល៣៦៖២៥-២៧)។ ត្រីវិស័យដើម្បីលាង

ជំរះមនុស្សចេញពីអំពើបាប បានចង្អុលទៅកាន់ព្រះជាម្ចាស់តែមួយអង្គគត់ដែលជាផ្លូវ មិនមែនអំពើល្អ ផលបុណ្យកុសល សំណាង សមត្ថភាព លនិងល៕

## ខ កំណើតក្នុងបណ្តាសា

"ដូច្នោះ ដែលបាបបានចូលមកក្នុងលោកិយ៍ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាលដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ត្បិតគ្រប់គ្នាបានធ្វើបាបហើយ" រ៉ូម៥៖១៣។

មនុស្សគ្រប់ៗរូប និងគ្រប់ទីកន្លែងទាំងអស់ដែលបានចាប់កំណើតបន្ទាប់ពីអាដាំ និងអេវ៉ា ជាប់និស្ស័យបាប និងបានធ្វើបាប ពោលពួកគេគឺជាមនុស្សបាបនៅចំពោះព្រះជាម្ចាស់។ ព្រះជាម្ចាស់បានទតមកមើលមនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ ហើយព្រះអង្គបានរាប់ពួកគេថាជាមនុស្សបាប ដោយព្រោះតែអំពើបាបរបស់មនុស្សដំបូងដែលជាតំណាងរបស់ពួកគេ។ ការនេះក៏មានន័យផងដែរថា មនុស្សគ្រប់គ្នាទាំងអស់សុទ្ធតែជាប់ជិតដាមដោយអំពើបាប បើទោះបីជាគេគ្មានឱកាសនឹងប្រព្រឹត្តិអំពើបាបសោះយ៉ាងណាក្តី។ បើនិយាយអោយចំទៅ ចាប់តាំងតែពីមុនពេលដែលមនុស្សបានកើតចាកចេញពីផ្ទៃម្តាយមកម្ល៉េះ ព្រះជាម្ចាស់បានគូសវាសយ៉ាងប្រទាំ្យតថាគេជាមនុស្សបាប ហើយគ្រប់យ៉ាងទាំងអស់ដែលគេមាន និងធ្វើដោយពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនឯង មិនអាចនឹងផ្គាប់ព្រះហឬទ័យរបស់ទ្រង់បានជាដាច់ខាត។ អំពើបាបរបស់អាដាំ និងអេវ៉ាដែលជាតំណាងរបស់មនុស្សជាតិ ត្រូវបានរាប់ថាជាអំពើបាបរបស់មនុស្សផងទាំងពួង ដូចគ្នានេះដែរ ទោសនៃអំពើបាបដែលមនុស្សដំបូងសមតែទទួល នោះមនុស្សទាំងពួងក៏ត្រូវតែទទួលដោយជៀសមិនផុត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ណាស់ថា "…. គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" (រ៉ូម៣៖២៣)។ "…. គ្រប់គ្នាបានវង្វេងចេញ បានត្រឡប់ទៅជាស្មោកគ្រោកទាំងអស់ គ្មានអ្នកណាមួយដែលប្រព្រឹត្តិល្អឡើង សូម្បីតែមួយក៏គ្មានផង" (ទំនុកតម្កើង១៤៖៣)។ "ពិតប្រាកដជាគ្មានមនុស្សសុចរិតណានៅផែនដីដែលប្រព្រឹត្តិសុទ្ធតែល្អឥតធ្វើបាបឡើយនោះទេ" (សាស្តា៧៖២០)។ មនុស្សគ្រប់ៗរូបបានត្រឡប់ជាកខ្វក់ ស្មោគគ្រោកទាំងគំនិត និងបញ្ញាចិត្ត (ទីតុស១៖១៥) ឯចិត្តមនុស្សគឺអាក្រក់ហួសក្បត់ដែលគ្មានអ្នកណាអាចស្ទង់ជម្រៅបានឡើយ (យេរេមា១៧៖៩)។ មនុស្សទាំងអស់តែងតែជំពប់ដួលក្នុងអំពើបាប (យាកុប៣៖២)។ "….. គ្មានមនុស្សណាមួយដែលមិនធ្វើបាបឡើយ" (ពង្សាវតាក្សត្រទី១ ៨៖៦៤)។ មនុស្សជាតិជាប់អំពើទុច្ចរិតតាំងពីចាប់កំណើតមកម្ល៉េះ (ទំនុកតម្កើង៥៨៖៣)។ "….. នៅព្រះនេត្រទ្រង់ គ្មានមនុស្សរស់ណាមួយដែលសុចរិតទេ" (ទំនុកតម្កើង១៤៣៖២)។ ទាក់ទងទៅនឹងការនេះផងដែរ ស្តេចដាវីឌបានសរសេរថា "មើល ទូលបង្គំបានកើតមកក្នុងសេចក្តីសុចរិត ហើយម្តាយទូលបង្គំបានមានទំងន់បង្កើតទូលបង្គំនៅក្នុងអំពើបាបដែរ" (ទំនុកតម្កើង៥១៖៥)។ គ្មាននរណាម្នាក់សុចរិតសោះឡើយនៅចំពោះព្រះដ៏សុចរិត ហើយក៏គ្មាននរណាម្នាក់ល្អប្រសើរជាងម្នាក់ទៀតដែរ ពោលគឺបុគ្គលគ្រប់ៗរូបសុទ្ធតែស្ថិតនៅក្រោមបន្ទាត់តែមួយដូចៗគ្នាគឺ ជាប់មានបាប និងខ្វះមិនដល់ស្តង់ដារបស់ព្រះជាម្ចាស់ (រ៉ូម១៖១៨-៣៖២០)។ ដោយឡែក លោកសាវ័កយ៉ូហានក៏បាននិយាយផងដែរថា "បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុង

យើងទេ” (យ៉ូហានទី១ ១៖៨)។ មនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ បន្ទាប់ពីការធ្លាក់ចុះនៃអំពើបាប មានកំណើតក្នុងអំពើបាប និងបណ្តាសារបស់ព្រះជាម្ចាស់៕

ជាការពិតណាស់ បើតាមចក្ខុវិស័យរបស់លោកិយ អ្នកប្រហែលជាមនុស្សដែលល្អប្រសើរជាងបុគ្គលផ្សេងៗទៀតជាប្រាកដមែន ក៏ប៉ុន្តែនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ មនុស្សគ្រប់វ័យ និងគ្រប់ស្រទាប់វណ្ណៈទាំងអស់ រួមបញ្ចូលទាំងរូបអ្នកផ្ទាល់ សុទ្ធតែជាប់មានបាប ប្រៀបបានដូចជាក្រណាត់មួយផ្ទាំងដ៏ខ្មៅកខ្វក់ដ៏ជាទីសំអប់ខ្ពើមបំផុត។ ក្នុងន័យដូចគ្នានេះដែរ បើទោះបីជាទង្វើខាងក្រៅរបស់មនុស្សមើលទៅល្អប្រសើរ គួរជាទីកោតស្ងប់ស្ងែងយ៉ាងណាក្តី ក៏ការនេះមិនបានជាទីគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ដែរ ដ្បិតជីវិតរបស់មនុស្សបានចាប់ចាក់គ្រឹះយ៉ាងជ្រៅចូលទៅក្នុងអំពើបាបដ៏គួរអោយស្អប់ខ្ពើមបំផុតនៅចំពោះព្រះជាម្ចាស់។ ការនេះក៏បានសេចក្តីផងដែរថា បើទោះបីជាមនុស្សជោគជ័យយ៉ាងណា បានទទួលការអប់រំខ្ពង់ខ្ពស់កំរិតណា បានធ្វើល្អយ៉ាងណា មានសន្តានចិត្តល្អឬអាក្រក់យ៉ាងណា មានទ្រព្យសម្បត្តិ និងទេពកោសល្យយ៉ាងណាក្តី លនិងល ក៏ពួកគេមានចំនុចរួមមួយដូចគ្នា គឺអំពើបាប។ លោកិយបានបែងចែកមនុស្សជាក្រុមៗខុសៗគ្នា ដោយផ្អែកលើសម្បកខាងក្រៅ ក៏ប៉ុន្តែនៅចំពោះព្រះជាម្ចាស់ មនុស្សទាំងអស់ស្ថិតនៅក្នុងក្រុមតែមួយដូចៗគ្នា និងស្មើៗគ្នា គឺក្រុមមនុស្សបាប។ គ្រប់ៗគ្នាបានកើតមកក្នុងអំពើបាប ហើយជាមនុស្សបាប ដូចដែលព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់តាមរយះលោកហោរ៉ាអេសេគាលថា ទ្រង់បានស្វែងរកមនុស្សសុចរិតតែម្នាក់នៅក្នុងចំណោមមនុស្សជាតិទាំងឡាយក៏គ្មានផង (អេសេគាល២២៖៣០ ទំនុកតម្កើង១៤) លើកលែងតែព្រះគ្រិស្ត និងអស់អ្នកណាដែលនៅក្នុងទ្រង់ ទើបបានសុចរិតជាទីពេញព្រះហឫទ័យព្រះអង្គណាស់៕

មិនមែនមកពីអាដាំទាំងស្រុង៖ ជាការពិតណាស់ តាមរយះអំពើបាបរបស់អាដាំដែលជាតំណាងរបស់មនុស្សជាតិនៅចំពោះព្រះជាម្ចាស់ មនុស្សគ្រប់ៗរូបទាំងអស់បានជាប់ក្រោមការវិនិច្ឆ័យ និងក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់ដោយផ្ទាល់ ដូចជាអាដាំដែរ ក៏ប៉ុន្តការនេះមិនមែនបានសេចក្តីថាមនុស្សអាចគេចផុតពីទំនួលខុសត្រូវរបស់ខ្លួនដោយទំលាក់កំហុសទាំងអស់ដាក់ដល់អាដាំ ហើយរាប់ខ្លួនឯងថាគ្រាន់តែជាជនរងគ្រោះពីអំពើរម្លងរបស់អាដាំតែប៉ុននោះ។ មនុស្សមិនត្រឹមតែមានកំណើតនៅក្នុងអំពើបាប ជាប់និស្ស័យបាបជាមរតកដែលប៉ុននោះទេ លើសពីនេះទៅទៀតមនុស្សគ្រប់គ្នាបានធ្វើបាបទាំងដោយចេតនា និងអចេតនា ព្រមទាំងបានបដិសេធន៍ព្រះជាម្ចាស់ដោយផ្ទាល់ ដូចមនុស្សដំបូងផងដែរ។ មនុស្សដំបូងបានពាំនាំអំពើបាបចូលមកក្នុងលោកិយ តែមនុស្សបច្ចុប្បន្ន ពេញចិត្ត រីករាយ ននៀលត្រេកត្រអាល តោងជាប់ក្នុងអំពើបាបដោយមិនកោតខ្លាចដល់ព្រះជាម្ចាស់ឡើយ។ លោកសាវ័កប៉ុលបានលើកឡើងថា “គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តិតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង បំពង់កគេជាផ្នូរខ្មោចនៅចំហរ គេប្រើអណ្តាតសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេមានសុទ្ធតែពិសពស់ហនុមាន ហើយមាត់គេមានពេញដោយសេចក្តីបណ្តាសា និងសេចក្តីជូរចត់ ជើងគេរហ័សនឹងកម្ចាយឈាម នៅអស់ទាំងផ្លូវរបស់គេមានសុទ្ធតែសេចក្តីវិនាស និងសេចក្តីទុក្ខលំបាក គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ក៏គ្មានសេចក្តីកោតខ្លាចចំពោះព្រះនៅភ្នែកគេឡើយ...... ហេតុនេះបានជាគ្មានមនុស្សណាបានរាប់ជាសុចរិតនៅចំពោះទ្រង់..... ” (រ៉ូម៣៖១១-២០)។ “..... មនុស្សលោកចូលចិត្តនឹងសេចក្តីងងឹតជាជាងពន្លឺ ពីព្រោះអំពើដែលគេធ្វើទាំងប៉ុន្មានសុទ្ធតែអាក្រក់” (យ៉ូហាន៣៖១៩)។ នៅត្រង់នេះ លោក

សាវ័កប៉ុលបានសង្កត់យ៉ាងធ្ងន់ថា មនុស្សគ្រប់ជាតិសាសន៍ទាំងអស់មិនមែនគ្រាន់តែជាជនរងគ្រោះពីសេចក្តីរំលងរបស់មនុស្សដំបូងតែប៉ុននោះទេ ផ្ទុយទៅវិញព្រះជាម្ចាស់វិនិច្ឆ័យពួកគេ ដោយព្រោះអំពើបាបរបស់ពួកគេផ្ទាល់។ ជាក់ស្តែង ខណៈពេលដែលស្តេចដាវីឌមានព្រះជន្មគង់នៅលើផែនដី ព្រះអង្គបានទទួលស្គាល់ និងសារភាពចំពោះអំពើរំលងរបស់ទ្រង់ថា ព្រះអង្គផ្ទាល់គឺជាអ្នកប្រព្រឹត្តិបាប ហើយអំពើបាបរបស់ទ្រង់មិនមែនជាកំហុសរបស់មនុស្សដំបូងឡើយ ព្រោះវាគឺជាជំរើសរបស់ទ្រង់ផ្ទាល់ (ទំនុកតម្កើង៥១៖៣)។ ជារៀងរាល់ថ្ងៃ មនុស្សគ្រប់ៗរូបត្រូវប្រឈមមុខនឹងការសម្រេចចិត្តដូចមនុស្សដំបូងដែរ៖ តើគួរស្តាប់បង្គាប់ព្រះជាម្ចាស់ ឬស្តាប់តាមចិត្តខ្លួនឯង ព្រមទាំងអ្នកដែលនៅជុំវិញខ្លួន? បើទោះបីជាយ៉ាងណាក៏ដោយ គ្រប់ៗគ្នាត្រូវតែទទួលខុសត្រូវចំពោះលទ្ធផលនៃការសម្រេចចិត្តរបស់ខ្លួន ដោយគ្មានលេសដោះសារ និងទំលាក់កំហុសដាក់អ្នកដ៏ទៃ ឬអ្វីមួយផ្សេងទៀត ដូចកាលដែលមនុស្សដំបូងបានធ្វើនៅក្នុងសួនច្បារអេដែនឡើយ (លោកុប្បត្តិ៣៖១២-១៣)៕

ទាសកររបស់អំពើបាប៖ បន្ទាប់ពីអំពើរំលងរបស់អាដាំ មនុស្សគ្រប់ៗរូបកើតមកក្នុងនឹមរបស់អំពើបាប ដាច់ចេញពីព្រះជាម្ចាស់ និងជាសត្រូវរបស់ព្រះជាម្ចាស់។ ដូចគ្នានេះដែរ គ្មាននរណាម្នាក់ (លើកលែងតែព្រះយេស៊ូវគ្រិស្ទ) ដែលកើតមកដោយមានជីវិតរស់ខាងព្រលឹងវិញ្ញាណនៅចំពោះព្រះជាម្ចាស់ឡើយ។ មនុស្សបានកើតមកដើម្បីបំរើអំពើបាបដោយជៀសចេញមិនផុត ហើយអំពើបាបបានគ្រប់គ្រងលើគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ ទាំងខ្លួនគេផ្ទាល់គ្មានកម្លាំងនឹងតទល់ រើបំរាស់ និងឈប់ប្រព្រឹត្តិបាបដោយខ្លួនឯងឡើយ។ មួយវិញទៀត បើទោះបីជាសតិរបស់មនុស្សបានកត់សំគាល់ឃើញនូវអ្វីដែលល្អ ត្រឹមត្រូវ ព្រមទាំងមានចិត្តចង់ធ្វើតាមយ៉ាងណាក្តី ក៏មនុស្សគ្មានសមត្ថភាពនឹងចុះចូលធ្វើតាមផង ព្រោះនិស្ស័យរបស់មនុស្សតាំងពីកំណើតមកម្ល៉េះ តែងតែលំអៀងទោរទន់ទៅរកអំពើបាបជានិច្ច។ បាបមួយរយសំពៅងាយស្រួលធ្វើជាងអំពើល្អត្រឹមត្រូវតែមួយ។ មនុស្សបានជាប់គាំងក្រោមនឹមរបស់អំពើបាបដោយរើចេញមិនរួចដោយខ្លួនឯងឡើយ។ ត្រង់ចំនុចនេះ លោកសាវ័កប៉ុលបានលើកឡើងថា "ដ្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំគឺក្នុងសាច់ឈាមខ្ញុំគ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អជានិច្ច ប៉ុន្តែរកធ្វើមិនកើតសោះ ខ្ញុំមិនប្រព្រឹត្តិការល្អដែលខ្ញុំចង់ធ្វើនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ នោះបែរជាខ្ញុំធ្វើវិញ" (រ៉ូម៧៖១៨-១៩)។ មនុស្សមិនមែនជាម្ចាស់លើខ្លួនឯងទេ ផ្ទុយទៅវិញអំពើបាបគឺជាម្ចាស់របស់ពួកគេ ជាអ្នកបញ្ជាគេ និងជាអ្នកមានអំណាចដាច់នៅលើគេ។ មនុស្សប្រព្រឹត្តិតាមតែគន្លងបាបដែលបានដាក់តាំងពីមុខពួកគេជាដរាប។ មនុស្សកើតនៅក្នុងអំពើបាប ហើយជាលទ្ធផល ពួកគេជាទាសកររបស់អំពើបាប ជាសត្រូវរបស់ព្រះជាម្ចាស់ ស្លាប់នៅចំពោះព្រះជាម្ចាស់ និងមិនអាចធ្វើការល្អគាប់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ (រ៉ូម៨) លនិងល។ មនុស្សបានកើតមកក្នុងសភាពជាសត្រូវរបស់ព្រះជាម្ចាស់ (រ៉ូម៥៖១០ កូឡូស១៖២១ យ៉ាកុប៤៖៤) ទាស់ប្រឆាំងជាមួយនឹងព្រះគ្រិស្ត (ម៉ាថាយ១២៖៣០) ជាខ្មាំងសត្រូវនឹងឈើឆ្កាងរបស់ព្រះគ្រិស្ត ហើយមនុស្សបានបដិសេធព្រះដ៏ពិត ដោយយកពោះគេទុកជាព្រះ ព្រមទាំងយកសេចក្តីគួរខ្មាស់របស់គេទុកជាសិរីល្អវិញ គេនឹកតែពីរបស់នៅផែនដីនេះ (ភីលីព៣៖១៨-១៩)។ បើនិយាយអោយចំទៅ មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ និងគ្រប់សម័យកាលទាំងអស់(លើកលែងតែព្រះយេស៊ូវគ្រិស្ទ) មិនបានកើតមកដោយមានទំនាក់ទំនងល្អឥតខ្ចោះជាមួយព្រះជាម្ចាស់ ដូចអាដាំ និងអេវ៉ាធ្លាប់មាននោះទេ ផ្ទុយទៅវិញ តាំងតែពីដើមកំណើតមកម្ល៉េះ បុគ្គលគ្រប់ៗរូបជាប់ក្នុងសេចក្តីខ្ញាល់របស់ព្រះជាម្ចាស់ (អេភេសូ២៖៣)។ ស្របពេលជាមួយគ្នានេះផងដែរ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចង្អុលបង្ហាញអោយឃើញថា ចាប់ពី

មួយជំនាន់ទៅមួយជំនាន់ទៀត អំពើបាបរបស់មនុស្សជាតិរឹតតែរាលដាលចម្រើនច្រើនឡើងៗជានិច្ចនៅចំពោះព្រះជាម្ចាស់ (ហូសេ១៣៖២) រហូតដល់អ្នកនិពន្ធទំនុកតម្កើងបានលើកឡើងថា គ្រប់ជាតិសាសន៍ទាំងអស់បានពួតដៃគ្នា ហើយក្រោកឡើងទាំងវង្វេងជាក្រុមៗដើម្បីទាស់ប្រឆាំងជាមួយព្រះដ៏ពិត (ទំនុកតម្កើង២៖១-៣)។ តាមនិស្ស័យខាងសាច់ឈាមតាំងពីកំណើតមកម្ល៉េះ មនុស្សតែងតែស្អប់ បដិសេធនិ៍ ហើយទាស់ប្រឆាំងជាមួយនឹងព្រះជាម្ចាស់ ព្រោះពួកគេមិនមែនជារបស់ព្រះជាម្ចាស់នោះទេ ផ្ទុយទៅវិញពួកគេជាទាសកររបស់អំពើបាប (យ៉ូហាន១៥៖១៨-២៥)។ មនុស្សបានកើតមកក្នុងនាមជាទាសកររបស់អំពើបាប ហើយការនេះបានកំណត់មនុស្សថាជាសត្រូវរបស់ព្រះជាម្ចាស់៕

ប្រាកដណាស់! មនុស្សគ្រប់ៗរូបសុទ្ធតែជាមនុស្សបាប ដែលបានរស់នៅក្នុងអំពើបាប ហើយប្រព្រឹត្តិបាបទាំងកាយ វាចារ ចិត្ត។ ដោយឡែក អំពើបាបរបស់មនុស្សមិនត្រឹមតែជាការខុសឆ្គងចំពោះមនុស្សដូចគ្នានោះទេ លើសពីនេះទៅទៀត អំពើបាបទាំងអស់របស់មនុស្សជាការទាស់ប្រឆាំងជាមួយនឹងព្រះជាម្ចាស់ដោយផ្ទាល់ (ទំនុកតម្កើង៥១៖៤)។ មនុស្សប្រព្រឹត្តិបាប នោះមនុស្សធ្វើខុសជាមួយនឹងព្រះដ៏ជាព្រះ ដូច្នេះមនុស្សត្រូវតែទទួលខុសត្រូវចំពោះព្រះជាម្ចាស់។ នេះគឺជាបន្ទុកដ៏ធ្ងន់ ហើយធំបំផុតមួយរបស់មនុស្សជាតិ ត្បិតអំពើបាបរបស់មនុស្សបានរាប់ញែកពួកគេថាជាសត្រូវរបស់ព្រះជាម្ចាស់។ ទាក់ទងទៅនឹងប្រធានបទនេះផងដែរ លោក ចេ. ឌី. ក្រោលី បានសរសេរថា “ការអាក្រក់បំផុតដែលអាចកើតឡើងចំពោះមនុស្សម្នាក់ៗនៅក្នុងជីវិតរបស់គេ គឺមានព្រះជាសត្រូវ ព្រោះទ្រង់មានគ្រប់ទាំងអំណាច ប្រាជ្ញាវាងវៃ និងភាពបរិសុទ្ធរបស់ទ្រង់តម្រង់ចំគេដើម្បីនឹងបង្ក្រាបគេ ហើយជំនុំជំរះគេ” [14]។ ចាប់តាំងតែពីដើមដំបូងមកម្ល៉េះ ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងប្រទ្បៃតថា ប្រសិនបើមនុស្សបដិសេធនិ៍ទ្រង់ដែលជាប្រភពនៃជីវិត នោះគេនឹងស្លាប់ជាក់ជាមិនខាន (លោកុប្បត្តិ២៖១៧)។ ចំណែកឯលោកសាវ៉កប៉ុលវិញ ក៏បានក្រើនរំលឹកផងដែរថា ត្រូវបណ្តាសាហើយអស់អ្នកណាដែលមិនបានប្រកាន់ខ្ជាប់តាមអស់ទាំងពាក្យដែលបានកត់ទុកក្នុងក្រិត្យវិន័យរបស់ព្រះជាម្ចាស់ (កាឡាទី៣៖១០)។ ព្រះជាម្ចាស់សុចរិត និងយុត្តិធម៌ ព្រះអង្គមិនអាចមើលរម្លងអំពើបាបណាមួយរបស់មនុស្សបានឡើយ បើដូច្នោះ ព្រះដ៏សុចរិត និងយុត្តិធម៌ត្រូវតែវិនិច្ឆ័យអំពើរម្លងរបស់មនុស្សបាបគ្រប់ជាតិសាសន៍ទាំងអស់។ អំពើបាបរបស់មនុស្សត្រូវតែវិនិច្ឆ័យ ជាដាច់ខាត៕

ខូចអស់ហើយ៖ ព្រះដ៏ល្អបរិសុទ្ធបានបង្កើតគ្រប់សព្វសារពើទាំងអស់ដោយល្អបរិសុទ្ធ គ្មានសៅហ្មងឡើយ (លោកុប្បត្តិ១៖៣១)។ ដោយឡែក អំពើបាបបានបង្ខូចគ្រប់ការល្អទាំងអស់របស់ព្រះជាម្ចាស់។ អំពើបាបដែលមនុស្សដំបូងបានប្រព្រឹត្តិមិនត្រឹមតែប៉ះពាល់ដល់ត្រឹមពួកគេតែប៉ុននោះទេ លើសពីនេះទៅទៀត វាបានប៉ះពាល់ដល់គ្រប់ជីវិតទាំងអស់គ្រប់សម័យកាលទាំងអស់ រួមបញ្ចូលទាំងធម្មជាតិទាំងឡាយដែលព្រះជាម្ចាស់បានបង្កើតមកយ៉ាងល្អឯកផងដែរ (រ៉ូម៥៖១២-១៩ ៨៖២២ ១កូរិនថូស១៥៖២១-២២)។ គ្រប់ការល្អទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកដើម្បីសិរីល្អរបស់ទ្រង់ ត្រូវបានបង្ខូច ទៅជាពុករលួយ ព្រមទាំងបានទទួលរងទុក្ខទោសជាមួយមនុស្សផងដែរ ព្រោះតែការប៉ះបោររបស់មនុស្សដំបូង។ ព្រះគម្ពីរបរិសុទ្ធគូសវាសបានបញ្ជាក់ថា ដោយសារអំពើបាបរបស់មនុស្សដំបូង គ្រប់សព្វសារពើទាំងអស់ត្រូវស្ថិតក្រោមព្រះពិរោធនិ៍ ការវិនិច្ឆ័យ និងបណ្តាសារបស់ព្រះជាម្ចាស់ (លោកុប្បត្តិ៣៖១៤-១៩)។ តួយ៉ាង សត្វត្រូវបានសម្លាប់ដំបូងបង្អស់ សម្រាប់ធ្វើជាអាវគ្របបាំងកេរ្តិ៍ខ្មាស់របស់មនុស្សដំបូង (លោកុប្បត្តិ៣៖២១) បន្ទាប់មកទៀត គ្រប់ទាំងជីវិតនៅ

[14] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. ក្រោលី ទំព័រ៣១៩

លើផែនដី (លើកលែងតែជីវិតដែលនៅក្នុងទូករបស់លោកណូអេ) ត្រូវបានវិនិច្ឆ័យដោយទឹកជំនន់ជាមួយមនុស្សដែរ ក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់ ដោយសារតែអំពើបាបរបស់មនុស្ស (លោកុប្បត្តិ៥-៩) លនិងល។ អំពើបាបរបស់មនុស្សដំបូងបានបំផ្លាស់ប្រែគ្រប់ការល្អទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកសម្រាប់ជាព្រះពរ អោយទៅជាបណ្តាសាវិញ។ ផ្ទុយពីការដើរតាមត្រីវិស័យរបស់ព្រះជាម្ចាស់ ដើម្បីនាំយកព្រះពរ និងសិរីល្អរបស់ទ្រង់ទៅកាន់គ្រប់ផ្នែកទាំងអស់នៃផែនដី មនុស្សបែរជាបង្ខូចផែនដីរបស់ព្រះជាម្ចាស់ដោយសារអំពើបាបទៅវិញ៕

សេចក្តីស្លាប់៖ លោកហោរាអេសាយបាននិយាយថា អំពើបាបគឺជាជញ្ជាំងដែលបានញែកផ្តាច់មនុស្សចេញពីព្រះជាម្ចាស់ (អេសាយ៥៩៖២) ស្របពេលជាមួយគ្នានេះផងដែរ លោកសាវ៉កប៉ុលក៏បានសង្កត់បន្ថែមទៀតដែរថា ដោយព្រោះអំពើបាប មនុស្សបានទទួលរងនូវព្រះពិរោធរបស់ព្រះជាម្ចាស់ដោយផ្ទាល់ (រ៉ូម១៖១៨)។ មិនខុសអីពីព្រះអាទិត្យដែលជះរស្មីចែងចាំងលើផែនដីនោះទេ ព្រះពិរោធន៏របស់ព្រះជាម្ចាស់បានធ្លាក់មកចំលើមនុស្សគ្រប់ជាតិសាសន៏ទាំងអស់ដោយគ្មាននរណាម្នាក់អាចគេចផុតបានឡើយ ព្រោះគ្រប់គ្នាទាំងអស់សុទ្ធតែជាមនុស្សបាប។ មនុស្សគ្រប់ជាតិសាសន៏ទាំងអស់ មិនបានកើតមកដោយសោយសុខលើគំនរព្រះពរដ៏ពេញបរិបូរណ៍ដូចជាមនុស្សដំបូងធ្លាប់ភ្លក់នោះទេ ផ្ទុយទៅវិញ មនុស្សបានកើតមកក្នុងព្រះពិរោធន៏របស់ព្រះជាម្ចាស់ (រ៉ូម១៖១៨) ដូចគ្នាទៅនឹងការលើកឡើងរបស់លោកសាវ៉កប៉ុលថា “…. តាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្តីខ្ញាល់ដូចជាមនុស្សឯទៀតដែរ” (អេភេសូ២៖៣)។ មិនខុសអី ពីអាដាំ និងអេវ៉ានោះទេ ក្នុងនាមជាពិរុទ្ធជនក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់ មនុស្សបាបត្រូវតែស្លាប់ “ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់… ”(រ៉ូម៦៖២៣)៕

រីឯសេចក្តីស្លាប់នៅក្នុងព្រះគម្ពីរបរិសុទ្ធវិញ គឺសំដៅទៅលើការស្លាប់ទាំងខាងសាច់ឈាម និងជាពិសេសគឺខាងព្រលឹងវិញ្ញាណ។ បន្ទាប់ពីមនុស្សស្លាប់ រូបកាយរបស់គេនឹងត្រឡប់ក្លាយទៅជាធូលីដីវិញ ត្បិតព្រះជាម្ចាស់បានសូនបង្កើតមនុស្សចេញពីធូលីដី (លោកុប្បត្តិ២៖៧ ៣៖១៩ សាស្ត្រា៣៖២០) ដោយឡែកព្រលឹងវិញ្ញាណរបស់មនុស្សវិញ នឹងត្រូវទទួលរងទុក្ខទោសនៃការវិនិច្ឆ័យដ៏អស់កល្បជានិច្ចក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់ (ម៉ាថាយ២៥៖៤១ ២៥៖៤៦ លូកា១៦៖២៤ វិវរណៈ២០៖១០-១៥)។ “គេនឹងរងទុក្ខទោស ជាសេចក្តីហិនវិនាសអស់កល្បជានិច្ច ឃ្លាតពីព្រះភក្រ្តព្រះអម្ចាស់ ហើយពីសិរីល្អនៃព្រះចេស្តាទ្រង់” (ថែស្សាឡូនិចទី២ ១៖៩)។ គ្មានមនុស្សបាបណាម្នាក់ដែលអាចគេចផុតពីការវិនិច្ឆ័យរបស់ព្រះជាម្ចាស់បានឡើយ សូម្បីតែពួកទេវតាដែលបានធ្វើបាបតាំងពីដើមដំបូងមកម្ល៉េះ ដូចដែលលោកពេត្រុសបាននិយាយថា “….. ព្រះមិនបានប្រណីដល់ពួកទេវតាដែលបានធ្វើអំពើបាប គឺទ្រង់បោះទំលាក់ទៅក្នុងជង្ហុកជ្រៅបំផុត អោយជាប់ច្រវ៉ាក់នៃសេចក្តីងងឹត ទាំងឃុំទុកសម្រាប់នឹងជំនុំជំរះវិញ”(ពេត្រុសទី២ ២៖៤)។ អនាគតរបស់មនុស្សបាបទាំងអស់ ក៏មិនខុសគ្នាអំពីអនាគតរបស់ពពួកទេវតាដែលបានប៉ះបោរប្រឆាំងជាមួយនឹងព្រះជាម្ចាស់ដែរ ចំណែកឯការបណ្តេញមនុស្សដំបូង ក៏ដូចជាមនុស្សបាបទាំងឡាយចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ គ្រាន់តែជាចំនុចចាប់ផ្តើមនៃការវិនិច្ឆ័យតែប៉ុននោះ (លោកុប្បត្តិ៣)៕

អំពើបាបបានបង្ខូចការល្អឥតខ្ចោះទាំងអស់ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សជាតិទាំងឡាយ ដូចគ្នានេះដែរ អំពើបាបបានផ្លាស់ប្តូរពីព្រះពរដ៏ពេញបរិបូរណ៍របស់ព្រះជាម្ចាស់ មកជាបណ្តាសាលើគ្រប់ស្នាព្រះហស្តទាំងអស់របស់ទ្រង់វិញ។ ក្នុងន័យដូចគ្នានេះផងដែរ មនុស្សគ្រប់ជាតិសាសន៏ទាំងអស់បានកើតមកក្នុងបណ្តាសា និង

សម្រាប់ទទួលរងនូវការវិនិច្ឆ័យដ៏អស់កល្បជានិច្ចក្រោមព្រះពិរោធន៍របស់ព្រះដ៏សុចរិត ប្រសិនបើគេរកមិនឃើញផ្លូវដើម្បីផ្សះផ្សាជាមួយនិងទ្រង់វិញ មុនពេលដែលគេលាចាកពីផែនដីនេះ ឬមុនពេលដែលព្រះគ្រិស្តយាងត្រឡប់មកវិញជាលើកទី២ (រ៉ូម២៖៨)។ ពេលវេលាដែលនឹងមកដល់មួយនោះ គឺជាសោនាធកម្មដ៏ខ្មៅងងឹតបំផុតមួយសម្រាប់ប្រវត្តិសាស្ត្រមនុស្សបាប ហើយក្នុងនាមជាគ្រិស្តបរិស័ទ គប្បីយើងគួរតែព្រួយបារម្ភ ខ្វល់ខ្វាយ ឈឺចាប់ និងសោកស្តាយ ដែលមនុស្សបាបទាំងពួង (អ្នកដែលមិនជឿ) កំពុងតែវិនាសបាត់បង់ក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់ ជាពិសេស សិរីល្អរបស់ព្រះជាម្ចាស់ក៏មិនត្រូវបានសរសើរតម្កើងពីសំណាក់ពួកគេផងដែរ។ ក្នុងពេលជាមួយគ្នានេះផងដែរ គ្រិស្តបរិស័ទមិនអាចគិតទៅដល់ថ្ងៃនោះ ដោយគ្មានអារម្មណ៍សោកសៅ និងខ្វល់ខ្វាយចំពោះអ្នកដែលកំពុងតែវិនាសបាត់បង់នៅជុំវិញខ្លួនគេសោះឡើយ ព្រោះបើផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងដឹងច្បាស់ណាស់អំពីអនាគតរបស់មនុស្សបាប៕

ជាចុងបញ្ចប់ លទ្ធផលនៃអំពើបាបរបស់មនុស្សដំបូងបានជំរុញអោយមនុស្សគ្រប់ជាតិសាសន៍ទាំងអស់មានកំណើតក្នុងបណ្តាសា ដោយពួកគេគ្មានជម្រើសសោះឡើយ។ មួយវិញទៀត ដោយព្រោះអំពើបាប មនុស្សជាតិមិនត្រឹមតែត្រូវរស់នៅក្រោមបណ្តាសារបស់ព្រះជាម្ចាស់ដោយលំបាកវេទនាផ្ទុយពីនិមិត្តនៃការបង្កើតនោះទេ ជាងនេះទៅទៀត បន្ទាប់ពីមនុស្សស្លាប់បាត់ទៅ ព្រលឹងវិញ្ញាណរបស់ពួកគេក៏ត្រូវរងទុក្ខទោសវេទនាក្រោមបណ្តាសា ព្រះពិរោធន៍ និងការជំនុំជំរះរបស់ព្រះជាម្ចាស់អស់កល្បជានិច្ចផងដែរ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានក្រើនរំលឹកម្តងហើយម្តងទៀតថា “ហើយដោយព្រោះបានដំរូវត្រូវអោយមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជំរះ” (ហេព្រើរ៩៖២៧)។ “កុំអោយឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមានពេលវេលាមកដល់ដែលអស់ទាំងខ្មោចនៅក្នុងផ្នូរនឹងលឺសម្លេងទ្រង់ ហើយនឹងចេញមក គឺពួកអ្នកដែលបានប្រព្រឹត្តិល្អគេនឹងរស់ឡើងវិញអោយបានជីវិត ឯពួកអ្នកដែលប្រព្រឹត្តិអាក្រក់វិញអោយនឹងរស់ឡើងអោយជាប់មានទោស”(យ៉ូហាន៥៖២៨-២៩)។ រីឯលោកសាវ័កប៉ុលវិញ ក៏បាននិយាយស្រដៀងគ្នានេះផងដែរថា “ដ្បិតយើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រិស្ត ដើម្បីអោយគ្រប់គ្នាបានទទួលតាមការដែលបានធ្វើ ពីកាលនៅក្នុងរូបកាយរៀងខ្លួន ទោះល្អឬអាក្រក់ក្តី”(កូរិនថូសទី២ ៥៖១០)។ មនុស្សគ្រប់ជាតិសាសន៍ គ្រប់ទីកន្លែង និងគ្រប់សម័យកាលទាំងអស់ តម្រូវអោយរស់រានមានជីវិតតែម្តងគត់ ហើយទាំងអស់គ្នានឹងត្រូវឈរនៅចំពោះព្រះជាម្ចាស់ ទទួលខុសត្រូវចំពោះរាល់អំពើបាបរៀងៗខ្លួន បន្ទាប់ពីគេស្លាប់ទៅ (ម៉ាថាយ១២៖៣៦)។ ថ្ងៃនោះនឹងមកដល់ ហើយនៅថ្ងៃនោះផងដែរ ព្រះគ្រិស្តនឹងអង្គុយលើព្រះរាជ្យបល្ល័ង្កកាត់ទោសបាបមនុស្សគ្រប់សម័យកាល និងគ្រប់ជាតិសាសន៍ទាំងអស់ ដោយយុត្តិធម៌ និងអំណាចព្រះចេស្តា (ម៉ាថាយ២៥៖៣១-៤៦)។ វរហើយមនុស្សបាប!

បើទោះបីជាយ៉ាងណាក៏ដោយ ពន្លឺនៃសេចក្តីសង្ឃឹមរបស់មនុស្សជាតិមិនទាន់ផុតរលត់សូន្យសុងទាំងស្រុងនោះទេ ដ្បិតដោយសារព្រះគុណ មនុស្សមានផ្លូវមួយដែលអាចនាំពួកគេអោយចូលទៅចំពោះព្រះជាម្ចាស់វិញបានដោយមិនត្រូវវិនាសបាត់បង់ឡើយ។ ជាបន្តមកទៀត យើងនឹងស្វែងយល់អំពីផ្លូវដ៏ពិតនោះជាមួយគ្នា តែសម្រាប់ពេលនេះវិញ គប្បីយើងត្រូវដឹងថា ការសម្រេចចិត្តរបស់មនុស្សនៅលើផែនដី មុនពេលដែលព្រះគ្រិស្តយាងត្រឡប់មកវិញជាលើកទីពីរ ជាការសម្រេចចិត្តដ៏សំខាន់បំផុតលើសអ្វីៗទាំងអស់នៅក្នុងជីវិតរបស់គេ ព្រោះមនុស្សមានជីវិតរស់នៅដើម្បីសម្រេចចិត្តតែម្តងគត់ រីឯលទ្ធផលនៃការសម្រេចចិត្តរបស់ពួកគេវិញ នឹងកំណត់អនាគតរបស់ពួកគេអស់កល្បជានិច្ច។ ដោយព្រោះអំពើបាប មនុស្សត្រូវស្លាប់ដោយជៀសមិនផុត ក៏ប៉ុន្តែសេចក្តីស្លាប់មិនមែនជាចុងបញ្ចប់នៃអ្វីៗគ្រប់យ៉ាងនោះទេ

ផ្ទុយទៅវិញ សេចក្តីស្លាប់គ្រាន់តែជាចំនុចចាប់ផ្តើមនៃការបោះជំហានឈានចូលទៅរកលទ្ធផលដ៏អស់កល្បជានិច្ចនៃការសម្រេចចិត្តរបស់មនុស្ស មុនពេលដែលគេស្លាប់តែប៉ុននោះ៕

### គ សេចក្តីសង្ឃឹមក្លែងក្លាយ

សេចក្តីស្លាប់ គឺជាដំណាក់កាលមួយនៃជីវិតដែលបុគ្គលគ្រប់ៗរូបត្រូវតែឆ្លងកាត់ ដ្បិតបុគ្គលគ្រប់ៗរូបសុទ្ធតែមានបាប ហើយឈ្នួលរបស់អំពើបាបនោះគឺជាសេចក្តីស្លាប់(រ៉ូម៦៖២៣)។ បុគ្គលគ្រប់ៗរូបភ័យខ្លាច និងព្រួយបារម្ភណ៍យ៉ាងខ្លាំងចំពោះសេចក្តីស្លាប់ ព្រោះសេចក្តីស្លាប់ជាឃាតករដែលមានអំណាចអាចឆក់យកគ្រប់យ៉ាងទាំងអស់ចេញពីជីវិតរបស់គេ ហើយលើសពីនេះទៅទៀត មនុស្សភាគច្រើនមិនដឹងជាប្រាកដសោះថា តើនឹងមានអ្វីកើតឡើងចំពោះព្រលឹងវិញ្ញាណរបស់ពួកគេបន្ទាប់ពីគេស្លាប់ទៅ? ដោយឡែក ក្នុងគោលបំណង ចង់ជៀសចេញពីទុក្ខទោសនៃអំពើបាបរបស់ខ្លួន មនុស្សបានខិតខំទ្រាំធ្វើការល្អៗជាច្រើនទាំងកាយ វាចារ ចិត្ត ខណះពេលដែលពួកគេកំពុងតែនៅរស់រានមានជីវិតលើផែនដីនៅឡើយ ដើម្បីលុបលាងអំពើបាបរបស់ខ្លួន។ មនុស្សបានព្យាយាមស្រវាចាប់យក អំពើល្អ គុណសម្បត្តិ ដោយប្រើសមត្ថភាព ព្រមទាំងកេរ្តិ៍ឈ្មោះរបស់ខ្លួន លនិងល ដើម្បីបន្តុបន្តុបគ្នាជាកាំជណ្តើរដើរឡើងទៅរកព្រះជាម្ចាស់ ហើយសង្ឃឹមថា គ្រប់យ៉ាងទាំងអស់ដែលពួកគេខិតខំសន្សំទុកខាងលើនេះ នឹងបានតម្កល់តម្កើងខ្លួនគេអោយមានតម្លៃនៅចំពោះព្រះជាម្ចាស់ ជាថ្នូរមកវិញ ព្រះជាម្ចាស់នឹងប្រោសប្រទានព្រះពរ ការប្រណីសន្តោសប្រោសមេត្តាដល់ពួកគេដើម្បីអោយបានសាកសមនឹងការល្អដែលពួកគេខិតខំប្រព្រឹត្តិ។ តាមទស្សនះរបស់មនុស្ស ពួកគេសមតែបានសោយសុខផលផ្លែពីព្រះជាម្ចាស់ តាមរយះអំពើល្អរបស់ខ្លួន។ ដូចគ្នានេះដែរ តាមចក្ខុវិស័យរបស់លោកិយ ការខិតខំប្រឹងប្រែងដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន គឺសេចក្តីសង្ឃឹមដ៏ចម្បងបំផុតមួយរបស់មនុស្សជាតិក្នុងការលុបលាងទោសនៃអំពើបាបរបស់ខ្លួន ចំពោះព្រះជាម្ចាស់ដ៏ធំឧត្តម៕

នេះមិនមែនជាត្រីវិស័យដែលមកពីព្រះជាម្ចាស់នោះទេ។ នេះគឺជាសេចក្តីសង្ឃឹមក្លែងក្លាយ។ មនុស្សជាតិមិនត្រូវបានបង្កើតមកដើម្បីអោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ដោយឯករាជ្យចេញពីព្រះជាម្ចាស់នោះទេ ពោលវត្តមានរបស់មនុស្សគឺដើម្បីពឹងផ្អែកលើព្រះជាម្ចាស់ដែលជាប្រភពដ៏ល្អឥតខ្ចោះនៃសព្វសារពើទាំងអស់ បើទោះបីជាស្ថិតនៅក្នុងកាលះទេសះបែបណាក៏ដោយ (ម៉ាថាយ៦៖២៤-៣៤ ៩៖៤)។ ក្នុងន័យដូចគ្នានេះផងដែរ មុនពេលដែលព្រះយេស៊ូគ្រិស្តយាងត្រឡប់ទៅស្ថានសួគ៍វិញ ព្រះអង្គបានសន្យាថានឹងប្រោសប្រទានព្រះវិញ្ញាណបរិសុទ្ធដល់អស់អ្នកណាដែលជឿដល់ទ្រង់ប្រយោជន៍អោយទ្រង់តែមួយអង្គគត់បានជាទីពឹងអាងដល់ពួកគេ កុំអោយពួកគេពឹងផ្អែកលើសមត្ថភាពខ្លួនឯង ព្រោះនេះមិនមែនជាគោលដៅនៃការបង្កើតទេ (កិច្ចការ១៖៤-៥ ១៖៨ យ៉ូហាន១៤៖១៥-១៧ ១៤៖២៦ រ៉ូម៨៖២៦)។ មនុស្សនឹងវង្វេងហើយហិនវិនាស ប្រសិនបើគេបដិសេធន៍ព្រះជាម្ចាស់ ហើយបែរទៅពឹងផ្អែកលើអ្វីមួយផ្សេងទៀតក្រៅពីទ្រង់។ បើទោះបីជាយ៉ាងដូច្នោះក្តី ការពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួនបានក្លាយជាគ្រឹះដ៏ធំចម្បងបំផុតមួយ នៅក្នុងស្រទាប់ដួងចិត្តរបស់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ព្រោះទស្សនះមួយនេះត្រូវគ្នាទៅនឹងចិត្តប៉ះបោររបស់មនុស្សដែលទោរទន់ទៅរកការទុកចិត្តលើខ្លួនឯង ជាជាងការទុកចិត្តលើព្រះជាម្ចាស់។ មួយវិញទៀត ទស្សនះមួយនេះបានអនុញ្ញាតអោយមនុស្សអាចបន្តធ្វើជាស្តេចគ្រប់គ្រងលើបល្ល័ង្កចិត្តរបស់ខ្លួនឯង ជាជាងផ្ទេរអំនាចដល់ព្រះជាម្ចាស់។ ទស្សនះមួយនេះ បំពេញអំនួត

របស់មនុស្សដែលចង់អោយអ្នកដទៃលើកសរសើរតម្កើងកេរ្តិ៍ឈ្មោះរបស់គេ។ ស្របពេលជាមួយគ្នានេះផងដែរ ការពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួនបានធ្វើអោយមនុស្សយល់ថាខ្លួនគេមានតម្លៃ ជាបុគ្គលដ៏ជោគជ័យ អស្ចារ្យ លនិងល ព្រោះគេបានសម្រេចកិច្ចការណាមួយដោយខ្លួនឯង ហើយលើសពីនេះទៅទៀត ឧត្តមភាពដែលកើតចេញពីការពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួននេះ បានលាក់បាំងកំសោយ និងភាពអាម៉ាស់របស់មនុស្សចំពោះសង្គម និងជាពិសេសគឺចំពោះព្រះជាម្ចាស់។ តាមនិស្ស័យបាបរបស់មនុស្ស មនុស្សមានអំនួត ហើយគេមិនអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដោយដៃទទេរនោះទេ ពោលគឺគេត្រូវតែពឹងផ្អែកលើសមត្ថភាពខ្លួនឯងដើម្បីសម្រេចកិច្ចការណាមួយជាមុនសិន ដើម្បីអោយខ្លួនគេមានតម្លៃ ហើយសាកសមនឹងចូលទៅជិតព្រះដ៏ពេញដោយសិរីល្អ ដើម្បីកុំអោយគេត្រូវខ្មាស់៕

តាមពិត! ទស្សនៈខ្លួនទីពឹងខ្លួន គឺជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបំផុតមួយរបស់មនុស្សជាតិនៅចំពោះព្រះជាម្ចាស់។ ជាងនេះទៅទៀត ទស្សនៈខ្លួនទីពឹងខ្លួន ជាឧបសគ្គរាំងសេចក្តីសង្គ្រោះពីមនុស្សដែលបាត់បង់ ក៏ដូចជារាំងមនុស្សមិនអោយរស់នៅដោយពឹងផ្អែកលើព្រះជាម្ចាស់ ស្របតាមជានិមិត្តនៃការបង្កើត៕

ដោយឡែក ទស្សនៈខ្លួនទីពឹងខ្លួនបានដើរតួប្រលូកក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ចាប់តាំងពីសម័យមនុស្សដើមដំបូងមកម្ល៉េះ។ ជាក់ស្តែង ដោយចិត្តចង់បានដូចជាព្រះ មនុស្សដំបូងបានបែរខ្នងដាក់ព្រះជាម្ចាស់ បដិសេធន៍គ្រប់យ៉ាងទាំងអស់ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេ ដោយទុកចិត្តលើការសម្រេចចិត្តរបស់ខ្លួនតាមពាក្យកុហករបស់អារក្សសាតាំង ហើយស៊ីផ្លែឈើដឹងខុសត្រូវដែលព្រះជាម្ចាស់បានហាមប្រាម (លោកុប្បត្តិ៣)។ មនុស្សបានទុកចិត្តលើអារក្សសាតាំង និងខ្លួនឯង ជាជាងព្រះជាម្ចាស់។ មនុស្សដំបូងបានបោះបង់ចោលឧត្តមភាពដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេ ហើយពឹងផ្អែកលើខ្លួនឯងដើម្បីស្វែងរកឧត្តមភាពដែលពួកគេប៉ងប្រាថ្នាទៅវិញ។ ការធ្លាក់ចុះរបស់មនុស្សដំបូងជាភស្តុតាងបង្ហាញថា មនុស្សមិនចង់ពឹងផ្អែកលើព្រះជាម្ចាស់ទៀតទេ។ ស្របពេលជាមួយគ្នានេះផងដែរ បន្ទាប់ពីអាដាំ និងអេវ៉ាបានធ្វើបាបភ្លាម “នោះស្រាប់តែភ្នែករបស់អ្នកទាំងពីរបានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បាំង”(លោកុប្បត្តិ៣:៧)។ ដោយឡែក សម្រាប់ដំណោះស្រាយរបស់មនុស្សដំបូងចំពោះអំពើបាបរបស់ខ្លួន គឺការពឹងផ្អែកលើសមត្ថភាពខ្លួនឯង ជាជាងចូលទៅរកសូមជំនួយពីព្រះជាម្ចាស់។ ព្រះបន្ទូលបានចង្អុលបង្ហាញថា មនុស្សដំបូងបានខិតខំទ្រាំប្រឹងប្រែងយកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បាំង (លោកុប្បត្តិ២:១៦-១៧) ដោយរំពឹងទុកថា ពួកគេអាចបិទបាំងភាពអាម៉ាស់របស់ខ្លួនចំពោះគ្នាទៅវិញទៅមក និងជាពិសេសគឺចំពោះព្រះជាម្ចាស់។ អាដាំ និងអេវ៉ាយល់អំពីទោសនៃអំពើបាបរបស់ខ្លួន ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់ពួកគេរួចជាមុនហើយ (លោកុប្បត្តិ២:១៧) បើទោះបីជាយ៉ាងដូច្នោះក្តី មនុស្សដំបូងសង្ឃឹមថា ការខិតខំធ្វើប្រដាប់បាំងបិទបាំងភាពអាម៉ាស់របស់ខ្លួន នឹងបណ្តាលអោយព្រះជាម្ចាស់សព្វព្រះហឫទ័យ ហើយទទួលយកពួកគេដូចដើមវិញ។ ដូច្នោះ យើងឃើញថា ចាប់តាំងពីដើមដំបូងមកម្ល៉េះ មនុស្សដំបូងបង្អស់បានឈរលើទស្សនៈ ខ្លួនទីពឹងខ្លួន ដើម្បីលុបលាងទោសនៃអំពើបាប និងភាពអាម៉ាស់របស់ពួកគេនៅចំពោះព្រះជាម្ចាស់ ក៏ដូចជាដើម្បីទទួលបានការសន្តោសប្រោសប្រណីពីព្រះជាម្ចាស់ផងដែរ៕

ដូចជាមនុស្សដំបូងផងដែរ មនុស្សជាច្រើនគិតថាប្រសិនបើគេធ្វើល្អគ្រប់គ្រាន់ នោះព្រះជាម្ចាស់នឹងសព្វព្រះហឫទ័យ ហើយទទួលយកគេវិញ។ ក្នុងគោលបំណងឆ្លើយតបទៅនឹងទស្សនៈខាងលើ ជាបឋម គប្បីយើងត្រូវយល់ថា តើព្រះជាម្ចាស់មានព្រះតំរិះយ៉ាងណាចំពោះអំពើល្អរបស់មនុស្ស? តើព្រះជាម្ចាស់សព្វព្រះហឫទ័យអោយមនុស្ស

ប្រព្រឹត្តិល្អដែរឬទេ? ពិតប្រាកដណាស់! “ដ្បិតយើងរាល់គ្នាជាស្នាដៃដែលទ្រង់បង្កើតក្នុងព្រះគ្រិស្តយេស៊ូវសម្រាប់ការល្អដែលព្រះបានរៀបចំជាមុនអោយយើងរាល់គ្នាប្រព្រឹត្តិតាម” (អេភេសូ២៖១០) ក៏ប៉ុន្តែប្រសិនបើមនុស្សធ្វើល្អដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន តាមផ្លូវរបស់ខ្លួន នោះអំពើល្អរបស់គេគឺគ្មានន័យ និងគ្មានតម្លៃអ្វីសោះឡើយនៅចំពោះព្រះជាម្ចាស់។ លោកយ៉ូហានបានប្រដូចការនេះទៅនឹងខ្នែងដែលដាច់ចេញពីគល់ ដែលមិនអាចបង្កើតផលផ្លែជាទីសព្វព្រះឬទ័យដល់ព្រះជាម្ចាស់បានឡើយ (យ៉ូហាន១៥៖៤-៧)។ ដូចគ្នានេះដែរ បន្ទាប់ពីមនុស្សដំបូងបានធ្វើបាប ពួកគេប្រៀបបានដូចជាខ្នែងដែលបានដាច់ចេញពីគល់ រីឯការខិតខំរបស់ពួកគេដើម្បីផ្គាប់ព្រះហឬទ័យរបស់ព្រះជាម្ចាស់ ត្រូវបានបដិសេធន៍ចោលទាំងស្រុង ព្រោះវាមិនល្អគ្រប់គ្រាន់ចំពោះព្រះជាម្ចាស់។ ដោយព្រោះអំពើបាប មនុស្សប្រៀបបានដូចជាដើមឈើអាក្រក់ ដែលមិនអាចផ្តល់ផលផ្លែល្អជាទីគាប់ព្រះហឬទ័យដល់ព្រះជាម្ចាស់បានឡើយ។ លោកអេសាយបាននិយាយថា “ដ្បិតយើងខ្ញុំទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្សដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំក៏ដូចជាអាវកខ្វក់....... ”(អេសាយ៦៤៖៦)។ ការនេះគឺបានសេចក្តីថា មនុស្សមិនអាចយកអំពើល្អរបស់ខ្លួនដើម្បីចងស្ពានមេត្រីជាមួយនឹងព្រះជាម្ចាស់ឡើងវិញនោះទេ។

ក្នុងនាមជាមនុស្សបាបដែលខ្វះមិនដល់សិរីល្អរបស់ព្រះជាម្ចាស់ យើងមិនអាចយកសមត្ថភាពផ្ទាល់ខ្លួនជាថ្នូរដោះដូរយកសេចក្តីសង្គ្រោះដ៏ថ្លៃថ្លាពីព្រះជាម្ចាស់បានឡើយ។ ជាក់ស្តែង ប្រសិនបើយើងក្រឡេកទៅមើលបញ្ញត្តិដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ប្រជារាស្ត្ររបស់ទ្រង់វិញ (និក្ខមនំ២០៖១-១៧) នោះយើងឃើញថា បញ្ញត្តិទាំងនោះបានចង្អុលចំៗចំពោះអំពើបាបរបស់មនុស្ស ដែលគ្មាននរណាម្នាក់មានសមត្ថភាពអាចធ្វើបានតាមការទាមទាររបស់ព្រះជាម្ចាស់សោះឡើយ ពោលគឺមនុស្សត្រូវការផ្លូវមួយផ្សេងទៀត ដើម្បីជួយសង្គ្រោះពួកគេ ក្រៅពីខ្លួនទីពឹងខ្លួន។ “មនុស្សមិនអាចរកបានសេចក្តីសុចរិត ដោយការខិតខំរបស់ខ្លួនផ្ទាល់នោះឡើយ បើយោងតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់មនុស្សទាំងអស់សុទ្ធតែមានទោស
ហើយត្រូវទទួលការកាត់ទោស” [15]។ គ្រប់ជំនាន់ទាំងអស់ មនុស្សបាបធ្វើបាប តាំងពីអតីតកាល បច្ចុប្បន្នកាល និងសូម្បីតែអនាគតដែលមិនទាន់នឹងឈានចូលមកដល់ផង ដូច្នោះការរំពឹងចង់ក្លាយខ្លួនជា សុចរិត បរិសុទ្ធ ល្អឥតខ្ចោះមួយរយភាគរយ ទាំងកាយ វាចារ ចិត្ត ស្របតាមស្តង់ដារបស់ព្រះដ៏សុចរិតនោះមិនអាចទៅរួចទេ។ មនុស្សបាបគ្មានសង្ឃឹមនឹងបានល្អគ្រប់គ្រាន់ ដើម្បីឈរនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដោយសំអាងលើសមត្ថភាពផ្ទាល់ខ្លួនឡើយ។ “គ្មានអ្នកណាដែលអាចសន្សំបុណ្យកុសល ឬអំពើល្អដែលអាចអោយអ្នកនោះយកមកដោះដូរទៅនឹងបាបរបស់ខ្លួនបានឡើយ ប៉ុន្តែអាចមានអ្នកខ្លះដែលមើលទៅហាក់ដូចជាប្រសើរជាងអ្នកឯទៀត ហើយដូចជាមានបុណ្យជាងអ្នកដ៏ទៃទៀត ប៉ុន្តែបុណ្យកុសលនោះគ្មានតម្លៃនៅចំពោះព្រះទេ” [16]។ ដោយឡែក នៅក្នុងសង្គមខ្មែរមានពាក្យប្រៀនប្រដៅជាច្រើនដែលបានឆ្លុះបញ្ចាំងថា មនុស្សបាបមិនអាចបានជាសុចរិតបរិសុទ្ធ និងល្អឥតខ្ចោះមួយរយភាគរយដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួនឡើយ។ គួយ៉ាងដូចជាពំនោលដែលថា “ធ្វើបុណ្យ១០០សំពៅ បាប១ចូលទៅរលាយបាត់” និង “ឯបុណ្យប្រៀប

---

[15] សងជាសម្រេច និពន្ធដោយលោករីឆាត រ៉ុដើរ ទំព័រ៣៥

[16] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. គ្រោលី ទំព័រ៨២

ដូចជាទឹកដែលស្រក់ដក់នៅលើស្លឹកឈូក គ្រាន់តែផ្អៀងល្អៀងតែបន្តិចប៉ុននោះ ក៏គង់កំពប់ខូចខាតអស់ទៅដែរ” ជាដើម។ សូមសាកគិតអំពីការប្រព្រឹត្តិ ចិត្តគំនិត និងពាក្យសំដីរបស់អ្នក ចាប់តាំងពីពេលដែលអ្នកភ្ញាក់ពីដំណេករហូតមកទល់ពេលនេះ តើអ្នកបានធ្វើបាបដែរឬទេ? គិតអាក្រក់ដែរឬទេ? ច្រណែនដែរឬទេ? ប្រើពាក្យមិនគប្បីដែរឬទេ? មើលអ្វីដែលត្រឹមត្រូវដែរឬទេ? បានថ្វាយសិរីល្អដល់ព្រះដែរឬទេ? លនិងល ហើយសូមគិតយ៉ាងដូច្នោះដដែលសម្រាប់មួយថ្ងៃពេញ សម្រាប់២ថ្ងៃ ៣ថ្ងៃ មួយអាទិត្យ មួយខែ ហើយសូមគិតរហូតដល់មួយឆ្នាំ។ ពិតប្រាកដណាស់! ប្រសិនបើអ្នករាប់ចំនួនដើម្បីទុកជាការទូទាត់រវាងអំពើល្អ និងអំពើអាក្រក់របស់អ្នក នោះអ្នកនឹងឃើញថាអំពើអាក្រក់របស់អ្នក មិនមែន១០០ ឬ ២០០នោះទេ តែគឺរាប់ភ្លេច។ រីឯព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ការទាមទាររបស់ព្រះជាម្ចាស់គឺភាពឥតខ្ចោះ ល្អបរិសុទ្ធមួយរយភាគរយ ហើយអំពើបាបដ៏តូចល្អិតបំផុតមួយក៏មិនត្រូវបានអនុញ្ញាតសោះឡើយ នៅក្នុងព្រះវត្តមានរបស់ទ្រង់ (កាឡាទី៣៖១០ យ៉ាកុប២៖១០)។ ដោយសំអាងលើសំដីរបស់លោកសាវ័កប៉ុលមនុស្សមិនអាចសម្រេចបានតាមការទាមទារមួយនេះជាដាច់ខាត “ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ” (រ៉ូម៣៖២៣)។ នៅលើលោកនេះ ពិតជាមានមនុស្សល្អជាច្រើន ដែលបានធ្វើការល្អរាប់មិនអស់ ក៏ប៉ុន្តែអំពើល្អទាំងអស់នោះមិនមែនជាការទាមទាររបស់ព្រះជាម្ចាស់ ប្រយោជន៍អោយពួកគេបានចូលទៅក្នុងនគរស្ថានសួគ៌ដ៏ឧត្តុងឧត្តមរបស់ទ្រង់ឡើយ។ លើសពីនេះទៅទៀត អំពើល្អទាំងអស់នោះសុទ្ធតែមិនត្រឹមត្រូវតាមស្តង់ដានៃការទាមទាររបស់ព្រះជាម្ចាស់។ អ្នកនិពន្ធសៀវភៅ “ស្គាល់អ្នកណាដែលអ្នកជឿតាម” ក៏បានបន្ថែមផងដែរថា “យើងប្រហែលជាគ្រាន់បើជាងអ្នកដ៏ទៃទៀត
ប៉ុន្តែអ្នកដ៏ទៃទៀតមិនមែនជាខ្នាតរង្វាស់សម្រាប់យើងទេ” [17]៕

ព្រះជាម្ចាស់បានកំណត់ស្តង់ដាដោយផ្ទាល់អង្គទ្រង់ សម្រាប់អស់អ្នកណាដែលប្រាថ្នាចង់ចូលទៅសោយសុខក្នុងនគរស្ថានសួគ៌តែមួយគត់របស់ទ្រង់។ អ្នកនោះត្រូវតែបរិសុទ្ធ ឥតខ្ចោះ ដូចទ្រង់ដែរ។ នេះគឺជាស្តង់ដាដ៏ពិតប្រាកដតែមួយគត់! ភាពបរិសុទ្ធ ឥតខ្ចោះ គឺជាសេចក្តីសង្ឃឹមដ៏ពិតប្រាកដតែមួយគត់សម្រាប់ចូលទៅក្នុងនគរស្ថានសួគ៌៕

### ឃ ត្រីវិស័យដ៏ពិតប្រាកដ

> “.... នោះហ្ន៎! កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក ........” (យ៉ូហាន១៖២៩)។

ស្នាព្រះហស្តដ៏ល្អឥតខ្ចោះ និងជាទីសព្វព្រះរាជហឫទ័យរបស់ព្រះជាម្ចាស់ បានត្រឡប់ដូចជាក្រណាត់ដ៏ខ្មៅកខ្វក់គួរអោយស្អប់ខ្ពើមបំផុតមួយ ក្រោមព្រះពិរោធន៍របស់ទ្រង់ផ្ទាល់។ បើជីវិតរបស់មនុស្សកើតមកដើម្បីរងទុក្ខទោសក្រោមបណ្តាសារបស់ព្រះជាម្ចាស់ នោះជីវិតគ្មានន័យអ្វីទាំងអស់។ ដូចគ្នានេះដែរ គម្រោងផែនការណ៍របស់ព្រះជាម្ចាស់ក្នុងការបង្កើត ក៏គ្មានន័យអ្វីដែរ ពោលគឺព្រះជាម្ចាស់បានចំណាយពេលវេលាក្នុងការបង្កើតដោយឥតប្រយោជន៍។ តើព្រះជាម្ចាស់នឹងឆ្លើយតបយ៉ាងណាចំពោះការធ្លាក់ចុះរបស់មនុស្សជាតិ? ជាងនេះទៅទៀត តើ

---

[17] ស្គាល់អ្នកណាដែលអ្នកជឿតាម និពន្ធដោយលោកប៉ុល អ៊ី. លីតផល ទំព័រ១៩

ព្រះជាម្ចាស់មានគម្រោងផែនការណ៍យ៉ាងណាខ្លះ ដើម្បីដឹកនាំមនុស្សចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ដូចដើមវិញ? ជាការពិតណាស់ ព្រះជាម្ចាស់ស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ ទើបព្រះអង្គបានប្រោសប្រទានត្រីវិស័យដ៏ជាក់លាក់ ហើយពិតប្រាកដតែមួយគត់ដើម្បីដឹកនាំមនុស្សអោយបានផ្សះផ្សាជាមួយនឹងទ្រង់វិញ។ រីឯការនេះទៀតសោះ គឺមិនអាស្រ័យលើមនុស្សដែលល្អល្មមសាកសមនឹងទទួលយកសេចក្តីមេត្តាករុណាពីព្រះដ៏បរិសុទ្ធឡើយ ផ្ទុយទៅវិញ ការនេះគឺអាស្រ័យលើព្រះគុណរបស់ព្រះជាម្ចាស់ទាំងស្រុង។ នេះគឺជាដំណឹងល្អដ៏ពិតប្រាកដសម្រាប់មនុស្សបាបគ្រប់ជាតិសាសន៍ទាំងឡាយ ដែលកំពុងតែវង្វេងបាត់បង់៕

លោកអេសាយបានលើកឡើងថា “ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា យញ្ញបូជាដ៏មានច្រើនម្លេះរបស់ឯងរាល់គ្នា តើជាអ្វីដល់អញ អញធុញទ្រាន់ចំពោះចៀមឈ្មោល និងខ្លាញ់នៃសត្វបំប៉នដែលឯងដុតថ្វាយណាស់ អញក៏មិនចូលចិត្តចំពោះឈាមនៃគោលឈ្មោល ឬកូនចៀម ឬពពែនោះទេ កាលណាឯងរាល់គ្នាលេចមកនៅចំពោះអញ នោះតើអ្នកណាមានបង្គាប់អោយឯងរាល់គ្នាធ្វើយ៉ាងដូច្នោះ ដើម្បីអោយបានចូលមកជាន់ទីលានរបស់អញ កុំអោយយកដង្វាយដ៏ឥតប្រយោជន៍មកទៀតឡើយ ឯកំញានជារបស់ស្អប់ខ្ពើមដល់អញ ឯបុណ្យចូលខែ និងថ្ងៃឈប់សម្រាក ព្រមទាំងការប្រជុំជំនុំ នោះអញទ្រាំមិនបានទេ សូម្បីតែបុណ្យប្រជុំជំនុំមុតមាំ ក៏ជាអំពើទុច្ចរិតដែរ ចិត្តអញស្អប់ចំពោះបុណ្យចូលខែ និងបុណ្យមានកំណត់ទាំងប៉ុន្មានរបស់ឯងរាល់គ្នាណាស់ ពិធីទាំងនោះជាបន្ទុកសង្កត់លើអញជាខ្លាំង អញក៏នឿយណាយដោយទ្រាំចំពោះការទាំងនោះ” (អេសាយ១៖១១-១៤)។ ក្នុងន័យដូចគ្នានេះផងដែរ ព្រះដ៏សុចរិតបានមានព្រះបន្ទូលយ៉ាងច្បាស់ថា “ដ្បិតអញពេញចិត្តចំពោះសេចក្តីសប្បុរស មិនមែនចំពោះយញ្ញបូជាទេ ហើយពេញចិត្តចំពោះការស្គាល់ព្រះជាជាងការថ្វាយដង្វាយដុតទៅទៀត”(ហូសេ៦៖៦ សូមមើលម៉ាថាយ៩៖១៣ ហេព្រើរ១០៖៦-៨ សាំយ៉ូអែលទី១ ១៥៖២២ អេម៉ុស៥៖២១-២៦)។ មនុស្សមិនអាចនាំយកអំពើល្អ និងបុណ្យកុសលរបស់ខ្លួនសម្រាប់ជាយញ្ញបូជាថ្វាយដល់ព្រះជាម្ចាស់ ដើម្បីជាថ្នូរដោះដូរយកសេចក្តីសង្គ្រោះពីទ្រង់ឡើយ ព្រោះគ្រប់យ៉ាងទាំងអស់ដែលមនុស្សបាបខិតខំរៀបចំសន្សំតម្កល់តម្កើងខ្លួនឡើងទៅកាន់ព្រះជាម្ចាស់ សុទ្ធតែជិតដាមជាប់ដោយអំពើបាបដែលខ្វះមិនដល់ស្តង់ដាររបស់ទ្រង់ ហើយព្រះដ៏បរិសុទ្ធមិនទទួលយកភាពមិនគ្រប់លក្ខណ៍ជាដាច់ខាត (ទំនុកតម្កើង៥១៖១៦)។ ផ្ទុយទៅវិញ ព្រះដ៏សុចរិតសព្វព្រះហឫទ័យអោយមនុស្សដែលព្រះអង្គបានបង្កើតមកដោយផ្ទាល់បានស្គាល់ទ្រង់វិញ ជាជាងគ្រាន់តែនាំយកដង្វាយដើម្បីថ្វាយដល់ទ្រង់ ដោយគ្មានទំនាក់ទំនងជាមួយនឹងទ្រង់សោះ។ យើងអាចនិយាយបានថា ផ្លូវដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ គឺចាប់ផ្តើមពីការស្គាល់ និងមានទំនាក់ទំនងជាមួយនឹងម្ចាស់ស្ថានសួគ៌៕

តើអ្វីដែលជាដំណោះស្រាយរបស់ព្រះដ៏សុចរិតចំពោះអំពើបាបរបស់មនុស្ស? ដំណឹងល្អ គឺស្តង់ដាដ៏គ្រប់លក្ខណ៍ដែលព្រះជាម្ចាស់បានទាមទារពីមនុស្សបាប គឺព្រះអង្គផ្ទាល់ជាអ្នកប្រោសប្រទានអោយដល់ពួកគេ ដោយព្រះគុណ។ “ដំណោះស្រាយនៃអំពើបាបគឺចេញមកពីអង្គព្រះផ្ទាល់។ យើងមិនអាចធ្វើការផ្សះផ្សារវាងយើង និងព្រះបានទេ គឺព្រះផ្សះផ្សាយើងជាមួយនឹងអង្គទ្រង់វិញ
ដោយតម្លៃមិនអាចកាត់ថ្លៃបានរបស់ទ្រង់” [18] ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចង្អុលបង្ហាញយ៉ាងច្បាស់ណាស់ថា គ្មាន

---

[18] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. គ្រោលី ទំព័រ១៤

នរណាម្នាក់អាចឡើងទៅឯព្រះជាម្ចាស់បានឡើយ តែគឺព្រះជាម្ចាស់ផ្ទាល់ដែលបានយាងចុះមករកមនុស្ស ដើម្បីដឹកនាំមនុស្សអោយទៅដល់ឯទ្រង់វិញ (យ៉ូហាន៣៖១៣)៕

សេចក្តីសង្ឃឹមដ៏ពិតប្រាកដ៖ កាលពីប្រមាណជាង៧០០ឆ្នាំមុនគស លោកហោរ៉ាអេសាយបានឆ្លុះបញ្ចាំងពីពន្លឺនៃសេចក្តីសង្ឃឹមដ៏ពិតប្រាកដមួយដល់មនុស្សបាបទាំងពួង ដោយលោកបានលើកឡើងថា មើលហ្ន៎! នឹងមានបុត្រមួយកើតដល់យើង ជាព្រះពរសម្រាប់យើង និងជាសេចក្តីសង្ឃឹមដល់យើងទាំងអស់គ្នា (អេសាយ៧៖១៤ ៩៖៦-៧)។ លោកហោរ៉ារូបនេះ មិនត្រឹមតែបានព្យាករណ៍ទុកអំពីការយាងមកដល់របស់ព្រះរាជបុត្រាអង្គនោះឡើយ លើសពីហ្នឹងទៅទៀត លោកអេសាយ រួមជាមួយនឹងហោរ៉ាដ៏ទៃផ្សេងៗទៀត ក៏បានគូសវាសបញ្ជាក់ប្រាប់យ៉ាងលំអិតផងដែរអំពីលក្ខណះរបស់ព្រះបុត្រអង្គនោះ។ យើងអាចនិយាយបានថា តាមរយះពួកហោរ៉ារបស់ព្រះជាម្ចាស់ ព្រះអង្គបានបង្ហើបបង្ហាញព្រះសង្គ្រោះដល់មនុស្ស ប្រយោជន៍អោយពួកគេបានត្រៀមចិត្តទទួលយកទ្រង់រួចជាស្រេចហើយ។ មួយវិញទៀត ខណះពេលដែលទេវតាលេចមកឯនាងម៉ារ៉ា និងលោកយ៉ូសែប ទេវតាបានជូនដំណឹងដល់ពួកគេក្នុងពេលវេលាផ្សេងៗគ្នាថា “មើលនាងនឹងមានគភ៌ប្រសូតបានបុត្រាមួយ ដែលត្រូវថ្វាយព្រះនាមថា “យេស៊ូវ” បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ថាជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត ព្រះអម្ចាស់ដ៏ជាព្រះ .... ហើយរាជ្យទ្រង់នឹងមិនផុតឡើយ” (លូកា១៖៣១-៣៣)។ “នាងនឹងប្រសូតបានបុត្រា១ ហើយត្រូវថ្វាយព្រះនាមថា “យេស៊ូវ” ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ អោយរួចពីបាប” (ម៉ាថាយ១៖២១)។ ដោយឡែក ក្នុងអំឡុងពេលដែលព្រះយេស៊ូគ្រិស្តមានព្រះជន្មគង់នៅលើផែនដីនៅឡើយ ព្រះអង្គបានអះអាងទទួលស្គាល់ដោយផ្ទាល់ម្តងហើយម្តងទៀតថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះដែលត្រូវយាងចុះមកដើម្បីសង្គ្រោះមនុស្សជាតិទាំងឡាយតាមគម្រោងផែនការណ៍របស់ព្រះដ៏ជាព្រះ តាំងពីដើមដំបូងមកម្លេះ (ម៉ាថាយ៥៖១៧ លូកា២៤៖១៣-៣៣ យ៉ូហាន៨៖៤៨-៥៩)។ ដូចគ្នានេះដែរ ការអះអាងរបស់ព្រះយេស៊ូវគ្រិស្ទ គឺជាគោលជំនឿដ៏សំខាន់បំផុតតែមួយគត់ ដែលព្រះគម្ពីរសញ្ញាថ្មីព្យាយាមចង្អុលបង្ហាញបង្រៀនដល់មនុស្សបាបគ្រប់ជាតិសាសន៍ទាំងឡាយ ប្រយោជន៍អោយពួកគេបានឃើញ និងស្គាល់អត្តសញ្ញាណដ៏ពិតប្រាកដរបស់ទ្រង់ ហើយទទួលជឿ ដើម្បីបានសង្គ្រោះ ជៀសចេញផុតពីបណ្តាសា និងព្រះពិរោធន៍របស់ព្រះជាម្ចាស់អស់កល្បជានិច្ច (យ៉ូហាន១៖១-៣ ១៖១៤ ៣៖១៥-១៨)។ ដំណឹងល្អដែលត្រូវបានរំលេចឡើងស្ទើតែគ្រប់ទំព័រទាំងអស់នៃព្រះគម្ពីរសញ្ញាថ្មីគឺ ព្រះយេស៊ូវគ្រិស្តគឺជាដំណោះស្រាយ និងជាសេចក្តីសង្ឃឹមដ៏ពិតប្រាកដមួយគត់ដែលមនុស្សបាបបានទន្ទឹងរង់ចាំ៕

ព្រះយេស៊ូវគ្រិស្ទដ៏បរិសុទ្ធ៖ ដើម្បីមនុស្ស ព្រះដ៏បរិសុទ្ធបានលះបង់ និងចាកចោលសិរីល្អ ត្រឡប់ជាសាច់ឈាមហើយមកស្នាក់នៅក្នុងចំណោមបណ្តាមនុស្សបាបទាំងឡាយ (យ៉ូហាន១៖១៤)។ ថ្វីបើព្រះយេស៊ូវគ្រិស្តបានយករូបអង្គបែបដូចជាសាច់ឈាមដែលតែងតែជាប់មានបាបយ៉ាងណាក្តី (រ៉ូម៨៖៣) ក៏ប៉ុន្តែ ក្នុងនាមជាព្រះរាជបុត្រានៃព្រះដ៏បរិសុទ្ធ ព្រះយេស៊ូគ្រិស្តល្អបរិសុទ្ធ ឥតមានបាប ឥតពុតមាយា ឥតសៅហ្មង ឥតខ្ចោះ ហើយព្រះអង្គបានញែកអង្គទ្រង់ចេញពីអំពើបាបទាំងអស់របស់មនុស្សទាំងឡាយ (ហេព្រើរ៧៖២៦)។ តួយ៉ាង លោកយ៉ូហានបាននិយាយថា ព្រះអង្គគ្មានបាបសោះ (យ៉ូហានទី១ ៣៖៥)។ ចំណែកលោកពេត្រុសបានប្រាប់ទៀតថា “ទ្រង់មិនបានធ្វើបាបអ្វីសោះ ក៏មិនឃើញកិច្ចកលអ្វីនៅព្រះឱស្ឋទ្រង់ឡើយ” (ពេត្រុសទី១ ២៖២២)។ ឯអ្នកនិពន្ធកណ្ឋំគម្ពីរហេព្រើរវិញ ក៏បានលើកឡើងស្រដៀងគ្នាផងដែរថា “..... ទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាងដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបានឡើយ”(ហេព្រើរ៤៖១៥)។ លើស

ពីនេះទៅទៀត លោកពីឡាត់ដែលជាចៅក្រមកាត់ទោសព្រះយេស៊ូវគ្រិស្តបានប្រកាសដោយផ្ទាល់ ហើយបើកចំហរថា ព្រះយេស៊ូវគ្រិស្តជាមនុស្សសុចរិតគ្មានទោសពៃរ៍ទេ (ម៉ាថាយ២៧៖២៤)។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានធ្វើបន្ទាល់ជាបន្តបន្ទាប់ថា ព្រះយេស៊ូគ្រិស្តគឺជារូបអង្គនៃព្រះដ៏មើលមិនឃើញ (កូឡូស១៖១៥) ល្អ បរិសុទ្ធ គ្មានបាបសោះនៅចំពោះព្រះជាម្ចាស់ ហើយក៏គ្មាននរណាម្នាក់ដូចព្រះអង្គសោះឡើយ (និក្ខមនំ១៥៖១១)។ ព្រះយេស៊ូវគ្រិស្ទ ផ្ទុកនូវភាពសុចរិតដ៏ល្អឥតខ្ចោះ ដូចជាព្រះអម្ចាស់ដែរ ហើយភាពសុចរិតដ៏ល្អឥតខ្ចោះដែលព្រះយេស៊ូវគ្រិស្ទមាន គឺជាតម្រូវការដ៏ចាំបាច់មួយរបស់មនុស្សជាតិ ដើម្បីជាស្ពានឈានចូលទៅផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់។ ព្រះយេស៊ូវគ្រិស្ទកាន់កូនសោរដ៏សំខាន់បំផុតមួយដែលមនុស្សត្រូវការដើម្បីសេចក្ដីសង្គ្រោះ៕

ត្រឡប់ជាតួបាបដើម្បីមនុស្សបាបៈ លោកសាវ៍កប៉ុលបានលើកឡើងថា "... ព្រះអង្គមិនដែលស្គាល់បាបសោះ នោះទ្រង់បានធ្វើអោយត្រឡប់ជាតួបាបជំនួសយើងរាល់គ្នា ដើម្បីអោយយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង" (កូរិនថូសទី២ ៥៖២១ សូមមើល ១ពេត្រុស២៖២២-២៤ ២កូរិនថូស៥៖២១ ១យ៉ូហាន៣៖៥)។ ព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ព្រះដ៏បរិសុទ្ធបានត្រឡប់ជាតួបាប ដើម្បីមនុស្សបាបបានត្រឡប់ជាបរិសុទ្ធដូចទ្រង់វិញនៅចំពោះព្រះជាម្ចាស់។ ស្របពេលជាមួយគ្នានេះផងដែរ តាមរយះការត្រឡប់ជាតួបាប ព្រះយេស៊ូវគ្រិស្តបានទទួលយកគ្រប់យ៉ាងទាំងអស់ដែលមនុស្សបាបសមតែទទួល ដោយរាប់បញ្ចូលទាំងសេចក្ដីស្លាប់ក្រោមការវិនិច្ឆ័យរបស់ព្រះវរបិតាផងដែរ ហើយផលដែលហុចអោយមកវិញគឺ មនុស្សបាបបានទទួលយកគ្រប់យ៉ាងទាំងអស់ដែលជារបស់ទ្រង់ ដែលពួកគេមិនសមនឹងទទួលសោះឡើយ (អេសាយ៥៣)។ នេះគឺជាដំណឹងល្អ។ សេចក្ដីសុចរិតដែលមនុស្សត្រូវការជាចាំបាច់ដើម្បីឆ្លើយតបទៅតាមការទាមទាររបស់ព្រះដ៏សុចរិត ត្រូវបានប្រោសប្រទានដល់ពួកគេ មិនមែនដោយព្រោះពួកគេល្អល្មមនោះទេ ផ្ទុយទៅវិញដោយព្រោះព្រោះគុណតែមួយគត់របស់ព្រះជាម្ចាស់ ដោយព្រោះព្រះអង្គល្អ និងដោយព្រោះព្រះអង្គស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានលើកឡើងថា "ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយគត់ ដើម្បីអោយអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ" (យ៉ូហាន៣៖១៦)។ "ព្រះយេហូវ៉ាទ្រង់ល្អដល់មនុស្សទាំងអស់ ហើយព្រះហឫទ័យទន់សន្ដោសរបស់ទ្រង់ក៏គ្របលើកិច្ចការរបស់ទ្រង់ទាំងប៉ុន្មាន" (ទំនុកតម្កើង១៤៥៖៩)។ "…. ដែលទ្រង់សព្វព្រះហឫទ័យអោយមនុស្សទាំងអស់បានសង្គ្រោះ ហើយអោយបានស្គាល់សេចក្ដីពិត" (ធីម៉ូថេទី១ ២៖៤)។ ព្រះអង្គមិនសព្វព្រះហឫទ័យនឹងឃើញស្នាព្រះហស្តរបស់ទ្រង់ផ្ទាល់ ឆ្លងកាត់ព្រះពិរោធន៍របស់ទ្រង់សោះឡើយ ដូចដែលលោកហោរ៉ាអេសេគាលបានលើកឡើងថា "ចូរប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាអញមិនរីករាយចំពោះសេចក្ដីស្លាប់របស់មនុស្សអាក្រក់ឡើយ គឺចូលចិត្តអោយគេលះចោលផ្លូវរបស់ខ្លួន ហើយមានជីវិតរស់នៅវិញទេតើ ចូរអោយឯងរាល់គ្នាបែរមក ចូរបែរមកពីផ្លូវអាក្រក់របស់ខ្លួនចុះ..... " (អេសេគាល៣៣៖១១)៕

កូនចៀមនៃព្រះៈ ក្នុងពេលជាមួយគ្នានេះផងដែរ លោកសាវ៍កប៉ុលបាននិយាយបន្ថែមថា "ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រិស្តយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា"(រ៉ូម៦៖២៣)។ លោកសាវ៍កប៉ុលបានកកាយបំផុសត្រីវិស័យដ៏ពិតប្រាកដតែមួយគត់ដែលបានប

ង្កុលបង្ហាញថា ព្រះយេស៊ូវគ្រិស្តគឺជាអំណោយទាននៃព្រះ ជាផ្លូវទៅរកជីវិតដ៏អស់កល្ប និងជាដំណោះស្រាយសម្រាប់អំពើបាបដែលអ័ដាំបាននាំចូលមកក្នុងផែនដីតាំងពីដើមដំបូងមកម្ល៉េះ។ លោកក៏បានផ្តល់អំនះអំនាងគាំទ្របន្តទៀតថា "... ដូចជាមនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសអោយរស់ក្នុងព្រះគ្រិស្តយ៉ាងនោះដែរ" (កូរិនថូសទី១ ១៥៖២២)។ មនុស្សបាបគ្រប់ៗរូបសមតែស្លាប់ ក៏ប៉ុន្តែដំណឹងល្អគឺ នៅក្នុងព្រះយេស៊ូវគ្រិស្ទ ពួកគេបានឆ្លងផុតពីសេចក្តីស្លាប់ ឈានដល់ជីវិតអស់កល្បជានិច្ច។ តើការនេះអាចកើតឡើងបានយ៉ាងដូចម្តេច? របៀបដែលព្រះជាម្ចាស់បានសង្គ្រោះកូនប្រុសរបស់លោកអ័ប្រាហាំ និងពួកអ៊ីស្រាអែល គឺជាកញ្ចក់ឆ្លុះបញ្ចាំងអំពីរបៀបដែលព្រះជាម្ចាស់នឹងសង្គ្រោះមនុស្សបាបទាំងឡាយ។ នៅលើអាសនៈ លោកអ៊ីសាកសមតែស្លាប់ ព្រោះនេះគឺជាការទាមទាររបស់ព្រះដ៏មានព្រះចេស្តា (លោកុប្បត្តិ២២) ស្របពេលជាមួយគ្នានេះផងដែរ ប្រជារាស្ត្រអ៊ីស្រាអែលក៏សមតែនឹងស្លាប់ជាមួយនឹងពួកអេស៊ីព្ទដែរ ព្រោះពួកអ៊ីស្រាអែលមិនមែនល្អ បរិសុទ្ធជាងពួកអេស៊ីព្ទនោះទេ ពោលគឺពួកគេទាំងអស់គ្នាសុទ្ធតែជាមនុស្សបាប ជាប់ក្រោមការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ (និក្ខមនំ១២) ផ្ទុយទៅវិញ ដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់ ព្រះអង្គបានប្រោសប្រទានកូនចៀមដើម្បីស្លាប់ជំនួសកន្លែងរបស់លោកអ៊ីសាក ក៏ដូចជាប្រជារាស្ត្រអ៊ីស្រាអែលទាំងឡាយណាដែលជឿ ហើយធ្វើតាមទ្រង់ផងដែរ។ ក្នុងន័យដូចគ្នានេះផងដែរ មនុស្សគ្រប់ជាតិសាសន៍ទាំងអស់សុទ្ធតែមានបាប ហើយសមតែនឹងស្លាប់ស្របតាមការទាមទាររបស់ព្រះដ៏សុចរិត ក៏ប៉ុន្តែ ដូចជាលំអានខាងលើនេះផងដែរ ព្រះជាម្ចាស់បានប្រោសប្រទានកូនចៀមដ៏ល្អឥតខ្ចោះមួយដើម្បីមកស្លាប់ជំនួសកន្លែងរបស់មនុស្សបាបផងទាំងពួង។ លោកអ៊ីសាក ពួកអ៊ីស្រាអែល ក៏ដូចជាមនុស្សបាបទាំងឡាយផងដែរ មិនមែនបានរួចជីវិតព្រោះព្រះជាម្ចាស់បានផ្លាស់ប្តូរព្រះហឫទ័យនោះទេ ផ្ទុយទៅវិញ មនុស្សបាបបានឆ្លងផុតពីសេចក្តីស្លាប់ ព្រោះមានអ្នកស្ម័គ្រចិត្តស្លាប់ជំនួសកន្លែងរបស់ពួកគេ ហើយស្របពេលជាមួយគ្នានេះផងដែរ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងការបង់រំលោះនោះ។ ពិសេសជាងហ្នឹងទៅទៀត កូនចៀមដែលស្លាប់ជំនួសកន្លែងរបស់មនុស្សបាប គឺជាព្រះរាជបុត្រារបស់ព្រះដ៏បរិសុទ្ធដោយផ្ទាល់ ដូចដែលលោកយ៉ូហានបាទីស្ទបានណែនាំព្រះយេស៊ូវគ្រិស្ទដល់បណ្តាជនថា "....... នោះហ្ន៎! កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក ........" (យ៉ូហាន១៖២៩)។ ព្រះយេស៊ូវគ្រិស្ទ គឺជាកូនចៀមនៃព្រះដែលដោះបាបមនុស្សលោក។ ព្រះជាម្ចាស់បានរម្លង ហើយមិនសម្លាប់ប្រជារាស្ត្រអ៊ីស្រាអែល ដោយយល់ដល់ឈាមរបស់កូនចៀមដែលពួកគេបានលាបនៅលើក្របទ្វារផ្ទះរបស់ពួកគេ ដូចគ្នានេះដែរ មនុស្សបាបគ្រប់ជាតិសាសន៍ទាំងអស់អាចគេចផុតពីសេចក្តីស្លាប់ក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់បាន ដរាបណាពួកគេស្ថិតនៅពីក្រោយឈាមរបស់កូនចៀមនៃព្រះ ពោលគឺពួកគេមានព្រះយេស៊ូគ្រិស្តដែលជាយញ្ញបូជានៃបុណ្យរម្លងសម្រាប់ពួកគេនៅចំពោះព្រះជាម្ចាស់ (កូរិនថូសទី១ ៥៖៧)។ នេះគឺជាគម្រោងផែនការណ៍តែមួយគត់របស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សបាប។ "ព្រះដ៏ជាព្រះវរបិតា ព្រះដ៏ជាព្រះរាជបុត្រានៃព្រះ ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ បានសម្រេចព្រះទ័យតាំងពីមុនអស់ទាំងកល្បដើម្បីនឹងសង្គ្រោះមនុស្សបាត់បង់ដោយបញ្ជូនព្រះរាជបុត្រាជាព្រះអង្គសង្គ្រោះនៃយើង"[19]។ ត្រីវិស័យដើម្បីឆ្ពោះទៅកាន់សេចក្តីសង្គ្រោះ គឺតាមរយៈព្រះយេស៊ូវគ្រិស្ទតែមួយអង្គគត់ដែលជាកូនចៀមនៃព្រះ ដែលព្រះជាម្ចាស់បានចាត់បញ្ជូនមកដើម្បីផ្សះផ្សារវាងមនុស្ស និងព្រះវិញ៕

---

[19] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. ក្រោលី ទំព័រ១៣

សេចក្តីសង្គ្រោះស្រេចនឹងកូនចៀមនៃព្រះ៖ ដំណោះស្រាយសម្រាប់អំពើបាបដែលព្រះជាម្ចាស់បានទាមទារ នោះ មនុស្សគ្មានសង្ឃឹមនឹងសម្រេចតាមបានដោយជោគជ័យ ដោយទីពឹងលើខ្លួនឯងជាដាច់ខាត។ បើទោះបីជាយ៉ាងណាក៏ដោយ ដំណោះស្រាយសម្រាប់អំពើបាបដែលព្រះជាម្ចាស់បានទាមទារ ព្រះអង្គផ្ទាល់បានប្រោសប្រទានអោយ ដោយព្រោះព្រះគុណដ៏ថ្លៃថ្លាកាត់ថ្លៃពុំបាន តាមរយៈព្រះយេស៊ូវគ្រិស្ទដែលជាកូនចៀមនៃព្រះ។ លោកសាវកយ៉ូហានបានពាំនាំនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់មកបញ្ជាក់ថា “....... សេចក្តីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង” (វិវរណៈ៧៖១០)។ នេះគឺជារូបភាពដែលព្រះគម្ពីរបរិសុទ្ធបរិសុទ្ធបានរំលេចឡើងម្តងហើយម្តងទៀត គឺព្រះជាម្ចាស់ និងបេសកកម្មរបស់ទ្រង់ក្នុងការសង្គ្រោះស្រោចស្រង់មនុស្សបាប តាមរយៈព្រះយេស៊ូវគ្រិស្តដែលជាកូនចៀមនៃព្រះតែមួយអង្គគត់។ ក្រៅពីនេះ គ្មានផ្លូវឯណាផ្សេងទៀតទេ ដើម្បីទទួលបានសេចក្តីសង្គ្រោះឡើយ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ណាស់ថា “ពីព្រោះមានព្រះតែមួយ ហើយមានអ្នកសង្រួបសង្រួមតែមួយនៅកណ្តាលព្រះ និងមនុស្ស គឺជាមនុស្សដ៏ជាព្រះយេស៊ូវគ្រិស្តនោះ” (ធីម៉ូថេទី១ ២៖៥)។ ត្រីវិស័យតែមួយគត់ដែលមកពីព្រះជាម្ចាស់ ដែលអាចដឹកនាំមនុស្សឆ្ពោះទៅរកសេចក្តីសង្គ្រោះ បានចង្អុលបង្ហាញថា “ដ្បិតគឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ” (អេភេសូ២៖៨ សូមមើល ទីតុស៣៖៥)។ “... គ្មានសេចក្តីសង្គ្រោះដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រោសប្រទានមកមនុស្សលោកអោយយើងរាល់គ្នាបានសង្គ្រោះឡើយ” (កិច្ចការ៤៖១២)។ បើគ្មានព្រះយេស៊ូវគ្រិស្ត គ្រប់ជាតិសាសន៍ទាំងអស់នឹងត្រូវវិនាសក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់អស់កល្បជានិច្ច ដ្បិតព្រះយេស៊ូវគ្រិស្តតែមួយអង្គគត់ គឺជាដំណោះស្រាយសម្រាប់អំពើបាប ដែលព្រះជាម្ចាស់បានរៀបចំទុកដើម្បីសង្គ្រោះមនុស្សបាបទាំងឡាយ តាំងតែពីដើមដំបូងមកម្ល៉េះ។ ក្នុងន័យស្រដៀងគ្នានេះផងដែរ ផ្លូវទៅកាន់សេចក្តីសង្គ្រោះមិនមែនអាស្រ័យលើកិច្ចការដែលមនុស្សបាបបានសម្រេចដោយខ្លួនឯងនោះទេ ផ្ទុយទៅវិញ គឺវាអាស្រ័យទាំងស្រុងលើព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានបើកសម្តែងមកយ៉ាងប្រទ្យាំតតាមរយៈអង្គព្រះយេស៊ូវគ្រិស្ទ និងកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង។ មនុស្សមិនអាចសងលោះថ្លៃបាបដែលពួកគេបានល្មើសចំពោះព្រះជាម្ចាស់ដោយខ្លួនឯងបានទេ ដូច្នោះ មនុស្សត្រូវការព្រះគុណរបស់ព្រះជាម្ចាស់ដើម្បីផ្សះផ្សាជាមួយនឹងទ្រង់វិញ។ មនុស្សត្រូវការកូនចៀមនៃព្រះដើម្បីសេចក្តីសង្គ្រោះរបស់ពួកគេ។ សេចក្តីសង្គ្រោះស្រេចនឹងកូនចៀមនៃព្រះ មិនមែនបុណ្យកុសល សមត្ថភាព កិត្តិយស ទ្រព្យសម្បត្តិ លនិងល នោះទេ។ កូនចៀមនៃព្រះគឺជាកូនសោរតែមួយគត់សម្រាប់សេចក្តីសង្គ្រោះ៕

> កូនចៀមនៃព្រះគឺជាកូនសោរតែមួយគត់
> សម្រាប់សេចក្តីសង្គ្រោះ។

ដូចដើមវិញ៖ ទាក់ទងទៅនឹងព្រះវត្តមានរបស់ព្រះយេស៊ូគ្រិស្តនៅលើផែនដីនេះផងដែរ ព្រះគម្ពីរបរិសុទ្ធបានគូសវាសបញ្ជាក់យ៉ាងប្រទ្យាំតអំពីបេសកកម្មរបស់ទ្រង់។ ព្រះយេស៊ូវគ្រិស្ទបានយាងមកផែនដីដើម្បីបំផ្លាញអំណាចរបស់បណ្តាសា ដោយទទួលរងបណ្តាសាម្តងជាសម្រេច ដើម្បីនាំយកព្រះពររបស់ព្រះជាម្ចាស់ដល់គ្រប់ជាតិសាសន៍ទាំងអស់ ប្រយោជន៍អោយគ្រប់ស្នាព្រះហស្តទាំងអស់មានទំនាក់ទំនងប្រកបដោយព្រះពរ និងព្រះគុណរបស់ព្រះជាម្ចាស់

ស្របតាមនិមិត្តនៃការបង្កើត។ ការមិនស្ដាប់បង្គាប់របស់មនុស្សដំបូងបានដាក់ស្នាព្រះហស្ដដ៏ល្អឥតខ្ចោះទាំងឡាយរបស់ព្រះជាម្ចាស់ អោយនៅក្រោមនឹមត្រួតត្រារបស់អារក្សសាតាំង ក៏ដូចជានៅក្រោមបណ្ដាសា ព្រះពិរោធន៏របស់ព្រះជាម្ចាស់ និងសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ចផងដែរ ដោយឡែក ដំណឹងល្អគឺ ព្រះរាជបុត្រាតែមួយគត់របស់ព្រះជាម្ចាស់បានយាងមក ហើយបានបំផ្លាញអំណាចរបស់អារក្សសាតាំងដោយជោគជ័យ ប្រយោជន៏ដើម្បីប្រោសលោះអស់អ្នកណាដែលជាប់ចំណងជាបាវបំរើរបស់វា អោយមានសេរីភាព បានរួចផុតពីសេចក្ដីស្លាប់ ហើយទទួលបានជីវិតដ៏ពេញបរិបូរណ៍ និងអស់កល្បជានិច្ចវិញ តាមរយៈសេចក្ដីជំនឿលើអង្គព្រះយេស៊ូវគ្រិស្ទ (យ៉ូហានទី១ ៣៖៨ កូឡូស២៖១៥ ហេព្រើរ២៖១៤-១៥ វិវរណៈ១២៖១០)។ បេសកកម្មដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចដោយជោគជ័យ បាននាំមកនូវជីវិតលើសេចក្ដីស្លាប់ដែលបណ្ដាលមកពីអំពើបាប តាំងពីដើមដំបូងមកម្ល៉េះ (កូរិនថូសទី១ ១៥៖៥៤-៥៥)។ ដូចដែលសេចក្ដីស្លាប់គ្មានអំណាចលើព្រះយេស៊ូវគ្រិស្ទ នោះវាក៏គ្មានអំណាចលើអស់អ្នកណាដែលនៅពីក្រោយឈាមរបស់ទ្រង់ដែលជាកូនចៀមនៃព្រះផងដែរ។ តួនៃជីវិតបានលេចមកដើម្បីផ្ដល់ជីវិតដល់ព្រលឹងវិញ្ញាណដែលស្លាប់អោយរស់ឡើងវិញ។ ខណៈពេលដែលព្រះយេស៊ូគ្រិស្ទមានព្រះវត្តមាននៅលើផែនដី ព្រះអង្គបានមានព្រះបន្ទូលដោយផ្ទាល់ថា "… កូនមនុស្សបានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះមនុស្សដែលបាត់បង់" (លូកា១៩៖១០)។ "ឯចោរ វាមកប្រយោជន៏តែនឹងលួច សំឡាប់ ហើយបំផ្លាញតែប៉ុណ្ណោះ តែឯខ្ញុំវិញ ខ្ញុំបានមកដើម្បីអោយវារាល់គ្នាមានជីវិត ហើយអោយមានជីវិតនោះពេញបរិបូរផង" (យ៉ូហាន១០៖១០)។ ព្រះយេស៊ូវគ្រិស្ទបានប្រោសប្រទានជីវិតដ៏ពេញបរិបូរណ៍ ល្អឥតខ្ចោះ ដែលជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ណាស់ ដល់មនុស្សផងទាំងពួង ដូចដើមវិញ៕

ស្របពេលជាមួយគ្នានេះផងដែរ តាមរយៈអង្គព្រះយេស៊ូវគ្រិស្ទ ទំនាក់ទំនងដែលបាក់បែកប្រះស្រាំរវាងព្រះជាម្ចាស់ និងមនុស្សត្រូវបានផ្សះផ្សាឡើងវិញ ដោយជោគជ័យជាស្ថាបពរ។ វាំងននៃអំពើបាបដែលធ្លាប់បានឃាត់ឃាំងរាំងមនុស្សពីព្រះជាម្ចាស់ត្រូវបានដាច់រហែកចែកចេញជាពីរផ្នែក បើកផ្លូវអោយមនុស្សចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បានដូចដើមវិញ។ ដោយមានព្រះយេស៊ូវគ្រិស្ទជាស្ពាន មនុស្សអាចមានទំនាក់ទំនងជាមួយនឹងព្រះដ៏ពិតរបស់ពួកគេវិញ ដូចនៅក្នុងសួនច្បារអេដែនដែរ ព្រោះព្រះយេស៊ូវគ្រិស្ទបានបំផ្លាញចោលអំពើបាបដែលនៅកណ្ដាលរវាងគេ និងព្រះជាម្ចាស់ហើយ។ "ព្រះដ៏អស់កល្បបានឈោងមកយើង បង្ហាញពីបំណងព្រះហឫទ័យរបស់ទ្រង់ដើម្បីរក្សាទំនាក់ទំនងដ៏ជិតស្និតរវាងទ្រង់នឹងយើង" [20]។ ព្រះយេស៊ូវគ្រិស្ទបានយាងមកផែនដី ហើយសម្រេចតាមស្ដង់ដាដែលព្រះជាម្ចាស់បានទាមទារពីមនុស្សបាប ជំនួសមនុស្សបាប ដើម្បីផ្សះផ្សាទំនាក់ទំនងរវាងមនុស្ស និងព្រះជាម្ចាស់អោយបានល្អឥតខ្ចោះដូចដើមវិញ៕

តាមរយៈព្រះយេស៊ូវគ្រិស្ទ ព្រះពររបស់ព្រះជាម្ចាស់ត្រូវបានចាក់បង្ហូរដល់គ្រប់ផ្នែកទាំងអស់នៃផែនដីទាំងមូលស្របតាមព្រះបន្ទូលសន្យារបស់ទ្រង់ (លោកុប្បត្តិ១២៖៣)។ នឹមនៃអំពើបាប បណ្ដាសា ទ្រនិចនៃសេចក្ដីស្លាប់ លនិងលត្រូវបានកិនបំផ្លាញ។ ទំនាក់ទំនងដែលបាក់បែករវាងមនុស្ស និងព្រះជាម្ចាស់ត្រូវបានផ្សះផ្សាឡើងវិញ។ ការនិទេសមនុស្សចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ត្រូវបានបញ្ចប់ ព្រោះព្រះយេស៊ូវគ្រិស្ទគឺជាផ្លូវដឹកនាំពួកគេអោយចូលទៅសោយសុខក្នុងព្រះពរ និងព្រះគុណរបស់ព្រះជាម្ចាស់ដូចដើមវិញ៕

---

[20] ស្គាល់អ្នកណាដែលអ្នកជឿតាម និពន្ធដោយលោកប៉ូល អ៊ី. លីតផល ទំព័រ១១

ត្រីវិស័យដ៏ពិតប្រាកដ៖ មនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ បានកើតមកដោយសារព្រះជាម្ចាស់ និងសម្រាប់ព្រះជាម្ចាស់ (កូឡូស១៖១៦)។ មនុស្សបានដើរតាមគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់ខ្លួនដរាបណាគេរស់នៅដោយថ្វាយបង្គំ សរសើរតម្កើង និងថ្វាយសិរីល្អដល់ព្រះជាម្ចាស់តែមួយអង្គគត់។ ថ្វីបើយ៉ាងដូច្នោះក្តី ដោយសារភាពលោភលន់ មនុស្សបែរជាជ្រើសរើសរស់នៅដោយវង្វេង ដើម្បីឧត្តមភាព និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឯងផ្ទាល់ ហើយបដិសេធន៍ចោលព្រះជាម្ចាស់ទៅវិញ។ ចាប់ពីមួយជំនាន់ទៅមួយជំនាន់ទៀត មនុស្សកាន់តែវង្វេងចេញឆ្ងាយទៅៗពីព្រះជាម្ចាស់ ដោយដើរតាមលំអាននៃត្រីវិស័យក្លែងក្លាយដែលមនុស្សដំបូងបានជ្រើសរើស។ មនុស្សបានរស់នៅតាមគោលដៅនៃជីវិតដែលលោកិយបានកំណត់អោយ ដោយផ្ទុយស្រឡះពីគោលដៅដ៏ពិតប្រាកដនៃជីវិតរបស់ខ្លួនដែលព្រះជាម្ចាស់បានប្រោសប្រទាន។ ជាជាងរស់នៅដើម្បីព្រះ មនុស្សបានបង្កើតព្រះ ហើយប្រើព្រះទុកជាឈ្នាន់ឈានជាន់ទៅរកឧត្តមភាពផ្ទាល់ខ្លួន ទាំងការនេះផ្ទុយស្រលះពីនិមិត្តនៃការបង្កើត និងជាអំពើបាប។ ក្រោមការដឹកនាំរបស់ត្រីវិស័យក្លែងក្លាយ មនុស្សមិនបានរស់នៅដោយចំគោលដៅនៃជីវិតរបស់ខ្លួនឡើយ រីឯព្រះជាម្ចាស់វិញ ក៏មិនបានទទួលយកការសរសើរតម្កើង ការថ្វាយបង្គំ ដែលព្រះអង្គសមនឹងទទួលពីសំណាក់មនុស្សដែលទ្រង់បានបង្កើតមកដែរ៕

មួយវិញទៀតសោត ត្រីវិស័យក្លែងក្លាយគឺជារនាំងដ៏ធំបំផុតមួយសម្រាប់មនុស្សជាតិក្នុងការចូលទៅរកព្រះជាម្ចាស់។ ជាក់ស្តែង មនុស្សបានខិតខំបង្កើតផ្លូវដោយខ្លួនឯង ដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ស្របតាមការចង្អុលបង្ហាញរបស់ត្រីវិស័យក្លែងក្លាយ ដើម្បីចូលទៅរកព្រះជាម្ចាស់ ជំនួសអោយការដើរតាមផ្លូវដែលព្រះជាម្ចាស់បានត្រៀមរៀបចំទុកជាស្រេចសម្រាប់ពួកគេ តាំងពីដើមដំបូងមកម្ល៉េះ ដើម្បីចូលទៅរកទ្រង់។ មនុស្សបាបបានជ្រើសរើស និងរៀបចំផ្លូវដើម្បីចូលទៅរកព្រះជាម្ចាស់តាមគ្រប់មធ្យោបាយទាំងអស់ លើកលែងតែផ្លូវដ៏ពិតប្រាកដដែលមកពីព្រះជាម្ចាស់ផ្ទាល់ ដែលគេបដិសេធន៍។ យើងអាចនិយាយម្យ៉ាងទៀតថា មនុស្សបាបស៊ូលះបង់ និងព្រមធ្វើគ្រប់យ៉ាងទាំងអស់ដើម្បីចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ តែគេមិនព្រមធ្វើតាមការទាមទាររបស់ព្រះជាម្ចាស់ជាដាច់ខាត។ ក្រោមការដឹកនាំរបស់ត្រីវិស័យក្លែងក្លាយ មនុស្សមិនត្រឹមតែមិនអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់បានទេ លើសពីនេះទៅទៀត ផលដែលហុចអោយគឺ ត្រីវិស័ក្លែងក្លាយបានដឹកនាំមនុស្សឆ្ពោះទៅរកសេចក្តីហិនវិនាស ជំនួសព្រះពរពីព្រះជាម្ចាស់៕

ដោយឡែក កាលពីប្រមាណជាង២ ០០០ឆ្នាំមុន ព្រះយេស៊ូវគ្រិស្ទដែលជាព្រះរាជបុត្រានៃព្រះដ៏បរិសុទ្ធ បានយាងចុះមកក្នុងចំណោមមនុស្សជាតិ ដើម្បីចង្អុលបង្ហាញផ្លូវមនុស្សទៅកាន់ត្រីវិស័យដ៏ពិតប្រាកដតែមួយគត់ដែលមកពីព្រះជាម្ចាស់ផ្ទាល់ ហើយអាចដឹកនាំផ្លូវមនុស្សបាបដែលកំពុងតែវង្វេងបាត់បង់អោយចូលទៅក្នុងព្រះវត្តមានព្រះជាម្ចាស់បានវិញដោយជោគជ័យ។ ក្នុងអំឡុងពេលនោះផងដែរ នៅក្នុងពន្ធកិច្ចរបស់ព្រះយេស៊ូវគ្រិស្ទ ព្រះអង្គបានបដិសេធន៍ចោលទាំងស្រុងនូវត្រីវិស័យក្លែងក្លាយទាំងឡាយដែលមនុស្សជាតិបានដើរតាមដើម្បីទទួលបានសេចក្តីសង្គ្រោះពីព្រះជាម្ចាស់។ នៅក្នុងសេចក្តីបង្រៀនរបស់ព្រះយេស៊ូវគ្រិស្ទ ព្រះអង្គបានសង្កត់យ៉ាងធ្ងន់ៗ ហើយច្បាស់ៗថា សេចក្តីសង្គ្រោះមិនមែនអាស្រ័យលើកិច្ចការដែលមនុស្សបានសម្រេចដោយពឹងផ្អែកលើសមត្ថភាពខ្លួនឯងនោះទេ ផ្ទុយទៅវិញវាអាស្រ័យទាំងស្រុងលើកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាងសម្រាប់មនុស្សទាំងអស់គ្នា។ ដូចគ្នានេះដែរ សេចក្តីសង្គ្រោះមិនមែនបានមកដោយសារ សមត្ថភាព អំពើល្អ បុណ្យកុសល ទ្រព្យសម្បត្តិ ចំណេះវិជ្ជា ឋានៈ បុណ្យ

សក្តិ ពូជអំបូរ ខ្សែស្រឡាយ គ្រួសារ លនិងល ជាថ្នូរនោះទេ ផ្ទុយទៅវិញ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ តាមរយះសេចក្តីជំនឿលើព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ នោះមនុស្សគ្រប់សណ្ឋាន គ្រប់ជាតិសាសន៏ និងគ្រប់សម័យកាលទាំងអស់បានទទួលសេចក្តីសង្គ្រោះ។ អំណះអំនាងរបស់ព្រះយេស៊ូវគ្រិស្ទទាក់ទងទៅនឹងសេចក្តីសង្គ្រោះផ្ទុយស្រលះពីផ្លូវទាំងឡាយដែលមនុស្សធ្លាប់បានដើរតាមដើម្បីចូលទៅក្នុងនគរស្ថានសួគ៌៕

ស្របពេលជាមួយគ្នានេះផងដែរ បើផ្អែកលើព្រះគម្ពីរបរិសុទ្ធជាត្រីវិស័យ ព្រះយេស៊ូវគ្រិស្ទគឺជាផ្លូវដ៏ពិតប្រាកដតែមួយគត់ដើម្បីចូលទៅកាន់នគរស្ថានសួគ៌ ដោយព្រះអង្គផ្ទាល់បានអះអាងយ៉ាងប្រទ្យ៉តថា “.......... ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មាននរណាទៅឯព្រះវរបិតាបានឡើយ” (យ៉ូហាន១៤៖៦)។ តាំងពីដើមរៀងមកមនុស្សបានបង្កើតផ្លូវជាច្រើនខុសៗគ្នាដើម្បីឈោងឈានទៅរកព្រះជាម្ចាស់ ក៏ប៉ុន្តែផ្លូវដ៏ពិតប្រាកដមានតែមួយគត់ គឺព្រះយេស៊ូវគ្រិស្ទ។ ក្នុងន័យដូចគ្នានេះផងដែរ សេចក្តីសង្ឃឹមដ៏ពិតប្រាកដសម្រាប់មនុស្សបាបក៏មានតែមួយគត់ដែរ គឺនៅក្នុងព្រះយេស៊ូវគ្រិស្ទ។ ព្រះយេស៊ូវគ្រិស្ទ គឺជាចម្លើយ និងជាគោលដៅដ៏ពិតប្រាកដតែមួយគត់ ដែលត្រីវិស័យដ៏ពិតប្រាកដតែមួយគត់ដែលមកពីព្រះជាម្ចាស់បានចង្អុលបង្ហាញមនុស្សបាបអោយឃើញ និងដើរតាម ប្រយោជន៏អោយគេទទួលបានសេចក្តីសង្គ្រោះ និងអភ័យឯកសិទ្ធិចូលទៅជ្រកកោនក្នុងនគរស្ថានសួគ៌របស់ទ្រង់វិញ៕

ម្យ៉ាងទៀត ខណះពេលដែលព្រះយេស៊ូវគ្រិស្ទមានព្រះជន្មនៅលើផែនដីនៅឡើយ ព្រះអង្គគឺជាគម្រូដ៏ពិតប្រាកដសម្រាប់ស្នាព្រះហស្តគ្រប់ៗរូបរបស់ព្រះជាម្ចាស់ក្នុងការរស់នៅដើម្បីបំពេញតាមនិមិត្តនៃការបង្កើត ដោយព្រះយេស៊ូវគ្រិស្ទផ្ទាល់បានរស់នៅដោយល្អសមសួនឥតខ្ចោះ ស្របតាមគោលដៅដ៏ពិតប្រាកដនៃជីវិត និងជាទីគាប់ព្រះហឬទ័យរបស់ព្រះជាម្ចាស់ខ្លាំងណាស់។ យើងនឹងនិយាយអំពីការនេះបន្តទៀតនៅពេលក្រោយ ក៏ប៉ុន្តែនៅត្រង់នេះតោងយើងដឹងថា តាមរយះព្រះយេស៊ូវគ្រិស្ទជាគម្រូ យើងបានឃើញអំពីរបៀបដែលត្រូវរស់នៅអោយចំគោលដៅនៃជីវិត។ ព្រះយេស៊ូវគ្រិស្ទគឺជាត្រីវិស័យដ៏ពិតប្រាកដ ដែលនាំជីវិតមនុស្សចូលទៅរកគោលដៅដ៏ពិតប្រាកដនៃជីវិតវិញ៕

សរុបសេចក្តីមក ព្រះយេស៊ូវគ្រិស្ទ គឺជារូបភាពឆ្លុះនៃជីវិតដែលរស់នៅចំតាមគោលដៅដ៏ពិតប្រាកដនៃជីវិតស្របតាមនិមិត្តនៃការបង្កើត។ ព្រះអង្គគឺជាគម្រូនៃការរបស់នៅរបស់មនុស្សគ្រប់ៗរូបដែលជាស្នាព្រះហស្តដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់។ ស្របពេលជាមួយគ្នានេះផងដែរ ព្រះយេស៊ូវគ្រិស្ទ គឺជាត្រីវិស័យ និងជាផ្លូវដ៏ពិតប្រាកដតែមួយគត់ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សលោកតាំងពីដើមដំបូងមកម្ល៉េះ ដើម្បីដឹកនាំពួកគេចូលទៅក្នុងនគរស្ថានសួគ៌របស់ទ្រង់វិញ។ តាមរយះព្រះយេស៊ូវគ្រិស្ទ មនុស្សបានទទួលជីវិតដ៏ពិតប្រាកដ និងពេញបរិបូរណ៍ គឺជាជាជីវិតដែលស្របតាមនិមិត្តនៃការបង្កើតតាំងពីដើមដំបូងមកម្ល៉េះ។ ជីវិតដែលរស់នៅដើម្បីសិរីល្អរបស់ព្រះជាម្ចាស់ ហើយតាមរយះការនេះ មនុស្សបានស្កប់ស្កល់ សុខសាន្ត ពេញដោយអំណរដ៏ពិតប្រាកដ និងពេញបរិបូរណ៍ លនិងល៕

ដូចដែលបានបរិយាយតាំងពីដើមដំបូងមកម្ល៉េះ បើជីវិតគ្រាន់តែដើម្បីកើតមកសម្រាប់រងទុក្ខទោសក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់ នោះជីវិតគ្មានន័យអ្វីទេ។ ឈប់សិន! ម៉េចវិញ ប្រសិនបើជីវិតដែលអ្នកមាននៅលើផែនដីនេះគឺជាព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានផ្តល់ឱកាសអោយអ្នកដើម្បីចូលមកផ្សះផ្សាជាមួយនឹងទ្រង់វិញ។ ការនេះគឺបានសេចក្តីថា ការសម្រេចចិត្តរបស់អ្នកនៅពេលនេះគឺសំខាន់ខ្លាំងណាស់ ព្រោះវានឹងហុចផលផ្លែដល់អ្នកអស់កល្បជានិច្ចបន្ទាប់ពីអ្នកលាចាកពីផែនដីនេះទៅ។ សេចក្តីស្លាប់គឺទៀងទាត់ គ្មាននរណាម្នាក់អាចគេចផុតបានឡើយ ដូចគ្នានេះដែរ

សម្រាប់សេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់។ ពេលវេលាចុងក្រោយរបស់អ្នកនៅលើផែនដីនឹងឈានចូលមកដល់ ដោយភ្ជាប់មកជាមួយផងដែរនូវការជំនុំជំរះរបស់ព្រះជាម្ចាស់ ដូចដែលព្រះបន្ទូលរបស់ព្រះអង្គបានសរបញ្ជាក់យ៉ាងច្បាស់ណាស់ថា “ហើយដោយព្រោះបានដំរូវអោយមនុស្សទាំងអស់ស្លាប់មួយដង រួចសឹមជាន់សេចក្តីជំនុំជំរះ”(ហេព្រើរ៩ះ២៧)។ តើអ្នកប្រាកដទេថា ព្រះដ៏សុចរិតនឹងទទួលយកអ្នកអោយចូលទៅក្នុងនគរស្ថានសួគ៌ដ៏ឧត្តុងឧត្តមរបស់ទ្រង់? បន្ទាប់ពីលាចាកផែនដីនេះ តើជីវិតរបស់អ្នកនឹងល្អប្រសើរជាងហ្នឹងដោយនឹកស្រម៉ៃមិនដល់ ឬក៏អាក្រក់ជាងហ្នឹងដោយហោមិនលើ?

### ៣ វិថីទៅកាន់សេចក្ដីសង្ឃឹម

លក្ខខណ្ឌំដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់សេចក្ដីសង្គ្រោះ ដែលព្រះជាម្ចាស់បានទាមទារពីមនុស្សបាប គឺព្រះអង្គផ្ទាល់ជាអ្នកសម្រេចអោយដោយជោគជ័យ តាមរយៈអង្គព្រះយេស៊ូវគ្រិស្ទ។ កាលពីជំពូកខាងលើ យើងបាននិយាយអំពីព្រះយេស៊ូគ្រិស្ទ ថាជាចម្លើយដ៏ពិតប្រាកដតែមួយគត់សម្រាប់អំពើបាបរបស់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ដោយឡែក នៅជំពូកនេះ យើងនឹងនិយាយបន្តអំពីវិថីដែលព្រះយេស៊ូគ្រិស្ទត្រូវយាងឆ្លងកាត់ដើម្បីផ្សះផ្សាទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្សបាប អោយបានជានានឹងគ្នាវិញ។ ព្រះគម្ពីរបរិសុទ្ធបានចាប់ផ្ដើមដោយបើកសម្ដែងអំពីពិភពដ៏ល្អអស្ចារ្យបំផុតមួយគឺសួនច្បារអេដែន ត្បិតនៅទីនោះព្រះវត្តមានរបស់ព្រះជាម្ចាស់ផ្ទាល់បានគង់នៅជាមួយនឹងបណ្ដាស្នាព្រះហស្តគ្រប់សព្វសារពើទាំងអស់ដែលព្រះអង្គបានបង្កើតមកដោយផ្ទាល់ ដោយសុខសាន្ត (លោកុប្បត្តិ១-២)។ ដូចគ្នានេះដែរ នៅចុងបញ្ចប់នៃព្រះគម្ពីរបរិសុទ្ធ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដដែលបានចង្អុលបង្ហាញដល់រូបភាពដ៏ឧត្ដុងឧត្ដមបំផុតមួយទៀត គឺនគរស្ថានសួគ៌ដែលជាទីប្រកបគ្នាដ៏សុខសាន្ត ហើយស្ថិតស្ថេរអស់កល្បជានិច្ចរវាងព្រះជាម្ចាស់ និងអស់អ្នកណាដែលដើរតាមព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ (វិវរណៈ២១-២២)។ ស្របពេលជាមួយគ្នានេះផងដែរ នៅចន្លោះរូបភាពដ៏អស្ចារ្យទាំងពីរខាងលើ បានរំលេចឡើងនូវវិថីដ៏ជាក់លាក់មួយដែលព្រះយេស៊ូគ្រិស្តត្រូវធ្វើដំណើរយាងឆ្លងកាត់ ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ ដើម្បីសាងសង់ស្ពានចម្លងប្រយោជន៍អោយមនុស្សបាបទាំងពួងអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធវិញ បន្ទាប់ពីការធ្លាក់ចុះនៃអំពើបាប។ វិថីដែលព្រះយេស៊ូគ្រិស្តត្រូវយាងឆ្លងកាត់ គឺជាគ្រោងឆ្អឹងដ៏សំខាន់បំផុតមួយដែលមិនអាចខ្វះបាន ដើម្បីសង្គ្រោះមនុស្សជាតិ ពោលគឺប្រសិនបើព្រះយេស៊ូវគ្រិស្ទមិនយាងឆ្លងកាត់វិថីដែលព្រះវរបិតាបានរៀបចំបម្រុងទុកអោយនោះទេ សេចក្ដីសង្គ្រោះក៏គ្មានដែរ។ យើងអាចនិយាយបានម្យ៉ាងទៀតថាព្រះវត្តមានរបស់ព្រះយេស៊ូវគ្រិស្ទនៅលើផែនដី គឺដើម្បីយាងឆ្លងកាត់វិថីមួយនោះ ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់តាំងពីដើមដំបូងមកម្ល៉េះ ដើម្បីសង្គ្រោះមនុស្សជាតិ។ ការបង្កើតបានបង្កប់នូវនិមិត្តដ៏ច្បាស់លាស់ជាក់លាក់បំផុតមួយគឺដើម្បីសិរីល្អរបស់ព្រះជាម្ចាស់ដែលជាព្រះអាទិករ តាមរយៈមនុស្ស និងស្នាព្រះហស្តសព្វសារពើទាំងអស់ដែលព្រះអង្គបានបង្កើតមក រីឯព្រះយេស៊ូគ្រិស្តគឺជាផ្លូវតែមួយគត់ដើម្បីបំពេញសម្រេចនិមិត្តដ៏អស្ចារ្យមួយនោះ ដោយជោគជ័យ៕

#### ក យ៉ូហាន១៖១៤

ការលះបង់ គឺជាគ្រឹះសម្រាប់ក្របក្រាលលើវិថីដែលព្រះយេស៊ូវគ្រិស្ទត្រូវយាងឆ្លងកាត់ ដើម្បីដឹកនាំមនុស្សបាបទៅឯព្រះដ៏បរិសុទ្ធវិញ ដូចដែលលោកសាវ័កយ៉ូហានបានចាប់ផ្ដើមដំណឹងល្អរបស់គាត់ដោយលើកឡើងថា “កាលពីដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ ទ្រង់គង់នៅជាមួយព្រះតាំងអំពីដើមរៀងមក គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ” (យ៉ូហាន១៖១-៣ សូមមើលកូឡូស១៖១៦)។ “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា ….. ”(យ៉ូហាន១៖១៤) ហើយលោកយ៉ូហានក៏បានបន្ថែមទៀតដែរ អំពីព្រះយេស៊ូវគ្រិស្តថា “គឺជាកូនដែលមិនមែនកើតមកពីសាច់ឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើង គឺកើតមកអំពីព្រះវិញ”(យ៉ូហាន១៖១៣៤) ថ្វីបើយ៉ាងដូច្នោះក្ដី “ទ្រង់បានគង់ក្នុងលោកិយ ហើយលោកិយក៏កើតមក

ដោយសារទ្រង់ តែមិនស្គាល់ទ្រង់ទេ ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ" (យ៉ូហាន១០-១១)។ ដោយឡែក ខណៈពេលដែលព្រះយេស៊ូគ្រិស្តគង់នៅលើផែនដីនៅឡើយ ព្រះអង្គធ្លាប់មានព្រះបន្ទូលដោយផ្ទាល់ថា "កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុក តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ" (ម៉ាថាយ៨៖២០)។ ការនេះបានឆ្លុះបញ្ចាំងអោយឃើញថាព្រះអាទិករនៃសព្វសារពើទាំងអស់ ព្រះដ៏ពោរពេញទៅដោយព្រះសព្វានុភាព ព្រះដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះដ៏បរិសុទ្ធ ព្រះដ៏លើសអស់ទាំងព្រះ លនិងល បានបន្ទាបអង្គទ្រង់ដោយត្រឡប់ជាសាច់ឈាម លះបង់គ្រប់យ៉ាងទាំងអស់ ព្រមទាំងស្នាក់នៅក្នុងចំណោមមនុស្សបាបដ៏គួរអោយស្អប់ខ្ពើមជាទីបំផុត ទាំងគ្មានអ្វីៗទាំងអស់។ មួយវិញទៀត ទាក់ទងទៅនឹងការចាប់កំណើតរបស់ព្រះរាជបុត្រានៃព្រះនៅលើផែនដីនេះផងដែរ លោកហោរ៉ាអេសាយបាននិយាយថា "..... ទ្រង់ឥតមានទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ ហើយកាលយើងបានមើលទ្រង់ នោះក៏គ្មានភាពលំអណាដែលអោយយើងរីករាយចិត្តដែរ ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់ ទ្រង់ត្រូវគេមើលងាយដូចជាអ្នកណាដែលមនុស្សគេចមុខចេញ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា..... ទ្រង់ត្រូវគេសង្កត់សង្កិនហើយធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋសោះ គឺដូចជាកូនចៀមដែលគេដឹកទៅសម្លាប់.... " (អេសាយ៥៣៖១-៧)។ នៅត្រង់ចំនុចនេះលោកហោរ៉ាអេសាយបានសង្កត់យ៉ាងធ្ងន់ថា ព្រះរាជបុត្រានៃព្រះដ៏បរិសុទ្ធដែលសមនឹងទទួលបានការលើកសរសើរតម្កើងពីសំណាក់គ្រប់ស្នាព្រះហស្តសព្វសារពើទាំអស់ដែលព្រះអង្គបានបង្កបង្កើតមកដោយផ្ទាល់ បែរជាត្រូវទទួលរែកពុនយកនូវភាពអាម៉ាស់គ្រប់បែបយ៉ាងដែលទ្រង់មិនសមនឹងទទួលសោះឡើយ។ ព្រះយេស៊ូវគ្រិស្តបានបន្ទាបអង្គទ្រង់មកក្នុងចំណោមមនុស្សបាប ដើម្បីក្លាយជាស្ពានចម្លងរវាងមនុស្សនិងព្រះ ប្រយោជន៍អោយមនុស្សមានផ្លូវចូលទៅក្នុងនគរស្ថានសួគ៌ ព្រោះ បើសំអាងលើព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រិស្តគឺ "គ្មានអ្នកណាបានឡើងទៅស្ថានសួគ៌ឡើយ មានតែព្រះអង្គដែលយាងចុះពីស្ថានសួគ៌មកប៉ណ្ណោះ គឺជាកូនមនុស្សដែលនៅស្ថានសួគ៌នោះឯង" (យ៉ូហាន៣៖១៣)។ ព្រះយេស៊ូវគ្រិស្តបានលះបង់ស្ថានសួគ៌មួយរយះ ដើម្បីចុះមកដឹកនាំមនុស្សបាបដែលកំពុងតែវង្វេងអោយបានចូលទៅស្ថានសួគ៌វិញ តាមរយះទ្រង់ដែលជាផ្លូវដ៏ពិត។ ការនេះក៏បានសេចក្តីផងដែរថា មនុស្សមិនអាចពឹងពាក់លើបុណ្យកុសលដើម្បីតម្កល់តម្កើងខ្លួនឡើងទៅដល់ព្រះដ៏ឧត្តុងឧត្តមបានឡើង ផ្ទុយទៅវិញ ព្រះដ៏ឧត្តុងឧត្តមអង្គនោះបានចុះមកដើម្បីរៀបចំផ្លូវអោយមនុស្សអាចឡើងទៅដល់ទ្រង់បានវិញដោយជោគជ័យ៕

ព្រះដ៏ជិតស្និទ្ធ៖ ដោយឡែក ការគង់នៅក្នុងចំណោមបណ្តាស្នាព្រះហស្តសព្វសារពើទាំងអស់ ដោយសិរីល្អនៅក្នុងទីកន្លែងដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ គឺជាបំណងព្រះហឫទ័យតែមួយគត់របស់ព្រះអាទិករដែលជាព្រះមហាក្សត្រនៃមនុស្សជាតិទាំងឡាយ។ ព្រះគម្ពីរបរិសុទ្ធបានចង្អុលបង្ហាញយ៉ាងប្រទាំតថា នៅក្នុងសួនច្បារអេដែនព្រះជាម្ចាស់បានគង់នៅជាមួយនឹងមនុស្ស ព្រមទាំងបណ្តាសព្វសារពើទាំងអស់ដែលទ្រង់បានបង្កើត ដោយសិរីល្អរុងរឿង នៅក្នុងទីកន្លែងដែលព្រះអង្គបានរៀបចំដោយផ្ទាល់ (លោកុប្បត្តិ៣៖៨)។ បន្ទាប់មកទៀត នៅខណៈពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់(អ៊ីស្រាអែល) កំពុងតែត្រាច់ចរនៅក្នុងទីវាលរហោស្ថាន ព្រះវត្តមានរបស់ព្រះជាម្ចាស់ដដែលបានគង់នៅ

ជាមួយនឹងពួកគេ ព្រមទាំងដឹកនាំពួកគេផងដែរ (និក្ខមនំ៤០៖៣៤-៣៨)។ ដូចគ្នានេះដែរ នៅក្នុងទឹកដីសន្យា រោងឧបោសថត្រូវបានជំនួសដោយព្រះវិហារដ៏ស្កឹមស្កៃដែលព្រះបាទសាឡូម៉ូនបានសាងសង់សម្រាប់ព្រះជាម្ចាស់ ហើយនៅក្នុងព្រះវិហារនោះទៀតសោត ព្រះជាម្ចាស់បានគង់នៅក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ (ពង្សាវតាក្សត្រទី១ ៨៖១០-១១ របាក្សត្រទី១ ៧៖១-២)។ សួនច្បារអេនដែន រោងឧបោសថ ក៏ដូចជាព្រះវិហាររបស់ព្រះជាម្ចាស់ផងដែរ បានលេចរូបរាងឡើងដើម្បីចង្អុលបង្ហាញអោយមនុស្សគ្រប់ជាតិសាសន៍ទាំងអស់បានឃើញថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងគង់នៅក្នុងចំណោមបណ្ដាស្នាព្រះហស្ដទាំងអស់របស់ទ្រង់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យមានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយមនុស្សដែលជាស្នាព្រះហស្ដដ៏វិសេសបំផុតរបស់ទ្រង់។ តាមពិត ការរួមប្រកបគ្នាជាមួយព្រះជាម្ចាស់ បានដៅដាក់ដាំជាប់ក្នុងជីវិតរបស់មនុស្សគ្រប់ៗរូប ពោលគឺមនុស្សកើតមកដើម្បីបានរួមប្រកបដោយជិតស្និទ្ធជាមួយព្រះជាម្ចាស់ ដែលជាព្រះដ៏ពិតតែមួយអង្គគត់របស់ពួកគេ៕

លើសពីនេះទៅទៀត ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយមនុស្សបានរស់នៅដោយសោយសុខក្នុងព្រះពរ ព្រះគុណ និងអំណរដ៏លើសលប់ក្នុងព្រះវត្តមានរបស់ទ្រង់ ស្របតាមនិមិត្តនៃការបង្កើតតាំងពីដើមដំបូងមកម៉្លេះ តាមរយៈការរួមប្រកបគ្នាជាមួយទ្រង់។ មនុស្សបានរស់នៅតាមគោលដៅនៃជីវិត ស្របតាមនិមិត្តនៃការបង្កើត ដរាបណាពួកគេបានដើរដោយរួមប្រកបជាមួយនឹងព្រះជាម្ចាស់៕

ថ្វីបើយ៉ាងដូច្នោះក្ដី គប្បីយើងត្រូវដឹងផងដែរថា ព្រះដ៏ខ្ពង់ខ្ពស់ហួសពីការពណ៌នាមិនត្រូវការរោងឧបោសថ ឬព្រះវិហារដើម្បីគង់នៅនោះទេ ព្រោះគ្មានព្រះដំណាក់ណាដែលសាងសង់ដោយដៃមនុស្ស បានល្អអស្ចារ្យ សាកសមនឹងព្រះកិត្តិនាមដ៏ប្រសើរឧត្តមរបស់ទ្រង់ឡើយ។ តួយ៉ាង ស្ដេចសាឡូម៉ូនដែលបានកសាងព្រះវិហារដ៏ស្កឹមស្កៃក្រៃលែងថ្វាយព្រះជាម្ចាស់ដោយផ្ទាល់ បានលើកឡើងថា “យីអើ តើព្រះនឹងគង់លើផែនដីជាប្រាកដឬ មើលផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃនោះមិនល្មមអោយទ្រង់គង់ចុះទៅហើយ ចំណងបើព្រះវិហារដែលទូលបង្គំបានស្អាងនេះ តើនឹងតូចចង្អៀតអំបាលម៉ានទៅទៀត” (ពង្សាវតាក្សត្រទី១ ៨៖២៨)។ រីឯលោកលូកាវិញ ក៏បានបំផុសឡើងដូចគ្នាផងដែរថា “ដ្បិតព្រះដែលបង្កើតលោកិយ៍ និងរបស់សព្វសារពើ ព្រះអង្គនោះ ទ្រង់ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី ទ្រង់មិនគង់នៅក្នុងព្រះវិហារដែលដៃមនុស្សបានធ្វើទេ” (កិច្ចការ១៧៖២៤)។ សម្រាប់ខ្ញុំ ព្រះដ៏ធំលើសអស់ទាំងព្រះ បានបន្ទាបអង្គទ្រង់មកគង់នៅក្នុងចំណោមមនុស្ស តាមរយៈរោងឧបោសថដែលសាងសង់ដោយដៃមនុស្ស បានសបញ្ជាក់យ៉ាងច្បាស់ពីបំណងព្រះហឫទ័យដ៏ជ្រាលជ្រៅរបស់ទ្រង់ក្នុងការគង់នៅក្នុងចំណោមមនុស្ស៕

បើទោះបីជាយ៉ាងណាក៏ដោយ ទាំងនៅក្នុងរោងឧបោសថ ក៏ដូចជានៅក្នុងព្រះវិហាររបស់ព្រះជាម្ចាស់ផងដែរ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់គ្មានសិទ្ធិសេរីភាពពេញលេញក្នុងការចេញចូលក្នុងព្រះវត្តមានរបស់ទ្រង់ដោយផ្ទាល់ ហើយគ្រប់ពេលវេលាតាមបំណងចិត្តរបស់ពួកគេឡើយ ដ្បិតពួកគេនៅតែជាមនុស្សជាប់មានបាបនៅឡើយ ហើយមនុស្សបាបមិនអាចឈរនៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធបានជាដាច់ខាត (អេសាយ៥៩៖២)។ រោងឧបោសថបានអនុញ្ញាតអោយព្រះជាម្ចាស់មានព្រះវត្តមានក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ តែការនេះមិនមែនមានន័យថា ប្រជារាស្ត្ររបស់ទ្រង់មានសិទ្ធិនៅជាមួយទ្រង់ដូចដើមនោះឡើយ។ មនុស្សបាបត្រូវតែដោះស្រាយជាមួយនឹងអំពើបាបរបស់ពួកគេជាមុនសិន ទើបពួកគេអាចរួមប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់បានដូចដើមវិញ។ មិនខុសអ្វីអំពីចេរូប៊ីនដែលត្រូវបានដាក់ចាំយាមការពារមិន

អោយមនុស្សឈានចូលទៅក្នុងសួនច្បារអេដែនវិញនោះទេ (លោកុប្បត្តិ៣៖២២-២៤) នៅក្នុងរោងបោសថ ក៏ដូចជានៅក្នុងព្រះវិហារផងដែរ វាំងននដែលដាក់ញែកទីបរិសុទ្ធចេញពីទីបរិសុទ្ធបំផុត គឺជារនាំងដែលឃាត់ឃាំងប្រជារាស្ត្រអ៊ីស្រាអែលមិនអោយចូលទៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធរបស់ពួកគេ (និក្ខមនំ២៦៖៣១-៣៥)។ លក្ខខណ្ឌនេះ គឺតម្រូវសម្រាប់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់នៅលើផែនដី ពោលគឺគ្មាននរណាម្នាក់អាចចូលទៅក្នុងទីបរិសុទ្ធបំផុតរបស់ព្រះជាម្ចាស់បានឡើយ លើកលែងតែសម្តេចសង្ឃដែលចូលទៅដើម្បីបំពេញកិច្ចការថ្វាយព្រះជាម្ចាស់ ក្រោមការអនុញ្ញាត ការណែនាំ និងការបង្គាប់បញ្ជារបស់ទ្រង់។ ដើម្បីរក្សាទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្សនោះ សម្តេចសង្ឃបានដើរតួយ៉ាងសំខាន់នៅកណ្តាលភាគីទាំងសងខាង។ បើទោះបីជាយ៉ាងណាក៏ដោយ តាមរយៈរោងឧបោសថ មនុស្សមិនបានប្រកបគ្នាដោយជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ ដូចជានិមិត្តនៃការបង្កើតនោះទេ៕

ពន្លឺនៃសេចក្តីសង្ឃឹម៖ ដោយឡែក ព្រះវត្តមានរបស់ព្រះយេស៊ូវគ្រិស្ទនៅលើផែនដី គឺដើម្បីរៀបចំផ្លូវអោយមនុស្សជាតិអាចចូលទៅក្នុងព្រះវត្តមានដ៏បរិសុទ្ធរបស់ព្រះដ៏បរិសុទ្ធបានដូចដើមវិញ ហើយដើម្បីសម្រេចការនេះទៀតសោត ព្រះយេស៊ូវគ្រិស្ទផ្ទាល់ត្រូវតែបំផ្លាញរនាំងវាំងននដែលដាក់ឃាត់ឃាំងមនុស្សពីព្រះជាម្ចាស់ចេញ។ ការលះបង់គ្រប់បែបយ៉ាងទាំងអស់ សូម្បីតែព្រះជន្មរបស់ទ្រង់ផ្ទាល់ គឺជាផ្លូវដើម្បីដូរយកជ័យជំនះដ៏អស្ចារ្យមួយនេះ សម្រាប់មនុស្សជាតិដែលព្រះអង្គស្រលាញ់ខ្លាំងដល់ម្ល៉េះ។ ប្រទ្បំតណាស់! នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានប្រកាសជោគជ័យលើបេសកម្មរបស់ទ្រង់។ ជាក់ស្តែង បន្ទាប់ពីព្រះយេស៊ូគ្រិស្ទបានដាក់ព្រះជន្មចុះភ្លាម លោកម៉ាថាយបានពិពណ៌នាយ៉ាងប្រុងប្រយត្ន័បំផុតថា “គ្រានោះ វាំងននក្នុងព្រះវិហារក៏របែកជាពីរភាគ ចាប់តាំងពីលើចុះទៅដល់ក្រោម ក៏មានកក្រើកដី ហើយថ្មប្រេះដាច់ចេញពីគ្នា” (ម៉ាថាយ២៧៖៥១)។ រនាំងវាំងននដែលដាក់ឃាត់ឃាំងមនុស្សពីព្រះជាម្ចាស់តាំងពីដើមរៀងមក បានរហែកចែកចេញជាពីរផ្នែក ហើយតាមរយៈរូបភាពផងដែរនេះ មនុស្សជាតិលែងវង្វេងតែលតោលនៅពីក្រោយរនាំងវាំងនន និងខាងក្រៅព្រះវត្តមានរបស់ព្រះជាម្ចាស់ទៀតហើយ ពោលគឺមនុស្សអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់វិញបានដូចដើម គ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់ ដោយមានព្រះយេស៊ូវគ្រិស្តជាស្ពាន (យ៉ូហាន៤៖២០-២៤)។ ក្នុងន័យដូចគ្នានេះផងដែរ តាមរយៈរូបភាពខាងលើនេះ ព្រះពរដែលព្រះជាម្ចាស់បានសន្យាដល់គ្រប់ជាតិសាសន៍ទាំងអស់តាមរយៈពូជលោកអ័ប្រាហាំ(លោកុប្បត្តិ១២៖១-៣) ត្រូវបានចាក់បង្ហូរទៅដល់គោលដៅចុងក្រោយបំផុតរបស់វា គឺគ្រប់ជាតិសាសន៍ទាំងអស់។ គ្រប់ជាតិសាសន៍ទាំងអស់ អាចចូលទៅក្នុងនគរស្ថានសួគ៌បានដោយជោគជ័យ តាមរយៈព្រះយេស៊ូវគ្រិស្ទតែមួយអង្គគត់ដែលជាផ្លូវដ៏ពិតប្រាកដ។ ព្រះរាជបុត្រានៃព្រះដ៏បរិសុទ្ធបានប្រសូតជាមនុស្ស ក្នុងចំណោមមនុស្សបាប ដើម្បីនាំមនុស្សបាបចូលទៅក្នុងព្រះវត្តមានដ៏បរិសុទ្ធរបស់ទ្រង់វិញ៕

ចាប់តាំងតែពីដើមដំបូងមកម្ល៉េះ ព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការរួបរួមរស់ប្រកបគ្នាជាមួយនឹងមនុស្សដែលព្រះអង្គបានបង្កើតមកដោយផ្ទាល់។ ដោយឡែក ការធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្សដំបូងមិនបានដកយកនិមិត្តនេះចេញពីព្រះជាម្ចាស់ឡើយ ផ្ទុយទៅវិញ ការធ្លាក់ចុះក្នុងអំពើបាបបានឆ្លុះបញ្ចាំងអំពីការលះបង់ដ៏ធំធេងជ្រាលជ្រៅបំផុតរបស់ព្រះជាម្ចាស់ ដើម្បីធានាមិនអោយមនុស្សត្រូវវិនាសចេញពីទ្រង់ឡើយ។ ពូជស្ត្រី គឺជាព្រះរាជបុត្រាតែមួយអង្គគត់របស់ព្រះជាម្ចាស់ដែលត្រូវបានលះបង់ដើម្បីសម្រេចនិមិត្តនៃការបង្កើត(លោកុប្បត្តិ៣៖១៥)។ ជាលទ្ធផល តាមរយៈកិច្ចការដែលព្រះយេស៊ូវគ្រិស្តបានសម្រេចនៅលើឈើឆ្កាង មនុស្ស និងព្រះបានរួមប្រកបជាមួយគ្នាយ៉ាងជិតស្និទ្ធដូចដើមវិញ

ស្របតាមនិមិត្តនៃការបង្កើត។ ប្រសើរលើសហ្នឹងទៅទៀត គ្រិស្ទបរិស័ទគឺជារោងឧបោសថដ៏ល្អបរិសុទ្ធឥតខ្ចោះរបស់ព្រះជាម្ចាស់ ដែលព្រះអង្គផ្ទាល់គង់នៅក្នុងពួកគេ ដូចដែលលោកសាវ័កប៉ុលបានរំលឹកពួកគ្រិស្តបរិស័ទនៅក្នុងទីក្រុងកូរិនថូសផងដែរថា “តើអ្នករាល់គ្នាមិនដឹងទេឬអី ថាខ្លួនអ្នករាល់គ្នាជាព្រះវិហារនៃព្រះ ហើយថាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតក្នុងអ្នករាល់គ្នា” (កូរិនថូសទី១ ៣៖១៦)។ អស់អ្នកដែលនៅក្នុងព្រះយេស៊ូវគ្រិស្ត ព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធគង់នៅក្នុងពួកគេដោយផ្ទាល់។ តាមរយៈព្រះយេស៊ូវគ្រិស្ទជាស្ពាន មនុស្សអាចរួមប្រកបជាមួយនឹងព្រះជាម្ចាស់បានដោយជិតស្និទ្ធបំផុត ស្របតាមបំណងព្រះហឬទ័យរបស់ទ្រង់៕

## ខ ព្រះរាជបុត្រាសុគតក្រោមព្រះពិរោធន៍របស់ព្រះវរបិតា

> “គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបរាងជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណះ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង” (ភីលីព២៖៧-៨)៕

ការលះបង់ គឺជាគ្រឹះដែលត្រូវបានក្របក្រាលលើវិថីដើម្បីសង្គ្រោះមនុស្សជាតិ។ ដូចដែលបានរៀបរាប់ខាងលើ ការលះបង់សិរីល្អមកយកកំណើតជាសាច់ឈាម ហើយស្នាក់នៅជាមួយមនុស្សបាបដ៏ទន់ទាប គ្រាន់តែជាចំនុចចាប់ផ្តើមនៅក្នុងវិថីនៃការលះបង់របស់ព្រះយេស៊ូវគ្រិស្ទតែប៉ុននោះ ព្រោះចាប់តាំងតែពីដើមដំបូងមកម្ល៉េះ ព្រះជាម្ចាស់មានគម្រោងផែនការណ៍លះបង់ព្រះរាជបុត្រាស្ងួនភ្ងាតែមួយគត់របស់ទ្រង់រហូតដល់ទីមរណះ ដើម្បីជាថ្នូរដូរយកសេចក្តីសង្គ្រោះសម្រាប់មនុស្សជាតិទាំងឡាយ។ នៅក្នុងសួនច្បារអេដែន ព្រះជាម្ចាស់បានបង្ហាញយ៉ាងប្រទៀតអំពីគម្រោងផែនការណ៍របស់ទ្រង់ក្នុងការបំផ្លាញអារក្សសាតាំង ដែលមនុស្សដំបូងបានបើកទ្វារអោយចូលមកបំពុលគ្រប់ស្នាព្រះហស្តដ៏ល្អឥតខ្ចោះទាំងអស់របស់ទ្រង់។ នៅទីនោះ ព្រះជាម្ចាស់បានមានព្រះបន្ទូលដោយផ្ទាល់ថា “អញនឹងធ្វើអោយឯងហើយនិងស្ត្រី គឺទាំងពូជឯងនិងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ” (លោកុប្បត្តិ៣៖១៥)។ លោកុប្បត្តិ៣៖១៥ គឺជាប្រទីបដ៏សំខាន់បំផុតមួយ សម្រាប់ស្វែងយល់អំពីដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះការរម្លងរបស់មនុស្សដំបូង។ ព្រះបន្ទូលនៅត្រង់នេះ បានលាតត្រដាងបញ្ជាក់យ៉ាងច្បាស់អំពីការជំនុំជំរះលើអារក្សសាតាំង(សត្វពស់) ដែលបានដាក់នឹមត្រួតត្រាលើស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ហើយស្របពេលជាមួយគ្នានេះផងដែរ លោកុប្បត្តិ៣៖១៥ ក៏បានរំលេចឡើងផងដែរនូវព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សជាតិទាំងឡាយដែលបានវិនាសបាត់បង់។ យើងអាចនិយាយបានថា បណ្តាសាលើអារក្សសាតាំង គឺជាព្រះពរសម្រាប់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់។ បើផ្អែកលើព្រះបន្ទូលសន្យានោះ ពូជស្ត្រីនឹងកិនបំផ្លាញនឹមត្រួតត្រាដែលអារក្សសាតាំងបានដាក់តាំងលើគ្រប់ស្នាព្រះហស្តទាំងអស់ដែលព្រះជាម្ចាស់បានបង្កបង្កើតមកដោយល្អឥតខ្ចោះ ដើម្បីរំដោះគ្រប់ស្នាព្រះហស្តទាំងអស់អោយមានសេរីភាពទ្រង់វិញនៅក្នុងទ្រង់។ ដោយឡែក ពូជស្ត្រីបានយកជ័យជំនះលើបេសកកម្មមួយនេះដោយការស្លាប់។ ការស្លាប់របស់ពូជស្ត្រីបានបញ្ចប់អំនាចរបស់អារក្សសាតាំង ហើយផ្តល់ជីវិតថ្មីដល់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ដែលជឿទុកចិត្តលើទ្រង់៕

ដោយសារព្រះគុណ ព្រះជាម្ចាស់បានប្រោសប្រទានផ្លូវដើម្បីជួយសង្គ្រោះមនុស្សបាបចេញពីចំណងរបស់អារក្សសាតាំង តាមរយៈពូជស្ត្រី មិនមែនអាស្រ័យលើសមត្ថភាពរបស់បុគ្គលនីមួយៗនោះទេ។ ការដាក់ជីវិតចុះរបស់ពូជស្ត្រី គឺជាសេចក្ដីសង្ឃឹមតែមួយគត់របស់មនុស្សបាប៕

ស្របពេលជាមួយគ្នានេះផងដែរ លោកសាវ័កប៉ុលបានបន្តពីអំនះអំនាងខាងលើមកថា "តែលុះវេលាកំណត់បានមកដល់ នោះព្រះបានចាត់ព្រះរាជបុត្រាទ្រង់អោយមកចាប់កំណើតនឹងស្ត្រី គឺកើតក្រោមអំណាចនៃក្រិត្យវិន័យ ដើម្បីនឹងលោះពួកអ្នកដែលនៅក្រោមក្រិត្យវិន័យ ..... " (កាឡាទី៤៖៤-៥)។ តើពូជស្ត្រីដែលព្រះជាម្ចាស់បានសន្យាសូបនោះជានរណា? បើផ្អែកលើការអះអាងរបស់ព្រះគម្ពីរបរិសុទ្ធ ព្រះយេស៊ូវគ្រិស្ទគឺជាពូជស្ត្រីដែលព្រះជាម្ចាស់បានសន្យា ដែលពួកយ៉ូដាក៏ដូចជាគ្រប់ស្នាព្រះហស្ដទាំងអស់បានទន្ទឹងរង់ចាំ ហើយព្រះវត្តមានរបស់ព្រះយេស៊ូវគ្រិស្ទនៅលើផែនដី គឺដើម្បីសម្រេចតាមព្រះបន្ទូលសន្យានៅលោកុប្បត្តិ៣៖១៥ (រ៉ូម១៦៖២០ ហេព្រើរ២៖១៤ វិវរណៈ១២៖៩ ១២៖១៧)។ បើដូច្នេះ ពិតប្រាកដណាស់! ព្រះយេស៊ូវគ្រិស្ទគឺជាសេចក្ដីសង្ឃឹមតែមួយអង្គគត់សម្រាប់មនុស្សបាប ដូចគ្នានេះដែរ ពិតប្រាកដណាស់! ព្រះយេស៊ូវគ្រិស្ទដែលជាពូជស្ត្រី ត្រូវតែសុគត តាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ ដើម្បីសង្គ្រោះមនុស្សបាប៕

សុគតក្រោមព្រះពិរោធន៍របស់ព្រះវរបិតា ស្របតាមគម្រោងផែនការណ៍៖ យើងបានរៀបរាប់ខាងលើខ្លះៗហើយថា ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទគឺជាគម្រោងផែនការណ៍របស់ព្រះវរបិតា។ បន្ទាប់ពីមនុស្សដំបូងបានប្រព្រឹត្តិបាបភ្លាម ព្រះជាម្ចាស់មិនត្រឹមតែជ្រាបអំពីអនាគតរបស់ពួកគេនោះទេ លើសពីនេះទៅទៀត ព្រះជាម្ចាស់ក៏បានជ្រាបភ្លាមផងដែរ អំពីតម្លៃនៃការលះបង់ដ៏ជ្រាលជ្រៅកាត់ថ្លៃពុំបានដែលព្រះអង្គត្រូវតែធ្វើដើម្បីសង្គ្រោះមនុស្សបាបអោយមកឯទ្រង់វិញ ពោលគឺការលះបង់ព្រះរាជបុត្រាស្ងួនភ្ញាតែមួយអង្គគត់របស់ទ្រង់។ យើងអាចនិយាយម្យ៉ាងទៀតបានថា ដោយព្រោះព្រះគុណ និងសេចក្ដីស្រឡាញ់សម្រាប់មនុស្សជាតិ ព្រះវរបិតាមិនត្រឹមតែទាមទារអោយព្រះរាជបុត្រារបស់ទ្រង់ត្រូវសុគតនោះទេ ជាងហ្នឹងទៅទៀត ព្រះអង្គផ្ទាល់បានអនុញ្ញាត ព្រមទាំងរៀបចំត្រួសត្រាយផ្លូវដើម្បីអោយព្រះយេស៊ូវគ្រិស្ទត្រូវសុគតនៅលើឈើឆ្កាងកុំបីខានឡើយ (រ៉ូម៥៖៨ យ៉ូហាន៣៖១៦)។ ព្រះរាជបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បំផុតបានចាប់កំណើតជាសាច់ឈាម ក្នុងចំណោមមនុស្សបាប ហើយរស់រងទុក្ខទោសវេទនាលើផែនដីរហូតដល់សុគតនៅលើឈើឆ្កាង ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ចាប់តាំងពីដើមដំបូងមកម៉្លេះ ដើម្បីសង្គ្រោះមនុស្សជាតិផងទាំងឡាយ។ ដោយឡែក ទាក់ទងទៅនឹងគំនិតខាងលើនេះផងដែរ លោកសាវ័កយ៉ូហានបានកត់ត្រានូវព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រិស្ទដោយផ្ទាល់ថា "ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញដែលទ្រង់ចាត់អោយខ្ញុំមក ឯបំណងព្រះហឫទ័យនៃព្រះវរបិតាដែលចាត់អោយខ្ញុំមកនោះ គឺមិនចង់អោយខ្ញុំបាត់អ្នកណាក្នុងគ្រប់អស់ទាំងមនុស្ស ដែលទ្រង់ប្រទានមកខ្ញុំនោះឡើយ គឺទ្រង់ចង់អោយខ្ញុំប្រោសទាំងអស់អោយរស់ឡើង នៅថ្ងៃចុងបំផុតវិញ នេះហើយជាបំណងព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺអោយអស់អ្នកណាដែលឃើញព្រះរាជបុត្រា ហើយក៏ជឿដល់ទ្រង់បានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងអោយអ្នកនោះរស់ឡើងវិញនៅថ្ងៃចុងក្រោយ"(យ៉ូហាន៦៖៣៨-៤០)៕

បើទោះបីជាយ៉ាងណាក៏ដោយ គប្បីយើងមិនគួរមើលរម្លងនោះទេ អំពីការចុះចូល និងបំណងព្រះហឫទ័យរបស់ព្រះយេស៊ូវគ្រិស្ទក្នុងការសុគតនៅលើឈើឆ្កាង ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ដើម្បីសង្គ្រោះមនុស្ស

បាប។ ព្រះយេស៊ូវគ្រិស្តផ្ទាល់ស្ម័គ្រព្រះទ័យដាក់ព្រះជន្មចុះ ប្រយោជន៍អោយមនុស្សបាបបានទទួលជីវិតដ៏ពេញបរិបូរណ៍។ ជាក់ស្តែង កាលពីពេលដែលព្រះយេស៊ូវគ្រិស្តមានព្រះជន្មគង់នៅលើផែនដី ព្រះអង្គបានមានព្រះបន្ទូលអំពីបុព្វហេតុនៃព្រះវត្តមានរបស់ទ្រង់ដោយផ្ទាល់ថា “ដ្បិតកូនមនុស្សក៏បានមកមិនមែនអោយគេបំរើដែរ គឺដើម្បីនឹងបំរើគេវិញ ហើយនឹងអោយជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង” (ម៉ាកុស១០៖៤៥)។ ព្រះអង្គក៏បានបន្ថែមទៀតដែរថា “គ្មានអ្នកណាដកយកជីវិតពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនឯង ខ្ញុំអាចនឹងដាក់ជីវិតនេះចុះ ហើយក៏អាចនឹងយកមកវិញបានដែរ ខ្ញុំបានទទួលអំណាចនេះពីព្រះវរបិតាខ្ញុំមក”(យ៉ូហាន១០៖១៨)។ ចាប់តាំងពីដើមដំបូងមកម្ល៉េះ ព្រះយេស៊ូវគ្រិស្តជ្រាបច្បាស់ណាស់អំពីអនាគតរបស់ទ្រង់នៅលើឈើឆ្កាង ថ្វីបើយ៉ាងដូច្នោះក្តី ព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសយកវាដោយមិនសោកស្តាយអ្វីឡើយ ដើម្បីបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា និងដើម្បីសេចក្តីសង្គ្រោះរបស់មនុស្សជាតិដែលព្រះអង្គស្រលាញ់ខ្លាំងដល់ម្ល៉េះ។ ឧទាហរណ៍ ប្រសិនបើយើងក្រឡេកមកមើល ព្រឹត្តិការណ៍ជុំវិញការសុគតរបស់ព្រះយេស៊ូគ្រិស្តវិញ នោះយើងឃើញថា បើទោះបីជាព្រះអង្គត្រូវបានគេក្បត់ ព្រមទាំងលបលួចរកឱកាសនឹងចាប់សម្លាប់ទ្រង់ ដោយប្រើឧបាយកលផ្សេងៗជាច្រើនយ៉ាងណាក្តី ក៏ព្រះអង្គជ្រាបច្បាស់អំពីគម្រោងផែនការណ៍ទាំងអស់នោះ ហើយជាងនេះទៅទៀត គ្រប់ស្ថានការណ៍ទាំងអស់នោះគឺស្ថិតនៅក្រោមព្រះហស្តរបស់ទ្រង់ផ្ទាល់ (ម៉ាកុស១៤)។ គ្មានល្បិចកលណាមួយដែលព្រះយេស៊ូវគ្រិស្តមិនបានជ្រាបជាមុននោះទេ ដូចគ្នានេះដែរ ព្រះយេស៊ូវគ្រិស្តអាចការពារអង្គទ្រង់ ហើយជៀសផុតពីការចោទប្រកាន់ និងសេចក្តីស្លាប់បានដោយងាយ។ បើទោះបីជាយ៉ាងដូច្នោះក្តី ព្រះយេស៊ូវគ្រិស្តសម្រេចព្រះទ័យដាក់ព្រះជន្មទ្រង់ចុះ ហើយទទួលយកពែងដែលព្រះវរបិតាបានរៀបចំទុកអោយ ដោយយាងឆ្លងកាត់វិថីឆ្ពោះតម្រង់ទៅរកឈើឆ្កាង ព្រោះការលះបង់ដ៏ធំធេងនេះគឺជាផ្លូវ និងជាសេចក្តីសង្ឃឹមតែមួយគត់ដើម្បីផ្សះផ្សាមនុស្សបាបទៅឯព្រះជាម្ចាស់វិញ។ ទាក់ទងទៅនឹងការនេះផងដែរ លោកលូកាបានសរសេរបញ្ជាក់ថា “តើមិនគួរអោយព្រះគ្រិស្តរងទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរីល្អនៃទ្រង់វិញទេឬអី” (លូកា២៤៖២៦)។ “ប៉ុន្តែសេចក្តីដែលព្រះបានប្រកាសប្រាប់ជាមុន ដោយសារមាត់នៃអស់ទាំងហោរារបស់ទ្រង់ពីដំណើរព្រះគ្រិស្តថា ទ្រង់ត្រូវរងទុក្ខលំបាក នោះព្រះទ្រង់ក៏បានសម្រេចតាមយ៉ាងដូច្នោះដែរ” (កិច្ចការ៣៖១៨)។ ព្រះយេស៊ូវគ្រិស្តសម្រេចព្រះហឫទ័យយាងតម្រង់ទៅកាន់ឈើឆ្កាងដោយផ្ទាល់ ដើម្បីបំពេញសម្រេចតាមបទគម្ពីរទាំងអស់ ស្របតាមគម្រោងផែនការណ៍របស់ព្រះវរបិតា និងសម្រាប់ជាសេចក្តីសង្គ្រោះដល់មនុស្សជាតិទាំងឡាយដែលដាក់សេចក្តីជំនឿនៅលើទ្រង់។ ការសុគតរបស់ព្រះរាជបុត្រានៃព្រះនៅលើឈើឆ្កាង មិនមែនជាការចៃដន្យដ៏គួរជាទីភ្ញាក់ផ្អើលនោះទេ ផ្ទុយទៅវិញ នេះគឺជាបេសកកម្មតែមួយគត់ដែលព្រះយេស៊ូវគ្រិស្តស្ម័គ្រព្រះហឫទ័យយាងមកសម្រេច ស្របតាមគម្រោងផែនការណ៍របស់ព្រះវរបិតា ដើម្បីសង្គ្រោះមនុស្សបាប៕

មួយវិញទៀត លោកយ៉ូហានបាទីស្តដែលជាអ្នករៀបចំផ្លូវថ្វាយព្រះមេស្ស៊ីដែលត្រូវយាងមកស្របតាមព្រះបន្ទូលសន្យា និងជាអ្នកប្រកាសដំណឹងអោយមនុស្សម្នាកែប្រែចិត្តចេញពីអំពើបាបដើម្បីទទួលយកនគរស្ថានសួគ៌ទុកជាមរតក បានណែនាំតួអង្គព្រះយេស៊ូវគ្រិស្តដែលជាស្តេចនៃនគរស្ថានសួគ៌ដល់បណ្តាជនថា “….. នុ៎ះន៏ កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក” (យ៉ូហាន១៖២៩)។ ពាក្យពេចន៍របស់លោកយ៉ូហានបាទីស្តនៅត្រង់នេះ បានសង្ខេបបញ្ជាក់យ៉ាងច្បាស់ ហើយពេញលេញអំពីបេសកកម្មដែលព្រះយេស៊ូវគ្រិស្តត្រូវយាងមកសម្រេច ព្រោះអ្នកស្តាប់របស់

គាត់ដែលជាសាសន៍យូដា គួរណាស់បានយល់ច្បាស់អំពីអត្ថន័យរបស់ពាក្យ “កូនចៀម” ដែលលោកយ៉ូហានបាទីស្ដបានប្រើនៅទីនោះ។ ព្រះយេស៊ូវគ្រិស្ទ គឺជាកូនចៀមនៃបុណ្យរម្លងដែលប្រជារាស្ត្រយូដាបានប្រារព្ធជារៀងរាល់ឆ្នាំ ដើម្បីរំលឹកពួកគេអំពីការប្រោសលោះ សេចក្ដីសង្គ្រោះ សេចក្ដីសង្ឃឹម ព្រះគុណដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេ ខណៈពេលដែលពួកគេនៅជាទាសករឯស្រុកអេស៊ីព្ទនៅឡើយ (និក្ខមនំ១១-១២)។ ពួកយូដាមិនត្រឹមតែយល់ច្បាស់អំពីតួនាទីរបស់កូនចៀមនោះទេ ជាងនេះទៅទៀត ពួកគេយល់ច្បាស់អំពីអនាគតរបស់កូនចៀម ដែលត្រូវបានគេដឹកនាំយកមកចំពោះព្រះជាម្ចាស់ទុកសម្រាប់ជាដង្វាយធួននឹងបាប ពោលគឺកូនចៀមត្រូវតែស្លាប់។ សេចក្ដីស្លាប់ គឺជាជោគវាសនារបស់កូនចៀមនៃបុណ្យរម្លង ហើយនេះក៏ជាជោគវាសនារបស់ព្រះរាជបុត្រានៃព្រះដ៏បរិសុទ្ធដែលជាកូនចៀមនៃព្រះផងដែរ។ នៅក្នុងដើមដំបូងនៃដំណើរបេសកកម្មរបស់ព្រះយេស៊ូវគ្រិស្ទ លោកយ៉ូហានបាទីស្ទបានពន្លយអាថ៌កំបាំងដ៏សំខាន់បំផុតដែលទាក់ទងទៅនឹងបេសកកម្មរបស់ទ្រង់នៅលើផែនដី គឺការសុគតនៅលើឈើឆ្កាង ក្រោមព្រះពិរោធន៍របស់ព្រះវរបិតា ជំនួសកន្លែងមនុស្សបាប និងដើម្បីមនុស្សបាប ក្នុងនាមជាកូនចៀមនៃព្រះ៕

មកដល់ត្រឹមនេះ គប្បីយើងគួរយល់ថា ព្រះរាជបុត្រាស្ងួនភ្ងាតែមួយអង្គគត់របស់ព្រះជាម្ចាស់ត្រូវតែសុគត ដើម្បីសម្រេចតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់តាំងពីដើមដំបូងមកម្ល៉េះក្នុងការសង្គ្រោះមនុស្សបាប។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទចាំបាច់ជាទីបំផុតសម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្សបាបទាំងឡាយ ព្រោះវាគឺជាកូនសោរតែមួយគត់ដើម្បីបើកទ្វារនៃនគរស្ថានសួគ៌ទទួលស្វាគមន៍មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ឡើងវិញ។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទសំខាន់ដល់ម្ល៉េះសម្រាប់សេចក្ដីសង្គ្រោះ ទើបលោកម៉ូសេ និងលោកអេលីយ៉ាដែលបានរស់នៅក្នុងអំឡុងពេលយ៉ាងយូរមុនពេលដែលព្រះយេស៊ូគ្រិស្តប្រសូត បានលេចមកឯទ្រង់ ដើម្បីទូលព្រះអង្គអំពីដំណើរនៃការសុគតរបស់ទ្រង់ ដែលត្រូវតែសម្រេចនៅក្រុងយេរ៉ូសាឡឹម (លូកា៩៖២៨-៣១) ព្រោះលោកទាំងពីរនាក់ត្រូវការជាចាំបាច់នូវការសុគតរបស់ព្រះយេស៊ូគ្រិស្ទដើម្បីធានានូវសេចក្ដីសង្គ្រោះរបស់ពួកគេ។ បើព្រះយេស៊ូវគ្រិស្ទមិនបានសុគតនោះទេ សេចក្ដីសង្គ្រោះ និងសេចក្ដីសង្ឃឹមក៏គ្មានដែរ។ ទាំងមនុស្សដែលបានរស់នៅមុនការប្រសូតរបស់ព្រះយេស៊ូគ្រិស្ត ក៏ដូចជាមនុស្សដែលបានកើតក្រោយព្រះយេស៊ូគ្រិស្តផងដែរ អាចទទួលបានសេចក្ដីសង្គ្រោះ គឺស្រេចលើការដែលព្រះយេស៊ូវគ្រិស្តបានសម្រេចនៅលើឈើឆ្កាងតែមួយគត់ មិនមែនអាស្រ័យលើជោគជ័យដែលខ្លួនបានសម្រេចនោះឡើយ។ នៅលើឈើឆ្កាង ព្រះរាជបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បានដាក់ព្រះជន្មទ្រង់ចុះ ដើម្បីចាក់បង្ហូរជីវិតដ៏ពេញបរិបូរណ៍ដល់មនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់៕

ផ្លូវតែមួយគត់ដើម្បីសង្គ្រោះមនុស្សបាប ចេញពីចំណងបណ្ដាសា គឺព្រះរាជបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បំផុតត្រូវតែសុគតជំនួសកន្លែងរបស់មនុស្សបាប ក្រោមព្រះពិរោធន៍របស់ព្រះវរបិតាដោយផ្ទាល់។ នេះគឺជាវិថីដែលព្រះយេស៊ូវគ្រិស្ទត្រូវតែយាងឆ្លងកាត់ ជាពែងដែលព្រះយេស៊ូវគ្រិស្ទត្រូវតែទទួល ជាបេសកកម្មដែលព្រះយេស៊ូវគ្រិស្ទបានយាងមកសម្រេច និងជាឈើឆ្កាងដែលព្រះយេស៊ូវគ្រិស្ទត្រូវតែលី ប្រយោជន៍កុំអោយមនុស្សដែលព្រះអង្គស្រលាញ់ខ្លាំងដល់ម្ល៉េះត្រូវភ្លក់រស់ជាតិដ៏ល្វីងជូរជត់នៃការវិនាសបាត់បង់អស់កល្បជានិច្ច ក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់៕

**ថ្ពាលបណ្តុះជីវិតថ្មីដ៏ពេញបរិបូរណ៍៖** លោកសាវ័កប៉ុលបានលើកឡើងថា “ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់....” (រ៉ូម៦៖២៣)។ មនុស្សដំបូងគួរណាស់តែបានយល់ច្បាស់ណាស់អំពីសេចក្តីពិតមួយនេះ ព្រោះព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់ពួកគេដោយផ្ទាល់ (លោកុប្បត្តិ២៖១៧)។ ដោយឡែក បើផ្អែកលើព្រឹត្តិការណ៍ដែលបានកើតឡើងនៅដើមជំពូកទី៣នៃព្រះគម្ពីរលោកុប្បត្តិ មនុស្សគ្រប់ៗរូបសមណាស់តែស្លាប់ ហើយវិនាសបាត់បង់នៅចំពោះព្រះជាម្ចាស់អស់កល្បជានិច្ច ព្រោះគ្រប់ៗគ្នាទាំងអស់សុទ្ធតែមានបាប (រ៉ូម៣៖២៣)។ បើទោះបីជាយ៉ាងដូច្នោះក្តី ដោយសារព្រះគុណ ព្រះជាម្ចាស់មិនបានសម្លាប់បំផ្លាញមនុស្សជាតិចោលភ្លាមមួយរំពេចនោះទេ ខណៈពេលដែលពួកគេបានធ្វើបាប ផ្ទុយទៅវិញព្រះអង្គផ្ទាល់បានរៀបចំផ្លូវសម្រាប់សង្គ្រោះមនុស្សបាបអោយមកឯទ្រង់វិញ ដោយមិនរំពឹងសំអាងលើសមត្ថភាពរបស់ពួកគេជាថ្នូរសោះឡើយ (លោកុប្បត្តិ៣៖១៥)។ (តាមពិត ព្រលឹងវិញ្ញាណរបស់មនុស្សដំបូងបានស្លាប់មួយរំពេចបន្ទាប់ពីពួកគេបានធ្វើបាប ដូចគ្នានេះដែរសម្រាប់ព្រលឹងវិញ្ញាណរបស់បុគ្គលគ្រប់ៗរូបទាំងអស់ដែលមានកំណើតចេញពីអាដាំ និងអេវ៉ា ក៏ប៉ុន្តែរូបកាយរបស់ពួកគេនៅរស់រានមានជីវិតជាបណ្តោះអាសន្ននៅឡើយ ដើម្បីទទួលយកឱកាសក្នុងការកែប្រែចិត្ត ប្រយោជន៍ទទួលបានជីវិតដ៏ពេញបរិបូរណ៍នៅចំពោះព្រះជាម្ចាស់វិញ ស្របតាមព្រះគុណរបស់ទ្រង់)។ សេចក្តីស្លាប់របស់មនុស្សជាតិត្រូវតែជំនួសដោយសេចក្តីស្លាប់របស់ពូជស្ត្រីដែលព្រះជាម្ចាស់បានសន្យា ទើបមនុស្សបាបអាចគេចផុតពីសេចក្តីស្លាប់ដ៏អស់កល្បជានិច្ច ហើយទទួលបាននូវជីវិតដ៏ពេញបរិបូរណ៍អស់កល្បជានិច្ចវិញ។ ចាប់តាំងពីដើមដំបូងមកម្ល៉េះ បន្ទាប់ពីមនុស្សបានធ្វើបាប ព្រះគម្ពីរបរិសុទ្ធបានចង្អុលបញ្ជាក់យ៉ាងប្រទៀតថាសត្វត្រូវបានសម្លាប់ដើម្បីរំលឹកមនុស្សអំពីទោសនៃអំពើបាបដែលពួកគេសមនឹងទទួល ស្របតាមការទាមទាររបស់ព្រះជាម្ចាស់ ព្រមទាំងដើម្បីស្លាប់ជំនួសកន្លែងរបស់ពួកគេ។ ការស្លាប់របស់សត្វ (លោកុប្បត្តិ៣៖២១ លោកុប្បត្តិ២២ និក្ខមនំ១២) គឺជាស្រមោលរូបភាពដែលនឹងត្រូវកើតឡើងចំពោះព្រះយេស៊ូគ្រិស្ទ ដែលជាកូនចៀមនៃព្រះ ដែលទ្រង់ត្រូវតែសុគតជំនួសកន្លែងមនុស្សបាប ដើម្បីសង្គ្រោះពួកគេពីសេចក្តីស្លាប់ដ៏អស់កល្បជានិច្ច ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់នៅលោកុប្បត្តិ៣៖១៥។ ព្រះយេស៊ូវគ្រិស្ទស្មគ្រ័ព្រះហឫទ័យទទួលយកសេចក្តីស្លាប់ដែលមនុស្សសមតែទទួល ដើម្បីអោយមនុស្សទទួលបានជីវិតដែលពួកគេមិនសមនឹងទទួលសោះឡើយ ដ្បិតពួកគេជាមនុស្សបាប។ ក្នុងន័យដូចគ្នានេះផងដែរ បើយោងទៅតាមអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរ “.... តាមក្រិត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាតដោយសារឈាម បើគ្មានការខ្ចាយឈាមទេ នោះគ្មានផ្លូវណាអោយបានរួចពីបាបឡើយ” (ហេព្រើរ៩៖២២) ក៏ប៉ុន្តែក្រោយមក លោកក៏បានបញ្ជាក់បន្ថែមទៀតដែរថា “...... ឈាមគោឈ្មោល និងពពែឈ្មោលនោះពុំអាចនឹងដោះបាបបានឡើយ” (ហេព្រើរ១០៖៤) ដ្បិតព្រះជាម្ចាស់បានទាមទារនូវដង្វាយដ៏គ្រប់លក្ខណ៍ ហើយប្រសើរជាងឈាមសត្វទៅទៀត (ហេព្រើរ៩៖២៣)។ ដំណឹងល្អសម្រាប់មនុស្សបាបទាំងពួងគឺ ការទាមទាររបស់ព្រះវរបិតាដែលមនុស្សមិនអាចបំពេញសម្រេចតាមបាន ជាអ្វីដែលព្រះយេស៊ូវគ្រិស្ទបានយាងមកសម្រេចសម្រាប់ពួកគេ ពោលគឺការសុគតនៅលើឈើឆ្កាងដើម្បីថ្វាយអង្គទ្រង់ទុកយញ្ញបូជាដ៏គ្រប់លក្ខណ៍ សម្រាប់លុបលាងចោល ហើយធួននឹងអំពើបាបទាំងអស់របស់មនុស្សបាបគ្រប់ជាតិសាសន៍ទាំងឡាយ (ហេព្រើរ៩៖២៥-២៦)។ ការដែលមនុស្សមិនសមនឹងទទួលពីព្រះជាម្ចាស់សោះឡើយគឺជីវិតដ៏ពេញបរិបូរណ៍ ក៏ប៉ុន្តែជីវិតដ៏ពេញបរិបូរណ៍ គឺជាអំណោយដែលព្រះជាម្ចាស់មានបំណងព្រះហឫទ័យប្រោសប្រទានដល់ពួកគេ ព្រោះទ្រង់គឺជាព្រះដែលពោរពេញទៅដោយព្រះគុណ និងសេចក្តីស្រលាញ់។ លោកុប្បត្តិ៣៖

១៥ គឺជាត្រីវិស័យដែលចង្អុលបង្ហាញផ្លូវអោយមនុស្សទទួលបានជីវិតថ្មីដ៏ពេញបរិបូរណ៍ដែលពួកគេបានបាត់បង់ ដោយសារអំពើបាប នៅក្នុងសួនច្បារអេដែន។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទដែលជាពូជស្ត្រី គឺជាថ្នាលបណ្តុះជីវិតថ្មីដ៏ពេញបរិបូរណ៍ដល់មនុស្សបាបផងទាំងពួង៕

## គ នៅលើឈើឆ្កាង

"បើមានអ្នកណាបានប្រព្រឹត្តិអំពើបាបដែលគួរអោយគេស្លាប់ ហើយឯងសម្លាប់ទៅដោយព្យួរនៅលើឈើ នោះមិនត្រូវអោយខ្មោចគេជាប់នៅលើឈើរហូតដល់ភ្លឺឡើយត្រូវអោយកប់ទៅនៅថ្ងៃនោះឯងជាកុំខាន ដ្បិតអ្នកណាដែលត្រូវព្យួរ នោះជាអ្នកដែលត្រូវព្រះដាក់បណ្តាសាហើយ...... " (ចោទិយកថា២១:២២-២៣)៕

### គ១ រួចផុតហើយ!

ព្រះគម្ពីរបរិសុទ្ធបានអះអាងយ៉ាងប្រទៀតថា មនុស្សគ្រប់ៗរូបទាំងអស់សុទ្ធតែជាប់មានបាប គ្មានអ្នកណាម្នាក់ល្អបរិសុទ្ធសុចរិតសោះឡើយ សូម្បីតែម្នាក់ក៏គ្មានផង (រ៉ូម៣:១០ ៣:២៣) បើដូច្នោះមនុស្សគ្រប់ៗរូបទាំងអស់សុទ្ធតែត្រូវជាប់ចំណងបណ្តាសា ក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចង្អុលបង្ហាញថា ព្រះជាម្ចាស់ផ្ទាល់ជាអ្នកដែលបានដាក់បណ្តាសាដល់មនុស្សជាតិ ព្រមទាំងគ្រប់បណ្តាស្នាព្រះហស្តទាំងអស់ ដ្បិតពួកគេជាប់មានបាប បានធ្វើបាប ហើយព្រះស្អប់អំពើបាបយ៉ាងខ្លាំង (លោកុប្បត្តិ៣ លេវីវិន័យ២០:២៣ ហូសេ៩:១៥ កូរិថូសទី១ ៦:៩-១០)។ ការនេះគួរអោយញញើតខ្លាចក្រែងជាទីបំផុត ព្រោះព្រះជាម្ចាស់មានពេញដោយអំណាចព្រះចេស្តាគ្មាននរណាម្នាក់អាចប្រៀបផ្ទឹម និងស្វាបស្ទង់បានសោះឡើយ ហើយជាងហ្នឹងទៅទៀត ព្រះអង្គមានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យ និងដាក់ទោសមនុស្សបាបដោយផ្ទាល់។ មនុស្សគ្រប់ៗរូបសមណាស់តែត្រូវឆ្កាងសម្លាប់យ៉ាងអាម៉ាសជាទីបំផុតនៅចំពោះព្រះដ៏សុចរិត។ ថ្វីបើយ៉ាងដូច្នោះក្តី ដំណឹងល្អគឺ "ព្រះគ្រិស្តទ្រង់បានលោះយើងរាល់គ្នាអោយរួចពីសេចក្តីបណ្តាសារបស់ក្រិត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា..... "(កាឡាទី៣:១៣)។ សូមយើងទាំងអស់គ្នាងាកមកគិតពិចារណាសារជាថ្មីអំពីព្រះបន្ទូលមួយនេះអោយបានល្អិតល្អន់! ព្រះយេស៊ូវគ្រិស្ទត្រូវបណ្តាសាជំនួសយើងរាល់គ្នា ប្រយោជន៍អោយយើងរាល់គ្នាបានរួចពីបណ្តាសា។ ព្រះយេស៊ូវគ្រិស្ទត្រូវបានឆ្កាងនៅចំពោះព្រះដ៏សុចរិតជំនួសយើងរាល់គ្នា ប្រយោជន៍កុំអោយយើងរាល់គ្នាត្រូវឆ្កាងនៅចំពោះព្រះដ៏សុចរិត។ ព្រះយេស៊ូវគ្រិស្ទបានទទួលទោស ហើយសុគតបង់ថ្លៃប្រោសលោះបាបជំនួសយើងរាល់គ្នា (ដ្បិតឈ្នួលនៃអំពើបាប នោះជាសេចក្តីស្លាប់) ប្រយោជន៍កុំអោយយើងរាល់គ្នាជាប់មានទោស ព្រោះអំពើបាបតទៅទៀត។ ព្រះយេស៊ូវគ្រិស្ទបានទទួលរងការវិនិច្ឆ័យក្រោមព្រះពិរោធន៍របស់ព្រះវរបិតានៅលើឈើឆ្កាងជំនួសយើងរាល់គ្នា ប្រយោជន៍កុំអោយយើងរាល់គ្នាត្រូវភ្លក់រស់ជាតិដ៏ឈឺចាប់អស់កល្បជានិច្ចមួយនេះ។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទនៅលើឈើឆ្កាង បានរំដោះយើងរាល់គ្នាអោយមានសេរីភាពពីចំណងបណ្តាសា និងអំណាចរបស់អំពើបាប។ "ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ជាប់លើឈើឆ្កាង ដើម្បីអោយយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមរំពាត់របស់ទ្រង់ ដែលអ្នករាល់គ្នាបានជា ដ្បិតពីដើមអ្នករាល់គ្នាប្រៀបដូចជាចៀមដែលវង្វេង តែឥឡូវនេះបានត្រឡប់មកឯអ្នកគង្វាលវិញ ជាអ្នកថែទាំព្រលឹង អ្នករាល់គ្នាវិញហើយ" (ពេត្រុសទី១ ២:២៤-២៥)។ មនុស្សបាបអាចរួចផុតពីចំណងបណ្តាសា ដរាបណា

គេមានព្រះយេស៊ូវគ្រិស្ទដែលបានរងបណ្តាសាជំនួសគេ បើពុំដូច្នោះទេ គេនឹងត្រូវវេទ្ធាងសម្លាប់ក្រោមការវិនិច្ឆ័យរបស់ព្រះជាម្ចាស់អស់កល្បជានិច្ច៕

លោកហោរ៉ាអេសាយបានលើកឡើងអំពីព្រះយេស៊ូវគ្រិស្ទថា "ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទុទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់ ទ្រង់ត្រូវគេមើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខចេញ ហើយយើងរាល់គ្នារាប់អានទ្រង់សោះ" (អេសាយ៥៣៖៣)។ "ឯពួកមនុស្សដែលរក្សាព្រះយេស៊ូវ គេចំអកអោយទ្រង់ ហើយវាយទ្រង់ ក៏ខ្ទប់ព្រះនេត្រ ហើយទះកំផ្លៀងទ្រង់ ដោយទូលថា ចូរទាយចុះ តើអ្នកណាបានទះឯងគេក៏ពោលពាក្យប្រមាថទ្រង់ជាច្រើនទៀតដែរ" (លូកា២២៖៦៣-៦៥)។ នៅលើឈើឆ្កាង ព្រះវរបិតាបានបដិសេធន៍ហើយបោះបង់ចោលព្រះរាជបុត្រាស្ងួនភ្ងាតែមួយអង្គគត់ដែលទ្រង់ស្រលាញ់ខ្លាំងដល់ម្ល៉េះអោយសុគត ដាច់ចេញពីទ្រង់ដោយវេទនាក្នុងនាមជាមនុស្សបាបដែលសមនឹងទទួលការវិនិច្ឆ័យពីព្រះជាម្ចាស់ ដូចមនុស្សបាបគ្រប់ៗរូបដែរ បើទោះបីជាព្រះយេស៊ូវគ្រិស្ទមិនដែលបានប្រព្រឹត្តិបាបសោះយ៉ាងណាក្តី (ម៉ាថាយ២៧៖៤៦)។ ព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ព្រះដ៏ជាព្រះ បានឆ្លងកាត់គ្រប់ការដ៏គួរអោយស្អប់ខ្ពើមទាំងអស់ជំនួសមនុស្សបាបដែលសមតែទទួលភាពអាម៉ាសទាំងអស់នេះ ដើម្បីអោយមនុស្សដែលព្រះអង្គស្រលាញ់ខ្លាំងដល់ម្ល៉េះ បានជៀសចេញផុតពីទោសនៃអំពើបាប៕

ដំណឹងល្អគឺ ដោយព្រោះតែកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង ព្រះវរបិតាបានទតមកមើលមនុស្សផងទាំងពួងដែលនៅក្នុងព្រះរាជបុត្រារបស់ទ្រង់ ហើយកំណត់ថាពួកគេល្អបរិសុទ្ធ គ្មានបាប គ្មានទោស គ្មានជាប់បណ្តាសាទៀតទេ ព្រោះព្រះយេស៊ូវគ្រិស្ទបានទទួលយកទោសនៃអំពើបាបរបស់ពួកគេផ្ទុកលើអង្គទ្រង់ ព្រមទាំងស្លាប់ក្រោមបណ្តាសារបស់ព្រះជាម្ចាស់ជំនួសពួកគេរួចហើយ (រ៉ូម៥៖៨-៩ ៨៖១-៣ កាឡាទី៣៖១៣ កូរិនថូសទី២ ៥៖២១ ពេត្រុសទី១ ២៖២៤ ទំនុកតម្កើង១០៣៖១២ )។ ផលផ្លែដែលហុចអោយ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទ បានប្រោសលោះអស់អ្នកណាដែលជាប់នៅក្នុងទ្រង់ចេញពីទោសនៃបណ្តាសារួចជាស្រេច (អេសាយ៥៣៖៣ លូកា២២៖៦៣-៦៦ ភីលីព២៖៨ ពេត្រុសទី១ ២៖២៤)។ ទាក់ទងទៅនឹងការនេះផងដែរ លោកសាវ័កប៉ុលបានលើកឡើងថា "តើអ្នកណានឹងចោទប្តឹងពីពួករើសតាំងរបស់ព្រះបាន ដ្បិតគឺព្រះហើយដែលទ្រង់រាប់គេជាសុចរិត តើអ្នកណានឹងកាត់ទោសគេបាន ដ្បិតគឺព្រះគ្រិស្ទទ្រង់បានសុគតជំនួសគេហើយ..... " (រ៉ូម៨៖៣៣-៣៤)។ ចម្លើយគឺគ្មានទេ! អស់អ្នកដែលនៅក្នុងព្រះយេស៊ូវគ្រិស្ទ គ្មានទោសសោះ! ពួកគេបានរួចផុតពីការជំនុំជំរះរបស់ព្រះជាម្ចាស់ហើយ (រ៉ូម៨៖១)៕

ដោយព្រោះថ្លៃប្រោសលោះដែលព្រះយេស៊ូវគ្រិស្ទបានបង់រំលោះនៅលើឈើឆ្កាង គ្រិស្ទបរិស័ទទាំងអស់គ្មានទោសពៃទៀតទេនៅចំពោះព្រះដ៏សុចរិត។ ស្របពេលជាមួយគ្នានេះផងដែរ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទនៅលើឈើឆ្កាងបានយកជ័យជំនះយ៉ាងពេញទីលើសេចក្តីស្លាប់ដ៏អស់កល្បជានិច្ចដែលមនុស្សដំបូងបាននាំចូលមកក្នុងផែនដីតាមរយះអំពើបាប។ សេចក្តីស្លាប់គ្មានអំណាចលើព្រះយេស៊ូវគ្រិស្ទយ៉ាងណា វាក៏គ្មានអំណាចលើអស់អ្នកណាដែលនៅជាប់ក្នុងទ្រង់យ៉ាងដូច្នោះដែរ។ នៅត្រង់ចំនុចនេះ លោកសាវ័កប៉ុលបានលើកយកបទគម្ពីរចេញពីកណ្ឌហូសេមកបញ្ជាក់ប្រាប់ថា "អញនឹងដោះគេអោយរួចពីកណ្តាប់ដៃនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏នឹងលោះគេអោយរួចពីសេចក្តីស្លាប់ដែរ ឱសេចក្តីស្លាប់អើយ ទុក្ខវេទនារបស់ឯងនៅឯណា ឱស្ថានឃុំព្រលឹងមនុស្សស្លាប់អើយ អំណាចបំផ្លាញរបស់ឯង តើនៅឯងណា......" (ហូសេ១៣៖១៤ សូមមើល កូរិនថូសទី១១៥៖៥៥-៥៧)។ ចំណងបណ្តាសានៃអំពើបាប ការជំនុំជំរះរបស់

ព្រះជាម្ចាស់ សេចក្ដីស្លាប់ ភាពអាម៉ាស ទុក្ខវេទនាដ៏អស់កល្បជានិច្ច លនិងល គ្មានអំណាចលើអស់អ្នកណាដែលនៅជាប់ក្នុងព្រះយេស៊ូវគ្រិស្ទទៀតទេ ព្រោះនៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានទទួលរងការទាំងអស់នោះជំនួសពួកគេរួចជាស្រេចហើយ។ តាមរយៈព្រះយេស៊ូវគ្រិស្ទ និងកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាង គ្រិស្ទបរិស័ទបានរួចផុតពីអំណាចនៃអំពើបាប និងព្រះពិរោធន៍របស់ព្រះជាម្ចាស់ហើយ៕

ផុតគ្រោះព្រោះព្រះយេស៊ូវ៖ មកដល់ត្រឹមនេះ លោកអ្នកប្រហែលជាអាចមើលឃើញហើយថា គ្រិស្តបរិស័ទអាចចូលទៅក្នុងនគរស្ថានសួគ៍បាន មិនមែនព្រោះតែព្រះជាម្ចាស់អើពើ មិនខ្វល់ខ្វាយ ហើយលំអៀងចំពោះអំពើបាបរបស់ពួកគេនោះទេ ផ្ទុយទៅវិញ ព្រះជាម្ចាស់មើលរម្លងអំពើបាបទាំងអស់របស់គ្រិស្តបរិស័ទ ព្រោះព្រះយេស៊ូវគ្រិស្តដែលជាតំណាងរបស់ពួកគេបានចេញសងបង់ថ្លៃប្រោសលោះសម្រាប់ពួកគេ ម្ដងរួចជាស្រេចហើយនៅលើឈើឆ្កាង។ ដោយព្រោះ ព្រះយេស៊ូវគ្រិស្ទបានបង់សងថ្លៃឈ្នួលនៃអំពើបាបជំនួសគ្រិស្ទបរិស័ទរួចហើយ ព្រះជាម្ចាស់មិនអាចទាមទារយកថ្លៃឈ្នួលនៃអំពើបាប(សេចក្ដីស្លាប់) ម្ដងទៀតពីគ្រិស្ទបរិស័ទនោះទេ។ ដូចគ្នានេះដែរ គ្រិស្ទបរិស័ទបានឆ្លងរួចផុតពីការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ឈានចូលទៅក្នុងនគរស្ថានសួគ៌ មិនមែនព្រោះតែពួកគេបានធ្វើល្អគ្រប់គ្រាន់ជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់សោះឡើយ ផ្ទុយទៅវិញ គ្រិស្តបរិស័ទមានសេរីភាពចេញពីការជំនុំជំរះរបស់ព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងថ្លៃប្រោសលោះដែលព្រះយេស៊ូវគ្រិស្ទបានចេញសងជំនួសពួកគេនៅលើឈើឆ្កាង។ អស់អ្នកណាដែលនៅជាប់ក្នុងព្រះយេស៊ូវគ្រិស្ទ ព្រះអង្គបានចេញសងថ្លៃឈ្នួលនៃអំពើបាបជំនួសពួកគេរួចជាស្រេច ហើយជាលទ្ធផលពួកគេមិននៅជាប់ជំពាក់ក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់តទៅទៀត រហូតដល់អស់កល្បជានិច្ច។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្តបានយកកន្លែងរបស់មនុស្សបាប ប្រយោជន៍អោយមនុស្សបាបមានចំណែកក្នុងកន្លែងរបស់ទ្រង់នៅឯនគរស្ថានសួគ៌។ ការដែលព្រះយេស៊ូគ្រិស្តបានសម្រេចនៅលើឈើឆ្កាង គឺជាកិច្ចការតែមួយគត់ដែលព្រះជាម្ចាស់បានទាមទារពីមនុស្សបាបគ្រប់ៗរូបដើម្បីផ្សះផ្សាពួកគេជាមួយទ្រង់វិញ។ ក្នុងគោលបំណងដូចគ្នានេះផងដែរ ក្រៅពីកិច្ចការដែលព្រះយេស៊ូគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង គ្មានកិច្ចការណាមួយផ្សេងទៀតដែលមនុស្សអាចយកមកធ្វើជាឈ្នាន់ឈានជាន់ចូលទៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់បានជាដាច់ខាត៕

ដោយឡែក សេចក្ដីបង្រៀនមួយនេះ ពិបាកនឹងជឿ ហើយទទួលស្គាល់ជាទីបំផុតសម្រាប់បណ្ដាជនដែលធំដឹងក្ដីព្រមទាំងចម្រើនលូតលាស់នៅក្នុងផ្នត់គំនិត "ខ្លួនទីពឹងខ្លួន" ព្រោះផ្នត់គំនិតដ៏ចាស់កាលមួយនេះ ផ្ទុយស្រលះពីទិសដៅនៃត្រីវិស័យរបស់ព្រះជាម្ចាស់ ក្នុងការសង្គ្រោះមនុស្សលោកដែលកំពុងតែវិនាសបាត់បង់។ បើផ្អែកលើត្រីវិស័យដែលចង្អុលបង្ហាញដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ សេចក្ដីសង្គ្រោះដ៏ពិតប្រាកដបានចាក់គ្រឹះយ៉ាងរឹងមាំ ហើយជ្រាលជ្រៅជាទីបំផុតទៅលើព្រះគុណរបស់ព្រះជាម្ចាស់តែមួយគត់ ដោយបដិសេធន៍ចោលទាំងស្រុងនូវអំពើល្អរបស់បុគ្គលក្នុងការជួយសង្គ្រោះខ្លួនឯង។ ដំណឹងល្អ មិនមែនសំអាងលើសមិទ្ធផលដែលមនុស្សខិតខំសម្រេចដើម្បីផ្សះផ្សាខ្លួនគេជាមួយនឹងព្រះជាម្ចាស់វិញនោះទេ ផ្ទុយទៅវិញ វាជាកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចទាំងស្រុងនៅលើឈើឆ្កាង សម្រាប់មនុស្សបាប ហើយប្រោសប្រទានដល់ពួកគេដោយសារព្រះគុណ តាមរយៈសេចក្ដីជំនឿ (អេភេសូ២៖៨-៩)៕

## គ២ បរិសុទ្ធឥតខ្ចោះ!

នៅក្នុងសំបុត្រមួយដែលលោកសាវ័កប៉ុលបានសរសេរដើម្បីក្រើនរំលឹកក្រុមជំនុំកូរិនថូសអំពីភាពបរិសុទ្ធរបស់ពួកគេនៅចំពោះព្រះជាម្ចាស់ តាមរយះអង្គព្រះយេស៊ូវគ្រិស្ទបានលើកឡើងថា “ដ្បិតព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើអោយត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីអោយយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង”(កូរិថូសទី២ ៥៖២១)។ ព្រះយេស៊ូវគ្រិស្ទគឺជារូបភាពរបស់ព្រះដ៏សុចរិត ដែលបានប្រសូតនៅលើផែនដី ហើយបានរស់នៅដោយសុចរិត បរិសុទ្ធនៅចំពោះព្រះវរបិតា សម្រាប់ជាប្រយោជន៏ដល់អស់អ្នកណាដែលនៅជាប់ក្នុងទ្រង់។ ខណះពេលដែលព្រះយេស៊ូវគ្រិស្ទមានព្រះវត្តមាននៅលើផែនដីនៅឡើយ ព្រះអង្គមានជ័យជំនះពេញលេញទៅលើសេចក្ដីល្បួងដែលមនុស្សគ្រប់ៗរូប និងគ្រប់សម័យកាលទាំងអស់បានបរាជ័យ (លូកា៤៖១-១៣) ព្រះអង្គដើរតាមបំណងព្រះហឬទ័យរបស់ព្រះវរបិតាគ្រប់កាលះទេសះទាំងអស់ដោយគ្មានគេចកែ (លូកា២២៖៤២) ព្រះអង្គបានរក្សាទំនាក់ទំនងជាមួយនឹងព្រះវរបិតាដោយឥតខ្ចោះ (លូកា២២៖៤៤-៤៦) ព្រះអង្គទុកចិត្តលើព្រះវរបិតាមួយរយភាគរយ (យ៉ូហាន១១៖៤០-៤២) ព្រះអង្គស្រលាញ់ អត់ទោស ហើយអធិស្ឋានអោយខ្មាំងសត្រូវរបស់ទ្រង់ តាមព្រះបង្គាប់របស់ព្រះវរបិតា (លូកា២២៖៥០-៥១ ២៣៖៣៤) ព្រះអង្គបានសម្រេចតាមក្រិត្យវិន័យដោយគ្មានកំហុសឆ្គង (ម៉ាថាយ ៣៖១៥ ៥៖១៧)។ យើងអាចនិយាយបានថា បន្ទាប់ពីការធ្លាក់ចុះនៃអំពើបាប មានតែព្រះយេស៊ូវគ្រិស្ទតែមួយអង្គគត់ដែលល្អ បរិសុទ្ធ សុចរិត គ្រប់លក្ខណ៍ ហើយគ្មានបាបសោះ នៅចំពោះព្រះជាម្ចាស់ និងជាទីសព្វព្រះហឬទ័យរបស់ព្រះជាម្ចាស់ខ្លាំងណាស់ ដោយសូម្បីតែលោកអំប្រាហាំ ស្ដេចដាវីឌ លោកណូអេ លោកសាវ័កប៉ុល លនិងល ជាដើមសុទ្ធសឹងតែជាមនុស្សមានបាប ដូចមនុស្សផងទាំងពួងដែរ។ ដោយឡែក បើផ្អែកលើព្រះបន្ទូលកូរិថូសទី២ ៥៖២១ ដែលលោកសាវ័កប៉ុលបានលើកឡើងខាងលើ ភាពសុចរិតដ៏ឥតខ្ចោះទាំងអស់របស់ព្រះយេស៊ូវគ្រិស្ទ បានផ្ទេរមកអោយអស់អ្នកណាដែលនៅជាប់ក្នុងទ្រង់ទុកជាមរតក ពោលគឺគ្រិស្ទបរិស័ទទាំងអស់សុទ្ធតែល្អឥតខ្ចោះ គ្មានជាប់ប្រឡាក់ស្នាមបាបបន្តិចសោះឡើយ នៅចំពោះព្រះវរបិតា ថែមទាំងជាទីពេញចិត្តរបស់ព្រះវរបិតាខ្លាំងណាស់ ដូចជាព្រះយេស៊ូវគ្រិស្ទផងដែរ។ ទាក់ទងទៅនឹងការនេះផងដែរ លោករីឆាត រ៉ុដើរ បាននិយាយថា “នៅពេលដែលយើងបានរាប់ជាសុចរិត កំណត់ត្រារបស់យើងមានតែសេចក្ដីសុចរិតឥតខ្ចោះរបស់ព្រះគ្រិស្ដ
និងគ្មានការកត់ត្រាអំពើបាបរបស់យើងទៀតឡើយ”[21] ។ ពេលដែលព្រះជាម្ចាស់ទតមកមើលគ្រិស្ទបរិស័ទទាំងឡាយ ព្រះអង្គឃើញតែភាពល្អបរិសុទ្ធរបស់ព្រះយេស៊ូវគ្រិស្ទនៅក្នុងពួកគេ ដោយគ្មានអំពើបាបសៅហ្មងសោះឡើយ៕

មួយវិញទៀត លោកបណ្ឌិត អ. ប. សិម្បសិន បានសរសេរថា “ព្រះទ្រង់រាប់យើងជាសុចរិត ហេតុនេះយើងអាចឈរនៅចំពោះទ្រង់ទុកជាមនុស្សសុចរិតទៀងត្រង់ឡើងវិញ។ ព្រះទ្រង់ទទួលយើងហាក់ដូចជាបានធ្វើការទាំងអស់ដែលព្រះទ្រង់បានបង្គាប់មក ហាក់ដូចជាបានកាន់តាមក្រិត្យវិន័យគ្រប់ជំពូកទៅហើយ គឺទ្រង់យកស្លាប់ប៉ាកកាឆូតជំពាក់របស់យើង លុបចេញពីបញ្ជីអស់រលីង ហើយក៏កត់អស់ទាំងសេចក្ដីសុចរិតរបស់ព្រះគ្រិស្ដចុះក្នុងបញ្ជីនោះវិញ។ ភាពឥតសៅហ្មងនៃព្រះយេស៊ូវបានចុះនៅក្នុងបញ្ជីរបស់យើង ទុកជារបស់ផងយើងពិតប្រាកដមែនហើយ។ អស់ទាំងការដែលទ្រង់ស្ដាប់បង្គាប់ព្រះវរបិតា អស់ទាំងសេចក្ដីអត់ធ្មត់ និងសេចក្ដីសុភាពស្លូតបូតនៃទ្រង់នោះត្រឡប់ទៅជារបស់ផងអ្នកវិញ។

---

[21] សងជាសម្រេច និពន្ធដោយលោករីឆាត រ៉ុដើរ ទំព័រ៤៣

អស់ទាំងបេសកកម្មដែលទ្រង់បានបំពេញ ដើម្បីប្រទានពរទៅលើគេនោះបានកត់ត្រាទៅក្នុងបញ្ជីរបស់អ្នក ក៏ដូចជាអ្នកបានធ្វើដោយខ្លួនឯងវិញ។ អស់ទាំងគុណសម្បត្តិដែលអ្នកអាចរកឃើញនៅក្នុងព្រះអង្គ នោះបានផ្ទេរមកលើអ្នក ហើយ
អស់ទាំង
អំពើអាក្រក់
(របស់អ្នក) នោះបានផ្ទុកទៅលើអង្គទ្រង់វិញ"[22]។ គ្រប់សព្វបែបយ៉ាងទាំងអស់ដែលជាកម្មសិទ្ធរបស់ព្រះយេស៊ូវគ្រិស្ទ គឺជាកម្មសិទ្ធរបស់គ្រិស្ទបរិស័ទ ហើយក្នុងន័យដូចគ្នានេះផងដែរ គ្រប់សព្វបែបយ៉ាងទាំងអស់ដែលព្រះយេស៊ូវគ្រិស្ទសមនឹងទទួល គ្រិស្ទបរិស័ទក៏សមនឹងទទួលផងដែរ (ក៏ប៉ុន្តែ ខ្ញុំជឿថា លើកលែងតែសិរីល្អ ព្រោះសិរីល្អគឺជាកម្មសិទ្ធតែមួយគត់របស់ព្រះជាម្ចាស់ ឯវត្តមានរបស់មនុស្សគឺដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់ដែលជាម្ចាស់នៃសិរីល្អតែមួយអង្គគត់)។ បើទោះបីជាយ៉ាងណាក៏ដោយ ស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់បានត្រឡប់ដូចជាព្រះរាជបុត្រាស្ងួនភ្ងាតែមួយអង្គគត់របស់ទ្រង់ ហើយពួកគេនឹងត្រូវបានលើកតម្កើងអោយគ្រងមរតកជាមួយនឹងព្រះយេស៊ូវគ្រិស្ទអស់កល្បជានិច្ច។ នេះគឺជាការរំពឹងទុក ប្រកបទៅដោយសេចក្ដីសង្ឃឹមរបស់គ្រិស្ទបរិស័ទគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់៕

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទត្រូវបានលោកសាវ័កប៉ុលលើកយកមកលាតត្រដាងយ៉ាងច្បាស់ថា "ដ្បិតបើសិនជាសេចក្ដីស្លាប់បានសោយរាជ្យដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តិសេចក្ដីរំលង ដូច្នោះប្រាកដជាពួកអ្នកដែលទទួលព្រះគុណជាបរិបូរណ៍ និងអំណោយទានជាសេចក្ដីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រិស្ទ" (រ៉ូម៥៖១៧)។ នៅពេលដែលមនុស្សដំបូងបានធ្វើបាប ព្រះជាម្ចាស់បានទតមើលមកមនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ ហើយសន្និត់ថា គ្រប់គ្នាទាំងអស់សុទ្ធតែជាមនុស្សបាប ដូចគ្នានេះដែរ ព្រះជាម្ចាស់បានរាប់អស់អ្នកណាដែលជាប់នៅក្នុងព្រះយេស៊ូវគ្រិស្ទថា គ្មានបាប សុចរិត ឥតខ្ចោះ ព្រោះតែជីវិតរបស់ព្រះយេស៊ូគ្រិស្ទនៅលើផែនដី និងកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាង (កូរិនថូសទី១ ១៖៣០)។ ព្រះយេស៊ូវគ្រិស្ទបានទទួលរងនូវការវិនិច្ឆ័យជំនួសកន្លែងរបស់មនុស្សបាប ក្រោមព្រះពិរោធន៏របស់ព្រះវរបិតា។ ព្រះអង្គបានទ្រាំទ្រយកទាំងអស់ ដើម្បីដកយកអំពើបាបទាំងអស់របស់មនុស្សចេញ (ទំនុកតម្កើង១០៣៖១២) ហើយបំពាក់គេដោយសំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ និងគ្រលំគេដោយសេចក្ដីសុចរិតជាជំនួសវិញ (អេសាយ៦១៖១០)។ គ្រិស្តបរិស័ទប្រៀបបានដូចជាកូនចៀមដ៏ល្អឥតខ្ចោះ ឥតស្លាកស្នាម នៅចំពោះព្រះជាម្ចាស់ដោយសារតែភាពល្អបរិសុទ្ធឥតខ្ចោះរបស់ព្រះយេស៊ូវគ្រិស្តតែមួយគត់ (១ពេត្រុស១៖១៩)៕

លើសពីនេះទៅទៀត ភាពល្អបរិសុទ្ធរបស់ព្រះយេស៊ូវគ្រិស្ទតែមួយគត់ដែលមានតម្លៃ ហើយគាប់ព្រះហឬទ័យរបស់ព្រះវរបិតា។ លោកសាវ័កប៉ុលបានឃើញ ហើយយល់យ៉ាងជាក់ច្បាស់អំពីការនេះ ហេតុដូច្នោះហើយបានជាក្នុងនាមជាមនុស្សដែលតែងតែខិតខំសង្វាតកាន់តាមក្រិត្យវិន័យយ៉ាងម៉ឺងម៉ាត់ជាទីបំផុត ដើម្បីអោយបានសុចរិតនៅចំពោះព្រះជាម្ចាស់ លោកសាវ័កប៉ុលបែរជាបានបោះបង់ចោលទាំងអស់ ហើយរាប់គ្រប់ទាំងអស់ដែលគាត់ធ្លាប់បានធ្វើពីមុនទុកដូចជាសំរាម ជាខាត ដើម្បីទទួលបានភាពបរិសុទ្ធរបស់ព្រះគ្រិស្ទវិញ (ភីលីព៣៖៧-១០) ព្រោះដូចដែលបានរៀបរាប់

---

[22] ទិដ្ឋភាពទាំងបួននៃដំណឹងល្អ និពន្ធដោយលោកបណ្ឌិត អ. ប. សិម្សុិន ទំព័រទី៧

ខាងលើ ភាពបរិសុទ្ធដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចតែមួយគត់ដែលមានតម្លៃ ហើយសព្វព្រះហឫទ័យរបស់ព្រះវរបិតា មិនមែនជាភាពបរិសុទ្ធក្លែងក្លាយដែលជាផលផ្លែរបស់សមត្ថភាពបុគ្គលនោះទេ៕

### គ.៣ ជ័យជំនះលើអំពើបាប

ពេលដែលព្រះយេស៊ូវគ្រិស្ទគង់នៅលើផែនដី ព្រះអង្គបានបង្រៀនសិស្សរបស់ទ្រង់អោយអធិស្ឋាថា "…. ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌…… សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ…… " (ម៉ាថាយ៦៖៩-១៣)។ ពិតមែនហើយ បើទោះបីជាគ្រិស្ទបរិស័ទមានសេរីភាពចេញពីចំណងរបស់អំពើបាប និងបានរួចផុតពីបណ្តាសារបស់អំពើបាបយ៉ាងណាក្តី ក៏ពួកគេនៅតែគេចមិនផុតពីការប្រព្រឹត្តិបាបដែរ ខណៈពេលដែលពួកគេកំពុងតែដើរតាមព្រះយេស៊ូវគ្រិស្ទនៅលើផែនដី។ បើផ្អែកលើព្រះបន្ទូលអធិស្ឋានរបស់ព្រះយេស៊ូវគ្រិស្ទ ព្រះអង្គបានជ្រាបច្បាស់ថា កូនចៀមរបស់ទ្រង់នឹងជំពប់ជើងដួល វង្វេងចេញពីទ្រង់ ហើយបដិសេធន៍សំលេងទ្រង់ ដោយចេតនា និងដោយអចេតនា។ បើទោះបីជាយ៉ាងណាក៏ដោយ ការនេះមិនមែនជាលេសសម្រាប់គ្រិស្ទបរិស័ទធ្វើបាបនោះទេ ផ្ទុយទៅវិញ វាជាការដាស់តឿនគ្រើនរំលឹក ប្រយោជន៍អោយពួកគេបានក្រាញនៀលចាំយាមជាជំនួស។ លោកយ៉ាកុប ដែលជាប្អូនប្រុសរបស់ព្រះយេស៊ូវគ្រិស្ទបានលើកឡើងដល់គ្រិស្ទបរិស័ទទាំងឡាយថា "ដ្បិតយើងទាំងអស់គ្នាក៏ជំពប់ជាញយៗដែរ"(យ៉ាកុប៣៖២)។ ចំណែកឯ លោកយ៉ូហានវិញ បានបង្រៀនប្រៀនប្រដៅដោយបើកចំហចំៗថា "បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ" (យ៉ូហានទី១ ១៖៨)។ ស្របពេលជាមួយគ្នានេះដែរ ព្រះគម្ពីរសញ្ញាចាស់បានគាំទ្រយ៉ាងពេញទំហឹងថា នៅលើផែនដីនេះ គ្មាននរណាម្នាក់ដែលអាចរស់នៅបានដោយបរិសុទ្ធ ល្អឥតខ្ចោះ មិនប្រព្រឹត្តិបាបបានសោះឡើយ សូម្បីតែគ្រិស្ទបរិស័ទ លើកលែងតែព្រះយេស៊ូវគ្រិស្ទតែមួយអង្គប៉ុននោះ (សុភាសិត២០៖៩ សាស្តា៧៖២០ ពង្សាវតាក្សត្រទី១ ៨៖៤៦)។ គ្មានអ្វីដែលអាចប្រកែកបាននោះទេថា ព្រះលោហិតរបស់ព្រះយេស៊ូវគ្រិស្ទបានលាងជំរះអស់អ្នកណាដែលនៅក្នុងទ្រង់អោយបានស្អាតពីអំពើបាប ប្រៀបបានដូចជាកូនចៀមដ៏ល្អឥតខ្ចោះ និងឥតស្លាកស្នាមនៅចំពោះព្រះជាម្ចាស់ (ពេត្រុសទី១ ១៖១៩) ក៏ប៉ុន្តែដរាបណាព្រះយេស៊ូវគ្រិស្ទមិនទាន់យាងត្រឡប់មកវិញជាលើកទីពីរ គ្រិស្តបរិស័ទមិនអាចគេចផុតពីការមិនប្រព្រឹត្តិបាបបាននោះទេ។ បើទោះបីជាយ៉ាងដូច្នោះក្តី ដំណឹងល្អគឺអំពើបាបគ្មានអំណាចលើគ្រិស្ទបរិស័ទតទៅទៀតទេ។ លោកសាវ័កប៉ុលបានសរសេរដើម្បីបង្រៀនពួកជំនុំនៅក្នុងទីក្រុងរ៉ូមអំពីសេចក្តីពិតដ៏អស្ចារ្យមួយនេះថា "ដ្បិតបាបមិនត្រូវមានអំណាចលើអ្នករាល់គ្នាទៀតឡើយ ដោយព្រោះអ្នករាល់គ្នាមិននៅក្រោមក្រិត្យវិន័យ គឺនៅក្រោមព្រះគុណវិញ" (រ៉ូម៦៖១៤)។ បើទោះបីជាគ្រិស្តបរិស័ទភ្លាត់ធ្វើបាប តែអំពើបាបគ្មានអំណាចចោទប្រកាន់ទោសពៃដល់គ្រិស្តបរិស័ទទៀតឡើយ ពោលគឺការនេះមិនប៉ះពាល់ដល់សេចក្តីសង្គ្រោះរបស់ពួកគេទេ ព្រោះខណៈពេលដែលគ្រិស្តបរិស័ទបានក្លាយជាគ្រួសារដ៏ពិតប្រាកដរបស់ព្រះ តាមរយះសេចក្តីជំនឿ និងព្រះគុណ នោះគ្មានអ្វីដែលអាចពង្រាត់ពួកគេចេញពីព្រះហស្តរបស់ព្រះជាម្ចាស់បានឡើយ សូម្បីតែអំពើបាប (រ៉ូម៨៖៣១-៣៩)។ លោកយ៉ូហានបានលើកឡើងថា "… បើព្រះរាជបុត្រាប្រោសអោយអ្នករាល់គ្នាបានរួច នោះនឹងបានរួចពិត"(យ៉ូហាន៨៖៣៦)។ គ្រប់អំពើបាបទាំងអស់របស់គ្រិស្តបរិស័ទចាប់តាំងពីអតីតកាល រហូតដល់បច្ចុប្បន្នកាល ហើយលើសពីនេះទៅទៀត សូម្បីតែអំពើបាប

នៅពេលអនាគតដែលគ្រិស្តបរិស័ទមិនទាន់បានប្រព្រឹត្តិផង ត្រូវបានព្រះយេស៊ូវគ្រិស្តបង់រំលោះ និងលាងជំរះអោយស្អាតអស់ហើយ។ អំពើបាបគ្មានអំណាចលើគ្រិស្តបរិស័ទទៀតឡើយ ព្រោះព្រះយេស៊ូវគ្រិស្តបានកិនបំផ្លាញវាម្តងជាសម្រេចសម្រាប់ពួកគេហើយ តាមរយះកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាង។ ជោគជ័យរបស់ព្រះយេស៊ូវគ្រិស្តលើអំពើបាប គឺជាជោគជ័យរបស់គ្រិស្តបរិស័ទគ្រប់ៗរូប។ ក្នុងនាមជាកូនស្ងួនភ្ងារបស់ព្រះជាម្ចាស់ អំពើបាបគ្មានអំណាចលើគ្រិស្តបរិស័ទសោះឡើយ៕

ជាការពិតណាស់ គ្រិស្តបរិស័ទក៏ដូចជាមនុស្សគ្រប់ៗរូបផងដែរ ពួកគេនៅតែជាប់មានកំសោយខាងសាច់ឈាមនៅឡើយ។ គ្រិស្តបរិស័ទនៅតែមានចិត្តចង់រស់នៅ តាមលំអានរបស់លោកិយ បើទោះបីជាការនេះមិនគាប់បំណងព្រះហឬទ័យរបស់ព្រះជាម្ចាស់យ៉ាងណាក្តី។ ជាពិសេស ខណះពេលដែលគ្រិស្តបរិស័ទភ្លេចខ្លួន មិនយល់ច្បាស់អំពីអត្តសញ្ញាណនៃជីវិតថ្មីរបស់ខ្លួន ងោកងុយ គ្មានចិត្តចាំយាម និងមិនព្រមដាក់ដាំគ្រាប់ពូជនៃជីវិតរបស់ខ្លួនលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្បែរទ្រទ្រង់ដែលជាប្រភពនៃទឹករស់ នោះគឺគេកំពុងតែរំកិលខ្លួនបន្តិចម្តងៗឆ្ពោះទៅជិតអំពើបាប ចេញឆ្ងាយពីព្រះជាម្ចាស់។ ការក្លាយជាគ្រិស្តបរិស័ទមិនមែនបានសេចក្តីថា អំពើបាបគ្មានឥទ្ធិពលមកលើរូបគេនោះទេ។ ការយល់ឃើញថា គ្រិស្តបរិស័ទល្អប្រសើរ និងបរិសុទ្ធជាងលោកិយដោយព្រោះពួកគេមិនធ្វើបាបសោះនោះ ជាការខុសឆ្គងដែលនាំមកនូវគ្រោះថ្នាក់ដ៏ធំសម្បើមបំផុតមួយដែលគ្រិស្តបរិស័ទគួរតែប្រុងប្រយត្ន័។ មួយវិញទៀត ការព្រងើយកន្តើយចំពោះអំពើបាបដែលអាចវាយប្រហារមកលើជីវិតខាងព្រលឹងវិញ្ញាណរបស់គ្រិស្តបរិស័ទបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់ គឺជាកំហុសឆ្គងមួយរបស់គ្រិស្តបរិស័ទ ព្រោះអារក្សសាតាំងដែលជាសត្រូវរបស់ព្រះជាម្ចាស់ និងអ្នកជឿ តែងតែឆ្លៀតឱកាសដើម្បីបំផ្លាញពួកគេជាដរាប។ និស្ស័យចាស់ ប្រៀបបានដូចជាស្រមោលអន្ទោលតាមប្រាណ ចាំរុញច្រានគ្រិស្តបរិស័ទអោយប្រព្រឹត្តិបាប ហើយឈប់រស់នៅដើម្បីសិរីល្អរបស់ព្រះជាម្ចាស់។ ទម្លាប់បាបពីអតីតកាល ជាឧបសគ្គសម្រាប់គ្រិស្តបរិស័ទក្នុងការរស់នៅ និងរីកចម្រើនក្នុងជីវិតថ្មីដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេ ហើយប៉ះពាល់ដល់ទីបន្ទាល់របស់ពួកគេក្នុងនាមជាតំណាងរបស់ព្រះរាជបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់។ ខ្ញុំពេញចិត្តនឹងពុំនោលខ្មែរបុរាណមួយដែលបានលើកឡើងថា “កុកអាចភ្លេចជុង តែជុងគ្មានថ្ងៃភ្លេចកុកជាដាច់ខាត” ក្នុងន័យដូចគ្នានេះផងដែរ ប្រសិនបើគ្រិស្តបរិស័ទភ្លេចខ្លួន មិនយូរមិនឆាប់ គេនឹងភ្លាត់ធ្លាក់ជាប់អន្ទាក់របស់និស្ស័យចាស់ ទម្លាប់ចាស់ និងអំពើបាបជាក់ជាមិនខាន។ ការងោកងុយ ព្រងើយកន្តើយ និងមិនចាំយាមរបស់គ្រិស្តបរិស័ទប្រៀបបានដូចជាការបើកទ្វារចំហរ ហើយហុចឱកាសអោយអំពើបាបចូលមករំលើងបំផ្លាញឬសគល់ ដែលជាប្រភពនៃការរីកចម្រើនលូតលាស់របស់ពួកគេ ក្នុងវិថីនៃសេចក្តីជំនឿ។ ដោយឡែក ក្នុងគោលបំណងដើម្បីបង្រៀនអប់រំ រំលឹកដាស់តឿនប្រៀនប្រដៅក្រុមជំនុំរបស់ព្រះយេស៊ូវគ្រិស្ទ លោកសាវ័កពេត្រុសបានលើកទឹកចិត្តដល់ពួកគ្រិស្តបរិស័ទថា “ចូរអោយដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងតែក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន”(ពេត្រុសទី១ ៥៖៨)។ ចូរអោយដឹងខ្លួន ហើយចាំយាមដោយក្រាញនៀល តែកុំចុះចាញ់ចំពោះអំពើបាប ព្រោះតាមរយះព្រះយេស៊ូវគ្រិស្ទ គ្រិស្តបរិស័ទមានជ័យជំនះលើអំពើបាបស្រេចហើយ។ ថ្វីត្បិតតែអំពើបាបគ្មានអំណាចដាក់គ្រិស្តបរិស័ទអោយស្ថិតនៅក្រោមការវិនិច្ឆ័យដ៏អស់កល្បរបស់

ព្រះជាម្ចាស់បានដូចមុនទៀតយ៉ាងណាក្តី តែអំពើបាបនៅតែមានឥទ្ធិពលលើជីវិតរបស់គ្រិស្ទបរិស័ទនៅឡើយ រហូតដល់ថ្ងៃដែលព្រះយេស៊ូវគ្រិស្ទយាងត្រឡប់មកវិញជាលើកទីពីរ៕

ព្រះយេស៊ូវគ្រិស្ទបានប្រោសលោះ និងសង្គ្រោះគ្រិស្តបរិស័ទចេញពីនឹមត្រួតត្រារបស់អំពើបាប។ គ្រិស្តបរិស័ទមិនមែនជាបាវបំរើរបស់អំពើបាបទៀតទេ តែជាកម្មសិទ្ធិរបស់ព្រះដ៏ខ្ពង់ខ្ពស់ទៅវិញ។ ហេតុដូច្នោះហើយ លោកសាវ័កប៉ុលបានក្រើនរំលឹកគ្រិស្ទបរិស័ទអោយឈប់រស់នៅដោយប្រព្រឹត្តិបាបដើម្បីផ្គាប់ជីវិតបាបខាងសាច់ឈាម ហើយបែរត្រឡប់មករស់នៅជាបាវរបស់សេចក្តីសុចរិត ដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាជំនួសវិញ (រ៉ូម៦៖១៨)។ មួយវិញទៀតស្របពេលដែលនិស្ស័យចាស់ចាំអូសទាញជាន់ពន្លិចគ្រិស្តបរិស័ទអោយធ្លាក់ចុះចូលទៅក្នុងជីវិតចាស់ ព្រះជាម្ចាស់បានប្រោសប្រទាននិស្ស័យថ្មីដល់គ្រិស្តបរិស័ទ ដើម្បីជួយគេអោយតតាំងច្បាំងនឹងនិស្ស័យបាប ហើយដើរតាមមាគ៌ាដ៏ត្រឹមត្រូវសុចរិតតែមួយគត់របស់ទ្រង់វិញ។ ព្រះយេស៊ូវគ្រិស្ទមិនត្រឹមតែបានសង្គ្រោះយើងចេញពីទោសនៃអំពីបាបនោះទេ លើសពីនេះទៅទៀត ព្រះអង្គបានរៀបចំផ្លូវអោយយើងអាចឈ្នះលើអំពើបាបក្នុងជីវភាពប្រចាំថ្ងៃផងដែរ។ ការនេះស្របគ្នាទៅនឹងលោកសាវ័កយ៉ូហានដែលបានលើកឡើងថា “ពីព្រោះគ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកិយ៍ហើយ ឯជ័យជំនះដែលឈ្នះលោកិយ៍ នោះគឺជាសេចក្តីជំនឿរបស់យើង តើអ្នកណាជាអ្នកឈ្នះលោកិយ បើមិនមែនជាអ្នកដែលជឿថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ” (យ៉ូហានទី១ ៥៖៤-៥)។ លោកសាវ័កយ៉ូហានដដែលក៏បានបន្តទៀតថា “យើងដឹងថា អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ” (យ៉ូហានទី១ ៥៖១៨)។ នៅក្នុងព្រះយេស៊ូវគ្រិស្ទ គ្រិស្ទបរិស័ទមានសេរីភាពចេញផុតពីចំណងនៃអំពើបាប ហើយពួកគេមិនស្ថិតក្រោមទោសរបស់អំពើបាបតទៅទៀតនោះទេ។ អ្នកនិពន្ធសៀវភៅ “បានល្អ ធ្វើល្អ” បានលើកឡើងថា “ដំណឹងល្អមិនគ្រាន់តែសង្គ្រោះមនុស្សពីនរកអស់កល្បជានិច្ចប៉ុណ្ណោះនោះទេ ដំណឹងល្អក៏សង្គ្រោះមនុស្សអោយផុតពីអំណាចបាបនៅក្នុងជីវិតនេះដែរ”[23]។ ខុសពីលោកិយ គ្រិស្តបរិស័ទមានសង្ឃឹមព្រមទាំងមានជ័យជំនះលើអំពើបាប ដោយមិនប្រព្រឹត្តិបាបតាមការអូសទាញរបស់និស្ស័យចាស់ ក៏ប៉ុន្តែការនេះមិនមែនដោយពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួននោះទេ តែដោយពឹងផ្អែកលើព្រះយេស៊ូវគ្រិស្ទតែមួយអង្គគត់៕

ជាចុងក្រោយ លោកសាវ័កប៉ុលបាននិយាយថា “..... បើអ្នកណានៅក្នុងព្រះគ្រិស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មី” (កូរិនថូសទី២ ៥៖១៧ សូមមើលកាឡាទី៦៖១៥)។ “ដូច្នោះអ្នករាល់គ្នាមិនមែនជាអ្នកដ៏ទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែមួយនឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ” (អេភេសូរ២៖១៩)។ “ទ្រង់បានប្រោសយើងអោយរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ .... ”(កូល៉ុស១៖១៣-១៤)។ គ្រិស្តបរិស័ទបានប្រដាប់កាយដោយព្រះគ្រិស្ទ (កាឡាទី៣៖២៧ រ៉ូម១៣៖១៤)។ នៅលើឈើឆ្កាង យើងបានឆ្កាងសម្លាប់ជីវិតចាស់ដែលតែងតែពុករលួយរបស់យើងចោល ហើយទទួលយកជីវិតថ្មីដ៏ស្ថិតស្ថេរអស់កល្បដែលជាព្រះគុណមកពីព្រះជាម្ចាស់វិញ។ ហេតុដូច្នោះហើយបានជាលោកសាវ័កប៉ុលហ៊ានលើកឡើងថា “ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រិស្ទ ប៉ុន្តែខ្ញុំរស់មិនមែនជាខ្ញុំទៀតទេ គឺជាព្រះគ្រិស្ទទ្រង់រស់ក្នុងខ្ញុំវិញ...... ”(កាឡាទី២៖២០)។ តាមរយះជ័យជំនះដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើ

[23] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. គ្រោលី ទំព័រ២៤

ឈើឆ្កាង សត្រូវដ៏គួរអោយស្អប់ខ្ពើមបំផុតរបស់ព្រះជាម្ចាស់ បានត្រឡប់ជាកូនស្ងួនភ្ងាដ៏ពិសិដ្ឋរបស់ទ្រង់វិញ។ មនុស្ស ដែលធ្លាប់រស់នៅដើម្បីអារក្សសាតាំង បានបែរមករស់នៅដើម្បីព្រះជាម្ចាស់វិញ។ បល្ល័ង្កចិត្តដែលធ្លាប់បានគ្រប់គ្រង ដោយអារក្សសាតាំង បានថ្វាយមកដល់ព្រះជាម្ចាស់គ្រប់គ្រងជាជំនួសវិញ។ ជ័យជំនះរបស់ព្រះយេស៊ូវគ្រិស្ទនៅលើ ឈើឆ្កាង ជាត្រីវិស័យដឹកនាំគ្រិស្ទបរិស័ទអោយរស់នៅតាមគោលដៅនៃជីវិត ស្របតាមនិមិត្តនៃការបង្កើតរបស់ ព្រះជាម្ចាស់ តាំងពីដើមដំបូងមកម្ល៉េះ៕

## គ ៤ សេចក្តីស្រលាញ់ និងភាពយុត្តិធម៌

នៅលើឈើឆ្កាង ឯកំពូលភ្នំកាល់វ៉ារី ទីដែលព្រះរាជបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បានដាក់ជីវិតចុះ មនុស្សជាច្រើនបាន មើលឃើញថា វាជាទារុណកម្មដ៏ព្រៃផ្សៃ ជាសេចក្តីអាម៉ាស និងជារឿងដ៏ឆ្កួតលីលា លនិងល ក៏ប៉ុន្តែមានសេចក្តីពិតជា ច្រើន ដែលមនុស្សបានមើលរម្លង ឬមើលមិនឃើញទាក់ទងទៅនឹងឈើឆ្កាងដែលព្រះយេស៊ូវគ្រិស្ទបានលើកលីដោយ លំបាកវេទនា ដូចជាព្រះគុណ សេចក្តីស្រលាញ់ ភាពយុត្តិធម៌ សេចក្តីសង្ឃឹម ការផ្សះផ្សា និងជីវិតថ្មី លនិងល៕

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដិតដាមទៅដោយស្នាកស្នាមនៃសេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅឥតគណនា។ ព្រះគម្ពីរបរិសុទ្ធបានអះអាងម្តងហើយម្តងទៀតថា ព្រះជាម្ចាស់ជាតួនៃសេចក្តីស្រលាញ់ ហើយព្រះអង្គស្រលាញ់ មនុស្សលោកខ្លាំងដល់ម្ល៉េះ បើទោះបីជាពួកគេនៅជាប់ជាមនុស្សមានបាបនៅឡើយយ៉ាងណាក្តី (អេសាយ៥៤៖១០ ទំនុក តម្កើង១៣៦៖២៦ យ៉ូហាន៣៖១៦ រ៉ូម៥៖៨ ៨៖៣៧-៣៩ យ៉ូហានទី១ ៤៖៧-១១)។ ស្របពេលជាមួយគ្នានេះផងដែរ ព្រះបន្ទូល របស់ព្រះជាម្ចាស់ក៏បានចង្អុលបង្ហាញដែរថា ព្រះជាម្ចាស់យុត្តិធម៌ ហើយសុចរិត ចំណែកឯមនុស្សបាបមិនអាចគេចផុតពី ការជំនុំជំរះរបស់ទ្រង់បានជាដាច់ខាត បើទោះបីជាសេចក្តីស្រលាញ់របស់ទ្រង់ចំពោះពួកគេធំធេងហួសល្បត់នឹងពិពណ៌នា យ៉ាងណាក្តី។ មួយវិញទៀត ដូចដែលបានរៀបរាប់ខាងលើ គ្មានអ្វីដែលមនុស្សអាចធ្វើបានដោយពឹងផ្អែកលើសមត្ថភាព ផ្ទាល់ខ្លួន ដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ប្រយោជន៍អោយទ្រង់មើលរម្លងអំពើបាបរបស់ពួកគេឡើយ។ ព្រះជាម្ចាស់មិនអាចលើកលែងទោសអោយមនុស្សបាបដោយទទេរ ដោយយល់ដល់សេចក្តីស្រលាញ់ដ៏ធំធេងរបស់ទ្រង់ នោះទេ ពោលគឺព្រះជាម្ចាស់ទាមទារជាដាច់ខាតថា ទោសនៃអំពើបាបរបស់មនុស្សត្រូវតែសងជាចាំបាច់។ ការនេះគឺបាន សេចក្តីថា មនុស្សបាបត្រូវតែស្លាប់ ហើយដាច់ចេញពីព្រះជាម្ចាស់អស់កល្បជានិច្ច ដ្បិតនេះគឺជាឈ្នួលនៃអំពើបាបដែល ព្រះជាម្ចាស់កំណត់មកដោយអង្គទ្រង់ផ្ទាល់ (លោកុប្បត្តិ២៖១៧ យ៉ូហានទី១ ៤៖៨ ៤៖១៦ យ៉ូប៣៤៖១២ ចោទិយកថា៣២៖៤ ទំនុកតម្កើង៨៦៖១៥ ៩៩៖៤)៕

ពេលដែលខ្ញុំនៅតូច ខ្ញុំតែងតែគិតថា ប្រសិនបើព្រះជាម្ចាស់ពិតជាស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ ព្រះអង្គ ប្រាកដជាលើកលែងទោស និងជួយសង្គ្រោះពួកគេដោយគ្មានលក្ខខណ្ឌំឡើយ។ ដូចគ្នានេះដែរ ធ្វើម៉េចអោយ ព្រះជាម្ចាស់អះអាងថា ព្រះអង្គស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ ប្រសិនបើទ្រង់នឹងវិនិច្ឆ័យពួកគេអោយស្លាប់រងទុក្ខ ទោសវេទនាអស់កល្បជានិច្ចនោះ។ ប្រាកដណាស់! មនុស្សជាច្រើនសុទ្ធតែធ្លាប់បានគិតយ៉ាងដូច្នោះដែរ។ គោលគំនិត ខាងលើ បានផ្តោតជាសំខាន់ទៅលើលក្ខណះសម្បត្តិតែមួយផ្នែកគត់របស់ព្រះជាម្ចាស់តែប៉ុននោះ គឺសេចក្តីស្រលាញ់ ដោយមិនយល់សោះថាព្រះជាម្ចាស់យុត្តិធម៌មួយរយភាគរយ ហើយគ្មានភាពលំអៀងសោះឡើយនៅក្នុងទ្រង់។

ស្របពេលជាមួយគ្នានេះផងដែរ ប្រសិនបើព្រះជាម្ចាស់មើលរម្លងអំពើបាបរបស់មនុស្ស ដោយឈ្នួលនៃអំពើបាបគ្មានការសងលោះនោះ បានសេចក្តីថាព្រះអង្គអយុត្តិធម៌ មិនទៀតត្រង់ មិនស្មោះត្រង់ ប្រែក្រឡាស់ព្រះបន្ទូលរបស់អង្គទ្រង់ផ្ទាល់ ហើយទ្រង់ក៏មិនខុសអ្វីអំពីមនុស្សផងទាំងពួងដែលពុករលួយ និងតែងតែប្រែប្រួលដែរ ដែលមិនសាកសមនឹងគ្រងមកុដនៃសេចក្តីសុចរិត សិរីល្អ ព្រមទាំងទទួលការគោរពថ្វាយបង្គំពីសព្វសារពើទាំងឡាយឡើយ។ ជាងនេះទៅទៀត ព្រះអង្គមិនមែនជាទីពឹងដ៏មាំមួនតែមួយគត់របស់មនុស្សបាបឡើង ព្រោះព្រះអង្គមិនស្មោះត្រង់។ យើងមិនអាចទុកចិត្ត និងទុកសេចក្តីសង្ឃឹមដ៏ធំធេងរបស់យើងលើព្រះហស្តរបស់ព្រះដែលមិនស្មោះត្រង់នោះទេ។ ដោយឡែក ការសុគតរបស់ព្រះយេស៊ូវគ្រិស្តនៅលើឈើឆ្កាង គឺជាការសងប្រោសលោះថ្លៃឈ្នួលនៃអំពើបាបសម្រាប់មនុស្សផងទាំងពួង។ សេចក្តីស្លាប់ដែលជាថ្លៃឈ្នួលនៃអំពើបាប ដែលព្រះជាម្ចាស់បានទាមទារពីមនុស្ស ត្រូវបានព្រះយេស៊ូវគ្រិស្តបង់សងជាជំនួស ដោយស្លាប់ជំនួសកន្លែងរបស់ពួកគេ។ ព្រះយេស៊ូវគ្រិស្តបានបង់សងលោះថ្លៃឈ្នួលនៃអំពើបាបសម្រាប់អស់អ្នកណាដែលនៅជាប់ក្នុងទ្រង់រួចស្រេចហើយ ដូច្នេះព្រះជាម្ចាស់មិនអាចទាមទារយកថ្លៃឈ្នួលនៃអំពើបាបពីគ្រិស្តបរិស័ទបានទៀតទេ ព្រោះព្រះអង្គយុត្តិធម៌។ ព្រះជាម្ចាស់មិនអាចទទួលយកថ្លៃសងឈ្នួលនៃអំពើបាបពីព្រះយេស៊ូវគ្រិស្តផង និងពីអ្នកដែលនៅជាប់ក្នុងទ្រង់ផងបានឡើយ។ ការសងថ្លៃឈ្នួលនៃអំពើបាបរបស់ព្រះយេស៊ូវគ្រិស្ត គឺត្រឹមត្រូវ គ្រប់លក្ខណ៍ តាមស្តង់ដានៃការទាមទាររបស់ព្រះជាម្ចាស់ និងជាការពេញព្រះហឫទ័យរបស់ព្រះជាម្ចាស់ខ្លាំងណាស់។ ដូច្នេះ នៅចំពោះព្រះជាម្ចាស់ គ្រិស្តបរិស័ទមិនមែនជាជនល្មើសទៀតទេ ផ្ទុយទៅវិញ ពួកគេមានសេរីភាព ព្រោះព្រះយេស៊ូវគ្រិស្តបានទទួលទោស និងបង់ថ្លៃប្រោសលោះគេរួចស្រេចហើយនៅលើឈើឆ្កាង។ នៅលើឈើឆ្កាង ព្រះជាម្ចាស់បានវិនិច្ឆ័យទោសនៃអំពើបាបដោយយុត្តិធម៌ ហើយស្របពេលជាមួយគ្នានេះផងដែរ ពន្លឺនៃសេចក្តីស្រលាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់បានចែងចាំងដល់អស់អ្នកណាដែលនៅជាប់ក្នុងព្រះរាជបុត្រារបស់ទ្រង់សារជាថ្មី ដោយគ្មានរនាំងរាំងឡើយ។ នៅលើឈើឆ្កាង សេចក្តីស្រលាញ់ និងភាពយុត្តិធម៌ដ៏គ្រប់លក្ខណ៍របស់ព្រះជាម្ចាស់ត្រូវបានបើកសម្តែងយ៉ាងប្រទាំ្យត៕

ប្រាកដណាស់ សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ត្រូវបានរំលេចឡើង មិនមែនតាមរយៈការមើលរម្លងអំពើបាបរបស់មនុស្សឡើយ ត្បិតព្រះដ៏សុចរិត និងយុត្តិធម៌ មិនអាចមើលរម្លងអំពើបាបណាមួយបានសោះឡើយ ពោលគឺអំពើបាបត្រូវតែវិនិច្ឆ័យ ផ្ទុយទៅវិញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ត្រូវបានរំលេចឡើងតាមរយៈការលះបង់ព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់អោយស្ថិតនៅក្រោមការវិនិច្ឆ័យ និងព្រះពិរោធន៍របស់ទ្រង់ផ្ទាល់រហូតដល់សុគតនៅលើឈើឆ្កាង ដើម្បីកុំអោយមនុស្សដែលព្រះអង្គស្រលាញ់ខ្លាំងដល់ម្ល៉េះត្រូវវត្តក់រស់ជាតិដ៏ល្វីងជូរចត់មួយនេះ។ សេចក្តីនេះស្របគ្នាទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានបញ្ជាក់យ៉ាងច្បាស់ថា "តែឯព្រះ ទ្រង់សម្តែងសេចក្តីស្រលាញ់របស់ទ្រង់ដល់យើងរាល់គ្នាអោយឃើញច្បាស់ដោយព្រះគ្រិស្តបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើងផង" (រ៉ូម៥៖៨)។ "ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីអោយអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ" (យ៉ូហាន៣៖១៦)។ ក្នុងន័យដូចគ្នានេះផងដែរ ខណៈពេលដែលព្រះយេស៊ូគ្រិស្តមានព្រះជន្មគង់នៅលើផែនដីនៅឡើយ ព្រះអង្គបានមានព្រះបន្ទូលដោយផ្ទាល់ថា "គ្មានអ្នកណាមានសេចក្តីស្រលាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិតជំនួសពួកសំឡាញ់ខ្លួនទេ" (យ៉ូហាន១៥៖១៣)។ ព្រះយេស៊ូវគ្រិស្តបានប្តូរព្រះជន្មជំនួសពួកសម្លាញ់របស់ទ្រង់ ខណៈពេលដែល

ពួកគេនៅជាសត្រូវរបស់ទ្រង់នៅឡើយ ហើយបើទោះបីជាពួកគេមិនសមនឹងទទួលយ៉ាងណាក្តី។ បើដូច្នោះ គប្បីអោយមនុស្សគ្រប់ជាតិសាសន៍ទាំងអស់បានឃើញ ហើយយល់ច្បាស់អំពីសេចក្តីស្រលាញ់ធំធេងដ៏ជ្រាលជ្រៅបំផុតរបស់ព្រះជាម្ចាស់ចំពោះពួកគេ ខណៈពេលដែលពួកគេសំលឹងមើលទៅឯឈើឆ្កាងរបស់ព្រះយេស៊ូវគ្រិស្ទ។ ចូរអោយគ្រប់ជាតិសាសន៍ទាំងអស់បានសរសើរតម្កើងសិរីល្អរបស់ព្រះជាម្ចាស់ ត្បិតតាមរយៈកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាងនោះ ទ្រង់តែមួយអង្គគត់ដែលសាកសមនឹងទទួលយកគ្រប់ទាំងអស់៕

ចាប់តាំងតែពីដើមរៀងមក មនុស្សម្នាបានពេបជ្រាយ ឆ្ងល់ ហើយសង្ស័យថា ធ្វើដូចម្តេចអោយព្រះដ៏ជាព្រះសុគតនៅលើឈើឆ្កាងដោយភាពអាម៉ាសយ៉ាងដូច្នោះ? សម្លេងនៅក្នុងចិត្តរបស់បណ្តាជនបានបន្លឺឡើងដោយមើលងាយម្តងហើយម្តងទៀតថា “វាជួយសង្គ្រោះមនុស្សឯទៀតបាន តែមិនអាចនឹងជួយសង្គ្រោះដល់ខ្លួនវាបានទេ បើសិនណាវាជាស្តេចសាសន៍អ៊ីស្រាអែលមែន ចូរអោយវាចុះពីឈើឆ្កាងមក នោះយើងនឹងជឿដល់វា វាបានទុកចិត្តនឹងព្រះ ដូច្នោះបើព្រះសព្វព្រះហឫទ័យនឹងវា សូមទ្រង់ជួយដោះវាឥឡូវចុះ! ដ្បិតវាបានថា ខ្ញុំជាព្រះរាជបុត្រានៃព្រះ” (ម៉ាថាយ២៧:៤២-៤៣)។ នេះគឺជាសម្លេងរបស់បណ្តាជននៅសម័យព្រះយេស៊ូវគ្រិស្ទ ជាសម្លេងរបស់បណ្តាជននៅសម័យនេះ និងគ្រប់សម័យកាលទាំងអស់ ហើយវាក៏ប្រហែលជាសម្លេងនៅក្នុងចិត្តរបស់អ្នកផងដែរ។ តាមពិត កាលដំបូងឡើយ ខ្ញុំផ្ទាល់ក៏ធ្លាប់បានគិតផងដែរថា ការសុគតរបស់ព្រះយេស៊ូគ្រិស្តគឺជារឿងដ៏គួរអោយខ្មាស់ ឆ្កួតលីលា និងល្ងង់ខ្លៅបំផុតមួយ ព្រោះធ្វើដូចម្តេចអោយបុគ្គលដែលមិនអាចនឹងជួយសង្គ្រោះខ្លួនឯងបានផង ចុះមកជួយសង្គ្រោះខ្ញុំបាន? រហូតដល់ពេលដែលខ្ញុំបានយល់ច្បាស់ថា ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទពិតជាសំខាន់ ហើយចាំបាច់ណាស់សម្រាប់សេចក្តីសង្គ្រោះរបស់ខ្ញុំ ព្រោះនេះគឺជាការទាមទារពីសំណាក់ព្រះដ៏សុចរិតដោយផ្ទាល់។ បើព្រះយេស៊ូគ្រិស្ទមិនបានសុគតក្រោមការវិនិច្ឆ័យ និងក្រោមព្រះពិរោធន៏របស់ព្រះជាម្ចាស់នោះទេ សេចក្តីសង្គ្រោះក៏គ្មានដែរ ពោលគឺមនុស្សគ្រប់ៗរូបនឹងត្រូវស្លាប់ដោយរងទុក្ខទោសវេទនាដាច់ចេញពីសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់អស់កល្បជានិច្ច។ ការសុគតរបស់ព្រះយេស៊ូគ្រិស្ទបានប្រកាសជោគជ័យលើអារក្សសាតាំងដែលជាសត្រូវដ៏ពិតប្រាកដ ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់តាំងតែពីដើមដំបូងមកម្ល៉េះ ដើម្បីជួយសង្គ្រោះមនុស្សបាបចូលទៅឯទ្រង់វិញ (ហេព្រើរ២:១៤ លោកុប្បត្តិ៣:១៥ វិវរណៈ៣:២១ ៥:៥ ១៧:១៤)។ ឥលូវនេះ ចិត្តខ្ញុំអរព្រះគុណចំពោះការសុគតរបស់ព្រះយេស៊ូវគ្រិស្ទ ដ្បិតខ្ញុំអាចរួចផុតពីសេចក្តីស្លាប់ដ៏អស់កល្បជានិច្ចបាន ព្រោះតែកិច្ចការដែលព្រះអង្គបានសម្រេចនៅលើឈើឆ្កាងជំនួសខ្ញុំ និងសម្រាប់ខ្ញុំ៕

ដោយព្រោះព្រះគុណ និងសេចក្តីស្រលាញ់ ព្រះជាម្ចាស់បានប្រោសប្រទានត្រីវិស័យតែមួយគត់ ដើម្បីដឹកនាំមនុស្សបាបទៅឯទ្រង់វិញ គឺតាមរយៈព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់ដែលជាផ្លូវដ៏ពិតប្រាកដ។ រីឯតម្លៃនៃការប្រោសលោះ គឺការសុគតរបស់ព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់នៅលើឈើឆ្កាង ក្រោមព្រះពិរោធន៏របស់ទ្រង់ផ្ទាល់ជំនួសកន្លែងរបស់មនុស្សបាបទាំងឡាយ។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទនៅលើឈើឆ្កាង គឺជាផ្លូវតែមួយគត់សម្រាប់សេចក្តីសង្គ្រោះ ដើម្បីបំពេញសម្រេចទៅតាមការទាមទាររបស់ព្រះដ៏សុចរិត។ វិថីទៅកាន់សេចក្តីសង្គ្រោះ បានក្រុបក្រាលទៅដោយការលះបង់ ពោលគឺបើគ្មានការលះបង់នោះទេ ក៏គ្មានសេចក្តីសង្គ្រោះ ហើយក៏គ្មានដំណឹងល្អដែរ៕

## ឃ ការស្រេចហើយ

*“ឯព្រះអង្គដែលគង់លើបល្លង្ក៍ទ្រង់មានព្រះបន្ទូលថា មើល! អញធ្វើទាំងអស់ឡើងជាថ្មី...... ទ្រង់ក៏មានបន្ទូលមកខ្ញុំថា ស្រេចហើយ អញជាអាលផា និងអូមេកា គឺជាដើមហើយជាចុង បើអ្នកណាស្រេកអញនឹងអោយអ្នកនោះផឹកពីរន្ធទឹកនៃជីវិតឥតយកថ្លៃ” (វិវរណះ២១៖៥-៦)*។

ការសម្រេចចិត្តរបស់មនុស្សដំបូងក្នុងការប៉ះបោរប្រឆាំងជាមួយនឹងព្រះជាម្ចាស់បានបង្កគ្រោះថ្នាក់មហន្តរាយដ៏ធ្ងន់ធ្ងរដល់គ្រប់ការល្អទាំងអស់ដែលព្រះជាម្ចាស់បានបង្កបង្កើតមកដោយផ្ទាល់ ដោយរួមបញ្ចូលទាំងគោលដៅ និងមុខងារនៃវត្តមានរបស់សព្វសារពើទាំងអស់នៅលើផែនដីផងដែរ។ បន្ទាប់ពីការធ្លាក់ចុះចូលក្នុងអំពើបាប ព្រះកិត្តិនាម និងសិរីល្អដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះជាម្ចាស់ មិនត្រូវបានលើកសរសើរតម្កើងអោយបានពេញលេញ ពីសំណាក់សព្វសារពើទាំងអស់ស្របតាមនិមិត្តរបស់ទ្រង់ក្នុងការបង្កើតនោះទេ។ ដោយឡែក ការសម្រេចព្រះរាជ្យហឫទ័យរបស់ព្រះយេស៊ូវគ្រិស្ទក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយបានលះបង់គ្រប់ទាំងអស់ បានស្តារឡើងវិញនូវគ្រប់ទាំងអស់ដែលបានធ្លាក់ចុះជាមួយនឹងមនុស្សដំបូង ដោយរាប់បញ្ចូលទាំងមុខងារ និងគោលដៅនៃវត្តមានរបស់សព្វសារពើទាំងអស់ដែលព្រះអង្គបានបង្កបង្កើតមក។ គ្រប់សព្វសារពើទាំងអស់ដែលបានជាប់ចំណងបណ្តាសារជាមួយមនុស្សដំបូង ហើយដាច់ចេញពីព្រះជាម្ចាស់ដែលជាប្រភពនៃជីវិតដ៏ពេញបរិបូរណ៍ ត្រូវបានដោះលែងអោយមានសេរីភាព ព្រមទាំងទទួលបានជីវិតដ៏ពេញបរិបូរណ៍ឡើងវិញ តាមរយៈព្រះយេស៊ូវគ្រិស្ទ។ ត្បិតតាមរយៈកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង នោះព្រះអង្គផ្ទាល់ដែលជាកូនចៀមនៃព្រះ និងជាពូជស្ត្រីបានជាន់កិនកំទេចនឹមត្រួតត្រារបស់មេកំណាចរួចជាស្រេច ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ ចាប់តាំងតែពីដើមដំបូងមកម្ល៉េះ (លោកុប្បត្តិ៣៖១៥)។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានដាក់ព្រះជន្មទ្រង់ចុះ ដើម្បីប្រកាសជោគជ័យលើបេសកកម្មតែមួយគត់ ដែលព្រះវរបិតាបានចាត់បញ្ជូនព្រះអង្គអោយមកសម្រេច គឺបំផ្លាញអំពើបាប និងនឹមត្រួតត្រារបស់អារក្សសាតាំង ដែលជាសត្រូវដ៏ធំអស់កល្បជានិច្ច។ ព្រះយេស៊ូវគ្រិស្ទបានទទួលជោគជ័យហើយ! ព្រះអង្គបានឈ្នះលើសត្រូវដ៏ពិតប្រាកហើយ!។ អារក្សសាតាំង និងអំណាចរបស់បាបគ្មានអំណាចលើអស់អ្នកណាដែលជ្រកក្រោមឈាមរបស់កូនចៀមនៃព្រះទៀតទេ។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទបានធានាលើព្រះបន្ទូលសន្យារបស់ទ្រង់ដែលបានលើកឡើងថា “..... ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ” (យ៉ូហាន១៤៖៦)។ ផ្លូវទៅកាន់សេចក្តីសង្គ្រោះមានតែមួយគត់ គឺជាផ្លូវដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចដោយផ្ទាល់។ បើមិនទៅតាមទ្រង់ មនុស្សគ្រប់ៗរូបនឹងត្រូវរងទុក្ខវិនាសវេទនាក្រោមព្រះពិរោធន៍ និងក្រោមការវិនិច្ឆ័យរបស់ព្រះជាម្ចាស់អស់កល្បជានិច្ច ដោយគេចមិនផុតឡើយ ព្រោះនេះគឺជាទោស និងជាឈ្នួលនៃអំពើបាបរបស់ពួកគេ៕

នៅក្នុងដង្ហើមចុងក្រោយរបស់ព្រះរាជបុត្រានៃព្រះនៅលើឈើឆ្កាង ព្រះយេស៊ូគ្រិស្ទបានប្រកាសដល់សាធារណៈជនគ្រប់ជាតិសាសន៍ទាំងអស់ថា “.... ការស្រេចហើយ ...” (យ៉ូហាន១៩៖៣០)។ បេសកកម្មដែលព្រះអង្គត្រូវយាងមកសម្រេចបានបញ្ចប់ជាបរិបូរណ៍។ បន្ទាប់មកទៀត ព្រះយេស៊ូវគ្រិស្ទក៏បានស្រែកឡើងខ្លាំងៗផងដែរថា “...... ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ..... ”(លូកា២៣៖៤៦)។

ការស្រេចហើយ! ព្រះរាជបុត្រាស្ងួនភ្ងាតែមួយអង្គគត់របស់ព្រះជាម្ចាស់ បានដាក់ព្រះជន្មទ្រង់ចុះដោយផ្ទាល់ ស្របតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា (យ៉ូហាន១០៖១៧-១៨) និងស្របតាមពាក្យទំនាយរបស់លោកហោរ៉ាអេសាយដែលបានលើកឡើងថា ទ្រង់បានច្រួចព្រលឹងចេញរហូតដល់ស្លាប់ ហើយទ្រង់បានទទួលរងទោសនៃអំពើបាបរបស់មនុស្សជាច្រើន (អេសាយ៥៣៖១៣)។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានទទួលទោសនៃអំពើបាបរបស់លោកិយទាំងមូល។ ចំណែកឯផលដែលហុចអោយគឺ ទោសនៃអំពើបាបរបស់អស់អ្នកណាដែលនៅជាប់ក្នុងទ្រង់ត្រូវបានសងលោះជាសម្រេចនៅចំពោះព្រះវរបិតា។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចង្អុលបញ្ជាក់យ៉ាងច្បាស់ថា "ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រិស្តយេស៊ូវ នោះគ្មានទោសសោះ"(រ៉ូម៨៖១)។ ព្រះយេស៊ូវគ្រិស្ទបានដើរតួជាដង្វាយធួននឹងបាបសម្រាប់គ្រិស្ទបរិស័ទ ហើយដង្វាយដ៏ថ្លៃថ្លានេះបានជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងខ្លាំង។ ជាលទ្ធផល លោកហោរ៉ាអេសាយបានលើកឡើងថា "ទ្រង់នឹងឃើញផលនៃការដែលព្រលឹងទ្រង់រងវេទនា នោះនឹងបានស្កប់ស្កល់ផង អ្នកដ៏សុចរិត គឺជាអ្នកបំរើរបស់អញ ទ្រង់នឹងធ្វើអោយមនុស្សជាច្រើនបានសុចរិតដោយគេស្គាល់ដល់ទ្រង់ ហើយទ្រង់នឹងរងទុក្ខទោសជំនួសអំពើទុចរិតរបស់គេ" (អេសាយ៥៣៖១១)។ តាមរយៈព្រះយេស៊ូវគ្រិស្ទដែលជាកូនចៀមនៃព្រះ មនុស្សបាបនឹងត្រូវបានរាប់ជាសុចរិតនៅចំពោះព្រះដ៏សុចរិត ហើយពួកគេនឹងបានរួចផុតពីព្រះពិរោធន៍ ព្រមទាំងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ព្រោះទោសនៃអំពើបាបរបស់ពួកគេត្រូវបានព្រះយេស៊ូវគ្រិស្ទសងជំនួសរួចស្រេចហើយ៕

ស្របពេលជាមួយគ្នានេះផងដែរ ព្រះដ៏ជាប្រភពនៃជីវិតបានដាក់ព្រះជន្មចុះដោយផ្ទាល់ ប្រយោជន៍អោយពន្លកនៃជីវិតដ៏ពេញបរិបូរណ៍ច្រើនលើសលប់បានដុះដាលឡើង។ ដូចដែលលោកសាវ័កប៉ុលបានលើកឡើងថា "ដ្បិតបើសិនជាសេចក្តីស្លាប់បានសោយរាជ្យដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តិរំលង ដូច្នេះប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀតដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រិស្ត" (រ៉ូម៥៖១៧)។ តាមរយៈកិច្ចការដែលព្រះយេស៊ូវគ្រិស្តបានសម្រេចនៅលើឈើឆ្កាង នោះអស់អ្នកណាដែលនៅជាប់ក្នុងទ្រង់បានដើរឆ្លងផុតសេចក្តីស្លាប់ ទៅឯព្រះដ៏ជាប្រភពនៃជីវិតដ៏អស់កល្ប និងពេញបរិបូរណ៍វិញ។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានបំផ្លាញ ហើយយកឈ្នះសេចក្តីស្លាប់ ព្រមទាំងប្រោសប្រទានមកវិញនូវជីវិតដ៏ពេញបរិបូរណ៍អស់កល្បជានិច្ច ដល់អស់អ្នកណាដែលនៅជាប់ក្នុងព្រះអង្គដែលជាដើមនៃជីវិតដ៏ពិតប្រាកដ៕

ដោយឡែក លោកសាវ័កម៉ាថាយបានកត់ត្រាព្រឹត្តិការណ៍ជុំវិញការសុគតរបស់ព្រះយេស៊ូវគ្រិស្ទ ដោយឆ្លុះបញ្ចាំងទៅនឹងគំនិតខាងលើដោយប្រុងប្រយត្ន័ថា "គ្រានោះវាំងននក្នុងព្រះវិហារក៏រហែកជាពីរភាគ ចាប់តាំងពីលើចុះទៅដល់ក្រោម ក៏មានកក្រើក ហើយថ្មប្រេះដាច់ពីគ្នា អស់ទាំងផ្នូរខ្មោចក៏របើកឡើង ឯខ្មោចពួកអ្នកបរិសុទ្ធដែលដេកលក់ទៅហើយ បានរស់ឡើងវិញជាច្រើន" (ម៉ាថាយ២៧៖៥១-៥៣)។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទនៅលើឈើឆ្កាង គឺជាកូនសោរតែមួយគត់សម្រាប់ចាក់បើកចំហរទ្វារនៃនគរស្ថានសួគ៌ ដើម្បីទទួលស្វាគមន៍មនុស្សគ្រប់ជាតិសាសន៍ទាំងអស់អោយចូលទៅក្នុងព្រះដំណាក់របស់ព្រះដ៏ពិតរបស់ពួកគេដូចដើមវិញ។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានបំផ្លាញចោលរនាំងវាំងននរវាងមនុស្ស ហើយនិងព្រះជាម្ចាស់។ ព្រះយេស៊ូវគ្រិស្ទបានសុគត ដើម្បីធ្វើជាស្ពានសម្លងមនុស្សទៅឯព្រះជាម្ចាស់វិញដោយជោគជ័យ។ តាមរយៈព្រះយេស៊ូវគ្រិស្ទ មនុស្សលែងឈរពួននៅពីក្រោម

រាំងននទៀតហើយ ផ្ទុយទៅវិញ មនុស្សបានចូលទៅដល់ក្នុងព្រះវត្តមានដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា និង គ្រប់ទីកន្លែងទាំងអស់ ដូចជាមនុស្សដំបូងមុនពេលដែលពួកគេបានធ្វើបាបយ៉ាងដូច្នោះដែរ៕

បេសកកម្មដែលព្រះយេស៊ូវគ្រិស្ទបានយាងមកបំពេញបានសម្រេចជាបរិបូរណ៍។ ការសុគតរបស់ព្រះយេស៊ូវគ្រិស្ទបាននាំមកនូវជីវិតថ្មីដ៏អស់កល្បជានិច្ច ជំនួសសេចក្តីស្លាប់ដែលបណ្តាលមកពីមនុស្សដំបូង។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានត្រឡប់ជាសាច់ឈាមអោយមនុស្សបាបបានមើលឃើញ ប្រយោជន៍អោយពួកគេបានស្គាល់ព្រះដ៏ពិតតែមួយអង្គគត់របស់ពួកគេ និងមានស្ពានឈានចូលទៅឯព្រះជាម្ចាស់វិញ។ ព្រះយេស៊ូវគ្រិស្ទគឺជាត្រីវិស័យតែមួយគត់ដែលមកពីព្រះជាម្ចាស់តាំងតែពីដើមដំបូងមកម្ល៉េះ(លោកុប្បត្តិ៣:១៥) ដែលបានចង្អុលបង្ហាញផ្លូវដ៏ពិត(គឺព្រះអង្គផ្ទាល់ដែលជាផ្លូវដ៏ពិត) ប្រយោជន៍អោយមនុស្សបានរស់នៅចំគោលដៅនៃជីវិត ដើម្បីសិរីល្អតែមួយគត់របស់ព្រះជាម្ចាស់ ជាពិសេស ដើម្បីរំដោះខ្លួនចេញពីនឹម និងទោសនៃអំពើបាប៕

## ៤ សេចក្ដីសង្គ្រោះ

ប្រសិនបើមនុស្សយល់ច្បាស់អំពីទម្ងន់ទោសនៃអំពើបាបដ៏ធ្ងន់ធ្ងររបស់ពួកគេនៅចំពោះព្រះដ៏សុចរិតនោះ ប្រាកដណាស់ថាពួកគេនឹងខិតខំស្វះស្វែងរកផ្លូវសង្គ្រោះចេញពីការវិនិច្ឆ័យ និងព្រះពិរោធន៍របស់ព្រះជាម្ចាស់ជាក់ជាមិនខាន។ ផ្ទុយទៅវិញ ការយល់ខុសអំពីអំពើបាប និងទម្ងន់ទោសរបស់វា បណ្ដាលអោយមនុស្សព្រងើយកន្តើយចំពោះជីវិតខាងព្រលឹងវិញ្ញាណរបស់ខ្លួន។ តាមពិត អ្នកខ្លះប្រហែលជាបានយល់អំពីផលដែលហុចអោយពីអំពើបាប ក៏ប៉ុន្តែការនេះមិនប្រាកដថា ពួកគេបានយល់អំពីទម្ងន់ទោសរបស់បាប ព្រមទាំងផ្លូវដ៏ពិតប្រាកដដើម្បីលាងជម្រះអំពើបាបរបស់ខ្លួននោះដែរ។ ជាទូទៅ មនុស្សម្នាទាំងពួងយល់ច្បាស់ជាប្រាកដថា អំពើបាបអាក្រក់ រីឯផលផ្លែនៃអំពើបាបទៀតសោតក៏ល្វីងជូរចត់គ្មាននរណាម្នាក់ប៉ងប្រាថ្នាចង់ទទួលបានដែរ។ ស្របពេលជាមួយគ្នានេះផងដែរ នៅក្នុងសង្គមកម្ពុជា មនុស្សមានផ្នត់គំនិតថាអំពើបាបគឺជាបញ្ហាបុគ្គល ជាការទទួលខុសត្រូវរបស់បុគ្គលរៀងៗខ្លួន ពោលគឺខ្លួនទីពឹងខ្លួន។ រីឯអាវុធដើម្បីទទួលជោគជ័យលើអំពើបាបគឺជាអំពើល្អ។ មនុស្សនឹងកាន់តែល្អបរិសុទ្ធ សាកសមនឹងទទួលយកសេចក្ដីសង្គ្រោះប្រសិនបើគេខិតខំសន្សំអំពើល្អអោយបានកាន់តែច្រើនឡើងៗ។ ទស្សនៈនេះឈរលើផ្នត់គំនិត សេចក្ដីសង្គ្រោះអាស្រ័យលើសមត្ថភាពរបស់មនុស្សក្នុងការប្រព្រឹត្តិអំពើល្អ។ បើទោះបីជាយ៉ាងណាក៏ដោយ នេះមិនមែនជាទស្សនៈរបស់ព្រះគម្ពីរបរិសុទ្ធនោះទេ ព្រោះបើផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គ្មាននរណាម្នាក់អាចបានល្អគ្រប់គ្រាន់ដើម្បីសង្គ្រោះខ្លួនឯងចេញពីការវិនិច្ឆ័យរបស់ព្រះជាម្ចាស់បានជាដាច់ខាត។ ព្រះគម្ពីរបរិសុទ្ធក៏បានចង្អុលបង្ហាញទៀតដែរថា សេចក្ដីសង្គ្រោះមិនមែនជាផលផ្លែដែលកើតចេញពីអំពើល្អរបស់បុគ្គលនោះទេ។ អំពើល្អរបស់បុគ្គលមិនអាចដោះដូរយកសេចក្ដីសង្គ្រោះបានជាដាច់ខាត។ មួយវិញទៀត អំពើបាបគឺជាបញ្ហារវាងបុគ្គល និងព្រះជាម្ចាស់ដែលស្រលាញ់មនុស្សលោកខ្លាំងដល់ម្ល៉េះ ហើយដោយព្រោះមនុស្សមិនអាចដោះស្រាយបញ្ហាបាបដោយខ្លួនឯងបាន ព្រះជាម្ចាស់ផ្ទាល់បានដោះស្រាយ និងរៀបចំផ្លូវសម្រាប់គេដើម្បីគេចផុតពីទោសនៃអំពើបាប និងដើម្បីទទួលយកសេចក្ដីសង្គ្រោះ។ កាលពីជំពូកមុន យើងបានមើលឃើញតាមរយៈការចង្អុលបង្ហាញរបស់ត្រីវិស័យដ៏ពិតប្រាកដតែមួយគត់ដែលមកពីព្រះជាម្ចាស់ថា ព្រះយេស៊ូវគ្រិស្ទគឺជាផ្លូវតែមួយគត់ ដើម្បីទទួលបានសេចក្ដីសង្គ្រោះ និងជីវិតដ៏អស់កល្បជានិច្ច។ ដោយឡែក នៅជំពូកនេះ យើងនឹងស្វែងយល់ទាំងអស់គ្នាអំពីរបៀបទទួលយកសេចក្ដីសង្គ្រោះ និងជីវិតដ៏អស់កល្បថ្លៃថ្លាមួយនោះ៕

### ក ដោយសារព្រះគុណ តាមរយៈសេចក្ដីជំនឿ

សេចក្ដីសង្គ្រោះ គឺជាព្រះអំណោយទានដែលមកពីព្រះជាម្ចាស់សម្រាប់មនុស្ស មិនមែនជាផលផ្លែនៃបុណ្យកុសលដែលមនុស្សខិតខំក៏សាងដើម្បីយោងចាប់យកនោះទេ។ លោកសាវ័កប៉ុល បានអះអាងគាំទ្រដោយដាច់អហឹង្ការថា "គឺដោយសារព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នកណាអួតខ្លួន" (អេភេសូរ២៖៨-៩)។ ដោយព្រោះព្រះគុណរបស់ព្រះជាម្ចាស់ នោះសេចក្ដីសង្គ្រោះបានប្រោសប្រទានដល់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ ដែលអសមត្ថភាពនឹងជួយសង្គ្រោះខ្លួនឯង (ទីតុស២៖១១ រ៉ូម៣៖២៤)។ ដោយសារព្រះគុណ តាមរយៈសេចក្ដីជំនឿ មនុស្សគ្រប់ៗរូប គ្រប់ទីកន្លែង និងគ្រប់សម័យកាលទាំងអស់បានទទួលយកសេចក្ដីសង្គ្រោះទុកជាមរតក ដោយមិនចាំបាច់ទាមទារអ្វី

ផ្សេងៗទៀតសោះឡើយពីពួកគេ។ តាមរយៈកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង ព្រះគុណ និង សេចក្តីជំនឿល្មមគ្រប់គ្រាន់ហើយសម្រាប់សេចក្តីសង្គ្រោះ៕

យើងមិនអាចបន្ថែមអ្វីផ្សេងទៀត ទៅលើកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង ដើម្បីទទួលបានសេចក្តីសង្គ្រោះនោះទេ។ អំពើល្អទាំងអស់ដែលមនុស្សបាបបានសម្រេច សុទ្ធតែខ្វះមិនដល់សិរីល្អរបស់ព្រះជាម្ចាស់ ខ្វះមិនដល់ស្តង់ដាររបស់ទ្រង់ និងមិនមែនជាទីសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ ហើយយើងក៏មិនអាចយកវាមកធ្វើជាថ្នូរសម្រាប់សេចក្តីសង្គ្រោះបានដែរ។ អ្នកនិពន្ធកណ្ឌគម្ពីរមីកាបានលើកឡើងថា "តើត្រូវអោយខ្ញុំយកអ្វី ដើម្បីចូលទៅចំពោះព្រះយេហូវ៉ា ហើយក្រាបថ្វាយបង្គំនៅមុនព្រះដ៏ខ្ពស់ តើត្រូវអោយខ្ញុំយកដង្វាយដុត ជាកូនគោអាយុមួយខួប ដើម្បីចូលទៅចំពោះទ្រង់ឬ តើព្រះយេហូវ៉ាទ្រង់នឹងសព្វព្រះហឫទ័យ ដោយចៀមទាំងពាន់ ឬដោយប្រេងទាំងម៉ឺនទន្លេឬ តើត្រូវអោយខ្ញុំថ្វាយកូនច្បងខ្ញុំ អោយបានធួននឹងអំពើរំលងដែលខ្ញុំប្រព្រឹត្ត គឺជាផលនៃរូបកាយខ្ញុំ អោយបានធួននឹងបាបនៃព្រលឹងខ្ញុំឬ" (មីកា៦៖៦-៧)។ ដូចគ្នានេះផងដែរ ខណៈពេលដែលស្តេចដាវីឌយល់អំពីអំពើបាបរបស់ទ្រង់ផ្ទាល់ ព្រះអង្គមានព្រះបន្ទូលថា "ដ្បិតទ្រង់មិនសព្វព្រះហឫទ័យនឹងយញ្ញបូជាទេ បើសព្វព្រះហឫទ័យវិញ នោះទូលបង្គំនឹងបានថ្វាយហើយ ទ្រង់ក៏មិនពេញព្រះទ័យនឹងដង្វាយដុតដែរ" (ទំនុកតម្កើង៥១៖១៦)។ ផ្ទុយទៅវិញ លោកសាវ័កប៉ុលបានបញ្ជាក់យ៉ាងប្រទ្យ៉ាតថា ផ្លូវតែមួយគត់ដើម្បីដឹកនាំមនុស្សបាបអោយបានត្រឡប់ទៅជាសុចរិតនៅចំពោះព្រះដ៏បរិសុទ្ធ គឺតាមរយៈសេចក្តីជំនឿលើព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់ មិនមែនដោយពឹងផ្អែកលើអំពើល្អនោះទេ (រ៉ូម៣៖២៦-២៨ កាឡាទី២៖១៦)។ មនុស្សបាបអាចចូលទៅកាន់ព្រះជាម្ចាស់បាន តាមរយៈព្រះយេស៊ូវគ្រិស្ទដែលជាផ្លូវតែមួយគត់។ ព្រះយេស៊ូវគ្រិស្ទគឺជាសេចក្តីសង្ឃឹមតែមួយគត់សម្រាប់មនុស្សបាប។ ដោយព្រោះហេតុដូច្នោះហើយ នៅក្នុងកណ្ឌគម្ពីររ៉ូម លោកសាវ័កប៉ុក បានចំណាយពេលជាងបីជំពូកដំបូង ដើម្បីពន្យល់បញ្ជាក់ថាមនុស្សទាំងអស់មិនអាចរាប់ជាសុចរិត និងទទួលបានសេចក្តីសង្គ្រោះដោយព្រោះអំពើល្អដែលខ្លួនបានប្រព្រឹត្តិសោះឡើយ (រ៉ូម១៖១៨-៣៖២០)។ លើសពីនេះទៅទៀត សំណេររបស់គាត់បានរំលេចឡើងអោយឃើញយ៉ាងច្បាស់ថា មនុស្សគ្មានសង្ឃឹមសោះឡើយក្នុងការគេចចេញផុតពីទុក្ខទោសនៃការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ បើគ្មានព្រះគុណរបស់ព្រះជាម្ចាស់។ ជាចុងក្រោយ ទើបលោកសាវ័កប៉ុល បានបញ្ចេញពន្លឺនៃដំណឹងល្អរបស់គាត់ សម្រាប់អ្នកអានសំបុត្ររ៉ូម។ ដូចដែលបានរៀបរាប់ខាងលើ អត្ថន័យរបស់ដំណឹងល្អតែមួយគត់ដែលលោកសាវ័កប៉ុលបានសង្កត់យ៉ាងធ្ងន់គឺ មានផ្លូវតែមួយគត់ដើម្បីទទួលបានសេចក្តីសង្គ្រោះ គឺដោយសារព្រះគុណ តាមរយៈសេចក្តីជំនឿលើអង្គព្រះយេស៊ូវគ្រិស្ទដែលជាព្រះរាជបុត្រាស្ងួនភ្ងាតែមួយគត់របស់ព្រះជាម្ចាស់។ បើគ្មានព្រះគុណរបស់ព្រះជាម្ចាស់ នោះគ្មានដំណឹងល្អទេ ហើយក៏គ្មានសេចក្តីសង្គ្រោះផងដែរ៕

ដោយឡែក ចូរយើងក្រឡេកទៅមើលពួកផារ៉ាស៊ីដែលបានខិតខំកាន់តាមច្បាប់សាសនាយ៉ាងតឹងរឹងជាទីបំផុត និងបានធ្វើល្អ ត្រឹមត្រូវតាមទំនៀមទំលាប់របស់ពួកគេវិញម្តង។ មានពេលមួយ ព្រះយេស៊ូវគ្រិស្ទបានមានព្រះបន្ទូលទៅកាន់ពួកគេដោយផ្ទាល់ថា "….. អ្នករាល់គ្នាជាពួកដែលសម្តែងខ្លួនថាជាសុចរិតនៅចំពោះមុខមនុស្ស តែព្រះទ្រង់ជ្រាបចិត្តអ្នកហើយ ដ្បិតរបស់ណាដែលមនុស្សគាប់ចិត្តរាប់អានជាច្រើន នោះជាទីស្អប់ខ្ពើមនៅចំពោះព្រះវិញ" (លូកា១៦៖១៥)។ អំពើល្អអាចផ្គាប់ចិត្តមនុស្សបាន ក៏ប៉ុន្តែបើគ្មានសេចក្តីជំនឿ មនុស្សបាបមិនអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។ ដូចគ្នានេះដែរ បើទោះបីជាមនុស្សបានប្រព្រឹត្តិល្អយ៉ាងណាក្តី ពួកគេមិនអាចរាប់ជាសុចរិតនៅចំពោះព្រះដ៏សុចរិត

បានទេ ដរាបណាពួកគេគ្មានសេចក្តីជំនឿ។ ជាភស្តុតាង ព្រះជាម្ចាស់បានរាប់លោកអ័ប្រាហាំថាជាមនុស្សដ៏សុចរិត នៅចំពោះទ្រង់ មិនមែនអាស្រ័យលើអំពើល្អ ឬការលះបង់ដ៏ធំធេងរបស់គាត់នោះទេ ផ្ទុយទៅវិញគឺដោយសារសេចក្តីជំនឿរបស់គាត់តែមួយគត់ (រ៉ូម៤៖៣ សូមមើលលោកុប្បត្តិ១៥៖៦ កាឡាទី៣៖៦-៩)។ ដោយព្រោះសេចក្តីជំនឿ គ្រប់កិច្ចការទាំងអស់ដែលមនុស្សមិនអាចធ្វើបាន ដោយរាប់បញ្ចូលទាំងសេចក្តីសង្គ្រោះផងដែរ ត្រូវបានប្រោសប្រទានដល់មនុស្សវិញ ដោយសារព្រះគុណ (ហេព្រើរ១១)។ នៅត្រង់នេះ លោកសាវ៉កក៏បានបញ្ជាក់បន្ថែមទៀតដែរថា “ដូច្នោះ ដែលយើងរាល់គ្នាបានរាប់ជាសុចរិតដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រិស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា” (រ៉ូម៥៖១)។ លោកសាវ៉កប៉ុលកំពុងតែធ្វើការសង្ខេបចាប់តាំងពីដើមជំពូកមកម្ល៉េះថា មនុស្សគ្រប់ៗគ្នាទាំងអស់បានកើតមកក្នុងនាមជាសត្រូវរបស់ព្រះជាម្ចាស់ សម្រាប់ស្ថិតនៅក្រោមការវិនិច្ឆ័យ និងព្រះពិរោធន៏របស់ព្រះជាម្ចាស់ ក៏ប៉ុន្តែដំណឹងល្អគឺ ដោយសារព្រះគុណ តាមរយះសេចក្តីជំនឿលើអង្គព្រះយេស៊ូវគ្រិស្ទ យើងបានជាមេត្រីនឹងទ្រង់វិញ ពោលគឺពួកយើងមិនមែនជាសត្រូវរបស់ព្រះជាម្ចាស់ទៀតទេ ហើយការវិនិច្ឆ័យ និងព្រះពិរោធន៏របស់ព្រះជាម្ចាស់ក៏ត្រូវបានបង្វែរចេញពីយើងរាល់គ្នាដែលនៅជាប់ក្នុងព្រះយេស៊ូវគ្រិស្ទ (រ៉ូម៥៖១០-១១ ពេត្រុសទី១ ២៖១០ កាឡាទី៤៖៧)។ ពេលដែលលោកសាវ៉កប៉ុលនិយាយអំពីផ្លូវទៅកាន់សេចក្តីសង្គ្រោះ គាត់បានបដិសេធន៏ចោលទាំងស្រុងនូវអំពើល្អរបស់បុគ្គល ហើយចង្អុលទៅកាន់ព្រះគុណរបស់ព្រះជាម្ចាស់តែមួយគត់ ដែលជាគ្រឹះសម្រាប់សេចក្តីសង្គ្រោះរបស់មនុស្សជាតិផងទាំងពួង (ធីម៉ូថេទេ២ ១៖៩)៕

ដូចគ្នានេះដែរ តាមរយះកិច្ចសន្ទនារវាងព្រះយេស៊ូវគ្រិស្ទ និងលោកនីកូដេម (យ៉ូហាន៣៖១-២១) ព្រះយេស៊ូវគ្រិស្ទបានចង្អុលបញ្ជាក់យ៉ាងច្បាស់ថា សេចក្តីសង្គ្រោះមិនមែនអាស្រ័យលើអំពើល្អដែលបុគ្គលខិតខំប្រព្រឹត្តិនោះទេ ផ្ទុយទៅវិញ វាគឺជាអំណោយទានដែលមកពីព្រះជាម្ចាស់ទាំងស្រុង ដោយសារព្រះគុណ តាមរយះសេចក្តីជំនឿ។ លោកនីកូដេម គឺជាប្រភេទមនុស្សដែលបានខិតខំព្យាយាមប្រតិបត្តិយ៉ាងត្រឹមត្រូវខ្ជាប់ខ្ជួនតាមវប្បធម៌ ច្បាប់ទម្លាប់ និងសាសនាប្រយោជន៏ដើម្បីទទួលបានសេចក្តីសង្គ្រោះ ក៏ប៉ុន្តែនៅពេលដែលលោកបានជួបជាមួយនឹងព្រះយេស៊ូវគ្រិស្ទដែលជាម្ចាស់ស្ថានសួគ៌ ព្រះអង្គបានបដិសេធន៏ចោលផ្លូវរបស់គាត់ភ្លាម ដ្បិតនគរស្ថានសួគ៌មិនមែនចូលទៅតាមផ្លូវរបស់គាត់នោះទេ។ ការខិតខំសន្សំអំពើល្អ ការរស់នៅដោយស្មោះត្រង់ សុចរិត ការកាន់តាមច្បាប់ទំលាប់ទាំងអស់របស់លោកនីកូដេម មិនអាចលុបលាងអំពើបាបរបស់គាត់អោយបានស្អាតស្រឡះឡើយ។ ព្រះយេស៊ូវគ្រិស្ទបានមានព្រះបន្ទូលដោយផ្ទាល់ថា លោកនីកូដែមត្រូវការ “ការកើតជាថ្មី” ទើបអាចចូលទៅក្នុងនគរព្រះបាន (យ៉ូហាន៣៖៣)។ បន្ទាប់ពីការធ្លាក់ចុះនៃអំពើបាប “គ្រប់ផ្នែកទាំងអស់របស់យើងត្រូវខូចដោយសារបាបដែលមិនអាចកែឆ្នៃបាន។ បើព្រះកែច្នៃយើងត្រង់នេះបន្តិចត្រង់នោះបន្តិច នោះមិនគ្រប់គ្រាន់ទេ យើងមានសង្ឃឹមតែមួយគត់ គឺសូមអោយទ្រង់ប្រទានចិត្តថ្មីដល់យើងទាំងស្រុង។ នេះហើយជាសេចក្តីសន្យានៅក្នុងដំណឹងល្អនៃព្រះយេស៊ូគ្រិស្ត”[24]។ បុគ្គលគ្រប់ៗរូប ក៏ដូចជាលោកនីកូដេមផងដែរ ត្រូវការចិត្តថ្មីជំនួសចិត្តចាស់ដែលត្រូវបានបង្ខូច និងពោរពេញទៅដោយអំពើបាប ដើម្បីចូលទៅក្នុងព្រះវត្តមានរបស់ព្រះដ៏បរិសុទ្ធ។ គ្មាននរណាម្នាក់ ឬក៏អ្វីមួយដែលអាចផ្លាស់ប្តូរ និងប្រោសប្រទានចិត្តថ្មីដល់មនុស្សបាបបានទេ លើកលែងតែព្រះជាម្ចាស់តែមួយអង្គគត់ (អេសេគាល១១៖១៩-២០ ៣៦៖២៥-២៧)។ តាមរយះកំណើតថ្មីក្នុងព្រះយេស៊ូវគ្រិស្ទ មនុស្សបាប

[24] បានល្អ ធ្វើល្អ និពន្ធដោយលោក ចេ. ឌី. ក្រោលី ទំព័រ៩៤

បានទទួលចិត្តថ្មីដែលល្អ បរិសុទ្ធ គ្មានបាប និងជាទីគាប់ព្រះហឬទ័យរបស់ព្រះជាម្ចាស់ខ្លាំងណាស់។ បើទោះបីជាយ៉ាងណាក៏ដោយ ចំនុចពីរដែលលោកនីកូដេមត្រូវតែសម្រេចចិត្តគឺ ការផ្លាស់ប្រែចិត្តចេញពីអំពើបាប និងការជឿទុកចិត្តលើព្រះរាជបុត្រារបស់ព្រះជាម្ចាស់ (យ៉ូហាន១៖១២-១៣ ម៉ាកុស១៖៤ កិច្ចការ២៖៣៨) ពោលគឺឈប់ពឹងផ្អែកលើអំពើល្អរបស់ខ្លួនដើម្បីទទួលបានសេចក្តីសង្គ្រោះ ហើយបែរទៅពឹងផ្អែកលើកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងសម្រាប់គេវិញ ដើម្បីទទួលបានសេចក្តីសង្គ្រោះ។ សេចក្តីសង្គ្រោះគឺជាអំណោយដែលមកពីព្រះជាម្ចាស់ដោយសារព្រះគុណ តាមរយះសេចក្តីជំនឿ មិនមែនមកពីមនុស្ស និងអំពើល្អដែលគេខិតខំប្រព្រឹត្តិជាដាច់ខាត។ នៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានសម្រេចសេចក្តីសង្គ្រោះសម្រាប់មនុស្សបាបទាំងពួងដោយជោគជ័យ ដោយមិនទាមទារបន្ថែមអំពើល្អរបស់បុគ្គលឡើយ។ ទាក់ទងទៅនឹងប្រធានបទនេះផងដែរ លោកប៉ូល អ៊ី. លីតផល បានលើកឡើងថា "ដំណឹងល្អមិនមែនជាអ្វីៗដែលយើងធ្វើសម្រាប់ផ្ទាល់ខ្លួន ប៉ុន្តែគឺជាអ្វីៗដែលព្រះបានត្រៀមអោយយើងវិញ"[25]។ ត្រីវិស័យដ៏ពិតតែមួយគត់ដែលមកពីព្រះជាម្ចាស់ បានចង្អុលទៅកាន់សេចក្តីសង្គ្រោះតាមរយះកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងតែមួយគត់ មិនមែនតាមរយះអំពើល្អនោះទេ។ ដូចគ្នានេះផងដែរ យើងក៏មិនត្រូវបន្ថែមអំពើល្អពីលើកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង ដើម្បីទទួលបានសេចក្តីសង្គ្រោះសោះឡើយ។ គ្រឹះសម្រាប់សេចក្តីសង្គ្រោះ គឺព្រះគុណ និងសេចក្តីជំនឿ គ្មានវត្តមានរបស់អំពើល្អឡើយ។ ដោយសារព្រះគុណ និងសេចក្តីជំនឿ នោះកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងគឺជាស្តង់ដាតែមួយគត់ដែលព្រះជាម្ចាស់បានទាមទារមនុស្សបាបសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ៕

ព្រះគុណរបស់ព្រះជាម្ចាស់ គឺជាសេចក្តីសង្ឃឹមតែមួយគត់សម្រាប់សេចក្តីសង្គ្រោះរបស់មនុស្ស។ មនុស្សមិនអាចទុកចិត្តអនាគតដ៏អស់កល្បជានិច្ចរបស់ពួកគេលើអំពើល្អបានឡើយ។ អ្នកនិពន្ធសៀវភៅ "ស្គាល់អ្នកណាដែលអ្នកជឿតាម" បាននិយាយថា "គំនិតចាស់ដែលយើងសង្ឃឹមថាការប្រព្រឹត្តិល្អរបស់យើង គឺឈ្នះទៅលើការប្រព្រឹត្តិអាក្រក់ តែយើងភ្លេចថាយើងមិនអាចធ្វើដូចខ្នាតគំរូនៃស្ថានសួគ៍ដោយខ្លួនឯងបានឡើយ។ យើងគ្មានសមត្ថភាពបែបនោះទេ ក៏គ្មានបុណ្យកុសលណាដែលអាចធ្វើអោយខ្លួនយើងឡើងទៅដល់កំរិតនោះបានដែរ។
យើងត្រូវការព្រះគុណនៃព្រះ"[26]។ មនុស្សបានយកអំពើល្អបន្តបន្ទាប់លើគ្នាជាកាំជណ្តើរដើម្បីឈានឡើងទៅរកព្រះជាម្ចាស់ ក៏ប៉ុន្តែកិច្ចការទាំងអស់នេះមិនអាចដឹកនាំពួកគេអោយទៅដល់ទ្រង់បានជាដាច់ខាត ព្រោះផ្លូវតែមួយគត់ដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់ផ្សះផ្សាមនុស្សបាបជាមួយនឹងព្រះអង្គវិញ គឺដោយសារព្រះគុណ តាមរយះសេចក្តីជំនឿលើព្រះយេស៊ូវគ្រិស្ទ មិនមែនខ្លួនទីពឹងខ្លួននោះទេ។ មនុស្សត្រូវការព្រះគុណរបស់ព្រះជាម្ចាស់ និងសេចក្តីជំនឿដើម្បីទទួលបានសេចក្តីសង្គ្រោះ មិនមែនអំពើល្អរបស់ខ្លួននោះឡើយ។ ការពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន អំពើល្អនឹងរុញច្រានមនុស្សអោយឃ្លាតចេញកាន់តែឆ្ងាយពីព្រះជាម្ចាស់ និងនគរស្ថានសួគ៌៕

---

[25] ស្គាល់អ្នកណាដែលអ្នកជឿតាម និពន្ធដោយលោកប៉ូល អ៊ី. លីតផល ទំព័រ៨៥

[26] ស្គាល់អ្នកណាដែលអ្នកជឿតាម និពន្ធដោយលោកប៉ូល អ៊ី. លីតផល ទំព័រ៥៨

ព្រះជាម្ចាស់បានជ្រើសរើសគ្រិស្តបរិស័ទគ្រប់ៗរូបដោយព្រោះព្រះគុណ និងបុគ្គលិកលក្ខណៈរបស់ទ្រង់ដែលជាព្រះដំពោរពេញទៅដោយសេចក្តីមេត្តាករុណា មិនមែនអាស្រ័យលើអំពើល្អ កេរ្តិ៍ឈ្មោះ យសសក្តិ ទ្រព្យសម្បត្តិ និងបុគ្គលិកលក្ខណៈល្អប្រសើរផ្សេងៗរបស់យើងនោះទេ។ លោកសាវ័កប៉ុលបានលើកឡើងថា "…. ទ្រង់បានរើសអ្នករាល់គ្នាតាំងពីដើមដំបូងមកដើម្បីអោយបានសង្គ្រោះ ដោយព្រះវិញ្ញាណទ្រង់ញែកចេញជាបរិសុទ្ធ ហើយដោយមានចិត្តជឿតាមសេចក្តីពិតផង" (ថេស្សាឡូនីចទី២ ២៖១៣)។ ដោយសំអាងលើសម្តីរបស់លោកសាវ័កប៉ុល ចាប់តាំងពីមុនពេលដែលយើងមិនទាន់បានចាប់កំណើតមកម្ល៉េះ ពោលគឺមិនទាន់នឹងបានប្រព្រឹត្តិអំពើល្អណាមួយដែលសាកសមនឹងទទួលយកព្រះគុណរបស់ព្រះជាម្ចាស់សោះឡើង ក៏ប៉ុន្តែព្រះអង្គបានសម្រេចព្រះហឬទ័យរាប់យើងថាជាសុចរិត ហើយសង្គ្រោះយើងវិញ ដ្បិតសេចក្តីសង្គ្រោះមិនមែនអាស្រ័យលើអំពើល្អរបស់យើងឡើង ផ្ទុយទៅវិញ វាគឺជាអំណោយទានដែលមកពីព្រះជាម្ចាស់ ដោយសារព្រះគុណ តាមរយៈសេចក្តីជំនឿ។ លោកសាវ័កប៉ុលបានផ្តល់ជាឧទាហរណ៍ចំពោះការនេះ ដោយចង្អុលបង្ហាញទៅកាន់របៀបដែលព្រះជាម្ចាស់បានជ្រើសរើសយកលោកយ៉ាកុប ហើយបដិសេធន៍លោកអេសាវជាគម្រូថា ការជ្រើសរើសនេះគ្មានអ្វីទាក់ទងទៅនឹងការប្រព្រឹត្តិរបស់អ្នកទាំងពីរនោះទេ ផ្ទុយទៅវិញគឺដើម្បីសម្រេចតាមបំណងព្រះហឬទ័យរបស់ទ្រង់តែមួយគត់។ គាត់បានសរសេរថា "គ្រាដែលកូនមិនទាន់កើតមកនៅឡើយ ហើយមិនទាន់ធ្វើការល្អ ឬអាក្រក់អ្វី នោះព្រះទ្រង់មានព្រះបន្ទូលប្រាប់នាងថា "កូនច្បងនឹងត្រូវបំរើកូនប្អូន" ដូចមានសេចក្តីចែងទុកមកថា "អញបានស្រលាញ់យ៉ាកុប តែស្អប់អេសាវវិញ" គឺដើម្បីអោយព្រះតម្រិះរបស់ព្រះ ខាងឯសេចក្តីរើសតាំងបានជាប់នៅ មិនមែនដោយអាងការប្រព្រឹត្តិទេ គឺដែលអាងព្រះដែលទ្រង់ហៅវិញ" (រ៉ូម៩៖១១-១៣)។ ដូចគ្នានេះដែរ លោកសាវ័កប៉ុលក៏បានបើកសម្តែងសេចក្តីជ្រាលជ្រៅជាងនេះទៅទៀតថា "… ទ្រង់បានជ្រើសរើសយើងរាល់គ្នាក្នុងព្រះគ្រិស្ទតាំងពីមុនកំណើតលោកិយមកប្រយោជន៍អោយយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្តីស្រលាញ់ ពីព្រោះទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សម្រាប់អោយទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រិស្ទ តាមបំណងព្រះហឬទ័យទ្រង់ ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់ ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ហើយយើងបានសេចក្តីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសអោយរួចពីទោស តាមព្រះគុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ ដែលបានផ្តល់មកយើងជាបរិបូរណ៍ ដោយនូវប្រាជ្ញា និងតម្រិះសព្វគ្រប់" (អេភេសូរ១៖៤-៨)។ ដោយព្រោះព្រះគុណ តាមរយៈសេចក្តីជំនឿ ព្រះជាម្ចាស់បានប្រោសប្រទាន សេចក្តីសង្គ្រោះដល់គ្រប់ៗគ្នាដែលមិនសាកសមនឹងទទួលយកសោះឡើយ។ យើងទទួលបានសេចក្តីសង្គ្រោះមិនមែនព្រោះតែយើងល្អនោះទេ ផ្ទុយទៅវិញ ព្រោះតែអង្គដែលបានប្រោសប្រទានសេចក្តីសង្គ្រោះនោះ ល្អអស្ចារ្យ។ សេចក្តីសង្គ្រោះមិនមែនអាស្រ័យលើកិច្ចការដែលយើងបានសម្រេចនោះទេ ក៏ប៉ុន្តែវាអាស្រ័យទាំងស្រុងលើកិច្ចការដែលព្រះរាជបុត្រានៃព្រះបានសម្រេចនៅលើឈើឆ្កាង។ ព្រះជាម្ចាស់តែមួយអង្គគត់ដែលសាកសមនឹងទទួលយកការសរសើរតម្កើងគ្រប់បែបយ៉ាងទាំងអស់ ព្រោះព្រះអង្គបានសម្រេចគ្រប់ទាំងអស់សម្រាប់សេចក្តីសង្គ្រោះរបស់មនុស្សជាតិ៕

ជាចុងក្រោយ ទាក់ទងទៅនឹងសេចក្តីសង្គ្រោះនេះផងដែរ សេចក្តីជំនឿ និងការកែប្រែចិត្តមានទំនាក់ទំនងជាមួយគ្នាយ៉ាងស្អិតរមួតដោយមិនអាចខ្វះផ្នែកណាមួយបានឡើយ។ នៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទបានបញ្ជាក់

ម្តងហើយម្តងទៀតថា ចូរកែប្រែចិត្ត ហើយទទួលជឿចុះ នោះអ្នកនឹងទទួលបានសេចក្តីសង្គ្រោះ បើពុំដូច្នោះទេ អ្នករាល់គ្នានឹងត្រូវវិនាសបាត់បង់ជាក់ជាមិនខាន (ម៉ាកុស១៖១៥ ១៦៖១៦ លូកា១៣៖៣ កិច្ចការ៣៖១៩)។ យ៉ាងណាមិញ ការកែប្រែចិត្តនៅត្រង់នេះ គឺសំដៅទៅលើការបោះបង់ចោលរាល់គ្រប់កិច្ចការទាំងអស់ដែលយើងធ្លាប់បានធ្វើពីមុនមក ដោយត្រឡប់មកពឹងផ្អែក ហើយទុកចិត្តលើកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងជំនួស និងសម្រាប់យើងវិញ ដើម្បីទទួលបានសេចក្តីសង្គ្រោះ។ យើងជឿថាកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងល្មមគ្រប់គ្រាន់ហើយសម្រាប់លុបលាងទោសនៃអំពើបាបរបស់យើង ក៏ដូចជាផ្តល់នូវសេចក្តីសង្គ្រោះដល់យើងផងដែរ ដោយមិនចាំបាច់ត្រូវបន្ថែមបន្ថយអ្វីផ្សេងទៀតទាំងអស់។ ទាក់ទងទៅនឹងការកែប្រែចិត្តនេះផងដែរ នៅក្នុងព្រះគម្ពីរបរិសុទ្ធបាននិយាយថា យើងត្រូវតែសម្លាប់ជីវិតចាស់ចោល ដោយឆ្កាងវាជាប់ជាមួយនឹងព្រះយេស៊ូវគ្រិស្ទនៅលើឈើឆ្កាង ហើយបំពាក់ជីវិតថ្មីនៅក្នុងព្រះយេស៊ូវគ្រិស្ទ ដែលព្រះជាម្ចាស់បានប្រោសប្រទានដល់យើងគ្រប់ៗគ្នានៅក្នុងកំណើតជាថ្មីរបស់យើងវិញ (រ៉ូម៦)។ ហេតុផលគឺបណ្តាលមកពី ជីវិតចាស់ និងផ្លូវចាស់ សម្រាប់ឆ្ពោះសំដៅទៅរកសេចក្តីសង្គ្រោះ ដោយការពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន មិនអាចដឹកនាំយើងឆ្ពោះតម្រង់ទៅរកសេចក្តីសង្គ្រោះដ៏ពិតប្រាកដបានឡើយ។ យើងត្រូវតែឈប់ចូលទៅរកព្រះជាម្ចាស់តាមរបៀបចាស់ដែលយើងធ្លាប់បានធ្វើពីមុនមក ហើយបែរត្រឡប់មកដើរតាម ព្រមទាំងធ្វើតាមព្រះយេស៊ូវគ្រិស្ទដែលជាផ្លូវដ៏ពិតតែមួយគត់វិញ។ តួយ៉ាង ក្នុងនាមជាអ្នកអនុវត្តន៍តាមសាសនា និងច្បាប់ទំលាប់ដ៏ខ្ជាប់ខ្ជួនម្នាក់ លោកសាវ៉កប៉ុលដែលធ្លាប់តែពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក៏ដូចជាដើម្បីទទួលបានសេចក្តីសង្គ្រោះផងដែរនោះ បានលើកឡើងថា គ្រប់កិច្ចការទាំងអស់ដែលគាត់បានខិតខំសន្សំពីមុនមកដើម្បីទទួលបានសេចក្តីសង្គ្រោះ ប្រៀបបានដូចជាសំរាមនៅចំពោះព្រះជាម្ចាស់ ដែលគ្មានតម្លៃអ្វីសោះឡើយដើម្បីប្តូរយកសេចក្តីសង្គ្រោះដ៏ថ្លៃថ្លា។ លើសពីនេះទៅទៀត គាត់ក៏បានបន្តទៀតដែរថា កិច្ចការដែលគាត់ខិតខំប្រព្រឹត្តិយ៉ាងម៉ត់ចត់ និងប្រុងប្រយត្ន័ទាំងអស់នោះ មិនអាចបណ្តាលអោយគាត់បានសុចរិតនៅចំពោះព្រះដ៏សុចរិតនោះទេ លើកលែងតែសេចក្តីសុចរិតតែមួយគត់ដែលមកពីព្រះជាម្ចាស់ផ្ទាល់ (ភីលីព៣៖៨-១០)។ ដោយឡែក ឆ្លើយតបទៅនឹងអំពើល្អដែលមនុស្សចូលចិត្តលើកយកមកថ្វាយព្រះជាម្ចាស់នោះ លោកហោរ៉ាអេសាយក៏បានលើកឡើងផងដែរថា “...... អស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់...... ” នៅចំពោះព្រះជាម្ចាស់ (អេសាយ៦៤៖៦)។ អំពើល្អដែលជាផលផ្លែនៃសមត្ថភាពរបស់មនុស្សបាប មិនអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ ហើយវាក៏មិនល្មមគ្រប់គ្រាន់តាមស្តង់ដាដែលព្រះជាម្ចាស់បានទាមទារទុកជាថ្លូរសម្រាប់សេចក្តីសង្គ្រោះដ៏ថ្លៃថ្លាផងដែរ។ ព្រះយេស៊ូវគ្រិស្ទបានមានព្រះបន្ទូលដោយផ្ទាល់ថា “...... ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ” (យ៉ូហាន១៤៖៦)។ អំពើល្អ បុណ្យកុសល កិត្តិយស ទ្រព្យសម្បត្តិ សមត្ថភាពបុគ្គល លនិងល មិនអាចដឹកនាំមនុស្សឆ្ពោះតម្រង់ទៅដល់គោលដៅដ៏ពិតប្រាកដនៃជីវិត ព្រមទាំងសេចក្តីសង្គ្រោះបានឡើយ។ ត្រីវិស័យដ៏ពិតប្រាកដដែលមកពីព្រះជាម្ចាស់បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ព្រះយេស៊ូវគ្រិស្ទគឺជាផ្លូវតែមួយគត់ដើម្បីទទួលបានសេចក្តីសង្គ្រោះ ហើយការនេះទៀតសោត អាចសម្រេចទៅបានដោយសារព្រះគុណ តាមរយះសេចក្តីជំនឿ មិនមែនដោយពឹងផ្អែកលើចំនុចល្អៗទាំងឡាយដែលបានរៀបរាប់ខាងលើ

នេះទេ ផ្ទុយទៅវិញ ទាំងអស់នោះអាចក្លាយជារនាំង និងបន្ទុកដ៏ធំសម្បើម ដែលរារាំងមនុស្សមិនអោយដើរតាមផ្លូវដែលព្រះជាម្ចាស់បានរៀបចំទុកសម្រាប់ពួកគេ តាមរយៈព្រះយេស៊ូវគ្រិស្ទ ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌៕

ដោយយោងទៅតាមសេចក្តីបង្រៀនរបស់សាសនានានា មនុស្សត្រូវតែលះបង់ចោលនូវអំពើអាក្រក់ ហើយបែរមកសង្វាតខិតខំកសាងអំពើល្អវិញ ដើម្បីជួយសង្គ្រោះខ្លួនឯងចូលទៅក្នុងនគរស្ថានសួគ៌។ អំពើល្អគឺជាស្ពានចម្លងមនុស្សអោយរួចផុតពីសេចក្តីវិនាសចូលទៅក្នុងនគររបស់ព្រះជាម្ចាស់។ ដោយឡែក ដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទវិញបានសង្កត់យ៉ាងធ្ងន់ថា ដោយសារព្រះគុណ តាមរយៈសេចក្តីជំនឿ កិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង គឺជាគ្រឹះតែមួយគត់សម្រាប់សេចក្តីសង្គ្រោះរបស់មនុស្សជាតិទាំងពួង។ ព្រះយេស៊ូវគ្រិស្ទតែមួយអង្គគត់ដែលជាផ្លូវ និងជាស្ពានសម្រាប់ចម្លងមនុស្សចូលទៅក្នុងនគរស្ថានសួគ៌។ ស្របពេលជាមួយគ្នានេះផងដែរ ព្រះអង្គបានទាមទារអោយមនុស្សត្រូវតែលះបង់ចោលទាំងអំពើអាក្រក់ និងអំពើល្អទាំងអស់ ហើយដើរតាមទ្រង់ដោយសេចក្តីជំនឿ និងទំនុកចិត្តវិញ ដើម្បីទទួលបានសេចក្តីសង្គ្រោះ (ម៉ាថាយ១៦៖២៤-២៥)។ សេចក្តីសង្គ្រោះ គឺជាផលផ្លែដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាងសម្រាប់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ មិនមែនជាផលផ្លែនៃអំពើល្អរបស់បុគ្គលនីមួយៗសោះឡើយ។ ដរាបណាយើងបន្ថែមអំពើល្អទៅលើកិច្ចការដែលព្រះយេស៊ូវគ្រិស្ទបានសម្រេចនៅលើឈើឆ្កាង ដើម្បីទទួលបានសេចក្តីសង្គ្រោះនោះ បានសេចក្តីថាយើងមិនទាន់យល់ច្បាស់អំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទនៅឡើយទេ។ ទាក់ទងទៅនឹងប្រធានបទដែលនេះផងដែរ លោកសាវ័កប៉ុលបាននិយាយថា “ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯអំពើបាបដែរ តែរស់ខាងឯព្រះវិញចុះ.... ” (រ៉ូម៦៖១១)។ គោលគំនិតរបស់លោកសាវ័កប៉ុលនៅត្រង់នេះគឺថា យើងត្រូវតែសម្លាប់អំពើបាបទាំងអស់នៅក្នុងជីវិតរបស់យើងចោល ដោយឈប់ប្រព្រឹត្តិវាតទៅទៀត ដូចជាការសន្សំបុណ្យកុសល ការថ្វាយបង្គំរូបព្រះក្លែងក្លាយ ការរស់នៅដោយអសីលធម៌ ខ្លួនទីពឹងខ្លួន ការប្រព្រឹត្តិអំពើល្អទុកជាថ្នូរសម្រាប់សេចក្តីសង្គ្រោះ លនិងល ព្រោះជាជាងដឹកនាំយើងឈានទៅរកសេចក្តីសង្គ្រោះ ការទាំងអស់នោះនឹងដឹកនាំយើងឆ្ពោះទៅរកព្រះពិរោធន៍ និងការវិនិច្ឆ័យដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់។ មនុស្សត្រូវតែឈប់ធ្វើល្អដើម្បីទទួលបានសេចក្តីសង្គ្រោះ ព្រោះនេះមិនមែនជាផ្លូវដែលព្រះជាម្ចាស់បានរៀបចំសម្រាប់មនុស្សដើម្បីទទួលយកសេចក្តីសង្គ្រោះឡើយ៕

ជាទូទៅ ទស្សនៈខាងលើនេះផ្ទុយស្រលះអំពីទស្សនៈរបស់លោកិយទាំងមូលទាក់ទងទៅនឹងសេចក្តីសង្គ្រោះ ហើយការនេះទៀតសោត បានជំរុញអោយមនុស្សពិបាកនឹងទទួលយក ក៏ដូចជាងាយស្រួលនឹងបដិសេធន៏ចោលផ្លូវរបស់ព្រះជាម្ចាស់ ដោយបែរមកដើរតាមផ្លូវរបស់ខ្លួនឯង ពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនឯងជាជំនួសវិញដើម្បីទទួលបានសេចក្តីសង្គ្រោះ។ មនុស្សបានបោះបង់ចោលត្រីវិស័យដែលព្រះជាម្ចាស់បានប្រោសប្រទានមកដើម្បីដឹកនាំពួកគេចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់វិញ ព្រោះតាំងពីដើមរៀងមក មនុស្សទម្លាប់យកសមត្ថភាពរបស់ខ្លួនចូលទៅឯព្រះជាម្ចាស់ ដើម្បីបង្ហាញអំពីតម្លៃរបស់ពួកគេនៅចំពោះព្រះដ៏ជាព្រះ និងដើម្បីលុបលាងភាពអាម៉ាស់របស់ពួកគេ។ មនុស្សសង្ឃឹមថា ព្រះជាម្ចាស់នឹងទតរម្លងភាពខ្មោងខ្មឹងនៅក្នុងដួងចិត្តរបស់ពួកគេ ខណៈពេលដែលព្រះជាម្ចាស់ទតឃើញអំពើល្អដែលពួកគេបានប្រព្រឹត្តិ។ មួយវិញទៀត មនុស្សចូលចិត្តរៀបចំខ្លួនឯងអោយបានល្អប្រសើរ និងមានតម្លៃជាមុនសិន មុននឹងពួកគេហ៊ានចូលទៅរកព្រះជាម្ចាស់ ព្រោះមនុស្សមានភាពខ្មាស់អៀនខណៈពេលដែលពួកគេចូលទៅ

ក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ទាំងកខ្វក់ មិនសមរម្យ ដោយដៃទទេរ ព្រមទាំងគ្មានអ្វីមួយថ្វាយទ្រង់សោះឡើយ។ មនុស្សមានអំនួតថា គេល្អល្មមគ្រប់គ្រាន់សមនឹងទទួលយកព្រះគុណពីព្រះជាម្ចាស់ ហើយនេះមិនមែនជាការពិតពីព្រះគម្ពីរបរិសុទ្ធសោះឡើយ ព្រោះគ្មាននរណាម្នាក់ដែលល្អល្មមគ្រប់គ្រាន់ដើម្បីទទួលយកព្រះគុណរបស់ព្រះជាម្ចាស់ឡើយ។ បើគ្មានសេចក្ដីជំនឿនោះ សេចក្ដីសង្គ្រោះក៏គ្មានដែរ៕

### ខ សេចក្ដីជំនឿ និងអំពើល្អ

គ្រឹះនៃសេចក្ដីសង្គ្រោះផ្អែកទៅលើព្រះគុណ តាមរយៈសេចក្ដីជំនឿលើព្រះយេស៊ូវគ្រិស្ទទាំងស្រុង មិនមែនជាផលផ្លែរបស់អំពើល្អនោះទេ។ តាមពិត មុនពេលដែលខ្ញុំបានយល់ច្បាស់អំពីសេចក្ដីពិតដែលបានបើកសម្ដែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ ការនេះពិបាកនឹងទទួលយកយ៉ាងខ្លាំង ព្រោះវាមិនគួរអោយជឿសោះឡើយ។ ការប្រព្រឹត្តិអំពើល្អដើម្បីសេចក្ដីសង្គ្រោះ គឺជាគ្រឹះ និងជាផ្នត់គំនិតដ៏មាំមួនចម្បងបំផុតមួយសម្រាប់ខ្ញុំដែលបានកើត ហើយរីកចម្រើនលូតលាស់ធំធាត់នៅក្នុងទស្សនះ ខ្លួនទីពឹងខ្លួន។ ដោយឡែក គោលជំនឿទាក់ទងទៅនឹងសេចក្ដីសង្គ្រោះដែលព្រះគម្ពីរបរិសុទ្ធបានបើកសម្ដែង បានចង្អុលបង្ហាញយ៉ាងច់ាថា អំពើល្អគ្មានតម្លៃអ្វីសោះឡើយ ដើម្បីប្ដូរយកសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់។ លើសពីនេះទៅទៀត ការខិតខំសន្សំអំពើល្អដើម្បីទទួលបានសេចក្ដីសង្គ្រោះនឹងដឹកនាំយើងឈានទៅរកព្រះពិរោធន៍ និងការវិនិច្ឆ័យដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ដែលជាម្ចាស់ស្ថានសួគ៌។ នេះគឺជាសេចក្ដីពិត! បើគ្មានព្រះយេស៊ូវគ្រិស្ទជាព្រះសង្គ្រោះ បុគ្គលគ្រប់ៗរូបនឹងវិនាសក្រោមការវិនិច្ឆ័យរបស់ព្រះដ៏សុចរិតជាក់ជាមិនខាន បើទោះបីជាពួកគេខិតខំសន្សំអំពើល្អបានច្រើនយ៉ាងណាក្ដី។ បើដូច្នោះ តើគ្រិស្ទបរិស័ទចាំបាច់ត្រូវប្រព្រឹត្តិអំពើល្អដែលឬទេ? ដូចគ្នានេះដែរ តើអំពើល្អមានតម្លៃដែរឬទេនៅចំពោះព្រះជាម្ចាស់? មួយវិញទៀត យើងគ្រប់ៗគ្នាបានដឹងច្បាស់ហើយថា ការប្រព្រឹត្តិអំពើល្អតែមួយនោះពិបាកជាងការប្រព្រឹត្តិអំពើអាក្រក់រាប់រយដង ដូចដែលលោកសាវ័កប៉ុលដែលបានលើកឡើងថា "ខ្ញុំមិនប្រព្រឹត្តិការល្អដែលខ្ញុំចង់ធ្វើនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ នោះបែរជាខ្ញុំធ្វើវិញ" (រ៉ូម៧៖១៩)។ ដោយព្រោះនិស្ស័យបាប មនុស្សទោរទន់ទៅរកការប្រព្រឹត្តិអំពើអាក្រក់ ដោយមិនសូវអើពើនឹងការប្រព្រឹត្តិល្អសោះឡើយ។ បើដូច្នោះស្ដាប់ទៅហាក់បីដូចជាដំណឹងល្អរបស់ព្រះយេស៊ូវគ្រិស្ទអាចក្លាយជាលេសមួយសម្រាប់មនុស្សឈប់ប្រព្រឹត្តិអំពើល្អ។ តើការនេះពិតដែរឬទេ?

នេះស្ទើតែជាចម្ងល់របស់មនុស្សគ្រប់ៗរូប គ្រប់ទីកន្លែង និងគ្រប់សម័យកាលទាំងអស់ ចាប់តាំងពីដើមកំណើតនៃក្រុមជំនុំមកម្ល៉េះ។ ដោយឡែក ទាក់ទងនៅនឹងប្រធានបទនេះផងដែរ លោកសាវ័កប៉ុលបានលើកឡើងស្រដៀងគ្នាថា "ដូច្នោះ យើងនឹងថាដូចម្ដេច តើត្រូវអោយយើងចេះតែប្រព្រឹត្តិបាបទៅទៀត ដើម្បីអោយព្រះគុណបានចម្រើនឡើងឬអី" (រ៉ូម៦៖១)។ ចម្លើយគឺទេ! ព្រោះព្រះយស៊ូវគ្រិស្ទបានប្រោសលោះគ្រិស្ទបរិស័ទចេញពីអំណាចរបស់អំពើបាបហើយ (យ៉ូហានទី១ ៥៖១៨) គ្រិស្ទបរិស័ទបានស្លាប់ក្នុងអំពើបាបហើយ (កាឡាទី៥៖២៤) ពួកគេមិនមែនជាបាវបំរើរបស់អំពើបាបទៀតទេ (អេភេសូរ២៖១៩-២០) ព្រះគ្រិស្តបានរស់នៅក្នុងគេ (កាឡាទី២៖២០) ហើយពួកគេមានជីវិតថ្មី (កូរិនថូសទី២ ៥៖១៧) លនិងល។ លើសពីនេះទៅទៀត ដោយព្រោះគ្រិស្ទបរិស័ទបានរួចផុតពីចំណងជីវិតចាស់ ហើយកំពុងតែរស់នៅក្នុងជីវិតថ្មី ដែលមានព្រះដ៏ជាព្រះគង់នៅក្នុងពួកគេទៀតនោះ គ្រិស្ទបរិស័ទត្រូវតែស្អប់ខ្ពើមអំពើបាប បែរមកស្រលាញ់ព្រមទាំងសង្វាតខាងឯអំពើល្អវិញ ដូចជាព្រះរបស់ពួកគេដែលស្អប់សេចក្ដីងងឹត ហើយសេចក្ដីងងឹតគ្មានវត្តមាននៅក្នុង

ទ្រង់ផងដែរ។ ជារៀងរាល់ថ្ងៃ គ្រិស្ទបរិស័ទត្រូវតែខិតខំ តស៊ូ ព្យាយាមរត់ចេញអោយឆ្ងាយពីសេចក្ដីងងឹត ដោយសំដៅទៅរកប្រភពនៃពន្លឺ ប្រយោជន៍អោយពួកគេបានកាន់តែដូចជាព្រះយេស៊ូវគ្រិស្ទពីមួយថ្ងៃទៅមួយថ្ងៃទៀត។ ស្របពេលជាមួយគ្នានេះផងដែរ ដោយសារព្រះគុណ ព្រះជាម្ចាស់បានប្រោសប្រទានអោយគ្រិស្ទបរិស័ទមានព្រះវិញ្ញាណបរិសុទ្ធ អំណាច និងកម្លាំងល្មមគ្រប់គ្រាន់ដើម្បីតយុទ្ធប្រឆាំងនឹងភាពងងឹត ចិត្តចង់ប្រព្រឹត្តិបាបអាក្រក់ ហើយជំរុញអោយពួកគេចង់ធ្វើល្អ ព្រមទាំងអាចធ្វើល្អបានទៀតផង ដែលការនេះពិបាកខ្លាំង បើយើងពឹងផ្អែកលើនិស្ស័យខាងសាច់ឈាម។ នៅត្រង់ចំនុចនេះ លោកសាវ័កប៉ុលបានផ្ដល់នូវសេចក្ដីសង្ឃឹមដ៏ត្រចេះត្រចង់មួយដើម្បីរំលឹក និងលើកទឹកចិត្តពួកក្រុមជំនុំនៅក្នុងទីក្រុងរ៉ូមដើម្បីកុំអោយពួកគេរស់នៅក្នុងអំពើបាបតទៅទៀត ដោយលោកបានលើកឡើងថា “ហេតុនេះ កុំអោយបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នាដែលតែងតែស្លាប់ ដើម្បីនឹងស្ដាប់តាមសេចក្ដីប៉ងប្រាថ្នារបស់បាបនោះឡើយ ក៏កុំអោយប្រគល់អវយវៈទាំងប៉ុន្មានរបស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់ទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ ដោយថ្វាយអវយវៈរបស់អ្នករាល់គ្នាទៅព្រះ ទុកដូចជាប្រដាប់ប្រដាសុចរិតផង ដ្បិតបាបមិនមានអំណាចលើអ្នករាល់គ្នាទៀតឡើយ ដោយព្រោះអ្នករាល់គ្នាមិននៅក្រោមក្រិត្យវិន័យ គឺនៅក្រោមព្រះគុណវិញ” (រ៉ូម៦៖១២-១៣)។ ដោយឡែក នៅក្នុងសំបុត្រផ្ញើរទៅកាន់ក្រុមជំនុំសួនភ្នានៅឯទីក្រុងកូរិនថូសវិញ លោកសាវ័កប៉ុលក៏បានពន្យល់រៀបរាប់ប្រាប់ដល់គ្រិស្ទបរិស័ទទាំងឡាយនៅទីនោះផងដែរថា ខ្លួនប្រាណរបស់ពួកគេគឺជាព្រះវិហារដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ និងជាទីលំនៅរបស់ព្រះវិញ្ញាណដ៏បរិសុទ្ធ ដូច្នេះពួកគេគប្បីត្រូវតែញែកខ្លួនអោយដាច់ដោយឡែកពីអំពើបាបគ្រប់រូបភាពទាំងអស់ថ្វាយដល់ព្រះជាម្ចាស់ (កូរិនថូសទី១ ៣៖១៦-១៧)។ ព្រះជាម្ចាស់បានជ្រើសរើសយកគ្រិស្ទបរិស័ទចេញពីលោកិយដែលជោគជាំជិតដាមទៅដោយអំពើបាប ហើយទ្រង់បានសំអាត ព្រមទាំងបន្សុទ្ធពួកគេអោយបានល្អបរិសុទ្ធដូចជាអង្គទ្រង់ សម្រាប់ជាកម្មសិទ្ធរបស់ទ្រង់ និងជាសិរីល្អរបស់ទ្រង់ផ្ទាល់។ ក្នុងនាមជាប្រជារាស្ត្ររបស់ព្រះដ៏បរិសុទ្ធ គ្រិស្ទបរិស័ទគប្បីត្រូវតែដើរអោយបានសុចរិត និងបរិសុទ្ធនៅចំពោះទ្រង់ ដោយការតយុទ្ធប្រយុទ្ធប្រឆាំងនឹងអំពើបាប មិនចុះចូលនឹងបាប មិនប្រព្រឹត្តិបាប មិនបំរើបាប ព្រោះព្រះយេស៊ូវគ្រិស្ទបានប្រោសលោះពួកគេចេញពីនឹមរបស់បាបហើយ។ គ្រិស្ទបរិស័ទមិនមែនជាសត្វមមាចដែលចូលចិត្តប្រលែងលេងជាមួយនឹងភ្លើងនៃអំពើបាបដូចកាលពីមុននោះទេ ផ្ទុយទៅវិញ ពួកគេត្រូវតែស្អប់ខ្ពើមអំពើបាបដូចជាព្រះរបស់ពួកគេផងដែរ៕

វត្តមានរបស់បុគ្គលនីមួយៗគឺសម្រាប់ថ្វាយបង្គំ និងជាសិរីល្អដល់ព្រះជាម្ចាស់ដែលបានបង្កើតពួកគេមក។ បើទោះបីជា អំពើបាបបានបំផ្លិចបំផ្លាញបំផ្លាញនិមិត្តនេះចោលក៏ពិតមែន ក៏ប៉ុន្តែនៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានដាក់ព្រះជន្មទ្រង់ចុះដោយផ្ទាល់ដើម្បីបំពេញនិមិត្តខាងលើនេះឡើងវិញ ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនត្រឹមតែបានសង្គ្រោះយើងចេញពីព្រះពិរោធន៍ និងការវិនិច្ឆ័យដ៏អស់កល្បជានិច្ចរបស់ទ្រង់នោះទេ លើសពីនេះទៅទៀត ព្រះអង្គបានសង្គ្រោះយើងចេញពីអន្លង់បាប ផ្លូវបាប និងការប្រព្រឹត្តិបាប ថែមទាំងបានទំនុកបំរុងយើងទុកសម្រាប់ធ្វើការល្អៗដែលមកពីទ្រង់ គាប់ព្រះហឫទ័យរបស់ទ្រង់ និងសម្រាប់ជាដង្វាយដ៏ឈ្ងុយឈ្ងប់នៅចំពោះអាសនារបស់ទ្រង់ផ្ទាល់ទៀតផង។ លោកសាវ័កប៉ុលបានលើកឡើងថា “ដ្បិតយើងរាល់គ្នាជាស្នាដៃដែលទ្រង់បង្កើតក្នុងព្រះគ្រិស្ទយេស៊ូវសម្រាប់ការល្អ ដែលព្រះបានរៀបចំជាមុន អោយយើងរាល់គ្នាប្រព្រឹត្តិតាម” (អេភេសូរ២៖១០)។ ព្រះជាម្ចាស់បានសង្គ្រោះយើង ប្រយោជន៍អោយយើងបានប្រព្រឹត្តិអំពើល្អដើម្បីថ្វាយបង្គំ និងជាសិរីល្អរបស់ទ្រង់។ ដោយឡែក អំពើល្អ

ដែលគ្រិស្តបរិស័ទបានប្រព្រឹត្តិ គឺជាអំពើល្អដែលគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ជាពន់ពេក ព្រោះវាជាអំពើល្អដែលមកពីទ្រង់ ហើយសម្រេចបានដោយពឹងផ្អែកលើទ្រង់ផ្ទាល់ មិនមែនលើសមត្ថភាពបុគ្គលនោះទេ។ ទិសដៅរបស់គ្រិស្តបរិស័ទគឺរត់ចេញអោយឆ្ងាយពីអំពើបាប ហើយដេញតាមអំពើល្អ ដោយនៅជាប់នឹងព្រះជាម្ចាស់ ស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់ និងសម្រាប់ជាសិរីល្អរបស់ទ្រង់៕

ប្រសិនបើយើងក្រឡេកមកមើលសំណេររបស់លោកយ៉ាកុបដែលជាប្អូនប្រុសរបស់ព្រះយេស៊ូវគ្រិស្ទវិញ គាត់បានសរសេរថា “បងប្អូនអើយ បើអ្នកណាថាខ្លួនមានសេចក្តីជំនឿ តែមិនប្រព្រឹត្តិតាម នោះតើមានប្រយោជន៍អ្វី តើសេចក្តីជំនឿអាចនឹងជួយសង្គ្រោះអ្នកនោះបានដែរឬ” (យ៉ាកុប២៖១៤)។ បន្ទាប់មកទៀត គាត់ក៏បាននិយាយយ៉ាងធ្ងន់ផងដែរថា “ឱមនុស្សកំឡៅអើយ..... សេចក្តីជំនឿដែលឥតមានការប្រព្រឹត្តិតាម នោះឈ្មោះថាស្លាប់ហើយ” (យ៉ាកុប២៖២០ សូមមើល ខ១៧ ២២ និង២៤)។ គួរបញ្ជាក់ជាមុនផងដែរថា មូលដ្ឋានគ្រឹះនៃគោលជំនឿរបស់លោកយ៉ាកុបដូចគ្នាប៉ះបិទទៅនឹងគោលជំនឿរបស់លោកសាវ៉កប៉ុល គឺថាសេចក្តីសង្គ្រោះកើតចេញពីព្រះគុណ តាមរយៈសេចក្តីជំនឿ មិនមែនការប្រព្រឹត្តិ ឬអំពើល្អនោះទេ (អេភេសូរ២៖៨-៩)។ លោកយ៉ាកុបបានព្យាយាមពន្យល់ដោយយកចិត្តទុកដាក់ជាទីបំផុត ដើម្បីកុំអោយអ្នកអានសំបុត្ររបស់គាត់យល់ច្រលំចំពោះគោលលទ្ធិដ៏សំខាន់មួយនេះ។ ដោយឡែក លោកសាវ៉កប៉ុលបាននិយាយថា សេចក្តីសង្គ្រោះត្រូវបានប្រោសប្រទានមកដោយសារព្រះគុណ តាមរយៈសេចក្តីជំនឿ រីឯលោកយ៉ាកុបវិញបានបញ្ជាក់បន្ថែមពីលើហ្នឹងទៅទៀតថា សេចក្តីជំនឿដែលលោកសាវ៉កប៉ុលបានរៀបរាប់ខាងលើនោះត្រូវតែជាសេចក្តីជំនឿដ៏ពិតប្រាកដ ដែលមានការប្រព្រឹត្តិតាមជាភស្តុតាង។ ជាក់ស្តែង នៅយ៉ាកុប២៖២២ គាត់បានសរសេរថា សេចក្តីជំនឿបានគ្រប់លក្ខណ៍ដោយសារការប្រព្រឹត្តិតាម។ ការនេះគឺបានសេចក្តីថា ការប្រព្រឹត្តិតាមគឺជារូបភាពនៃសេចក្តីជំនឿនៅក្នុងចិត្តដែលយើងមើលមិនឃើញ។ សេចក្តីជំនឿដ៏ពិតប្រាកដ ដ៏គ្រប់លក្ខណ៍ បានផ្តល់ផលផ្លែជាការប្រព្រឹត្តិសម្តែងចេញមកខាងក្រៅ ហើយនេះគឺជាសេចក្តីជំនឿដែលនាំមកនូវសេចក្តីសង្គ្រោះដែលលោកសាវ៉កប៉ុលបានពិពណ៌នាខាងលើ។ ដូច្នេះ ទាំងលោកយ៉ាកុប និងលោកសាវ៉កប៉ុលបានឯកភាពគ្នាជាផ្លូងមួយថាសេចក្តីសង្គ្រោះចាក់គ្រឹះនៅលើព្រះគុណ តាមរយៈសេចក្តីជំនឿ មិនមែនអំពើល្អនោះទេ។ បើទោះបីជាយ៉ាងដូច្នោះក្តី គ្រិស្ទបរិស័ទត្រូវតែប្រព្រឹត្តិអំពើល្អ ព្រោះអំពើល្អគឺជាផលផ្លែរបស់សេចក្តីជំនឿដ៏ពិតប្រាកដ។ សេចក្តីជំនឿដែលគ្មានផលផ្លែជាភស្តុតាងគឺជាសេចក្តីជំនឿដែលស្លាប់ ដែលគ្មានតម្លៃសម្រាប់សេចក្តីសង្គ្រោះឡើយ។ ដោយឡែក គួរបញ្ជាក់សារជាថ្មីផងដែរថា គ្រិស្ទបរិស័ទមិនមែនប្រព្រឹត្តិអំពើល្អដើម្បីទទួលបានសេចក្តីសង្គ្រោះនោះទេ ផ្ទុយទៅវិញ ដោយព្រោះពួកគេទទួលបានសេចក្តីសង្គ្រោះ អំពើល្អគឺជាផលផ្លែដែលស្តែងចេញពីជីវិតរបស់ពួកគេ ស្របតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ និងសម្រាប់ជាសិរីល្អរបស់ទ្រង់។ ប្រាកដណាស់ ព្រះជាម្ចាស់សព្វព្រះរាជហឫទ័យអោយគ្រិស្ទបរិស័ទប្រព្រឹត្តិអំពើល្អ ព្រោះពួកគេគឺជាតំណាងរបស់ព្រះដ៏ល្អបរិសុទ្ធ ហើយនៅក្នុងទ្រង់គ្មានសេចក្តីងងឹតឡើយ។ មួយវិញទៀត គ្រិស្ទបរិស័ទប្រព្រឹត្តិអំពើល្អសម្រាប់ជាការសរសើរតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងសម្រាប់ជាដង្វាយដ៏ឈ្ងុយឈ្ងប់នៅលើអាសនារបស់ទ្រង់។ ថ្វីបើយ៉ាងដូច្នោះក្តី ប្រសិនបើយើងប្រព្រឹត្តិអំពើល្អដោយដាច់ចេញពីព្រះជាម្ចាស់ ឬក្នុងគោលបំណងដើម្បីប្តូរយកសេចក្តីសង្គ្រោះពីទ្រង់នោះ វានឹងដឹកនាំយើងឆ្ពោះទៅរកសេចក្តីវិនាសអន្តរាយក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់អស់កល្បជានិច្ចជាក់ជាមិនខាន៕

មួយវិញទៀត ការនេះស្របគ្នាទៅនឹងសេចក្ដីបង្រៀនរបស់លោកសាវ័កប៉ុលផងដែរ អំពីផលផ្លែខាងព្រលឹងវិញ្ញាណ ដែលគ្រិស្ដបរិស័ទគ្រប់ៗរូបគប្បីត្រូវតែបង្កើតចេញមក (កាឡាទី៥:១៩-២៦)។ ផលផ្លែខាងព្រលឹងវិញ្ញាណបានញែកសេចក្ដីជំនឿដ៏ពិតប្រាកដ ចេញពីសេចក្ដីជំនឿក្លែងក្លាយ។ ដោយសារតែព្រះគុណរបស់ព្រះជាម្ចាស់ ព្រះអង្គបានប្រោសប្រទានព្រះវិញ្ញាណបរិសុទ្ធអោយមកសណ្ឋិតនៅក្នុងជីវិតថ្មីរបស់អ្នកជឿគ្រប់ៗរូប ប្រយោជន៍អោយពួកគេអាចប្រព្រឹត្តិការល្អដែលជាទីគាប់ព្រះហឫទ័យរបស់ទ្រង់ ដែលទ្រង់បានរៀបចំទុកសម្រាប់ពួកគេ និងសម្រាប់ជាសិរីល្អរបស់ទ្រង់។ ថ្វីត្បិតតែការប្រព្រឹត្តិល្អមិនបណ្ដាលអោយគ្រិស្ដបរិស័ទទទួលបានសេចក្ដីសង្គ្រោះក៏ពិតមែន ក៏ប៉ុន្តែការប្រព្រឹត្តិល្អបានញែកដាច់រវាងគ្រិស្ដបរិស័ទក្លែងក្លាយ និងគ្រិស្ដបរិស័ទពិតប្រាកដ។ តួយ៉ាង ព្រះយេស៊ូវគ្រិស្ដបានមានព្រះបន្ទូលបង្រៀនដោយផ្ទាល់ថា "អ្នករាល់គ្នានឹងស្គាល់គេបានដោយសារផលផ្លែដែលគេបង្កើត...... ធម្មតាដើមឈើល្អមិនដែលបញ្ចេញផលអាក្រក់ទេ ហើយដើមឈើអាក្រក់ក៏ពុំអាចផលល្អបានដែរ...... ដូច្នេះ អ្នករាល់គ្នានឹងស្គាល់គេបានគឺដោយសារផលគេបង្កើត" (ម៉ាថាយ៧:១៦-២០)។ ការប្រព្រឹត្តិល្អតាមគម្រោងផែនការណ៍របស់ព្រះជាម្ចាស់ គឺជារូបភាពឆ្លុះនៃសេចក្ដីជំនឿ ពោលបើគ្មានការប្រព្រឹត្តិតាម នោះក៏គ្មានសេចក្ដីជំនឿដែរ។ ដូច្នេះ គោលដៅនៃសំណេររបស់លោកសាវ័កយ៉ាកុប បានដាស់តឿន និងលើកទឹកចិត្តអោយគ្រិស្ដបរិស័ទគ្រប់ៗរូបបានប្រព្រឹត្តិតាមការល្អទាំងឡាយដែលព្រះជាម្ចាស់បានបំរុងទុកសម្រាប់ពួកគេ បង្កើតផលផ្លែអោយសំណាំនឹងជីវិតថ្មីដែលព្រះជាម្ចាស់បានប្រោសប្រទានដល់ពួកគេដោយសារព្រះគុណ តាមរយះសេចក្ដីជំនឿ៕

គ្រិស្ដបរិស័ទចាំបាច់ត្រូវតែប្រព្រឹត្តិអំពើល្អ ព្រោះនេះគឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងជាផែនការដែលព្រះជាម្ចាស់មានសម្រាប់ពួកគេ ដើម្បីសិរីល្អរបស់ទ្រង់។ លើសពីនេះទៅទៀត ព្រះវិញ្ញាណបរិសុទ្ធដែលដាក់បញ្ចាំនៅក្នុងជីវិតរបស់គ្រិស្ដបរិស័ទគ្រប់ៗរូប គឺដើម្បីធានាជួយពួកគេអោយអាចប្រព្រឹត្តិតាមការល្អទាំងឡាយបានដោយជោគជ័យ ដែលលោកិយមិនអាចសម្រេចបាន។ ជាចុងក្រោយ សេចក្ដីជំនឿប្រៀបបានដូចជាគ្រាប់ពូជដ៏ពិសេសបំផុតមួយគ្រាប់ បើកាលណាបានដាក់ដាំដុះនៅក្នុងជីវិតហើយ នោះវានឹងបង្កើតផលផ្លែថ្វាយព្រះជាម្ចាស់ និងសម្រាប់ជាព្រះពរដល់មនុស្សម្នាទាំងពួងជាក់ជាមិនខាន។ បើទោះបីជាយ៉ាងណាក៏ដោយ គ្រិស្ដបរិស័ទមិនមែនព្យាយាមស្ដាប់បង្គាប់ ប្រព្រឹត្តិតាម និងធ្វើល្អ ដើម្បីជាថ្នូរដោះដូរយកសេចក្ដីសង្គ្រោះនោះទេ ផ្ទុយទៅវិញ ដោយសារព្រះគុណ តាមរយះសេចក្ដីជំនឿគ្រិស្ដបរិស័ទបានទទួលសេចក្ដីសង្គ្រោះ បានកើតជាថ្មី មាននិស្ស័យថ្មី ទទួលជីវិតថ្មី ហើយបង្កើតផលផ្លែ ដោយស្ដាប់បង្គាប់ ប្រព្រឹត្តិតាម និងធ្វើល្អ លនិងល ដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់ ដែលបានលះបង់គ្រប់ទាំងអស់ដើម្បីសង្គ្រោះពួកគេ។ គ្រិស្ដបរិស័ទមិនមែនធ្វើការល្អដើម្បីទទួលយកសេចក្ដីសង្គ្រោះនោះទេ ក៏ប៉ុន្តែ ដោយព្រោះពួកគេបានទទួលសេចក្ដីសង្គ្រោះ នោះគ្រិស្ដបរិស័ទត្រូវតែធ្វើការល្អ៕

## ៥ លិខិតអញ្ជើញ

"អស់អ្នកដែលនឿយព្រួយ ហើយមានបន្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានឈប់សម្រាក" (ម៉ាថាយ១១៖២៨)៕

ព្រះគម្ពីរបរិសុទ្ធបានគូសវាសបញ្ជាក់យ៉ាងប្រទ្យាំតថា បន្ទាប់ពីការធ្លាក់ចុះរបស់មនុស្សដំបូង "... ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏បណ្តេញគាត់ពីសួនច្បារអេដែនចេញ អោយទៅភ្ជួររាស់ដីដែលទ្រង់បានយកមកបង្កើតគាត់នោះវិញ ទ្រង់បណ្តេញមនុស្សចេញ ហើយដាក់ចេរ៉ូប៊ីននៅខាងកើតសួនច្បារអេដែន និងដាវដែលជាអណ្តាតភ្លើងរេបែរទៅគ្រប់ទិសដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត" (លោកុប្បត្តិ៣៖២៣-២៤)។ ដោយឡែក នៅខាងក្រៅសួនច្បារអេដែនវិញ មនុស្សបានរស់នៅដោយវង្វេងចេញពីព្រះជាម្ចាស់ ជាប់បណ្តាសា រស់រងទុក្ខវេទនា ផ្ទុយស្រលះពីនិមិត្តដែលព្រះជាម្ចាស់បានរៀបចំសម្រាប់ស្នាព្រះហស្តរបស់ទ្រង់។ មនុស្សដែលព្រះជាម្ចាស់ស្រលាញ់ខ្លាំងដល់ម្លេះ បានរស់នៅដោយល្វើយ តែលតោលឈឺចាប់ នឿយព្រួយ អស់សង្ឃឹម ហើយវង្វេងខ្ចាត់ខ្ចាយ ប្រៀបបានដូចជាហ្វូងចៀមដែលឥតមានអ្នកគង្វាលយ៉ាងដូច្នោះដែរ (ម៉ាថាយ៩៖៣៦)។ រីឯ ហ្វូងចៀមដែលវង្វេងចេញពីអ្នកគង្វាល ឥតមានអ្នកគង្វាលដឹកនាំមើលថែរក្សា មិនខុសអីពីចំណីរបស់ហ្វូងចចកនោះទេ ពោលគឺវានឹងស្លាប់វិនាសអន្តរាយជាក់ជាមិនខាន។ នៅក្រៅសួនច្បារអេដែន មនុស្សកំពុងតែវង្វេងបាត់បង់ចេញពីព្រះជាម្ចាស់ ហើយគ្រោះថ្នាក់រាប់រយជំពូក ប្រៀបបានដូចជាស្រមោលអន្ទោលតាមប្រាណរបស់ពួកគេជាប់ជានិច្ច។ មនុស្សបានត្រឹមតែឈរលួចសំលឹងមើលសួនច្បារអេដែនដែលជាប្រភពនៃព្រះពរដោយចិត្តសោកសង្រេងជាទីបំផុត៕

តើព្រះជាម្ចាស់មានព្រះហឫទ័យយ៉ាងណា ខណៈពេលដែលស្នាព្រះហស្តដ៏ល្អវិសេសរបស់ទ្រង់បានត្រឡប់ជាខូចបង់អស់យ៉ាងដូច្នោះ? ជាការពិតណាស់ លោកម៉ាថាយបានរំលេចអោយឃើញពីបំណងព្រះហឫទ័យរបស់ព្រះចំពោះមនុស្សបាបដែលកំពុងតែវង្វេងបាត់បង់យ៉ាងច្បាស់ថា "កាលទ្រង់ឃើញហ្វូងមនុស្សហើយ នោះទ្រង់មានព្រះហឫទ័យក្តួលអាណិតដល់គេ ដ្បិតគេល្វើយ ហើយខ្ចាត់ខ្ចាយ ដូចហ្វូងចៀមដែលឥតអ្នកគង្វាល" (ម៉ាថាយ៩៖៣៦)។ ដូចគ្នានេះដែរ លោកលូកាក៏បានបើកបង្ហាញផងដែរថា ព្រះរាជបុត្រានៃព្រះ ព្រះកន្សែងនឹងទីក្រុងយេរូសាឡឹម ត្បិតមនុស្សផងទាំងឡាយនៅទីនោះកំពុងតែដើរក្នុងភាពងងឹត វង្វេងតែលតោលឥតស្គាល់ព្រះដ៏ពិតរបស់ពួកគេសោះឡើយ (លូកា១៩៖៤១-៤៤)។ តាំងពីដើមរៀងមក បន្ទាប់ពីការសម្រេចចិត្តខុសរបស់មនុស្សដំបូង ព្រះជាម្ចាស់ក្តួលអាណិត ហើយសោកសង្រេងជាពន់ពេកចំពោះស្នាព្រះហស្តរបស់ទ្រង់ ព្រោះព្រះអង្គស្រលាញ់ពួកគេខ្លាំងដល់ម្លេះ៕

បើទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពរបស់មនុស្សជាតិនឹងត្រូវបានផ្លាស់ប្តូរទាំងស្រុង តាមរយៈព្រះយេស៊ូវគ្រិស្ទ ព្រោះនៅលើឈើឆ្កាង ព្រះយេស៊ូវគ្រិស្ទបានដកយករាល់បណ្តាសារបស់មនុស្សជាតិទាំងឡាយ ផ្ទុកលើអង្គទ្រង់ផ្ទាល់ ហើយប្រោសប្រទានដល់ពួកគេវិញនូវព្រះពរដ៏ពេញបរិបូរណ៍ដូចដើម។ ព្រះវត្តមានរបស់ព្រះយេស៊ូវគ្រិស្ទនៅលើផែនដី ដើម្បីមនុស្សបាបបានទទួលជីវិតថ្មីដ៏ពេញបរិបូរណ៍ស្របតាមនិមិត្តរបស់ព្រះជាម្ចាស់។ ជាក់ស្តែង ខណៈពេលដែលព្រះយេស៊ូវគ្រិស្ទកំពុងតែបំពេញបេសកម្មរបស់ទ្រង់នៅលើផែនដី ព្រះអង្គបានមានព្រះបន្ទូលដោយផ្ទាល់ថា "ដ្បិតកូន

មនុស្សបានមក ដើម្បីនឹងជួយសង្គ្រោះដល់អ្នកណាដែលបាត់បង់” (ម៉ាថាយ១៨៖១១)។ “….. ពួកអ្នកដែលជាសុខសប្បាយ គេមិនត្រូវការនឹងគ្រូពេទ្យទេ គឺជាមនុស្សដែលមានជំងឺវិញទេតើ ខ្ញុំមិនបានមកដើម្បីហៅមនុស្សសុចរិតទេ គឺមកហៅតែមនុស្សមានបាបតែប៉ុណ្ណោះ ដើម្បីអោយគេប្រែចិត្តឡើង” (ម៉ាកុស២៖១៧)។ ស្របពេលជាមួយគ្នានេះផងដែរ ប្រស្នាអំពីកូនចៀមដែលវង្វេងបាត់ហើយរកឃើញវិញ ប្រស្នាអំពីប្រាក់ដួងដែលបាត់ហើយរកឃើញវិញ ប្រស្នាអំពីកូនពៅដែលបាត់ហើយរកឃើញវិញ (លូកា១៥) បានព្យាយាមចង្អុលបង្ហាញទៅកាន់រូបភាពតែមួយគឺ ការស្វែងរកមនុស្សបាប ហើយដឹកនាំពួកគេចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់វិញ ព្រោះបើសំអាងលើព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រិស្ទ ដែលជាអ្នកគង្វាលដ៏ល្អ បានលើកឡើងថា “… ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ ទ្រង់ក៏មិនសព្វព្រះហឫទ័យអោយកូនតូចណាមួយនេះត្រូវវិនាសដូច្នោះដែរ” (ម៉ាថាយ១៨៖១៤)។ ព្រះជាម្ចាស់មានបំណងព្រះហឫទ័យអញ្ជើញ ស្នាព្រះហស្តទាំងអស់របស់ទ្រង់អោយចូលទៅសោយសុខក្នុងព្រះពរ និងព្រះវត្តមានរបស់ទ្រង់ដូចដើមវិញ។ មនុស្សបាបដែលកំពុងតែវិនាសបាត់បង់នឹងមានសេរីភាពឡើងវិញ ហើយបានរួចចាកផុតពីការវិនិច្ឆ័យ ព្រមទាំងព្រះពិរោធនៃរបស់ព្រះជាម្ចាស់ ខណះពេលដែលពួកគេលឺសម្លេងដង្ហើយស្រែកហៅស្វែងរករបស់ព្រះយេស៊ូវគ្រិស្ទ រួចឆ្លើយតប និងអនុញ្ញាតអោយព្រះអង្គដឹកនាំពួកគេត្រឡប់ទៅឯព្រះវរបិតាវិញ៕

នៅក្នុងសួនច្បារអេដែន មនុស្សដំបូងមានភាពភ័យខ្លាច ហើយបានរត់ពួនពីព្រះជាម្ចាស់បន្ទាប់ពីពួកគេបានធ្វើបាប (លោកុប្បត្តិ៣៖៨-១០) ហើយការនេះទៀតសោត បានក្លាយទៅជាលំអានសម្រាប់មនុស្សជាតិទាំងឡាយនៅចំពោះព្រះជាម្ចាស់ ពោលគឺមនុស្សតែងតែភ័យខ្លាច រត់ពួន គេចចេញ និងមិនហ៊ានចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់នោះទេ  ខណះពេលដែលខ្លួនកំពុងតែធ្វើបាប ក៏ដូចជាបន្ទាប់ពីពួកគេធ្វើបាបហើយផងដែរ។ អំពើបាបជារនាំងរវាងព្រះជាម្ចាស់ និងមនុស្សជាតិ។ នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ អំពើបាបត្រូវតែវិនាស។ ជាភស្តុតាងបញ្ជាក់ខណះពេលដែលលោកអេសាយស្ថិតនៅក្នុងព្រះវត្តមានដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ លោកបាននិយាយដោយផ្ទាល់ថា “…. វរហើយខ្ញុំ ខ្ញុំត្រូវវិនាសជាពិត ដ្បិតខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត ហើយខ្ញុំនៅកណ្តាលបណ្តាមនុស្សដែលមានបបូរមាត់មិនស្អាតដែរ ពីព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ គឺជាព្រះយេហូវ៉ានៃពលបរិវារ” (អេសាយ៦៖៥)។ រីឯ លោកពេត្រុសវិញ ខណះពេលគាត់បានជួបព្រះយេស៊ូវគ្រិស្ត “…. នោះគាត់ក្រាបនៅទៀបព្រះជង្ឃព្រះយេស៊ូវ ទូលថា ព្រះអម្ចាស់អើយ សូមថយចេញពីទូលបង្គំ ដ្បិតទូលបង្គំជាមនុស្សមានបាប” (លូកា៥៖៨)។ ដូចគ្នានេះដែរ បន្ទាប់ពីបានចាកចេញពីប្រទេសអេស៊ីព្ទ ពួកអ៊ីស្រាអែលញាប់ញ័រ និងភ័យខ្លាចចំពោះព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ផ្ទាល់បានហាមឃាត់ពួកគេមិនអោយចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ជាដាច់ខាត ខណះពេលដែលពួកគេស្ថិតនៅជើងភ្នំស៊ីណាយដែលមានព្រះវត្តមានរបស់ព្រះជាម្ចាស់គង់នៅលើកំពូលភ្នំ (និក្ខមនំ១៩)។ អំពើបាបបានក្លាយទៅជារនាំងដ៏ធំបំផុតមួយរវាងមនុស្ស និងព្រះជាម្ចាស់។

ដោយឡែក គ្រិស្តបរិស័ទមួយចំនួនមិនត្រឹមតែបានរត់ពួនពីព្រះជាម្ចាស់តែប៉ុននោះទេ បន្ទាប់ពីពួកគេបានធ្វើបាបលើសពីនេះទៅទៀត គេតែងតែចាំធ្វើអំពើល្អណាមួយជាមុនសិន មុននឹងគេហ៊ានឈានជើងចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ដូចជាឈប់ធ្វើបាបមួយរយះសិន ចាប់ផ្តើមទំនាក់ទំនងជាមួយគ្រិស្តបរិស័ទដ៏ទៃផ្សេងៗទៀត ជួយក្រុមជំនុំព្យាយាមខិតខំធ្វើជាគ្រិស្តបរិស័ទល្អ លនិងល ជាដើម ព្រោះអំពើបាបបានធ្វើអោយពួកគេខ្មាស់ព្រះជាម្ចាស់ ហើយគេចង់

អោយព្រះជាម្ចាស់ទតមើលមកគេឃើញការល្អដែលគេខំប្រព្រឹត្តិ ជាជាងអំពើបាបដែលគេខិតខំលាក់ទុក។ មនុស្សជាតិចង់ចូលទៅកាន់ព្រះជាម្ចាស់ ដោយមានជាប់អ្វីមួយនៅនឹងដៃដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពួកគេចង់ចូលទៅកាន់ព្រះជាម្ចាស់ ដោយរំពឹងគិតថា ពួកគេបានលើពាក្យពោលសរសើរពីព្រះជាម្ចាស់ អំពីអំពើល្អរបស់ពួកគេ។ ដោយឡែក ខណៈពេលដែលពួកគេមើលមកខ្លួនឯង ហើយឃើញភាពអាក្រក់/ភាពអាក្រាករបស់ខ្លួនវិញ នោះពួកគេខ្មាស មិនហ៊ានចូលទៅជួបព្រះជាម្ចាស់នោះទេ។ នេះគឺជាអ្វីដែលព្រះយេស៊ូវគ្រិស្តបានយាងមកផ្លាស់ប្តូរ គឺដើម្បីបើកផ្លូវអោយមនុស្សចូលទៅព្រះវត្តមានរបស់ព្រះជាម្ចាស់ដោយគ្មានការភ័យខ្លាចទៀតឡើយ ព្រោះព្រះអង្គបានបំផ្លាញរាំងនននៃអំពើបាបដែលរារាំងពួកគេពីព្រះជាម្ចាស់ចោលហើយ។ ដោយព្រោះរនាំងនៃអំពើបាប មនុស្សខ្មាស់ ខ្លាច នឹងមិនស្វែងរកព្រះជាម្ចាស់ជាដាច់ខាត ផ្ទុយទៅវិញ ដោយព្រោះព្រះគុណ មនុស្សបាបអាចចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ដោយគ្មានការភ័យខ្លាច តាមរយៈព្រះយេស៊ូវគ្រិស្ទដែលជាផ្លូវ។ នៅក្នុងព្រះយេស៊ូវគ្រិស្ទ មនុស្សបាបបានស្អាត និងទទួលជីវិតដ៏អស់កល្បជានិច្ច៕

ជាចុងក្រោយ ព្រះយេស៊ូវគ្រិស្ទមិនត្រឹមតែបានបើកទ្វារនៃនគរស្ថានសួគ៌សម្រាប់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់នោះទេ លើសពីនេះទៅទៀត ព្រះអង្គផ្ទាល់បានអញ្ជើញពួកគេអោយចូលទៅសម្រាកក្នុងនគរដ៏ឧត្តុងឧត្តមរបស់ទ្រង់ថែមទៀតផង (ម៉ាថាយ២២៖១-១៤ លូកា១៤៖១៥-២៤)។ ក្រុមមនុស្សគ្រប់ប្រភេទ បានទទួលលិខិតអញ្ជើញពីព្រះដែលជាម្ចាស់ស្ថានសួគ៌ដោយផ្ទាល់។ ព្រះយេស៊ូវគ្រិស្ទបានមានព្រះបន្ទូលដោយផ្ទាល់ថា “អស់អ្នកដែលនឿយព្រួយ ហើយមានបន្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានឈប់សម្រាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូតហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសម្រាកដល់ព្រលឹង ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល” (ម៉ាថាយ១១៖២៨-៣០)។ “... អ្នកណាដែលផឹកទឹកខ្ញុំអោយ នោះនឹងមិនស្រេកទៀតឡើយ.... ”(លូកា៤៖១៤)។ ដូចគ្នានេះដែរ នៅចុងបញ្ចប់នៃព្រះគម្ពីរបរិសុទ្ធ លិខិតអញ្ជើញដែលបានលេចឡើងសារជាថ្មីម្តងទៀតថា “ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលលឺ ក៏ថាអញ្ជើញមកដែរ អ្នកណាដែលស្រេកនោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ”(វិវរណៈ២២៖១៧)។ ដោយឡែក ថ្វីត្បិតតែលិខិតអញ្ជើញបានប្រោសប្រទានដល់មនុស្សគ្រប់ៗរូបយ៉ាងណាក្តី ក៏ប៉ុន្តែការនេះមិនមែនបានសេចក្តីថាគ្រប់ៗគ្នាសុទ្ធតែមានវត្តមាននៅក្នុងនគរស្ថានសួគ៌នោះទេ។ អនាគតរបស់មនុស្សជាតិនៅក្នុងនគរស្ថានសួគ៌ គឺអាស្រ័យលើការឆ្លើយតបរបស់ពួកគេដោយផ្ទាល់ ចំពោះការអញ្ជើញរបស់ព្រះជាម្ចាស់(ម៉ាថាយ២២៖១៤)៕

អស់អ្នកណាដែលបានឆ្លើយតបទៅតាមការអញ្ជើញរបស់ម្ចាស់ស្ថានសួគ៌ នោះនឹងបានឆ្លងកាត់ផុតសេចក្តីវិនាសអន្តរាយ ឈានទៅដល់ឯត្រើយជីវិតដ៏ប្រកបដោយព្រះពរអស់កល្បជានិច្ច។ នៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់មានការសម្រាកដ៏ពេញលេញបរិបូរណ៍ ដូចនៅក្នុងសួនច្បារអេដែនដែរ ស្របតាមនិមិត្តរបស់ទ្រង់ក្នុងកាលបង្កើត។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានលើកឡើងថា “ដូច្នោះ មានសេចក្តីឈប់សម្រាកទុកសម្រាប់រាស្ត្ររបស់ព្រះនៅខាងមុខ ដ្បិតអ្នកណាដែលចូលទៅក្នុងសេចក្តីសម្រាករបស់ទ្រង់ហើយ នោះក៏បានឈប់សម្រាកពីការខ្លួនប្រព្រឹត្តិទាំងប៉ុន្មានដូចជាព្រះបានឈប់ពីការដែលទ្រង់ធ្វើដែរ”(ហេព្រើរ៤៖៩-១០)។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏បានសម្តែងទៀតដែរថា “មើល អញឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាលឺសម្លេងអញហើយបើកទ្វារអោយ នោះអញនឹងចូលទៅឯអ្នកនោះ

អញនឹងបរិភោគជាមួយនឹងអ្នកនោះ ហើយអ្នកនោះជាមួយនឹងអញដែរ”(វិវរណៈ៣៖២០)។ ព្រះរាជបុត្រានៃព្រះ បានយាងមកដើម្បីនឹងហៅមនុស្សបាបអោយកែប្រែចិត្ត ប្រយោជន៍អោយពួកគេបានគ្រងនគរស្ថានសួគ៌ជាមរតកជាមួយនឹងទ្រង់ដែរ (ម៉ាថាយ៩៖១៣) បើដូច្នោះគួរគប្បីអោយមនុស្សបាបទាំងឡាយបានស្គាល់ ហើយស្តាប់តាមការអញ្ជើញរបស់ទ្រង់ស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រិស្ទដែលបានលើកឡើងថា “ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំអោយជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ ព្រះវរបិតានៃខ្ញុំដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់វាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ”(យ៉ូហាន១០៖២៧-២៩)៕

## ៦ ការសម្រេចចិត្តដ៏សំខាន់បំផុត

> “ហើយដោយព្រោះបានតម្រូវអោយមនុស្សទាំងអស់ស្លាប់១ដង រួចសឹមដាប់សេចក្តីជំនុំជម្រះ”(ហេព្រើរ៩:២៧)។

ព្រះគម្ពីរបរិសុទ្ធ លើសពីសៀវភៅសាសនាទៅទៀត ព្រោះនេះគឺជាលិខិតអញ្ជើញរបស់ព្រះជាម្ចាស់ដោយផ្ទាល់ដល់មនុស្សគ្រប់ជាតិសាសន៍ទាំងអស់អោយបានចូលរួមក្នុងនគររបស់ទ្រង់។ ដោយឡែក លិខិតអញ្ជើញមួយនេះទាមទារជាដាច់ខាតនូវការសម្រេចចិត្តឆ្លើយតបរបស់បងប្អូន មុនពេលកំណត់បានឈានមកដល់។ បន្ទាប់ពីការធ្លាក់ចុះក្នុងអំពើបាប មនុស្សជាតិគ្រប់ទីកន្លែង និងគ្រប់សម័យកាលទាំងអស់ ត្រូវប្រឈមមុខនឹងជម្រើសតែពីរគត់ គឺទីមួយ៖ ឆ្លើយតបតាមការអញ្ជើញរបស់ព្រះជាម្ចាស់ ហើយចូលទៅក្នុងនគរស្ថានសួគ៌អស់កល្បជានិច្ច ឬក៏ទីពីរ៖ បដិសេធន៏ការអញ្ជើញរបស់ព្រះជាម្ចាស់ ហើយដើរតាមអារក្សសាតាំងឆ្ពោះទៅរកសេចក្តីវិនាសអន្តរាយអស់កល្បជានិច្ច។ មនុស្សមានជំរើសតែពីរគត់គឺ ដើរតាមព្រះយេស៊ូវគ្រិស្ទ ឬក៏បដិសេធន៍ព្រះយេស៊ូវគ្រិស្ទដោយដើរតាមអារក្សសាតាំងវិញ។ មនុស្សគ្រប់ៗរូប ត្រូវតែធ្វើការសម្រេចចិត្តមុនពេលដែលពួកគេលាចាកចេញពីផែនដីនេះ ឬមុនពេលដែលព្រះយេស៊ូវគ្រិស្ទយាងត្រឡប់មកវិញជាលើកទីពីរដើម្បីនឹងជំនុំជម្រះមនុស្សគ្រប់ជាតិសាសន៍ទាំងអស់៕

មួយវិញទៀត គួរគប្បីយើងត្រូវដឹងផងដែរថា ការមិនសម្រេចចិត្តអ្វីសោះស្មើនឹងការបដិសេធន៍មិនព្រមទទួលយកការអញ្ជើញរបស់ព្រះជាម្ចាស់ ដែលលទ្ធផលរបស់វា មិនខុសអីពីអស់អ្នកដែលជ្រើសរើសដើរតាមផ្លូវរបស់អារក្សសាតាំងនោះទេ។ មានពេលមួយ លោកយ៉ូហាន-បាទីស្ទ បានប្រកាសដំណឹងល្អនៅឯទីវាលរហោស្ថាន ឯស្រុកយ៉ូដាថា “ចូរប្រែចិត្ត ដ្បិតព្រះរាជ្យនៃស្ថានសួគ៌ជិតមកដល់ហើយ” (ម៉ាថាយ៣:២)។ លោកហោរ៉ាខាងលើហាក់បីដូចជាកំពុងតែរំលឹករន្ធើន ប្រជារាស្ត្រយ៉ូដា ក៏ដូចជាមនុស្សគ្រប់ជាតិសាសន៍ទាំងអស់អោយឆាប់ភ្ញាក់រលឹក ហើយបែរចេញពីអំពើបាបរបស់ខ្លួន  មកស្វែងរកព្រះជាម្ចាស់វិញជាប្រញាប់ មុនពេលដែលកាលកំណត់បានឈានមកដល់។ ស្របពេលជាមួយគ្នានេះផងដែរ បន្ទាប់ពីអវត្តមានរបស់លោកយ៉ូហាន-បាទីស្ទ ព្រះយេស៊ូវគ្រិស្ទផ្ទាល់បានចាប់ផ្តើមពន្ធកិច្ចរបស់ទ្រង់ក្នុងគោលបំណងដូចគ្នាទៅនឹងលោកយ៉ូហាន-បាទីស្ទផងដែរ គឺដើម្បីអោយមនុស្សប្រញាប់សម្រេចចិត្តដាកចេញពីអំពើបាបរបស់ខ្លួន ហើយបែរទៅរកមាគ៌ារបស់ព្រះវិញ ដើម្បីជៀសផុតពីការវិនិច្ឆ័យនាថ្ងៃចុងក្រោយ (ម៉ាថាយ៤:១៧)។ លើសពីនេះទៅទៀត បេសកកម្មដែលព្រះយេស៊ូវគ្រិស្ទបានប្រោសប្រទានដល់អស់អ្នកដែលបានដើរតាមទ្រង់ នៅក្នុងព្រះគម្ពីរ ម៉ាថាយ ២៨:១៨-២០ មុនពេលដែលព្រះអង្គបានយាងត្រឡប់ទៅឯព្រះវរបិតាវិញ គឺដើម្បីអោយមនុស្សបានសម្រេចចិត្តបែរចេញពីអំពើបាបរបស់ខ្លួន ហើយដើរតាមទ្រង់ ប្រយោជន៍នឹងទទួលបានសេចក្តីសង្គ្រោះ មុនពេលដែលព្រះអង្គយាងមកវិញ។ សូមកុំចាកចេញពីផែនដីនេះ ដោយគ្មានការសម្រេចចិត្តច្បាស់លាស់។ សូមកុំចាកចេញពីផែនដីនេះ ដោយគ្មានព្រះយេស៊ូវគ្រិស្ទ បើពុំដូច្នោះទេ អ្នកនឹងត្រូវវិនាសអន្តរាយអស់កល្បជានិច្ច៕

ព្រះគម្ពីរបរិសុទ្ធ ប្រៀបបានដូចជាត្រីវិស័យដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដ្បិតព្រះគម្ពីរបរិសុទ្ធបានចង្អុលអោយឃើញនគរស្ថានសួគ៌ និងផ្លូវទៅឯនគរស្ថានសួគ៌។ ដោយឡែក បុគ្គលគ្រប់ៗរូបត្រូវតែសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ មុន

ពេលកាលកំណត់បានឈានមកដល់។ ព្រះយេស៊ូវគ្រិស្ទមិនត្រឹមតែបានបង្រៀនអំពីនគរស្ថានសួគ៌នោះទេ ជាងនេះទៅទៀត ព្រះអង្គផ្ទាល់ជាផ្លូវចូលទៅក្នុងនគរស្ថានសួគ៌។ ព្រះអង្គទាមទារ ហើយរង់ចាំការសម្រេចចិត្តពីមនុស្សគ្រប់ៗរូប ដោយអត់ធ្មត់បំផុត៕

អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានលើកឡើងបញ្ជាក់ថា "ហើយដោយព្រោះបានតម្រូវអោយមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជម្រះ" (ហេព្រើរ៩៖២៧)។ ព្រះបន្ទូលនេះ បានគូសវាសបញ្ជាក់យ៉ាងប្រទ្យឹតថា ការសម្រេចចិត្តរបស់មនុស្សជាតិ ចំពោះលិខិតអញ្ជើញរបស់ព្រះជាម្ចាស់សំខាន់ជាទីបំផុត ព្រោះមនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់មានជីវិតតែម្តងគត់ ដើម្បីធ្វើការសម្រេចចិត្ត។ អនាគតដ៏អស់កល្បជានិច្ចរបស់មនុស្ស បន្ទាប់ពីពួកគេចាកចេញពីផែនដីនេះ គឺអាស្រ័យទាំងស្រុងលើការសម្រេចរបស់ពួកគេមុនពេលដែលពួកគេចាកចេញពីផែនដីនេះ។ ផែនដីបច្ចុប្បន្នមិនមែនជាទីលំនៅស្ថានដ៏ពិតប្រាកដ អស់កល្បជានិច្ចរបស់មនុស្សនោះទេ ពោលគឺវត្តមានរបស់អ្នកនៅលើផែនដីគ្រាន់តែបណ្តោះអាសន្នតែប៉ុណ្ណោះ (ទំនុកតម្កើង១១៩៖១៩)។ ថ្ងៃណាមួយ ជីវិតរបស់លោកអ្នកនឹងឈានទៅដល់ទីបញ្ចប់ ក៏ប៉ុន្តែទីបញ្ចប់នៃជីវិតរបស់អ្នកនៅលើផែនដី គឺជាការចាប់ផ្តើមថ្មីនៃជីវិតរបស់អ្នកអស់កល្បជានិច្ច។ បន្ទាប់ពីលាចាកពីផែនដីនេះ "…… យើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រិស្ទ….. "(កូរិនថូសទី២ ៥៖១០) ហើយអស់អ្នកណាដែលឆ្លើយតបតាមការអញ្ជើញរបស់ទ្រង់ ខណៈពេលដែលពួកគេនៅលើផែនដីនៅឡើយ នឹងទទួលបានជីវិតអស់កល្បជានិច្ចជាមរតកនៅឯនគរស្ថានសួគ៌ជាមួយទ្រង់ ផ្ទុយទៅវិញ អស់អ្នកណាដែលបានបដិសេធន៍លិខិតអញ្ជើញរបស់ទ្រង់ នោះនឹងត្រូវរងការវិនិច្ឆ័យ វិនាស វេទនា ក្រោមព្រះពិរោធន៍របស់ព្រះជាម្ចាស់អស់កល្បជានិច្ច។ ការសម្រេចចិត្តរបស់មនុស្សនៅលើផែនដី នឹងផ្តល់លទ្ធផលអស់កល្បជានិច្ចដល់ពួកគេបន្ទាប់ពីស្លាប់។ មនុស្សមានពេលវេលាត្រឹមតែមួយពព្រិចភ្នែកតែប៉ុននោះនៅលើផែនដី ប្រៀបបានដូចជាស្មៅដែលតែងតែក្រៀមស្វិត ឬផ្កាដែលតែងតែរុះរោយក្នុងរយះពេលដ៏ខ្លីយ៉ាងដូច្នោះដែរ (ពេត្រុសទី១ ១៖២៤) ក៏ប៉ុន្តែលទ្ធផលនៃការសម្រេចចិត្តរបស់ពួកគេនឹងនៅជាប់អស់កល្បជានិច្ច៕

ដោយសារព្រះគុណ ព្រះជាម្ចាស់បានប្រោសប្រទានអោយអ្នកមានជីវិតនៅលើផែនដី ប្រយោជន៍អោយអ្នកសម្រេចចិត្តដ៏ត្រឹមត្រូវនៅចំពោះទ្រង់ ដើម្បីគេចផុតពីសេចក្តីវិនាសអស់កល្បជានិច្ច។ នៅក្នុងសួនច្បារអេដែន មនុស្សដំបូងបានសម្រេចចិត្តជ្រើសរើសយកសេចក្តីស្លាប់ ហើយសេចក្តីស្លាប់បានរាលដាលដល់មនុស្សគ្រប់ជាតិសាសន៍ និងគ្រប់សម័យកាលទាំងអស់ ក៏ប៉ុន្តែអ្នកផ្ទាល់មានសិទ្ធិជ្រើសរើសយកជីវិតដ៏អស់កល្បជានិច្ច និងពេញបរិបូរណ៍វិញ ដោយឆ្លើយតបតាមលិខិតអញ្ជើញរបស់ព្រះយេស៊ូវគ្រិស្ទ។ អនាគតដ៏អស់កល្បជានិច្ចរបស់មនុស្ស គឺអាស្រ័យលើការសម្រេចចិត្តរបស់គេនៅលើផែនដីចំពោះលិខិតអញ្ជើញរបស់ព្រះជាម្ចាស់៕

ដោយឡែក អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងបានលើកឡើងថា "ផ្ទៃមេឃសម្តែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ" (ទំនុកតម្កើង១៩៖១)។ រីឯលោកសាវ័កប៉ុលវិញ ក៏បានបញ្ជាក់បន្ថែមពីលើនេះទៀតដែរថា "…. ការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសម្តែងមកក្នុងពួកគេហើយ ដោយព្រះទ្រង់សម្តែងការនោះអោយគេឃើញជាក់ ដ្បិតអ្វីៗរបស់ទ្រង់ដែលរកមើលមិនឃើញតាំងពីកំណើតលោកិយមក ទោះទាំងព្រះចេស្តាដ៏នៅអស់កល្បជានិច្ច និងនិស្ស័យជាព្រះរបស់ទ្រង់នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មានដែលទ្រង់

បានបង្កើតមក” (រ៉ូម១៖១៩-២០)។ មួយវិញទៀត ព្រះយេស៊ូវគ្រិស្ទមិនត្រឹមតែបានអះអាងអំពីអត្តសញ្ញាណដ៏ពិតប្រាកដរបស់ទ្រង់ថាជាព្រះដ៏ពិតនោះទេ លើសពីនេះទៅទៀត ព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងមូលក៏បានធ្វើទីបន្ទាល់អំពីការទាំងអស់នេះផងដែរ បើដូច្នោះ អស់អ្នកដែលជឿលើព្រះយេស៊ូវគ្រិស្ទនឹងបានជីវិតដ៏ពេញបរិបូរណ៍អស់កល្បជានិច្ចជាពិតប្រាកដ។ សរុបសេចក្តីមក នៅថ្ងៃចុងក្រោយ មនុស្សគ្រប់ៗរូបនឹងទទួលបានលទ្ធផលនៃការសម្រេចចិត្តរបស់ពួកគេរៀងៗខ្លួនដោយគ្មានលេសដោះសារឡើយ៕

ជាអវសាន្ត សេចក្តីសង្គ្រោះមិនមែនឈរលើទស្សនះខ្លួនទីពឹងខ្លួននោះទេ ផ្ទុយទៅវិញសេចក្តីសង្គ្រោះគឺជាព្រះគុណដែលព្រះជាម្ចាស់បានប្រោសប្រទានដល់មនុស្សគ្រប់ៗដោយសារសេចក្តីស្រលាញ់ តាមរយះសេចក្តីជំនឿ ដ្បិតមនុស្សគ្រប់ៗរូបសុទ្ធតែមានបាប ខ្វះមិនដល់សិរីល្អរបស់ព្រះជាម្ចាស់ ដែលពួកគេមិនអាចជួយសង្គ្រោះខ្លួនឯងបានជាដាច់ខាត។ បើទោះបីជាយ៉ាងណាក៏ដោយ មនុស្សគ្រប់ៗរូបត្រូវតែធ្វើការសម្រេចចិត្តតាមលិខិតអញ្ជើញរបស់ព្រះជាម្ចាស់ដោយខ្លួនឯងផ្ទាល់។ លទ្ធផលដ៏អស់កល្បជានិច្ចរបស់អ្នក កើតចេញពីការសម្រេចរបស់អ្នកផ្ទាល់ មិនមែនជាការសម្រេចចិត្តរបស់អ្នកដ៏ទៃជំនួសអ្នកនោះទេ។ នៅចុងបញ្ចប់ អ្នកត្រូវតែធ្វើការសម្រេចចិត្តដ៏សំខាន់បំផុតមួយដែលនឹងកំណត់ជីវិតអស់កល្បជានិច្ចរបស់អ្នក។ សូមគិតគូរ ថ្លឹងថ្លែង ហើយធ្វើការសម្រេចចិត្តដោយប្រុងប្រយត្ន័បំផុត ព្រោះលទ្ធផលរបស់វាខុសគ្នាដូចជាមេឃ និងដី ហើយអ្នកនឹងទទួលយកវាអស់កល្បជានិច្ច។ “មើល អញឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាលឺសម្លេងអញហើយបើកទ្វារអោយ នោះអញនឹងចូលទៅឯអ្នកនោះ អញនឹងបរិភោគជាមួយនឹងអ្នកនោះ ហើយអ្នកនោះជាមួយនឹងអញដែរ”(វិវរណះ៣៖២០)។ “សូមអោយអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្តអំពីព្រះដ៏ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រិស្ទ”(អេភេសូរ១៖២)។ សូមព្រះដ៏ជាព្រះប្រទានព្រះពរ!

ឯកសារពិគ្រោះ

១ ព្រះគម្ពីរបរិសុទ្ធខ្មែរ
២ វចនានុក្រមខ្មែរ ភាគ១និងភាគ២
៣ ជីវិតដែលជំរុញដោយគោលបំណង និពន្ធដោលោក រីក វ៉ររិន
៤ វិសាលភាពនៃព្រះជាម្ចាស់
រៀបរៀងដោយ លោក ហ្វន រ៉ូប៊ីត បោះពុម្ពនៅរោងពុម្ព អាតា ក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ខែសីហា ឆ្នាំ២០១៩
៥ ផ្លូវទៅកាន់ភ្នំកាល់វ៉ារី
រៀបរៀងដោយលោក រ៉យ ហេសសាន់ បោះពុម្ពនៅរោងពុម្ព អាតា រាជធានីភ្នំពេញ ប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០១៥
៦ បានល្អ ធ្វើល្អ
រៀបរៀងដោយលោក ចេ.ឌី. ក្រោលី បោះពុម្ពនៅរោងពុម្ព ឌីជីថល អ៊ែតវើថាយស៊ីង ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ខែមេសា ឆ្នាំ២០១៤
៧ សងជាសម្រេច
រៀបរៀងដោយលោក រីឆាត រ៉ុជើរ បោះពុម្ពនៅរោងពុម្ព ហាវែ ប្រទេសកម្ពុជា ខែមករា ឆ្នាំ២០១១
៨ ស្គាល់អ្នកណាដែលអ្នកជឿតាម; ទំនាក់ទំនងដ៏អស្ចារ្យ
រៀបរៀងដោយលោក ប៉ូល អ៊ី. លីតថល បោះពុម្ពនៅទីក្រុងភ្នំពេញ ប្រទសកម្ពុជា ខែមករា ឆ្នាំ២០០៨
៩ ទិដ្ឋភាពទាំងបួននៃដំណឹងល្អ
រៀបរៀងដោយលោកបណ្ឌិត អ. ប. សិម្បសុិន បោះពុម្ពលើកទី១ នៅរោងពុម្ព អប្សរា ឆ្នាំ១៩៩៧
១០ From Eden to the New Jerusalem By T. Desmond Alexander. Published in the United states of America in 2009 by Kregel Publications.